# សៀវភៅណែនាំ ស្ដីពីការរៀបចំកម្មវិធី ត្រៀមបង្ការ គ្រោះទឹកជំនន់ សំរាប់អាជ្ញាធរ ថ្នាក់ខេត្ត និងស្រុក ក្នុងប្រទេសតាមដងទន្លេមេគង្គក្រោម



MEKONG RIVER COMMISSION MRC FOR SUSTAINABLE DEVELOPMENT gtz EUROPEAN COMMISSION Humanitarian Aid adpc

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADPC | មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី |
| CBDP | ការត្រៀមបង្ការទឹកជំនន់សហគមន៍ |
| CBOs | អង្គការសហគមន៍ |
| CCFSC | គណៈកម្មាធិការកណ្តាលត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ |
| CFSC | គណៈកម្មាធិការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ |
| CRC | កាកបាទក្រហមកម្ពុជា |
| DARD | មន្ទីរកសិកម្មនិងអភិវឌ្ឍជនបតខេត្ត |
| CDCM | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក |
| DCFSC | គណៈកម្មាធិការត្រួតពិនិត្យគ្រោះទឹកជំនន់ និង ខ្យល់ព្យុះស្រុក |
| DDMC | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក |
| DM | ការគ្រប់គ្រងគ្រោះមហន្តរាយ |
| OEC | មណ្ឌលប្រតិបត្តិការគ្រោះអាសន្ន |
| EWS | ប្រព័ន្ធប្រកាសភាពអាសន្នមុន |
| FGD | ការពិភាក្សាជាក្រុមគោលដៅ |
| FPP | កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ |
| GIS | ប្រព័ន្ធព័តិមានភូមិសាស្ត្រ |
| HVCA | ការប៉ាន់ប្រមាណគ្រោះថ្នាក់ ភាពដែលងាយរងគ្រោះនិងសមត្ថភាព |
| INGO | អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ |
| MLSW | ក្រសួងការងារ និងសង្គមកិច្ច |
| MOH | ក្រសួងសុខាភិបាល |
| MOWRAM | ក្រសួងគ្រប់គ្រងធនធានទឹក |
| MRC | ក្រសួងការងារគណៈកម្មការទន្លេមេគង្គ |
| NCDM | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅប្រទេសកម្ពុជា |

| | |
|---|---|
| NDMC | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NCDM | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក |
| NGOs | អង្គការក្រៅរដ្ឋាភិបាល |
| PC | គណៈកម្មាធិការប្រជាជន |
| PCDM | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត |
| PCFSC | គណៈកម្មាធិការខេត្តត្រួតពិនិត្យទឹកជំនន់ និង ខ្យល់ព្យុះ |
| PDMC | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក |
| PRA | ការប៉ាន់ប្រមាណរហ័សតាមបែបមានការចូលរួម |
| RFMMC | មជ្ឈមណ្ឌលគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់ថ្នាក់តំបន់ |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| ToR | ឯកសារយោង |
| VPU | អង្គភាពការពារភូមិ |

# សេចក្តីផ្តើម

***ឯកសារមេរៀន ស្តីពីការត្រៀមបង្ការទឹកជំនន់សំរាប់អាជ្ញាធរមូលដ្ឋានកំរិតថ្នាក់ស្រុក និងខេត្ត នៅតាមបណ្តាប្រទេស ដីសណ្តទន្លេមេគង្គក្រោម*** ត្រូវបានបង្កើតឡើងផ្អែកលើការប៉ាន់ប្រមាណលើតំរូវការរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការធ្វើផែនការត្រៀមបង្ការទឹកជំនន់នៅក្នុងប្រទេសកម្ពុជា ឡាវ និង វៀតណាម។ ឯកសារមេរៀននេះ នឹងជួយដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក និងខេត្តនៃបណ្តាប្រទេសនៅតាមមាត់ទន្លេទាំងនេះក្នុងការបង្កើតនិងអនុវត្តលើ **កម្មវិធីត្រៀមបង្ការទឹកជំនន់**។ ម្យ៉ាងទៀត ឯកសារនេះអាចប្រើប្រាស់ជាសៀវភៅមគ្គុទេសក៏ សំរាប់ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ អ្នកអនុវត្តការងារផ្ទាល់ ក៏ដូចជា អង្គការNGOs ដើម្បីកសាងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមអនុវត្តលើវិធានការណ៍ត្រៀមបង្ការគ្រោះទឹកជំនន់។

ឯកសារមេរៀននេះបង្កើតឡើងដោយ **មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី** ហៅកាត់ថា (ADPC) តាមរយៈអ្នកឯកទេសផ្ទៃក្នុងរបស់ខ្លួន មេរៀនបណ្តុះបណ្តាលនានា និងឯកសារយោងមួយចំនួនទៀតស្តីពីទឹកជំនន់ ក៏ដូចជាមានការចូលរួមផ្តល់យោបល់ពីមន្ត្រីជំនាញសំខាន់ៗមកពី លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ(MRCs) គណៈកម្មការជាតិទន្លេ មេគង្គ (NMCs) ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយជាតិ (NDMO) និងគណៈកម្មាធិការ-ការិយាល័យថ្នាក់ស្រុកនិងខេត្ត នានា ក្រោយពីមានកិច្ចពិគ្រោះយោបល់កម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ខេត្តជាច្រើនលើក និងតាមរយៈដំណើរការបង្កើត កម្មវិធីត្រៀមបង្ការទឹកជំនន់ជាក់ស្តែងនៅតាមខេត្ត និងតាមស្រុកនៅតាមបណ្តាប្រទេសដីសណ្តទន្លេមេគង្គក្រោម ជាពិសេស ប្រទេសកម្ពុជា និងប្រទេសឡាវ។ ឯកសារមេរៀននេះ ក៏ជាលទ្ធផលមួយនៃផ្នែកទាំង០៤ របស់កម្មវិធីកាត់បន្ថយនិងគ្រប់គ្រងគ្រោះទឹកជំនន់(FMMP) របស់គណៈកម្មការទន្លេមេគង្គ(MRC) ផងដែរ។ ADPC សហការជាមួយ MRC បាននឹងកំពុងអនុវត្តគំរោងកម្មវិធីទាំង០២ខាងលើសំដៅពង្រឹងសមត្ថភាពដល់អាជ្ញាធរថ្នាក់ខេត្តនិង ស្រុក។

- *ការពង្រឹងការគ្រប់គ្រងគ្រោះទឹកជំនន់ (FEMS)* ផ្នែកទី៤ នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយទឹកជំនន់ របស់ MRC ចាប់តាំងពីខែកញ្ញាឆ្នាំ២០០៤ ដោយមានការឧបត្ថម្ភថវិកាពីអង្គការ GTZ។
- ការកសាងសមត្ថភាពសំរាប់កម្មវិធីធ្វើផែនការ និងអនុវត្តការត្រៀមបង្ការទឹកជំនន់នៅថ្នាក់ខេត្ត និងស្រុក នៅតាមដី សណ្តទន្លេមេគង្គក្រោម ចាប់តាំងពីឆ្នាំ២០០៣ ស្ថិតក្នុង០៣ដំណាក់កាល។ ដំណាក់កាលទី ១: ពីឆ្នាំ ២០០៣-២០០៤ ដំណាក់កាលទី ២: ពីឆ្នាំ២០០៥-២០០៦ និង

ដំណាក់កាលទី ៣: ពីឆ្នាំ២០០៧-២០០៨ ក្រោមជំនួយឧបត្ថម្ភថវិកាពី ECHO សំរាប់អនុវត្ត ផែនការសកម្មភាពនៅអាស៊ីខាងត្បូងភាគឈៀងខាងកើតរបស់ DIPECHO ។

នៅក្នុងកំឡុងពេលនៃការប្រតិបត្តិគំរោងកម្មវិធីខាងលើមេរៀនសំរាប់ការបណ្តុះបណ្តាលមួយ ត្រូវបាន បង្កើតឡើងនៅក្នុង ឆ្នាំ២០០៣ ដើម្បីកសាងសមត្ថភាពអាជ្ញាធរមូលដ្ឋានថ្នាក់ខេត្ត និងស្រុក ស្តីពីការ រៀបចំធ្វើផែនការ និងការអនុវត្តន៏កម្មវិធី ត្រៀមបង្ការ ទឹកជំនន់។ មេរៀនបណ្តុះបណ្តាល គឺរៀបចំឡើង ផ្អែកលើចំណុចខ្លាំង និងមេរៀនដែលទទួលបានកន្លងមក គួបផ្សំជាមួយគំនិតផ្តួចផ្តើម ពីការគ្រប់គ្រងគ្រោះ មហន្តរាយនៅក្នុងតំបន់ និងបានមកពីតំបន់អាស៊ីភាគខាងត្បូងផ្សេងទៀត។ រវាងខែកញ្ញាឆ្នាំ២០០៣ ដល់ ខែកក្កដា ឆ្នាំ២០០៤ ក្រោមដំណាក់កាលទី១ របស់គំរោងកម្មវិធី MRC- ADPC ECHO ការបណ្តុះបណ្តាល ថ្នាក់ជាតិសរុបចំនួន ០២ លើក: លើកទី១ រៀបចំនៅក្នុងប្រទេសកម្ពុជា (ចំនួន ៤ ខេត្ត) និង លើកទី២ រៀបចំនៅ ប្រទេសវៀតណាម (ចំនួន ២ ខេត្ត) សុទ្ធតែបានប្រើប្រាស់ឯកសារមេរៀននេះ សំរាប់ធ្វើការបណ្តុះបណ្តាល។ បន្ថែមលើនេះទៅទៀត សិក្ខាសាលាថ្នាក់ជាតិចំនួន ០២លើកទៀត (មួយលើកធ្វើនៅប្រទេសថៃ និងមួយលើក ទៀតធ្វើនៅប្រទេសឡាវ) ស្តីពីការធ្វើផែនការត្រៀមបង្ការទឹកជំនន់ ត្រូវបានធ្វើឡើង ហើយមេរៀនបណ្តុះ បណ្តាលត្រូវបានកែលំអឡើងវិញ។ នៅក្នុងកំឡុងពេលដំណាក់កាលទី ៣ របស់គំរោងកម្មវិធី MRC-ADPC ECHO រវាងឆ្នាំ២០០៥-២០០៦ មេរៀនបណ្តុះបណ្តាល ត្រូវបានយកមកប្រើប្រាស់នៅក្នុងលក្ខ័ណ្ឌ និងភាសា ជាក់លាក់របស់ប្រទេសចំនួន ០៣ ហើយជាសរុបការបណ្តុះបណ្តាលថ្នាក់ខេត្តចំនួន ៣ ត្រូវបានធ្វើឡើងនៅក្នុង ប្រទេសកម្ពុជា វៀតណាម និងឡាវ ហើយដំណើរការធ្វើផែនការត្រៀមបង្ការទឹកជំនន់ថ្នាក់ស្រុកមួយ ត្រូវបាន ធ្វើចប់សព្វគ្រប់នៅខេត្តក្រចេះ។

នៅក្រោមគំរោងកម្មវិធី MRC-ADP-GTZ ឯកសារមេរៀននេះ ត្រូវបានប្រើប្រាស់សំរាប់ធ្វើការបណ្តុះ បណ្តាលជាច្រើនវគ្គនៅ តាមបណ្តាខេត្ត ដែលឧបត្ថមថវិកាគាំទ្រគំរោងសំរាប់ដំណាក់កាលទី២ ដោយ ECHO ។ ក្រោយមកឯកសារនេះ ត្រូវបានកែប្រែទៅជា សៀវភៅមគ្គុទេសក៏សំរាប់បំរើឱ្យការងារប្រតិបត្តិជាក់ស្តែង ស្តីពី *"ការត្រៀមបង្ការទឹកជំនន់សំរាប់អាជ្ញាធរមូលដ្ឋានក៏រិតស្រុក និខេត្ត នៅតាមបណ្តាប្រទេសដីសណ្តទន្លេមេគង្គ "*។ នៅឆ្នាំ២០០៥-២០០៦កន្លងទៅនេះ ឯកសារសារមេរៀនពព្រងាងនេះ ត្រូវបានប្រើប្រាស់ សំរាប់បើកវគ្គហ្វឹកហ្វឺនពី កម្មវិធីត្រៀមបង្ការទឹកជំនន់ថ្នាក់ខេត្តចំនួន ០២លើក និង ថ្នាក់ស្រុកចំនួន ០៤លើក នៅក្នុងប្រទេសកម្ពុជា ក្រោមគំរោងកម្មវិធីរបស់ MRC-ADPC-GTZ។ សិក្ខាសាលា និងការបណ្តុះបណ្តាល ស្តីពីដំណើរការធ្វើផែនការ ត្រៀមបង្ការទឹកជំនន់ថ្នាក់ខេត្ត នៅតាមស្រុកនិងឃុំគោលដៅទាំងអស់ស្ថិតក្នុង ខេត្តព្រៃវែង ខេត្តកណ្តាល និង ខេត្តក្រចេះ ក៏នៅបានប្រើប្រាស់នូវឯកសារ ពង្រាងនេះ ដែរ។

នៅថ្ងៃទី២៣ វិច្ឆិកា ឆ្នាំ២០០៦ ឯកសារមេរៀនពង្រាងខាងលើ ត្រូវបានពិនិត្យកែសំរួលឡើងវិញ នៅក្នុងសិក្ខាសាលា (write-shop) ថ្នាក់តំបន់មួយ មានរយៈពេល០២ថ្ងៃនៅប្រទេសថៃ ដែលមានអ្នកចូលរួមជាអ្នកអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយ សរុបចំនួន២១នាក់ មកពីប្រទេសថៃ កម្ពុជា ឡាវ វៀតណាម ស្រីលង្កា និង បង់ក្លាដេស។ បន្ថែមលើនេះទៅទៀត ឯកសារមេរៀននេះ ត្រូវបានប្រើប្រាស់ និងបកប្រែជាភាសាឡាវ នៅក្រោមគំរោងកម្មវិធី MRC-ADPC-ECHO សំរាប់គំរោងដំណាក់កាលទី ៣ ។

ឯកសារមេរៀននេះ ផ្តល់នូវមូលដ្ឋាននៃការយល់ដឹងនិងបរិយាយពីរបៀបនៃដំណើរការអនុវត្តន៏ ក្នុងការរៀបចំធ្វើផែនការ ត្រៀមបង្ការទឹកជំនន់ រួមមាន ១០ជំពូក ដូចខាងក្រោមនេះ :

១. ការធ្វើផែនការត្រៀមបង្ការទឹកជំនន់

២. ការត្រៀមបង្ការនៅកំរិតថ្នាក់ខេត្ត និងថ្នាក់ស្រុក

៣. ការប៉ាន់ប្រមាណលើការគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព

៤. យន្តការរបស់ស្ថាប័ននិងអង្គការពាក់ពន្ធ័នានា សំរាប់ដំណើរការត្រៀមបង្ការនិងគ្រប់គ្រងគ្រោះទឹកជំនន់

៥. ឯកសារយោងផ្សេងៗ សំរាប់ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់

៦. វិធានការណ៍ត្រៀមបង្ការគ្រោះទឹកជំនន់: មុនពេល កំឡុងពេល និង ក្រោយពេលទឹកជំនន់

៧. ការត្រៀមបង្ការ និងការថែរក្សាបញ្ជីធនធាន

៨. ការប៉ាន់ប្រមាណ និង ក ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់

៩. ការបញ្ជ្រាបតំរូវការចាំបាច់នានារបស់ក្រុមងាយរងគ្រោះ ទៅក្នុងការផែនការត្រៀមបង្ការគ្រោះទឹកជំនន់

១០. សមាហរណកម្មផែនការត្រៀមបង្ការទឹកជំនន់ ទៅក្នុងផែនការអភិវឌ្ឍន៏ថ្នាក់ស្រុក ខេត្ត និង ថ្នាក់ជាតិ

# មាតិកាអត្ថបទ


**បញ្ជីអក្សរកាត់** ........ i

**សេចក្តីផ្តើម** ........ iii

**ជំពូកទី១: ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់** ........ **២**

១.១ ទិដ្ឋភាពរួម ........ ២

១.២ គោលបំណងជំពូក ........ ២

**ផ្នែកទី ១: ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ គឺជាអ្វី?** ........ **៣**

១.៣ គោលគំនិតសំខាន់ៗ ........ ៣

១.៤ ផ្នែកសំខាន់ៗនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ........ ៤

**ផ្នែកទី២ : របៀបបង្កើតផែនការត្រៀមបង្ការទឹកជំនន់** ........ **៦**

១.៦ ទម្រង់នៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់ថ្នាក់ខេត្ត និងថ្នាក់ស្រុក ........ ៦

១.៧ សំណួរសំរាប់ធ្វើការពិចារណា ........ ១៨

១.៨ សេចក្តីយោង ........ ១៨

**ជំពូកទី ២: ការរៀបចំកំរងឯកសារថ្នាក់ខេត្ត និង ស្រុក** ........ **២០**

២.១ ទិដ្ឋភាពរួម ........ ២០

២.២ គោលបំណង ........ ២០

២.៣ គោលគំនិតសំខាន់ៗ ........ ២០

២.៤ ផ្នែកសំខាន់ៗនៃសាវតាខេត្ត-ស្រុក ........ ២១

២.៥ សំណួរសំរាប់ពិចារណា ........ ២២

២.៦ សេចក្តីយោង ........ ២២

**ជំពូកទី ៣: ការប៉ាន់ប្រមាណពីការគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព (HVCA)** ........ **២៤**

៣.១ ទិដ្ឋភាពរួម ........ ២៤

៣.២ គោលបំណង ........ ២៤

៣.៣ គោលគំនិតសំខាន់ៗ ........ ២៥

៣.៤ ផ្នែកសំខាន់នៃ HVCA ....... ២៨
៣.៤.១ ការប៉ាន់ប្រមាណគ្រោះទឹកជំនន់ ....... ២៨
៣.៤.២ ការប៉ាន់ប្រមាណលើ ភាពងាយរងគ្រោះ ....... ៣០
៣.៤.៣ ការប៉ាន់ប្រមាណសមត្ថភាព ....... ៣៣
៣.៥ សំណួរសំរាប់ពិចារណា ....... ៣៥
៣.៦ សេចក្តីយោង ....... ៣៦

**ជំពូកទី ៤: យន្តការស្ថាប័ន និង អង្គការពាក់ពន្ធ័ដទៃទៀតសំរាប់ការត្រៀមបង្ការ និង ការគ្រប់គ្រងគ្រោះទឹកជំនន់ ....... ៣៨**
៤.១ ទិដ្ឋភាពរួម ....... ៣៨
៤.២ គោលបំណង ....... ៣៨
៤.៣ គោលគំនិតសំខាន់ៗ ....... ៣៩
៤.៤ ការវិភាគអ្នកពាក់ព័ន្ធ និងផលប្រយោជន៏សំខាន់ៗនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ ....... ៤០
៤.៥ នរណាខ្លះជាអ្នកពាក់ព័ន្ធនៅក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់? ....... ៤១
៤.៦ សំណួរសំរាប់ពិចារណា ....... ៤៤

**ជំពូកទី ៥: ឯកសារយោងរបស់ស្ថាប័ន សំរាប់ធ្វើផែនការត្រៀមបង្ការទឹកជំនន់ ....... ៦៨**
៥.១ ទិដ្ឋភាពរួម ....... ៦៨
៥.២ គោលបំណង ....... ៦៨
៥.៣ គោលគំនិតសំខាន់ៗ ....... ៦៨
៥.៤ ផ្នែកសំខាន់នៃតើឯកសាយោងរបស់ស្ថាប័ន គឺជាអ្វី? ....... ៦៩
៥.៥ ហេតួអ្វីបានជាឯកសារយោងរបស់ស្ថាប័នមានសារៈសំខាន់? ....... ៦៩
៥.៦ ផ្នែកសំខាន់នៃ SOP ....... ៦៩
៥.៧ សំណួរសំរាប់ការពិចារណា ....... ៨១
៥.៨ សេចក្តីយោង ....... ៨១

**ជំពូកទី ៦: វិធានការកាត់បន្ថយគ្រោះទឹកជំនន់ដែលត្រូវអនុវត្ត នៅមុនពេល ក្នុងពេល និង ក្រោយពេលទឹកជំនន់ ....... ៨៣**

៦.១ ទិដ្ឋភាពរួម ........ ៨៣
៦.២ គោលបំណង ........ ៨៣
៦.៣ គោលគំនិតសំខាន់ៗ ........ ៨៣
ផ្នែកទី១ : វិធានការត្រៀមបង្ការទឹកជំនន់ ........ ៨៥
I ការលើកកំពស់ការយល់ដឹងជាសាធារណៈ ........ ៨៥
*II វិធីសាស្ត្រលើកកំពស់ការយល់ដឹងជាសាធារណៈ* ........ ៨៥
III ការបង្កើតប្រព័ន្ធមួយសំរាប់ការផ្សព្វ *ផ្សាយការព្យាករណ៍ទឹកជំនន់ និង ការប្រកាសអាសន្នមុន* ........ ៨៧
IV *ផែនការជំលៀស និង គ្រប់គ្រងទីជំរកបណ្តោះអាសន្ន* ........ ៩០
V *ការធ្វើផែនការស្វែងរក និងសង្គ្រោះ* ........ ៩២
VI *ការធ្វើផែនការទឹក អនាម័យ និងការថែទាំសុខភាព* ........ ៩២
*VII ការធ្វើផែនការជីវភាពរស់នៅ* ........ ៩៤
*VIII លំហាត់ Drills និង Mock* ........ ៩៥
ផ្នែកទី២ : ប្រតិបត្តិការឆ្លើយតបទឹកជំនន់ ........ ៩៦
*I. ការតាមដានទឹកជំនន់* ........ ៩៧
II. ការព្យាករណ៍ និងការផ្សព្វផ្សាយគ្រោះអាសន្នមុន ........ ៩៧
*III ប្រតិបត្តិការជំលៀស* ........ ៩៨
*IV. តំបន់សុវត្ថិភាព និងការគ្រប់គ្រងជំរកបណ្តោះអាសន្ន* ........ ៩៨
*V. ប្រតិបត្តិការស្វែងរក និង សង្គ្រោះ* ........ ៩៩
*VI ការថែទាំសុខភាព និង ប្រតិបត្តិការផ្នែកសុខាភិបាល* ........ ១០០
*VII. ការប៉ាន់ប្រមាណរហ័សអំពីការខូចខាត និងតំរូវការ* ........ ១០១
*VIII. ការសំរបសំរួល និងការគ្រប់គ្រងជំនួយសង្គ្រោះ* ........ ១០១
ផ្នែកទី៣ : វិធានការស្តារឡើងវិញ និងការស្តារនីតិសម្បទាទឹកជំនន់ ........ ១០៣
*I. ការប៉ាន់ប្រមាណការខូចខាតក្រោយពេលគ្រោះមហន្តរាយ* ........ ១០៤
*II ការសំអាតបរិដ្ឋាន* ........ ១០៦
*III. ការស្តារហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានឡើងវិញ* ........ ១០៧
ផ្នែកទី៤ : វិធានការកាត់បន្ថយទឹកជំនន់ ........ ១០៨
*I.* ការការពារទឹកជំនន; ........ ១០៨
*II. ការទប់ទឹកជំនន,* ........ ១០៩

*III. ការកំនត់តំបន់ទំនាបទឹកលិច* ........ ១១២

*IV. ការកសាងសមត្ថភាព និងការលើកកំពស់ចំណេះដឹង និងការអនុវត្តន៍ក្នុងស្រុក* ........ ១១៣

*V. ការលើកកំពស់ការយល់ដឹងជាសាធារណ:* ........ ១១៤

៦.៤ បញ្ហាសំរាប់ពិចារណា ........ ១១៥

៦.៥ សេចក្តីយោង ........ ១១៥

**ជំពូកទី ៧: ការរៀបចំ និង ការថែរក្សាបញ្ជីរធនធាន ........ ១១៧**

៧.១ ទិដ្ឋភាពរួម ........ ១១៧

៧.២ គោលបំណង ........ ១១៧

៧.៣ គោលគំនិតសំខាន់ៗ ........ ១១៧

៧.៤ បញ្ជីរធនធានសំរាប់ការត្រៀមបង្ការទឹកជំនន់ ........ ១១៨

៧.៥ ការវិភាគធនធាន ........ ១១៩

៧.៦ សំណួរសំរាប់ពិចារណា ........ ១២២

**ជំពូកទី ៨: ការវាយតំលៃ និង ការធ្វើវឌ្ឍនភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ........ ១២៤**

៨.១ ទិដ្ឋភាពរួម ........ ១២៤

៨.២ គោលបំណង ........ ១២៤

៨.៣ គោលគំនិតសំខាន់ៗ ........ ១២៤

៨.៤ តើអ្វីជាការវាយតំលៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់? ........ ១២៥

៨.៥ តើអ្វីជាវឌ្ឍនភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់? ........ ១២៥

៨.៦ ការវាយតំលៃនិងការវឌ្ឍនភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ........ ១២៦

៨.៧ សំណួរសំរាប់ពិចារណាអំពីការធ្វើវឌ្ឍភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ........ ១២៦

៨.៨ ជំហានការវាយតំលៃនិងការធ្វើវឌ្ឍនភាពដែលត្រូវតាមដាន ........ ១២៧

៨.៩ អ្នកពាក់ព័ន្ធ និង តួនាទីសំខាន់ៗរបស់ពួកគេក្នុងការវាយតំលៃនិងធ្វើវឌ្ឍនភាព ........ ១២៧

**តួនាទីនៅក្នុងការវាយតំលៃនិងការធ្វើវឌ្ឍនភាព ........ ១២៧**

៨.១០ ការប្រមូលនិងការគ្រប់គ្រងពតិមានមានប្រសិទ្ធិភាពនិងទាន់ពេលវេលា ........ ១២៩

៨.១១ ការពិនិត្យឡើងវិញ និង ការធ្វើវឌ្ឍនភាព នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ........ ១៣០

៨.១២ សំណួរសំរាប់ពិចារណា ........ ១៣១

៨.១៣ សេចក្តីយោង.......................................................................................................................... ១៣១

**ជំពូកទី ៩: ការបញ្ច្រៀបតំរូវការពិសេស របស់ក្រុមដែលងាយរងគ្រោះទៅក្នុងការធ្វើផែនការត្រៀមបង្ការ ទឹកជំនន់.......................................................................................................................... ១៣៣**

៩.១ ទិដ្ឋភាពរួម .......................................................................................................................... ១៣៣

៩.២ គោលបំណង.......................................................................................................................... ១៣៣

៩.៣ គោលគំនិតសំខាន់ៗ.......................................................................................................................... ១៣៣

៩.៤ ការកំណត់ក្រុមដែលងាយរងគ្រោះនៅក្នុងស្ថានភាពទឹកជំនន់.......................................................... ១៣៥

៩.៥ វិធានការត្រៀមបង្ការដើម្បីដោះស្រាយតំរូវការពិសេស.......................................................... ១៣៧

៩.៦ មធ្យោបាយដោះស្រាយតំរូវការពិសេសរបស់ក្រុមដែលងាយរងគ្រោះ.......................................... ១៣៨

៩.៧ សេចក្តីយោង.......................................................................................................................... ១៤០

**ជំពូកទី ១០: ការធ្វើសមហរណកម្មផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយផែនការអភិវឌ្ឍថ្នាក់ជាតិ ខេត្ត និង ស្រុក.......................................................................................................................... ១៤២**

១០.១. ទិដ្ឋភាពរួម.......................................................................................................................... ១៤២

១០.២ គោលបំណង.......................................................................................................................... ១៤២

១០.៣ គោលគំនិតសំខាន់ៗ.......................................................................................................................... ១៤៣

១០.៤ ឧបសគ្គធំៗនៃការធ្វើសមាហរណកម្ម.......................................................................................... ១៤៤

១០.៥ សចក្តីយោង.......................................................................................................................... ១៤៦

# ជំពូកទី ១

## ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់

# ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់

## ១.១ ទិដ្ឋភាពរួម

ជាបឋម ជំពូកនេះផ្តល់ការយល់ដឹង និងទម្រង់ជាមូលដ្ឋាននៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់។ ដូច្នេះ វាត្រូវបែងចែកជាពីរផ្នែក។ ផ្នែកទីមួយ និយាយជាសំខាន់លើការយល់ដឹងពីដំណើរការនៃការធ្វើផែនការ ចំណែកឯផ្នែកទីពីរ ជាទម្រង់នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់។ ជំពូកនេះបញ្ជាក់ច្បាស់ពីគោលគំនិតសំខាន់ៗ ដែលប្រើសំរាប់ធ្វើផែនការ និង រៀបចំនូវផ្នែកសំខាន់ៗនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់នៅថ្នាក់ខេត្តនិងថ្នាក់ស្រុក។

ជំពូកនេះ ក៏លើកឡើងពីគុណប្រយោជន៍នៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់នេះផងដែរ ។ ជាគោលការណ៍ណែនាំ ការសង្កត់ធ្ងន់ជាពិសេស ចំពោះការព្រួយបារម្ភរបស់សហគមន៍ ដែលអាចកំណត់ពីភាពជោគ ជ័យ ឬភាពបរាជ័យនៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់។ នេះបង្ហាញថា ជំពូកថ្លែងពីការទទួលខុសត្រូវលើគ្រោះថ្នាក់ និងស្ថានភាពទឹកជំនន់ក្នុងពេលជាក់ស្តែង ជាជាងគ្រាន់តែជាឧបករណ៍បច្ចេកទេសតែម្យ៉ាង ប៉ុណ្ណោះ។

សន្និដ្ឋានជារួម ផ្នែកគន្លឹះនៃជំពូកនេះ- ជំពូកទី២ បង្ហាញពីទម្រង់នៃផែនការត្រៀមបង្ការទឹកជំនន់។ វាគឺជាលទ្ធផលនៃបទពិសោធន៍ បច្ចេកទេសជាក់ស្តែង និងជាការពិនិត្យឡើងវិញបែបទ្រឹស្តី និងការស៊ីជំរៅលើការធ្វើផែនការត្រៀមបង្ការទឹកជំនន់ដែលបានមកពី ADPC នៅក្នុងកំឡុងពេលពីរទសវត្សន៍មុន។

ទម្រង់នេះ ផ្តល់នូវខ្នាតគំរូមួយ ដែលនឹងបង្ហាញពីតំលៃដល់អ្នកធ្វើផែនការថ្នាក់ខេត្ត និងថ្នាក់ស្រុក។ វាគឺជាគំរោងធ្វើការងារដែលណែនាំដល់វិធានការត្រៀមបង្ការ និងយុទ្ធសាស្ត្រទាំងអស់ ដែលមាននៅក្នុងឯកសារមេរៀននេះ ហើយត្រូវការតាមដានបន្តមួយជំហានម្តងៗ។ ទម្រង់បង្ហាញពីផ្លូវគួរឱ្យជឿទុកចិត្តមួយនៃដំណើរការទាក់ទិនទៅនឹងការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់។ ដូចជាមនុស្សម្នាក់ដែលសង្កេតឃើញថា អត្ថបទរបស់ឯកសារមេរៀន ការពិតទៅ គឺជាការអធិប្បាយនៃទម្រង់នេះ។

## ១.២ គោលបំណងជំពូក

- ស្វែងយល់ពីដំណើរការទាក់ទងទៅនឹងការធ្វើផែនការត្រៀមបង្ការទឹកជំនន់
- ទទួលស្គាល់ផ្នែកជាគន្លឹះនៃផែនការត្រៀមបង្ការទឹកជំនន់
- ស្វែងយល់ពីរបៀបបង្កើតការធ្វើផែនការត្រៀមបង្ការទឹកជំនន់ថ្នាក់ខេត្ត និងថ្នាក់ស្រុក
- ប្រើប្រាស់ទម្រង់គំរូមួយសំរាប់ផែនការត្រៀមបង្ការទឹកជំនន់នៅកំរិតថ្នាក់ខេត្ត និងស្រុក

# ផ្នែកទី ១: ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ គឺជាអ្វី?

## ១.៣ គោលគំនិតសំខាន់ៗ

- ការធ្វើផែនការត្រៀមបង្ការទឹកជំនន់ប្រើដើម្បី : *ចាត់វិធានការសមស្របមុនពេលទឹកជំនន់ ដើម្បីធានាដល់ការឆ្លើយតប និងជំនួយសង្គ្រោះដ៏មានប្រសិទ្ធិភាព នៅក្នុងកំឡុងពេល និងក្រោយព្រឹត្តិការណ៍។*
- លទ្ធផលសំខាន់នៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់ គឺជាឯកសារផែនការមួយ ជាការធ្វើផែនការត្រៀមបង្ការទឹកជំនន់ ឬជាយុទ្ធសាស្ត្រដែលបានចងក្រងជាឯកសារមួយ ដែលមានការរៀបចំចាត់ចែងពណ៌នាពីរបៀបឆ្លើយតប និងជំនួយសង្គ្រោះពីព្រឹត្តិការណ៍គ្រោះមហន្តរាយដែលនឹងត្រូវទទួលរ៉ាប់រង។
- ការធ្វើផែនការមុនគ្រោះមហន្តរាយ គឺមានសារៈសំខាន់សំរាប់ធានាដល់ការឆ្លើយតប យ៉ាងមានប្រសិទិភាព នៅពេលមានគ្រោះមហន្តរាយ។
- ការធ្វើផែនការទៅលើទឹកជំនន់ គួរតែត្រូវបានធ្វើឡើងនៅគ្រប់តំបន់ទាំងអស់ ដែលមានទំនាក់ទំនងរវាងទឹកជំនន់ និងសកម្មភាពរបស់មនុស្ស។
- រចនាសម្ព័ន្ធស្ថាប័នមួយ គួរតែបង្កើតឡើងមុនការធ្វើផែនការត្រៀមបង្ការទឹកជំនន់។ វានឹង ធានាថាវិធានការត្រៀមបង្ការសមស្របប្រព្រឹត្តទៅនៅគ្រប់កំរិតនីមួយៗរបស់រដ្ឋាភិបាល ដូចមានចែងនៅក្នុងផែនការត្រៀមបង្ការទឹកជំនន់។ វានឹងធានាផងដែរ នូវផែនការដែលមានការ សំរបសំរួលបានល្អ ជាមួយនឹងតួនាទី និងការទទួលខុសត្រូវដែលបានកំណត់ច្បាស់លាស់ទៀតផង។
- រដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់ស្រុក គឺជាជនបង្គោលសំរាប់ការអនុវត្តន៏ផែនការទាំងអស់របស់រដ្ឋាភិបាល រួមទាំងផែនការ និងសកម្មភាពត្រៀមបង្ការទឹកជំនន់ ផងដែរ។
- ផែនការត្រៀមបង្ការទឹកជំនន់ដែលមានប្រសិទិភាព គ្របដណ្តប់មុខងារសំខាន់ៗដូចតទៅ :

i. ការប៉ាន់ប្រមាណលើភាពងាយរងគ្រោះដោយសារទឹកជំនន់នៅតាមតំបន់ ដែលរួមមានការវិភាគព្រឹត្តិការណ៏ទឹកជំនន់ជាប្រវត្តិសាស្ត្រ និងការវាយតំលៃនិន្នាការនៅពេលអនាគតផងដែរ។

ii. ការប៉ាន់ប្រមាណប្រភពធនធាន និងសមត្ថភាពនៅតាមកំរិតមូលដ្ឋាន

iii. ការត្រៀមរៀបចំ និងវិធានការនានា ដែលនិយាយពីគ្រោះមហន្តរាយទឹកជំនន់ នឹងត្រូវប្រើប្រាស់នៅដំណាក់កាលមុនពេល កំឡុងពេល និងក្រោយពេលទឹកជំនន់។ នេះ ណែនាំពីប្រតិបត្តិការជួយ

សង្គ្រោះ ការជំលៀស កិច្ចខិតខំប្រឹងប្រែងសង្គ្រោះ និងជំនួយផ្នែកពេទ្យ នៅក្នុងកំឡុងពេល និងក្រោយពេលទឹកជំនន់ ជាឧទាហរណ៍ : ការចេញប្រកាសអាសន្នទាន់ពេលវេលា និងមានប្រសិទ្ធិភាព ការជំលៀសប្រជាជន និងរើទ្រព្យសម្បត្តិជាបណ្តោះអាសន្នពីទីតាំងដែលមានការគំរាមកំហែង ការសាងសង់ជំរកបណ្តោះអាសន្ន និងការថែទាំ ការស្តុកទុកសំភារៈជំនួយសង្គ្រោះ និងការធានាអោយមាននូវបណ្តាញទំនាក់ទំនង មានការបើកចំហរជានិច្ច នៅក្នុងពេលមានអាសន្ន។

iv. ការកំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារផ្សេងៗដែលទាក់ទងនឹងការរៀបចំ និងវិធានការផ្សេងៗ ដែលបានកំនត់។

## ១.៤ ផ្នែកសំខាន់ៗនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ គឺជាឯកសារសកម្មភាពមួយ ។ វាបង្ហាញលំអិតពីសកម្មភាពវិធានការជាក់លាក់ដែលត្រូវធ្វើនៅមុនទឹកជំនន់ ដែលមានគោលការណ៍ធ្វើកិច្ចប្រតិបត្តិការនៃការឆ្លើយតបនៅពេលមានអាសន្ន និងសកម្មភាពស្តារឡើងវិញ យ៉ាងមានប្រសិទ្ធិភាពនៅក្នុងកំឡុងពេល និងក្រោយទឹកជំនន់។ ផែនការនេះក៏បានគូសបញ្ជាក់ពីតំរូវការរបស់សហគមន៏ និង តួនាទី និង ការទទួលខុសត្រូវដ៏ជាក់លាក់របស់អ្នកពាក់ព័ន្ធផ្សេងៗទៀតផងដែរ។

ការធ្វើផែនការត្រៀមបង្ការ គួរតែចាត់ជាសកម្មភាពដែលកំពុងបន្ត ហើយត្រូវការពិនិត្យឡើងវិញលើមូលដ្ឋានរដូវកាល និងនៅពេលដែលចាំបាច់នោះ វាត្រូវធ្វើឱ្យទាន់សភាពការណ៍។ ការធ្វើផែនការត្រៀមបង្ការរួមមានផ្នែកដូចខាងក្រោម :

១. **ការប៉ាន់ប្រមាណពីភាពងាយរងគ្រោះនៃទឹកជំនន់ :** ប្រវត្តិទឹកជំនន់នៅក្នុងតំបន់ អាចជួយឱ្យអ្នកអនុវត្ត និងអ្នកធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយ កំណត់បាននូវតំបន់ដែលងាយរងគ្រោះ និងប្រការនានាដែលស្ថិតក្នុងគ្រោះភ័យ ។ បូករួមជាមួយនឹងការរីកចំរើននៃការរៀបចំនៅក្នុងតំបន់ គ្រោះថ្នាក់ទឹកជំនន់នៅពេលអនាគត អាចប៉ាន់ស្មានទុកជាមុនបាន។ ផែនទីគ្រោះទឹកជំនន់ ក៏អាចជួយនៅក្នុងការធ្វើការប៉ាន់ប្រមាណនេះបានដែរ។

២. **ការប៉ាន់ប្រមាណពីតំរូវការដែលមានពិត :** ផ្អែកលើទិន្នន័យនៃគ្រោះមហន្តរាយពីមុនៗ អ្នកធ្វើផែនការនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ចងក្រងបញ្ជីនៃសេចក្តីត្រូវការ និងធនធានដែលអាចរកបាន។ ការខ្វះចន្លោះរវាងសេចក្តីត្រូវការ និង ធនធានគួរតែកំណត់ជាមុន ហើយ ត្រូវស្នើឱ្យមានមធ្យោបាយកាត់បន្ថយវាផងដែរ។

៣. **ការធ្វើឱ្យមានដំណើរការនូវការផ្តល់ពតិមានជាមុន និងប្រព័ន្ធឆ្លើយតបគ្រោះមហន្តរាយ :** ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ត្រូវតែបញ្ជាក់ឱ្យបានច្បាស់ពីរបៀបផ្តល់ពតិមានជាមុនដល់សហគមន៏ទាំងមូល។

អ្នកធ្វើផែនការថ្នាក់ខេត្ត និងថ្នាក់ស្រុក គួរតែផ្អែកបញ្ហានេះ ទៅលើការព្យាករណ៍ដែលទទួលបានពីទីភ្នាក់ងារថ្នាក់ជាតិ និងពីថ្នាក់តំបន់។ ពួកគេក៏ត្រូវលើកឡើងនូវមធ្យោបាយនានា ដូចទៅនឹងអ្វីដែលសហគមន៍ត្រូវតែធ្វើជាមុន។ ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ក៏ធានាឱ្យមាននូវមធ្យោបាយនានានៃការពាក់ព័ន្ធរបស់ដៃគូចូលរួមទាំងអស់ អាស្រ័យទៅតាមតួនាទី និងការទទួលខុសត្រូវសំរាប់ការសម្របសម្រួល និងប្រព័ន្ធរាយការណ៍ ដ៏ល្អប្រសើរ ហើយផ្តល់នូវចំនុចសំខាន់ៗនៅក្នុងផែនការ។

៤. **ការប្រមូលធនធាន និង ថវិកា :** ការឆ្លើយតបទៅនឹងទឹកជំនន់ គឺត្រូវការធនធានជាច្រើន ដូច្នេះផែនការនេះ ត្រូវតែកំនត់ឱ្យបានច្បាស់ពីធនធានអ្វីដែលមានជាក់ស្តែងនៅថ្នាក់ខេត្ត ស្រុក ឃុំ និងថ្នាក់ភូមិ។ ផែនការនេះ ក៏កំនត់ផងដែរពីធនធានអ្វីដែលនឹងចាំបាច់ និងទីកន្លែងណាដែលអាចរកធនធាននេះបាន។

៥. **ការទំនាក់ទំនងនៅក្នុង និង ក្រៅសហគមន៍ :** ដើម្បីធានាឱ្យមានសារគ្រាអាសន្នច្បាស់លាស់ និងមានប្រសិទ្ធិភាព ផែនការគួរតែកំនត់ឱ្យបានច្បាស់លាស់ពីមធ្យោបាយទំនាក់ទំនងដែលនឹងកើតមានឡើង ហើយ កើតឡើងតាមរយៈប្រព័ន្ធផ្សព្វផ្សាយអ្វី (វិទ្យុ ឬប្រព័ន្ធក្នុងស្រុក។ល។)

៦. **តាមផ្អែក :** ផែនការត្រៀមបង្ការ គួរតែបញ្ចូលជំនួយជួយសង្គ្រោះ និងជំនួយថ្នាំពេទ្យសំរាប់អ្នកដែលរងឥទ្ធិពល ដូចជា ការផ្គត់ផ្គង់ទឹក អនាម័យ ចំណីអាហារ និងអាហារូបត្ថម្ភ, និងការដឹកជញ្ជូន សុខាភិបាល ជំរក នីតិវិធីនៃការជំលៀស ការការពារ និងសន្តិសុខ។

## ១.៥ តើការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់មានប្រយោជន៍អ្វីខ្លះ?

ការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជួយនៅក្នុងការរៀបចំចាត់ចែង និងការដាក់ពង្រាយធនធាន ដើម្បីកាត់បន្ថយឥទិពលនៃគ្រោះមហន្តរាយ។ ផែនការត្រៀមបង្ការទឹកជំនន់ដែលល្អ បានជួយ :

- សហគមន៍ដែលងាយរងគ្រោះ ទទួលបានពត៌មានពិសេស ដូចជា ការព្យាករណ៍ និងការប្រកាស អាសន្នពីទឹកជំនន់ទាន់ពេលវេលា។
- ការផ្តល់នូវតំរូវការជាមូលដ្ឋាន ដូចជា ទីជំរក និងការថែទាំផ្នែកសុខាភិបាល ទឹកស្អាត អនាម័យ និងចំណីអាហារនៅក្នុងកំឡុងពេលទឹកជំនន់។
- ទទួលបានជាបន្ទបន្ទាប់សំរាប់ជីវភាពរស់នៅ បន្ថយការរំខានដល់សកម្មភាពសេដ្ឋកិច្ចឱ្យនៅតិចបំផុត។
- ការស្តារឡើងវិញជាបន្ទាន់នៃហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ។
- ការកំណត់ និងការត្រៀងគប្រភពធនធានបានល្អមុនស្ថានភាពទឹកជំនន់។
- ការសហការមាន ប្រសិទ្ធិភាព នៅក្នុងចំណោមទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីធានាដល់ការឆ្លើយតបគ្រោះមហន្តរាយបានគ្រប់គ្រាន់នៅក្នុងកំឡុងពេលទឹកជំនន់។

# ផ្នែកទី២ : របៀបបង្កើតផែនការត្រៀមបង្ការទឹកជំនន់

អ្នកធ្វើផែនការថ្នាក់ខេត្ត និងថ្នាក់ស្រុក ត្រូវប្រុងប្រយ័ត្នពិនិត្យមើលឱ្យបានច្បាស់លាស់ទម្រង់ដូចតទៅស្តីពី ការធ្វើផែនការត្រៀមបង្ការទឹកជំនន់ និងបង្កើតផែនការផ្ទាល់ខ្លួនរបស់គេដោយការប្រើប្រាស់តាម និងធ្វើទៅតាមបរិបទខ្នាតនេះ។

## ១.៦ ទម្រង់នៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់ថ្នាក់ខេត្ត និងថ្នាក់ស្រុក

ផ្នែកដូចតទៅនេះ គួរតែត្រូវបានពិចារណា ស្របពេលដែលរៀបចំធ្វើផែនការត្រៀមបង្ការទឹកជំនន់ :

*១.* **សេចក្តីផ្តើម** *(យ៉ាងច្រើនបំផុត ១ ទំព័រ)*

***សូមមើលជំពូកទី១ផ្នែកទី១.៣ និង ១.៤***

***ការពិពណ៌នាសង្ខេបមួយស្តីពីប្រវត្តិទឹកជំនន់ និងឥទ្ធិពលរបស់វា គោលបំណងនៃផែនការ ភាពមានប្រយោជន៍នៃផែនការ យន្តការធ្វើផែនការ និងអ្នកពាក់ព័ន្ធនៃផែនការ។***

### ១.១ សាវតា

ទឹកជំនន់ទន្លេមេគង្គ និងចំណុចល្អ និងចំណុចមិនល្អនៃទឹកជំនន់ប្រចាំឆ្នាំ។

### ១.២ គ្រោះមហន្តរាយ និងឥទ្ធិពលនៃទឹកជំនន់

- យោងលើទឹកជំនន់ដែលអាក្រក់បំផុត (ឧ. ឆ្នាំ២០០០ ២០០១ និង ២០០២)
- សេចក្តីសង្ខេបទឹកជំនន់នាឆ្នាំបន្ទាប់
- ការពិពណ៌នាលំអិតពីទឹកជំនន់ឆ្នាំមុនៗ

### ១.៣ គោលបំណង និង យុទ្ធសាស្ត្រ

ក. ហេតុអ្វីត្រូវមានផែនការត្រៀមបង្ការទឹកជំនន់?

ខ. តើ ផែនការត្រៀមបង្ការទឹកជំនន់ អាចជួយអ្វីបាន?

គ. តើនរណាខ្លះពាក់ព័ន្ធនៅក្នុងការរៀបចំធ្វើផែនការត្រៀមបង្ការទឹកជំនន់? *សូមមើលជំពូកទី៤ យន្តកាស្ថាប័ន សំរាប់ការត្រៀមបង្ការទឹកជំនន់ និង ការរៀបចំទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះទឹកជំនន់ ផ្នែកទី ៤.៥ និង៤.៦ និងជំពូកទី៩ ផ្នែកទី៩.៨*

ឃ. យន្តកាធ្វើផែនការ (របៀបធ្វើឱ្យចេញផែនការនេះ)

ង. ប្រជាជនគោលដៅនៃផែនការ

ច. តើប្រើប្រាស់ផែនការនេះយ៉ាងដូចម្តេច?

*សូមមើលជំពូកទី១ និង ១.៦ ប្រសិទិភាពនៃ ការធ្វើផែនការត្រៀមបង្ការទឹកជំនន់*

**១.៤ ការទទួលខុសត្រូវ និង អាជ្ញាធរនៃផែនការ**

ក. តួនាទីរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត (PCDM) ចែងដោយក្រិតពីរដ្ឋាភិបាល

ខ. អភិបាលខេត្ត-ក្រុង គឺជាអាជ្ញាធរ

*សូមមើលជំពូកទី១ និង ១.៥ ប្រតិទិនសំរាប់ការធ្វើផែនការត្រៀមបង្ការទឹកជំនន់*

**១.៥ កាលបរិច្ឆេទរៀបចំផែនការ និង កំណត់ត្រាទាន់សភាពការណ៍**

ក. ឆ្នាំ រៀបចំធ្វើផែនការ និងសុពលភាព ( ឧ. ២០០៥-២០០៦)

ខ. ការពិនិត្យផែនការឡើងវិញ និងធ្វើឱ្យផែនការថ្មីជានិច្ច ( ពីរដងក្នុងមួយឆ្នាំ មុន និង ក្រោយទឹកជំនន់ភ្លាមៗ)

**២. សវិតាខេត្ត-ស្រុក** *( យ៉ាងច្រើនបំផុត ២ ទំព័រ)*

*សូមមើល ជំពូកទី ២ ការរៀបចំសវិតាថ្នាក់ខេត្ត និងស្រុក*

*ទិដ្ឋភាពរួមសង្ខេបមួយ ស្តីពីខេត្ត-ស្រុក អំពី ភូមិសាស្ត្រ ប្រជាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន*

**2.1. ភូមិសាស្ត្រ**

ក. លំអិតពីទីកន្លែងខេត្ត-ស្រុក

ខ. អាកាសធាតុ

គ. ចំនួនស្រុក ឃុំ និងភូមិ

ឃ. គំនូរប្លង់ការកាន់កាប់ដីធ្លី

ង. ស្ទឹង ទន្លេសំខាន់ៗ និងប្រភពទឹកផ្សេងទៀត

**2.2. ប្រជាសាស្ត្រ**

ក. សេចក្តីលំអិតអំពីប្រជាជន

ខ. អត្រាអក្ខរកម្ម

គ. អត្រាប្រាសក់ចំណូល

ឃ. សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

### 2.3. ហេដ្ឋារចនាសម្ព័នជាមូលដ្ឋាន

**ការចុះបញ្ជីរនៃហេដ្ឋារចនាសម្ព័នដែលមាន ដូចជា :**

ក. ប្រព័ន្ធផ្លូវថ្នល់

ខ. ប្រព័ន្ធ ប្រឡាយសំខាន់ៗ

គ. មន្ទីរពេទ្យ និងមណ្ឌលសុខភាព

ឃ. វិទ្យាស្ថានអប់រំ

ង. ប្រាសទ-ទីកន្លែងសាសនា

ច. ស្ពាន

ឆ. ប្រភពទឹកសំរាប់ផឹក

ជ. ការតំឡើងសំខាន់ៗ

ឈ. បរិក្ខារសំរាប់គ្រាអាសន្ន

1. **គ្រោះថ្នាក់ ឬគ្រោះភ័យ និងភាពដែលងាយរងគ្រោះនៃទឹកជំនន់ និង ការប៉ាន់ប្រមាណលើសមត្ថភាព**

*សូមមើលជំពូកទី៣ ការប៉ាន់ប្រមាណលើគ្រោះទឹកជំនន់*

*លទ្ធផលនៃការប៉ាន់ប្រមាណលើគ្រោះថ្នាក់ សមត្ថភាព និងភាពងាយរងគ្រោះ (HCVA) បំរើជាទិន្នន័យបឋមសំរាប់ដំណើរការធ្វើផែនការត្រៀមបង្ការទឹកជំនន់ ។ វាមាន :*

- *ប្រភេទនៃគ្រោះថ្នាក់ដែលខេត្ត-ស្រុកជួបប្រទះ*
- *ការវិភាគលើឥទិពលនៃករណីមុនៗដែលអាក្រក់ជាងគេបំផុត*
- *ប្រការដែលងាយរងគ្រោះ និងមូលហេតុនៃភាពងាយរងគ្រោះ និងកត្តា ( សេដ្ឋកិច្ចសង្គម ធម្មចាតិ និង បរិដ្ឋាន) ដែលនាំឱ្យមានការកើនឡើង ឬចុះថយនៅក្នុងភាពងាយរងគ្រោះ និងគ្រោះថ្នាក់ ។*
- *ធនធានក្នុងស្រុកដែលមាន ( មនុស្ស ថវិកា សំភារៈ) និងការកំណត់រកធនធានពីខាងក្រៅ ( វត្តមានរបស់អង្គការក្រៅរដ្ឋាភិបាលថ្នាក់តំបន់ ឬអង្គការអន្តរជាតិដែលកំពុងធ្វើការនៅក្នុងតំបន់ ការចំណាត់ថវិកាជាតិសំរាប់ជំនួយសង្គ្រោះទឹកជំនន់ ។ល ។) ការចុះបញ្ជីរធនធានមួយ អាចធ្វើឡើងបានអាស្រ័យលើទិន្នន័យដែលប្រមូលបាន ។*

### គ្រោះទឹកជំនន់

*សូមមើលជំពូកទី ៣ ផ្នែកទី ៣.៧*

ក. ប្រវត្តិនៃគ្រោះថ្នាក់ ( ឧ. សវិតាទិដ្ឋភាពរួម រយៈពេលជាមធ្យម-រយៈពេលនៃការជន់លិច

ប្រវត្តិសង្ខេបអំពីការបាក់ច្រាំងទន្លេ ការបាត់បង់ដីបង្កបង្កើនផល ការបាត់បង់ជីវភាពរស់នៅ ការរើទីតាំង រោគរាតត្បាត ភាពរីករវរនៅក្នុងសង្គម)

ខ. មូលហេតុ និងរដូវកាល-រយៈពេលទឹកជំនន់ប្រចាំឆ្នាំ (ពីខែកក្កដា ដល់ ខែតុលា)

គ. កំរិតទឹកជំនន់ (ពេលចាប់ផ្តើម ឡើងដល់កំពូល និងពេលស្រកវិញ)

ឃ. ទំហំ-មាឌ-ភាពធ្ងន់ធ្ងរនៃទឹកជំនន់ប្រចាំឆ្នាំ

ង. តំបន់ទឹកជនលិចប្រចាំឆ្នាំ

ច. ការប៉ាន់ស្មានទុកមុនសំរាប់អនាគត ពីព្រោះតែអាកាសធាតុផ្លាស់ប្តូរ (បើមាន)

## គ្រោះថ្នាក់ផ្សេងៗ

ក. រាំងស្ងួត មូលហេតុផ្សេងៗ ភាពធ្ងន់ធ្ង និងរដូវកាល

ខ. គ្រោះថ្នាក់ដោយអគ្គិភ័យ

គ. ផ្សេងៗ...

## ភាពងាយរងគ្រោះផ្នែកសេដ្ឋកិច្ចសង្គម (យោង : ផ្នែក ២.១ និង ២.២)

*សូមមើលជំពូកទី ៣ ផ្នែក ៣.៧*

ក. ចំនួនស្រុកដែលងាយរងគ្រោះ និង មូលហេតុនៃភាពងាយរងគ្រោះ

ខ. ប្រជាជនដែលទំនងជាត្រូវរងផលប៉ះពាល់ដោយទឹកជំនន់ (ត្រូវបង្ហាញលើតារាង)

## ភាពងាយរងគ្រោះផ្នែកធម្មជាតិ (យោង : ផ្នែក ២.៣)

ក. ចំនួនផ្លូវសរុបនៅជិតតំបន់ដែលរងគ្រោះខ្ពស់

ខ. ប្រឡាយ-ព្រែកជីក-ទំនប់ទឹកដែលអាចរងគ្រោះ-បំផ្លិចបំផ្លាញ

គ. ចំនួនមន្ទីរពេទ្យនៅក្នុងតំបន់រងគ្រោះខ្ពស់

ឃ. ចំនួនអគារសាលារៀននៅក្នុងតំបន់រងគ្រោះខ្ពស់

## ធនធាន និងសមត្ថភាព (ដែលមានស្រាប់ និងត្រូវការ)

*សូមមើលជំពូកទី ៣ ផ្នែកទី ៣.៥ និង ៣.៦*

ក. បរិក្ខារទីជំរក

ខ. បរិក្ខារដឹកជញ្ជូន

គ. ប្រព័ន្ធទំនាក់ទំនង

ឃ. បរិក្ខារការពារទឹកជំនន់

ង. បរិក្ខារស្តុបទុក

ច. បរិក្ខារពេទ្យ

ឆ. បរិក្ខារស្ថាប័ន និងផ្សេងៗ

ជ. ធនធានមនុស្ស

**2. យន្តកាស្ថាប័ន**

*សូមមើលជំពូកទី ៤ : យន្តកាស្ថាប័ន សំរាប់ការត្រៀមបង្ការទឹកជំនន់ និងការរៀបចំទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះទឹកជំនន់ និងជំពូកទី ៥ និតិវិធីប្រតិបត្តិកាតាមស្តង់ដារសំរាប់ផែនការត្រៀមបង្ការទឹកជំនន់*

*ជាសំខាន់ ត្រូវមានរចនាសម្ព័ន្ធ និងការរៀបចំចាត់ចែងជាផ្លូវការមួយ នៅកំរិតផ្សេងៗពីគ្នា ។ ផែនការត្រៀមបង្ការទឹកជំនន់ដែលល្អឆ្លុះបញ្ចាំងពីភាពសកម្មមុន និងគំរោងស្ថាប័នរដ្ឋាភិបាលដែលបានរៀបចំចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់នៅគ្រប់កំរិតខុសៗគ្នា និងមានឆន្ទៈនយោបាយធំធេងដើម្បីបង្កើតគោលនយោបាយជួយដល់ការអនុវត្តន៏ផែនការ ។ ការប្តេជ្ញាចិត្តនេះ ធានាដល់ដំណើរការធ្វើផែនការដែលមានតម្លាភាព និងមានគណនេយ្យភាព ។*

## 4.1. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក

*សូមមើលជំពូកទី៤ ឧបសម្ព័ន្ធសំរាប់ ឧទាហរណ៏បី នៃFPP ពីប្រទេសកម្ពុជា វៀតណាម និងឡាវ*

ក. រចនាសម្ព័ន្ធ PCDM/DCDM ( អង្គការលេខ)

ខ. បញ្ជីរសមាជិករបស់ PCDM/DCDM

គ. ឯកសារយោងរបស់ PCDM/DCDM *(ភ្ជាប់មកជាមួយជាឧបសម្ព័ន្ធ)*

## 4.2. រចនាសម្ព័ន្ធក្រុមគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក

ក. ស្រាវជ្រាវ និងសង្គ្រោះ

ខ. ការគាំទ្រផ្នែកសុខភាព អនាម័យ និងផ្លូវចិត្ត

គ. ការសំរបសំរួលជំនួយសង្គ្រោះ

ឃ. ការគ្រប់គ្រងព័តិមាន (រួមមាន ការប៉ាន់ប្រមាណលើការខូចខាត និងការបាត់បង់)

### 4.3. បន្ទប់ត្រួតពិនិត្យទឹកជំនន់នៅថ្នាក់ខេត្ត-ស្រុក

ក. បញ្ជីរឈ្មោះមន្ត្រី

ខ. បញ្ជីឧបករណ៏ (ឧ. កុំព្យូទ័រ ការតភ្ជាប់បណ្តាញអ៊ីនធឺណែត ម៉ាស៊ីនព្រីនធ័រ ហ្វាក់ ទូរស័ព្ទ Projector និងប្រព័ន្ធទប់ភ្លើង)

គោលការណ៏ប្រតិបត្តិកា

## 3. តួនាទី និងការទទួលខុសត្រូវរបស់សមាជិក PCDM និង DCDM

*សូមមើលជំពូកទី ៥ តួនាទី និងការទទួលខុសត្រូវរបស់សមាជិក PCDM និងDCDM*

*តួនាទី និងការទទួលខុសត្រូវរបស់សមាជិកនីមួយៗ គួរតែនិយាយឱ្យបានច្បាស់លាស់ពីគោលគំនិតជាគន្លឹះនៃប្រតិបត្តិការរបស់សាខា និងភ្នាក់ងារបណ្តាញក្នុងកំឡុងពេលគ្រប់គ្រងគ្រោះមហន្តរាយ ។ បានសេចក្តីថា ការត្រៀមបង្ការ ក្នុងកំឡុងពេល និងក្រោយគ្រោះមហន្តរាយ អាចនិយាយបានម្យ៉ាងទៀតថា គឺជាអ្វីដែលត្រូវធ្វើមុន ក្នុងកំឡុងពេល និងក្រោយ ពេលទឹកជំនន់ (កិច្ចការធម្មតាដែលពួកគេបានធ្វើ ក៏ដូចជាកិច្ចការបន្ថែមដែលពួកគេអាចធ្វើសំរាប់ការអនុវត្តន៏ ផែនការត្រៀមបង្ការទឹកជំនន់ ។*

### 5.1 ឯកសារសំអាងសំរាប់ក្រុមគ្រប់គ្រងគ្រោះមហន្តរាយ

*សំរាប់ក្រុមគ្រប់គ្រងគ្រោះមហន្តរាយ*

*សូមមើល ជំពូកទី ៥ ផ្នែកទី៥.៧*

ក. ការស្រាវជ្រាវ និងសង្គ្រោះ

ខ. ការគាំទ្រផ្នែកសុខភាព អនាម័យ និងផ្លូវចិត្ត

គ. ការសំរបសំរួលជំនួយសង្គ្រោះ

ឃ. ការគ្រប់គ្រងព័ត៌មាន (រួមមាន ការប៉ាន់ប្រមាណលើការខូចខាត និងការបាត់បង់)

## ៥.២ តួនាទី និងការទទួលខុសត្រូវរបស់សមាជិក PCDM និង DCDM

*សូមមើលជំពូកទី ៤ ផ្នែកទី ៤.៥ និង ៤.៦ និងជំពូកទី ៩ ការអនុវត្តន៏ និងការថែរក្សាផែនការត្រៀមបង្ការទឹកជំនន់ ផ្នែកទី ៩.៨*

*សំរាប់មន្ទីរទាំងអស់របស់ PCDM និងDCDM, ទិដ្ឋភាពទាំងនេះ នឹងត្រូវលំអិតដូចតទៅ :*

ក. តើពួកគេមានតួនាទី និងការទទួលខុសត្រូវសំខាន់ៗអ្វីខ្លះ នៅមុនពេល (ត្រៀមបង្ការ) កំឡុងពេល (ឆ្លើយតប) និងក្រោយពេលទឹកជំនន់ (ស្តារឡើងវិញ) ?

*នេះ មានទាំងមន្ទីរដែលដឹងពីកិច្ចការរបស់ពួកគេដែលត្រូវធ្វើ មានន័យថា សកម្មភាពដែលពួកគេត្រូវធ្វើ និងកិច្ចការបន្ថែមដែលពួកគេអាចធ្វើបានដើម្បីធានាការអនុវត្តន៍ផែនការត្រៀមបង្ការទឹកជំនន់មានប្រសិទ្ធិភាព ។*

ខ. តើយន្តកាសំរបសំរួល និងសហប្រតិបត្តិកា គឺជាអ្វី?

## វិធានការត្រៀមបង្ការទឹកជំនន់ ប្រតិបត្តិកាឆ្លើយតប ការស្តារឡើងវិញ និងការស្តារនីតិសម្បទា និងវិធានការកាត់បន្ថយ

*សូមមើលជំពូកទី ៦ ការត្រៀមបង្ការទឹកជំនន់ និងវិធានការកាត់បន្ថយ ប្រតិបត្តិកាឆ្លើយតប ការស្តារឡើងវិញ និង ការស្តារនីតិសម្បទា និងវិធានការកាត់បន្ថយ*

*ការបង្កើតផែនការសកម្មភាពសំរាប់ការអនុវត្តន៍ផែនការត្រៀមបង្ការទឹកជំនន់ និងអាទិភាពសកម្មភាពធ្វើឱ្យPCDM និង DCDM កំណត់នូវធនធានដែលត្រូវការ និងការចំណាត់មានប្រសិទ្ធិភាពរបស់ពួកគេ ។ សកម្មភាពត្រូវធ្វើឱ្យលំអិតនៅក្នុងមាតិការាងដូចមាននៅខាងក្រោម ។ ឧទាហរណ៍នៃសកម្មភាពលំអិត (មាតិកាតែប៉ុណ្ណោះ) មានសំរាប់យោង ។*

៦.១ វិធានការត្រៀមបង្ការ

ក. ការលើកកំពស់ការយល់ដឹងជាសាធារណៈ

- *ការបង្កើតសំភារៈការលើកកំពស់ការយល់ដឹងជាសាធារណៈ*
- *ការសាកល្បងសារលើកកំពស់ការយល់ដឹង*
- *ការរៀបចំធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈ*

ខ. ការព្យាករណ៍ និងការប្រកាសអាសន្នមុន

- *ការបង្កើតការព្យាករណ៍ និងប្រកាសអាសន្ន*
- *ការចែកចាយព័ត៌មានអំពីការព្យាករណ៍ និងប្រកាសអាសន្ន*

គ. ការរៀបចំតំបន់សុវត្ថិភាព

- *ការតំឡើងបរិក្ខាជាមូលដ្ឋាន (អនាម័យ ទឹក)*
- *ការសំអាតផ្លូវចូលដល់ និងការតំឡើងផ្លាកសញ្ញា*
- *ការកំណត់រកតំបន់សុវត្ថិភាពបន្ថែម*

ឃ. ការតំឡើងឧបករណ៍បញ្ជូនទឹកជំនន់ និងប្រព័ន្ធចែកចាយព័មិមាន

- *ការបង្កើតប្រព័ន្ធទំនាក់ទំនង*
- *ការតំឡើងឧបករណ៏*
- *ការកសាងសមត្ថភាពរបស់ភ្នាក់ងារទទួលខុសត្រូវ*

ង. ផែនទីគ្រោះទឹកជំនន់ និងផែនទីប្រភពធនធាន

- *កាបង្កើត-ការរៀបចំផែនទី*
- *ការចែកចាយផែនទី*
- *ការថែរក្សា-ការធ្វើឱ្យផែនទីទាន់សម័យ*

ច. ឃ្លាំងសំភារៈ

- *ការបង្កើតឃ្លាំងស្តុកនៅតំបន់ថ្មី*
- *ការថែរក្សារចនាសម្ព័ន្ធឃ្លាំងស្តុកដែលមានស្រាប់ (ឃ្លាំងរបស់រដ្ឋ កាកបាទក្រហម កន្លែងផ្គត់ផ្គង់ឯកជន ផ្សេងៗ បញ្ជីសារពើភ័ណ្ឌ ការកត់បញ្ជីស្តុក)*
- *ធ្វើបញ្ជីសារពើភ័ណ្ឌសំភារៈជំនួយសង្គ្រោះដែលសំខាន់ៗ និងរក្សាឱ្យគង់វង្ស*
- *ការបង្កើតផែនការចែកចាយ (ផ្តែកលើផែនទីភាពងាយរងគ្រោះ)*

ឆ. ប្រព័ន្ធសំរបសំរួល និងការរាយការណ៏

- *ការបង្កើតក្រុមកិច្ចការឯកទេសនៅក្នុង PCDM/DCDM (យោងលេខ ៤.២ និង៥.១)*
- *ការបង្កើតទម្រង់បែបបទតាមស្តង់ដារសំរាប់ការរាយការណ៏*
- *ការចែកចាយរបាយការណ៏ទៅទស្សនិជនទូទៅ (អាជ្ញាធរជាតិ អង្គការ..)*

ជ. ការកំណត់រកមន្ទីរ-ភ្នាក់ងារដែលទទួលខុសត្រូវ (យោងលេខ ៥.២)

ឈ. ការបង្កើតសូចនាករណ៏ (សំរាប់សកម្មភាពនីមួយៗ)

ញ. ការកំណត់រកប្រភពធនធានដែលត្រូវការ (សំរាប់សកម្មភាពនីមួយៗ)

## ៦.២ វិធានការកាត់បន្ថយ (ការត្រៀមបង្ការរយៈពេលវែង)

### ៦.២.១ ការកាត់បន្ថយបែបរចនាសម្ព័ន្ធ

ការកាត់បន្ថយបែបរចនាសម្ព័ន្ធមានដូចជា dykes ទំនប់ទឹក អាងស្តុបទឹក ប្រព័ន្ធធារាសាស្ត្រ គំរោងសាងសង់ទប់ទឹកជំនន់តាមរចនាសម្ព័ន្ធខុសៗគ្នា វិធានការទប់ទឹកជំនន់។

ក. សំណង់

- *Dykes ទំនប់ទឹក ព្រែកជីក*

- *តំបន់សុវត្ថិភាពរបស់សហគមន៍ និងផ្លូវចូលដល់របស់ពួកគេ*
- *ការថែទាំ និងការការពារ Dykes អាងស្តុកទឹកក្នុងកំឡុងពេលទឹកជំនន់*
- *ជំនួយបន្ថែមនៃគ្រឹះស្ថានសំខាន់ៗ (ឧ. ស្ពាន អគារ ផ្លូវថ្នល់)*

ខ. ការទប់ទឹកជំនន់

## ៦.២.២ ការត្រៀមបង្ការគ្មានរចនាសម្ព័ន្ធ

*ការត្រៀមបង្ការមិនមែនរចនាសម្ព័ន្ធ មានដូចជា ការបណ្តុះបណ្តាល ការធ្វើផែនការ ការលើកកំពស់ការយល់ដឹង ការផ្លាស់ប្តូរពេលវេលាបង្កបង្កើនផលកសិកម្ម-ដំណាំធន់នឹងទឹកជំនន់ ។ល។*

ក. ការលើកកំពស់ការយល់ដឹង និងការអប់រំជាសាធារណៈ

- *ការរៀបចំធ្វើយុទ្ធនាការជាទៀងទាត់*
- *ការភ្ជាប់ប្រព័ន្ធទំនាក់ទំនងអប់រំដែលមានស្រាប់ ដូចជា ការបង្កើតកម្មវិធីសុវត្ថិភាពតាមសាលារៀន ការអប់រំសិស្សសាលាតាមរយៈគ្រូបង្រៀន ថ្នាក់រៀនហែលទឹកសំរាប់កុមារ ។ល។*

ខ. ការបង្កើតស្ថាប័ន

- *កិច្ចសហការនៅក្នុងចំណោមអ្នកពាក់ព័ន្ធ*
- *ការភ្ជាប់ទំនាក់ទំនងទៅនឹងប្រភពធនធានខាងក្រៅ*

គ. ការបណ្តុះបណ្តាល និង ការកសាងសមត្ថភាព

- ការប៉ាន់ប្រមាណលើតំរូវការផ្នែកបណ្តុះបណ្តាល
- ការលើកគំរោង និងការផ្តល់កម្មវិធីបណ្តុះបណ្តាលផ្អែកលើតំរូវការ

ឃ. ការបង្កើតប្រព័ន្ធប្រកាសអាសន្នមុន និងការថែទាំ

ង. ការធ្វើផែនទីទឹកជំនន់

ច. ការកំណត់រកមន្ទីរ-ភ្នាក់ងារទទួលខុសត្រូវ (យោងទៅលេខ ៥.២)

ឆ. ការបង្កើតសូចនាករណ៏ (សំរាប់សកម្មភាពនីមួយៗ)

ជ. ការកំណត់រកប្រភពធនធានដែលត្រូវការ (សំរាប់សកម្មភាពនីមួយៗ)

## ៦.៣ ប្រតិបត្តិកាឆ្លើយតប

ក. វិធីសាស្រ្តជំលៀស

- *ការបង្កើតយុទ្ធសាស្រ្ត*

- *ការត្រៀមរៀបចំសំរាប់បរិក្ខាដឹកជញ្ជូន ( ទូក រទេះ ។ល ។)*

ខ. ការគ្រប់គ្រងតំបន់សុវត្ថិភាព

- *សន្តិសុខ*
- *ទឹក និងអនាម័យ*

គ. ការត្រៀមរៀបចំការទំនាក់ទំនង

- *ការបង្កើតប្រព័ន្ធទំនាក់ទំនងពេលគ្រាអាសន្ន*
- *ការចែកចាយព័ត៌មានស្តីពីការព្យាករណ៍ និងប្រកាសអាសន្ន*
- *ការប្រមូល ការចងក្រង និងចែកចាយទិន្នន័យ ( ការប៉ាន់ប្រមាណពីការខូចខាត និងការបាត់បង់ ការប៉ាន់ប្រមាណលើតំរូវការ)*

ឃ. ការត្រៀមរៀបចំផ្នែកពេទ្យ និងសុខភាព ( ការចូលរួមពីផ្នែកឯកជន និងផ្នែកសាធារណៈ)

- *ក្រុមគ្រូពេទ្យចល័ត*
- *ការប្រកាសជាសាធារណៈអំពីទីកន្លែងមណ្ឌលសុខភាព គ្លីនិក និងប៉ុស្តិ៍ជំនួយបឋមពេលគ្រាអាសន្ន*

ង. ការជួសជុលហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗជាបន្ទាន់ ( ទំនប់ទឹកមាត់ព្រែក ទំនប់ទឹក ស្ពាន ផ្លូវថ្នល់)

ច. ការជ្រើសរើស និងការគ្រប់គ្រងអ្នកស្ម័គ្រចិត្ត

ឆ. ការតាមដានគ្រោះថ្នាក់

ជ. ប្រតិបត្តិកាស្វែងរក និងសង្គ្រោះ

ឈ. ប្រតិបត្តិកាសង្គ្រោះគ្រាអាសន្ន

- *ការជ្រើសរើសអ្នកទទួលផល*
- *ការបែងចែកជំនួយសង្គ្រោះ*
- *ការបង្កើតប្រព័ន្ធមួយដើម្បីទទួលពាក្យបណ្តឹង និងការអំពាវនាវពីសហគមន៍*

ញ. ការត្រៀមរៀបចំការសំរបសំរួល

- *ការរៀបចំការប្រជុំគ្រាអាសន្ន*
- *ការបង្កើតបន្ទប់សំរបសំរួលគ្រាអាសន្ន*

ដ. ការកំណត់រកមន្ទីរ-ភ្នាក់ងារទទួលខុសត្រូវ ( យោងលេខ ៥.២)

ឋ. ការបង្កើតសូចនាករណ៍ ( សំរាប់សកម្មភាពនីមួយ)

ឌ. ការកំណត់ប្រភពធនធានដែលត្រូវការ ( សំរាប់សកម្មភាពនីមួយៗ)

### ៦.៣ ការស្តារឡើងវិញ និងការស្តារនីតិសម្បទា

ក. ការខូចខាតក្រោយពេលមហន្តរាយ និងការប៉ាន់ប្រមាណសេចក្តីត្រូវការ

ខ. ការធ្វើផែនការស្តារឡើងវិញ ផ្អែកលើការប៉ាន់ប្រមាណសេចក្តីត្រូវការ

គ. ការផ្សាភ្ជាប់ផែនការស្តារឡើងវិញជាមួយផែនការអភិវឌ្ឍខេត្ត-ស្រុក

ឃ. ការដោះស្រាយតាមបែបបរិដ្ឋាន

ង. ការជួសជុល-ការសាងសង់ឡើងវិញផ្ទះសម្បែង និងហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត

ច. ការផ្តល់ការថែទាំផ្នែកផ្លូវចិត្ត

ឆ. ប្រព័ន្ធសំរបសំរួល និងការរាយការណ៍

ជ. ការកំណត់រកមន្ទីរ-ភ្នាក់ងារទទួលខុសត្រូវ ( យោងលេខ ៥.២)

ឈ. ការបង្កើតសូចនាករណ៏ ( សំរាប់សកម្មភាពនីមួយ)

ញ. ការកំណត់ប្រភពធនធានដែលត្រូវការ ( សំរាប់សកម្មភាពនីមួយៗ)

### ៦.៥ ការចំណាត់ហិរញ្ញវត្ថុ

ក. ការចំណាត់ថវិកា និងហិរញ្ញវត្ថុ ( ថវិកាក្នុងស្រុក)

## ៧. ការរៀបចំ និងការថែទាំបញ្ជីប្រភពធនធាន

*សូមមើលជំពូកទី ៧ ការរៀបចំ និងការថែទាំបញ្ជីប្រភពធនធាន និងជំពូកទី ៣ ផ្នែកទី ៣.៤*

៧.១ ការវិភាគប្រភពធនធាននៅថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ថ្នាក់អន្តរជាតិ និងតាមផ្ទះ ថ្នាក់ភូមិ និងថ្នាក់ឃុំ

៧.២ បញ្ជីប្រភពធនធានសំរាប់ការធ្វើផែនការត្រៀមបង្ការទឹកជំនន់

- *ធនធានមនុស្ស - ឧ. អ្នកស្ម័គ្រចិត្ត ក្រុមពន្លត់អគ្គីភ័យ*
- *ធនធានសំភារៈ - ឧ. ទូក រទេះ ឧបករណ៏វិទ្យុ*
- *ធនធានហិរញ្ញវត្ថុ - ថវិកាឆ្លើយតបភាពអាសន្នដែលអាជ្ញាធរមូលដ្ឋានជាអ្នកកាន់កាប់ សំរាប់ចំណាយរហ័សនៅពេលទឹកជំនន់ ។*

## ៨. ការប៉ាន់ប្រមាណ និងការធ្វើផែនការថ្មីត្រៀមបង្ការទឹកជំនន់

*សូមមើលជំពូកទី៨ ផ្នែកទី ៨.៨*

*វាសំខាន់ ត្រូវកំណត់ឱ្យច្បាស់លាស់អំពី :*

ក. ធ្វើឱ្យដំណើរថ្មីជាទៀតទាត់ ( មួយឆ្នាំម្តង)

ខ. ការរៀបចំធ្វើ mock drills តាមពេលវេលា និងលំហាត់សម

## ៩. ការបញ្ជ្រៀបតំរូវការពិសេសរបស់ក្រុមដែលងាយរងគ្រោះទៅក្នុងផែនការត្រៀមបង្ការទឹកជំនន់

*សូមមើលជំពូកទី ៩ និងផ្នែកទី ៣.៧ នៃជំពូកទី ៣*

## ១០. សមាហរណកម្ម FPP ទៅក្នុងដំណើការធ្វើផែនការអភិវឌ្ឍមូលដ្ឋាន

*សូមមើលជំពូកទី ១០ ផ្នែកទី ៥.៣ នៃជំពូកទី ៥*

*ផ្នែកនេះពិពិណនាពីរបៀបការបង្កើតផែនការថ្នាក់ខេត្ត*

*និងថ្នាក់ស្រុកអាចភ្ជាប់ជាមួយនឹងផែនការត្រៀមបង្ការទឹកជំនន់ ។*

ក. ការភ្ជាប់ជាមួយនឹងផែនការមន្ទីរខេត្ត-ស្រុក

ខ. ការភ្ជាប់ជាមួយនឹងផែនការអភិវឌ្ឍមូលដ្ឋាន

## ១១. ឧបសម្ព័ន្ធសំរាប់ FPP

- បញ្ជីកង្វល់របស់សហគមន៍
- លេខទំនាក់ទំនងសំខាន់ៗ ( ក្រុមគ្រប់គ្រងគ្រោះមហន្តរាយ លេខាធិការដ្ឋាន PCDM-DCDM - NCDM ប៉ូលីស ទាហាន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ)
- បញ្ជីរឈ្មោះសមាជិក PCDM-DCDM
- បញ្ជីរឈ្មោះសមាជិក NCDM
- ផែនទីខ្នាតធំ :
  - ផែនទីខេត្ត-ស្រុក ដែលមានការកំណត់ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន និងសំខាន់ៗ
  - ទីតាំងទីជំរកសុវត្ថិភាព
  - ផែនទីគ្រោះទឹកជំនន់នៅតាមខេត្ត-ស្រុក
- ក្រិត្យ និងអនុក្រិត្យសំខាន់របស់រដ្ឋាភិបាល
- ទម្រង់សំរាប់ការប៉ាន់ប្រមាណ និងការរាយការណ៍

## ១.៧ សំណួរសំរាប់ធ្វើការពិចារណា

១. **ខ្នាតមួយសំរាប់** FPP សំរាប់កំរិតថ្នាក់ខេត្ត ឬថ្នាក់ស្រុកត្រូវបានគូសបញ្ជាក់ ។ តើការប្រឈមអ្វីខ្លះ ដែលអ្នកមាននៅក្នុងការបំពេញផែនការនេះ? តើអ្នកអាចជំនះវាបានយ៉ាងដូចម្តេច?

២. ក្នុងនាមជាអ្នកធ្វើផែនការ-ជាមន្ត្រីរដ្ឋាភិបាល តើអ្នកគិតថា យន្តកាស្ថាប័នដែលមានស្រាប់នៅក្នុងទីតាំងរបស់អ្នក គ្រប់គ្រាន់សំរាប់ការត្រៀមរៀបចំ និងអនុវត្ត FPP ស្របតាមទម្រង់ FPP ដែលផ្តល់ឱ្យនៅក្នុងជំពូកនេះដែរឬទេ? តើវាស្មុគស្មាញច្រើនពេកឬ ទាក់ទិនទៅនឹងរចនាសម្ព័ន្ធរដ្ឋាភិបាល នាពេលបច្ចុប្បន្ន?

៣. ដើម្បីឱ្យ FPP មួយមានប្រសិទ្ធិភាព តើការព្រួយបារម្ភសហគមន៍អ្វីខ្លះដែលត្រូវកំណត់ ហើយវិធានការអ្វីខ្លះ ដែលគួរតែធ្វើ ដើម្បីដោះស្រាយការព្រួយបារម្ភទាំងនេះ?

## ១.៨ សេចក្តីយោង


- កម្ពុជា (២០០៦) :ផែនការត្រៀមបង្ការទឹកជំនន់ ខេត្តព្រៃវែង)២០០៦-២០០៧)
- ADPC (២០០៤) : សំភារៈវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងគ្រោះទឹកជំនន់
- ADPC (២០០២) : ទឹកជំនន់ : គ្រោះថ្នាក់ និងមហន្តរាយធម្មជាតិ
- VRNC : ឯកសារមេរៀន ស្តីពី ការត្រៀមបង្ការគ្រោះមហន្តរាយ ជំពូកទី V : ការធ្វើផែនការត្រៀមបង្ការទឹកជំនន់ ។

# ជំពូកទី ២

## ការរៀបចំកំរងឯកសារថ្នាក់ខេត្ត និង ស្រុក

# ការរៀបចំកំរងឯកសារថ្នាក់ខេត្ត និង ស្រុក

## ២.១ ទិដ្ឋភាពរួម

ជំពូកនេះពិពិណនាព័ត៌មានកំរងឯកសារដែលតំរូវសំរាប់រៀបចំសំរាប់ថ្នាក់ខេត្ត-ស្រុក។ វាភាគច្រើន គឺជាប្រព័ន្ធទិន្នន័យ ព័ត៌មានចង្អុលទិស និងការពន្យល់ដោយខ្លួនឯង។ អ្នកធ្វើផែនការនឹងត្រូវការ ហើយ បំពេញសេចក្តីលំអិតទៅតាមខេត្ត-ស្រុកមុនការរៀបចំធ្វើផែនការត្រៀមបង្ការទឹកជំនន់។

ព័ត៌មានកំរងឯកសារខេត្ត-ស្រុកនឹងជួយដឹងចំនួនគ្រោះទឹកជំនន់ និងផលប៉ះពាល់ដែលអាចកើតមានមកលើប្រជាជន និងភាពក្រីក្រ តាមមធ្យោបាយមួយជាមូលដ្ឋាន និងងាយស្រួល។ វា ក៏បង្កើតឱ្យមាន បរិបទនៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់ នៅក្នុងទីតាំងជាក់លាក់មួយ ដោយការកំណត់ផែនទី ពីលក្ខណៈនៃតំបន់គោលដៅ។ វានឹងជួយឱ្យស្គាល់យ៉ាងច្បាស់ពីការទំនាក់ទំនងរវាងចរិកលក្ខណៈ សេដ្ឋកិច្ចសង្គមនៃទីតាំងមួយ និងសហគមន៍របស់វាដែលមានគ្រោះទឹកជំនន់ និងអតីតកាលរបស់វា និងឥទ្ធិពលដែលអាចកើតមានមកលើជីវិត និងប្រភពធនធានរបស់ប្រជាជន។

បន្ថែមលើនេះទៅទៀត ជំពូកនេះពិភាក្សាជាសង្ខេបពីមូលហេតុរៀបចំព័ត៌មានកំរងឯកសារខេត្ត-ស្រុក មានសារៈសំខាន់ចំពោះការធ្វើផែនការត្រៀមបង្ការទឹកជំនន់។

## ២.២ គោលបំណង

- ស្វែងយល់ពីតំរូវការព័ត៌មានជាមូលដ្ឋាន និង ពីប្រភព និងប្រភេទព័ត៌មានដែលត្រូវប្រមូល និងពិនិត្យ ដើម្បីរៀបចព័ត៌មានកំរងឯកសារខេត្ត-ស្រុក។
- បង្ហាញព័ត៌មានតាមមធ្យោបាយមានប្រយោជន៍ និងទាក់ទងគ្នា សំរាប់ការធ្វើផែនការត្រៀមបង្ការទឹកជំនន់មួយមានប្រសិទ្ធិភាព ដែលគូសបញ្ជាក់ពីភាពងាយរងគ្រោះ និងសមត្ថភាពរបស់ខេត្ត-ស្រុក។
- បង្កើតបរិបទនៃការធ្វើផែនការត្រៀមបង្ការទឹកជំនន់នៅតាមខេត្ត-ស្រុក។

## ២.៣ គោលគំនិតសំខាន់ៗ

- ព័ត៌មានស្តីពីខេត្ត-ស្រុក ទឹកជំនន់នៅអតីតកាល និងទឹកជំនន់ដែលអាចកើតមាននៅពេលអនាគត និងសហគមន៍ គឺជាកំលាំងរួមសាមគ្គីគ្នាដ៏សំខាន់របស់កម្មវិធីត្រៀមបង្ការទឹកជំនន់។
- ខណៈពេលដែលព័ត៌មាន និងទិន្នន័យត្រូវការអាចមិនមានពិតជាក់ស្តែងនៅគ្រប់ប្រការចាំបាច់ ទាំងអស់សំរាប់ផែនការត្រៀមបង្ការទឹកជំនន់ ជាពិសេស នៅកំរិតថ្នាក់ស្រុក លំហាត់ប្រមូលទិន្នន័យ គឺមិនអាចចែកចាយ

បាន។ នៅពេលដែលសាវតាព័ត៌មានមានប្រយោជន៍ត្រូវបានបង្ហាញនៅក្នុង ផែនការត្រៀមបង្ការទឹកជំនន់ នឹងបង្កើតនូវមូលដ្ឋាននៃសកម្មភាពថែមទៀត នៅក្នុងការធ្វើផែនការ និងការអនុវត្តន៍។

- ដើម្បីចងក្រងព័ត៌មានកំរងឯកសារថ្នាក់ខេត្ត-ស្រុកទូលំទូលាយមួយ ត្រូវចំណាយរាល់កិច្ចខិតខំប្រឹងដើម្បីស្រាវជ្រាវតាមរយៈប្រភពព័ត៌មានឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន។ ទាំងនេះ អាចជាទិន្នន័យជំរឿន ជាការសិក្សាផ្នែកសេដ្ឋកិច្ចសង្គម ជាកំណត់ហេតុថ្នាក់ខេត្ត-ស្រុក និងជាកាសែត។
- សុពលភាពនៃព័ត៌មានដែលប្រមូលបាន គឺមានសារៈសំខាន់ស្មើគ្នា និងគួរតែធ្វើឡើងតាមរយៈមន្ទីរ ឬភ្នាក់ងារដែលទទួលខុសត្រូវផ្នែកស្ថិតិ និងការធ្វើផែនការ។

## ២.៤ ផ្នែកសំខាន់ៗនៃសាវតាខេត្ត-ស្រុក

សាវតាខេត្ត-ស្រុក គឺជាទិដ្ឋភាពសង្ខេបរបស់ខេត្ត-ស្រុក ស្តីអំពីប្រជាជន ភូមិសាស្ត្រ សេចក្តីលំអិតពីជីវភាពរស់នៅ ប្រជាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋាន។ ប្រការទាំងអស់ខាងលើមានសារៈសំខាន់ដើម្បីប៉ាន់ប្រមាណពីតំរូវការ និងសកម្មភាពអាទិភាពពេលអនាគត នៅក្នុងកម្មវិធីត្រៀមបង្ការទឹកជំនន់។ ព័ត៌មានទូទៅ តំរូវឱ្យផែនការថ្នាក់ខេត្ត-ស្រុក មានដូចខាងក្រោម :

- ការគ្រប់ដណ្តប់

    ក. សេចក្តីលំអិតពីទីតាំងខេត្ត-ស្រុក

    ខ. ប្រជាជន

    គ. ចំនួនស្រុក ឃុំ និងភូមិ

    ឃ. ព្រំប្រទល់ខេត្ត (ផែនទីខេត្ត-ស្រុក រួមទាំងទន្លេមេគង្គ និងប្រព័ន្ធស្ទឹង-ទន្លេផ្សេងទៀត)

    ង. តំបន់រងគ្រោះខ្លាំង ឬតំបន់ប្រឈមនឹងគ្រោះមហន្តរាយ

- ភូមិសាស្ត្រ

    ក. ការកាន់កាប់ដីធ្លី

    ខ. ដីសំរាប់កសិកម្ម

    គ. ទឹកភ្លៀង

- ព័ត៌មានលំអំពីជីវភាពរស់នៅ

    ក. មុខរបរសំខាន់ៗរបស់ប្រជាជន

    ខ. សកម្មភាពរកប្រាក់ចំណូល

- ភូមិសាស្រ្ត
  - ក. សេចក្តីលំអិតអំពីប្រជាជន
  - ខ. អត្រាអនក្ខរកម្ម
  - គ. ប្រាក់ជំណូលជាមធ្យម

- ហេដ្ឋារចនាសម្ព័នជាមូលដ្ឋាន
  - ក. ប្រវែង និងប្រភេទផ្លូវថ្នល់សរុប
  - ខ. ប្រព័ន្ធព្រែកជីកសំខាន់ៗ
  - គ. ចំនួនមន្ទីរពេទ្យ (រដ្ឋ និងឯកជន) និងមណ្ឌលសុខភាព
  - ឃ.ប្រភពទឹកសំរាប់បរិភោគ
  - ង.វិទ្យាស្ថាន-គ្រឹះស្ថានអប់រំ
  - ច. វត្តអារាម-ទីកន្លែងសាសនា
  - ឆ. ស្ពាន
  - ជ. ការលេនដ្ឋានសំខាន់ៗ (បន្ទាយទាហាន ស្ថានីយ៍ប៉ូលីស ចំណតរថយន្តក្រុង អាកាសយានដ្ឋាន ស្ថានីយ៍វិទ្យុ និងទូរទស្សន៍)
  - ឈ. បរិក្ខាអាសន្ន (ក្រុមពន្លត់អគ្គីភ័យ ស្ថានីយ៍ឧត្តុនិយម ប៉ុស្តិ៍ស្វែងរក និងសង្គ្រោះ តំបន់សុវត្ថិភាព សំរាប់ទីក្រុង)

ការកំណត់ប្រភពព័ត៌មានសំរាប់ FPP, ការគូសបញ្ជាក់ គួរតែជាការកត់ត្រាទុកប្រភពធនធាន ទាំងព័ត៌មានចំនួន និងព័ត៌មានបរិមាណ គួរតែស្វែងរក។

ព័ត៌មានភាគច្រើននឹងមាននៅតាមមន្ទីរថ្នាក់ខេត្ត និងថ្នាក់ស្រុក ដូចជា មន្ទីរ,កាិយាល័យផែនការ ស្ថិតិ អភិវឌ្ឍន៍ជនបទ ធនធានទឹក និងកាិយាល័យគ្រប់គ្រង ជាដើម ។ល។

## ២.៥ សំណួរសំរាប់ពិចារណា

១. តើព័ត៌មានទូទៅអ្វី ដែលត្រូវមានដើម្បីបង្កើតព័ត៌មានកំរងឯកសារថ្នាក់ខេត្ត-ស្រុក?

២. តើព័ត៌មាននេះ បានមកពីណា?

៣. តើមន្ទីរមួយណាដែលទំនងមានព័ត៌មានកំរងឯកសារថ្នាក់ខេត្ត-ស្រុក?

## ២.៦ សេចក្តីយោង


- NIDM ឥណ្ឌា (២០០៥) ផែនការគ្រប់គ្រងគ្រោះមហន្តរាយ (DDMP): ឯកសារគំរូ

# ជំពូកទី ៣

## ការប៉ាន់ប្រមាណពីការគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព

# ការប៉ាន់ប្រមាណពីការគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព (HVCA)

សូមមើលផ្នែកទី ៣: *ស្តីពីខ្លាតផែនការត្រៀមបង្ការទឹកជំនន់*

## ៣.១ ទិដ្ឋភាពរួម

ការប្រើប្រាស់វិធីសាស្រ្ត ស្តីពីការប៉ាន់ប្រមាណពីការគ្រោះថ្នាក់ ភាពងាយរងគ្រោះ និងសមត្ថភាព(HVCA) គឺដើម្បីប៉ាន់ប្រមាណពីទំហំនៃគ្រោះភ័យ ។ វាជួយក្នុងការបង្កើតនូវបណ្តុំប្រពន្ធ័ពតិមាន និងការវិភាគពីស្ថានភាពទឹកជំនន់ បានត្រឹមត្រូវ និងច្បាស់លាស់ ដូចជា:

- តើទំហំនៃការខូចខាតធ្ងន់ធ្ងរ ស្ថិតនៅតាមតំបន់ណាខ្លះ?
- តើមានវិធានការណ៍ និងសមត្ថភាពអ្វីខ្លះ ដើម្បីត្រៀមបង្ការចំពោះគ្រោះទឹកជំនន់?

ជំពូកនេះ ផ្តល់ការយល់ដឹងពីការប៉ាន់ប្រមាណគ្រោះភ័យនៃទឹកជំនន់ និងបង្ហាញយ៉ាងលំអិតពីជំហាននានាដែលទាក់ទិនទៅនឹងការអនុវត្តន៏ខាងលើ ។ លើសពីនេះទៅទៀត ជំពូកនេះ នៅបានគូសបញ្ជាក់ពីវិធីសាស្រ្តនានា ដែលសហគមន៏មូលដ្ឋានបានអនុវត្តកន្លងមក ដើម្បីធ្វើប៉ាន់ប្រមាណពីគ្រោះភ័យនៃទឹក ជំនន់ផងដែរ ។

## ៣.២ គោលបំណង

- ផ្តល់ការយល់ដឹងពីគ្រោះភ័យនៃទឹកជំនន់ និងអ្វីជាកត្តាគន្លឹះដែលត្រូវពិចារណា ក្នុងការប៉ាន់ប្រមាណ ចំពោះគ្រោះភ័យទាំងនោះ ។
- ពិពិណនាលើផ្នែកសំខាន់ៗនៃការប៉ាន់ប្រមាណពីការគ្រោះថ្នាក់ រួមទាំងទម្រង់ខុសៗគ្នានៃការបង្ហាញ ដូចជា: ផែនទី ជាដើម ។
- ពន្យល់ពីភាពងាយរងគ្រោះ និងសមត្ថភាព រួមទាំងវិធីសាស្រ្តចូលរួមផ្សេងៗ ដើម្បីធ្វើការវិភាគរូបវន្ត័ សំភារៈ សង្គម អង្គការ និង ការលើកទឹកចិត្ត និងឥរិយាបថនៃ ភាពងាយរងគ្រោះ និងសមត្ថភាព ។
- ផ្តល់ការយល់ដឹងពីទំនាក់ទំនងគ្នា រវាងគ្រោះទឹកជំនន់ ជាមួយនឹងផលប៉ះពាល់របស់វាដែលអាចកើតមានលើ មនុស្ស និងទ្រព្យសម្បត្តិ ។

## ៣.៣ គោលគំនិតសំខាន់ៗ

- គ្រោះទឹកជំនន់ គឺជារំពឹងទុកពីការបាត់បង់ ដែលអាស្រ័យលើទំហំនៃព្រឹត្តិការណ៍ទឹកជំនន់។ វាមានមុខងារ និងតួនាទី បំរើឱ្យ :
  - ភាពប្រហាក់ប្រហែលនៃទំហំគ្រោះថ្នាក់ដែលអាចកើតឡើង
  - ភាពងាយរងគ្រោះ និងសមត្ថភាព របស់សហគមន៍នៅក្នុងតំបន់ទទួលរងឥទ្ធិពល
  - កំរិតនៃបង្ហាញប្រាប់ពីសមាសភាពផ្សេងៗ ដែលមាននៅក្នុងតំបន់
- HVCA គឺជាផ្នែករួមមួយនៃដំណើរការកសាងផែនការត្រៀមបង្ការ និងជាទម្រង់មូលដ្ឋានសំរាប់ការរៀបចំ និងអនុវត្តលើ FPPs.
- HVCA គឺជាការកំណត់ពីលក្ខណៈ និងវិសាលភាពនៃគ្រោះភ័យ តាមរយៈការធ្វើវិភាគលើទំហំនៃផលប៉ះពាល់របស់គ្រោះទឹកជំនន់ ជាមួយនឹងលក្ខខ័ណ្ឌដែលមានស្រាប់នៃភាពងាយរងគ្រោះដែលបានគំរាមកំហែងធ្ងន់ធ្ងរ ឬបង្កភាពអន្តរាយដល់មនុស្ស ទ្រព្យសម្បត្តិ ជីវភាពរស់នៅ និងបរិស្ថាន *(ផ្អែកតាមឯកសារ UNISDR, 2004)*។
- ការប៉ាន់ប្រមាណគ្រោះភ័យ គឺមានទំនាក់ទំនងជាមួយនឹង ការប៉ាន់ប្រមាណនៃគ្រោះទឹកជំនន់ ទំហំនៃផលប៉ះពាល ភាពងាយរងគ្រោះ និង សមត្ថភាព។
- ការប៉ាន់ប្រមាណលើគ្រោះភ័យ គួរធ្វើឡើងតាមបែបវិធីសាស្ត្រនៃការចូលរួមពីសហគមន៍ ដែលអាចជាចំណុចចាប់ផ្តើមសំរាប់លើកកំពស់ដល់ការយល់ដឹងពីគ្រោះទឹកជំនន់ នៅក្នុងសហគមន៍។

**ការប៉ាន់ប្រមាណពីគ្រោះភ័យនៃទឹកជំនន់តាមសហគមន៍**

ការប៉ាន់ប្រមាណគ្រោះទឹកជំនន់តាមសហគមន៍លើ ការគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព (HVCA)នៅក្នុងសហគមន៍/តំបន់ជាក់លាក់ណាមួយ គឺជាដំណើរការមួយដែលធ្វើឡើងនៅខណៈ ពេលដែលសហគមន៍នោះស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ។ ការជួយគាំទ្រពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីចូលរួមប្រមូលពិតមាន និងធ្វើការវិភាគលើស្ថានគ្រោះភ័យ ពេលមានព្រឹត្តិការណ៍ទឹកជំនន់ គឺមិនអាចខ្វះបាន។ ផ្អែកលើកត្តាខាងលើនេះ ការរៀបចំគំរោងផែនការ និងអនុវត្តសកម្មភាពដែលមានគោលបំណងកាត់បន្ថយគ្រោះទឹកជំនន់
ត្រូវបានធ្វើឡើងដើម្បីបញ្ចៀសផលប៉ះពាល់មកលើអាយុជីវិតរបស់ មនុស្ស។ សហគមន៍ទទួលរងការគំរាមកំហែង មានៈ ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ អាជ្ញាធរមូលដ្ឋាន និងអង្គការធ្វើការនៅក្នុងសហគមន៍នៅក្នុងតំបន់នោះ។

ការប៉ាន់ប្រមាណគ្រោះទឹកជំនន់តាមសហគមន៍ ទាក់ទងនឹងការវិភាគដែលមានការចូលរួម :

- ឯកសារ/ពិតមានទាក់ទិនជាមួយនឹងគ្រោះទឹកជំនន់ពីអតីតកាល
- ពិតមានទាក់ទិននឹងការគំរាមកំហែងនាពេលបច្ចុប្បន្ននៅក្នុងសហគមន៍ *(ការប៉ាន់ប្រមាណពីភាពគ្រោះថ្នាក់)* គួបផ្សំជាមួយនឹង ការយល់ដឹងពីមូលហេតុសំខាន់ៗដែលនាំឱ្យគ្រោះថ្នាក់ និងក្លាយទៅជាគ្រោះមហន្តរាយ *(ការប៉ាន់ប្រមាណលើ ភាពងាយរងគ្រោះ)*។
- ធនធានទាំងឡាយដែលសហគមន៍ទទួលរងផលប៉ះពាល់ប្រើប្រាស់ គឺដើម្បីកាត់បន្ថយគ្រោះថ្នាក់ *(ការ ប៉ាន់ប្រមាណពី សមត្ថភាព)*
- ក្រៅពីវិធីខាងលើ នៅមានវិធីផ្សេងៗទៀតដែលប្រជាជនតែងប្រើប្រាស់សំរាប់ធ្វើការវាស់វែងពីគ្រោះភ័យ។ (សេចក្តីយោង)

**ឧបករណ៍ សំរាប់ប្រើក្នុងការប៉ាន់ប្រមាណពីគ្រោះភ័យទឹកជំនន់ តាមបែបចូលរួម**

ព័ត៌មានទាក់ទងនឹងគ្រោះទឹកជំនន់ត្រូវប្រមូលដោយប្រើឧបករណ៍តាមបែបចូលរួម ឬបច្ចេកទេស — ជាទូទៅ សំដៅលើ PRA (Participatory, Rapid or (Rural) Appraisal or (Assessment) – គឺជាវិធីសាស្ត្រវាយតំលៃបែបចូលរួមពីសហគមន៍/ជនបទ។ ក្រុមអនុវត្តលើវិធីសាស្ត្រ និងឧបករណ៍ខាងលើអាចធ្វើការវិភាគព័ត៌មាន ដំបូងដែលប្រមូលបាន ប៉ុន្តែផ្នែកសំខាន់នៃដំណើរការអនុវត្តន៍ គឺត្រូវធ្វើការ ចែករំលែក និងផ្ទៀងផ្ទាត់ព័ត៌មានឡើងវិញជាមួយសហគមន៍ជាមុនសិន មុននឹងបន្តទៅជំហានក្រោយៗទៀត ។

ជំហាន HVCA អាចត្រូវបានគេប្រើប្រាស់ សំរាប់:

- ការរៀបចំសំរាប់ HVCA (វិជ្ជាដឹកនាំ និង ខ្លឹមសារ)
- ការប្រមូលព័ត៌មានផ្អែកលើសំណួរដែលបានកំណត់ និងការប្រើឧបករណ៍/វិធីសាស្ត្រ PRA
- ការវិភាគព័ត៌មាន និងប្រើប្រាស់វិធានការនានា ដែលបានស្នើឡើងទាក់ទិននឹងលទ្ធផលដំណើរការរបស់ គំរោង ក្នុងតារាងម៉ាទ្រិច ស្តីពីភាពងាយរងគ្រោះ
- ផែនការសំរាប់ការត្រៀមបង្ការគ្រោះមហន្តរាយ និងការកាត់បន្ថយគ្រោះថ្នាក់ (ជាមួយអាជ្ញាធរមូល- ដ្ឋាន អង្គការសង្គម និង សហគមន៍)

**ឧបករណ៍ PRA ត្រូវបានគេប្រើប្រាស់សំរាប់ការប៉ាន់ប្រមាណលើ :**

- ការគូសផែនទី ពីតំបន់គ្រោះថ្នាក់
- សាវតាជាប្រវត្តិ
- ប្រតិទិនរដូវកាល
- ការគូសផែនទី ពីចំណុចធនធាន
- ការដើរកាត់ទទឹង
- ការវិភាគបណ្តាញស្ថាប័ន និងសង្គម
- កិចសំភាសន៏ពាក់កណ្តាលផ្លូវការ
- ក្រុមពិភាក្សាផ្តោតលើ (FGD)
- ការវិភាគរកបញ្ហា តាមគំនូសដើមឈើ ( ដើមឈើបញ្ហា)
- ការចាត់ជាចំណាត់ថ្នាក់
- ការសង្កេតការណ៏

តំរូវការព័តិមាន គួរតែធ្វើឱ្យបានមុន បន្ទាប់មក ឧបករណ៏ PRA ដែលត្រឹមត្រូវបំផុតសំរាប់ប្រមូលទិន្នន័យ។ ឧបករណ៏ត្រូវប្រើប្រាស់តាមលំដាប់ ពីងាយទៅស្មុគ្រស្មាញ។ ខាងក្រោម គឺវិធីប្រើប្រាស់តាមលំដាប់លំដោយនៃឧបករណ៏ PRA :

**លំដាប់លំដោយនៃការប្រើឧបករណ៏តាមពេលវេលា**

**លំដាប់លំដោយនៃការប្រើឧបករណ៏តាមពេលវេលា**

ការពិនិត្យឡើងវិញលើទិន្នន័យបន្ទាប់ ពិសេសគឺព័តិមានក៏រិតថ្នាក់តំបន់-ខេត្ត

ដែលទាក់ទងនឹងគ្រោះថ្នាក់ គ្រោះភ័យ ភាពងាយរងគ្រោះ និង សមត្ថភាព

សាវតាជាប្រវត្តិ ផែនទី កាត់ទទឹង

ប្រតិទិនរដូវកាល

ការវិភាគលើស្ថាប័ន និង បណ្តាញការងារសង្គម

ការប៉ាន់ប្រមាណលើបញ្ហាសុខភាព និង ការថែបំប៉ន

ការវិភាគលើជីវភាពរស់នៅ-ការដោះស្រាយបន្ទាល់

ដើមឈើបញ្ហា

ការចាត់ជាចំណាត់ថ្នាក់

HCVA

ព័តិមានទូទៅស្តីអំពីក៏រិតសហគមន៏

ព័ត៌មានជាក់លាក់ស្តីអំពីកិរិតសហគមន៏ ផ្ទះសម្បែង និងបុគ្គល

## ៣.៤ ផ្នែកសំខាន់នៃ HVCA

ទម្រង់ HVCA ជាមូលដ្ឋានសំរាប់រៀបចំផែនការត្រៀមបង្ការទឹកជំនន់។ វាកំណត់ច្បាស់ពីលក្ខណៈនៃបញ្ហាក្នុងន័យគ្រោះទឹកជំនន់ និងលក្ខខ័ណ្ឌដែលមានស្រាប់ ។ ម្យ៉ាងទៀត ទំរង់ HVCA ត្រូវបានគេយកទៅប្រើប្រាស់ដើម្បីវិភាគលើគ្រោះទឹកជំនន់ ពិសេសលើការវិភាគលើហេតុការណ៍លើកទីពីរ ដូចជា ការរអិលបាក់ដី ជំងឺរាតត្បាតនិងភាពងាយរងគ្រោះដល់មនុស្ស និង ហេដ្ឋារចនាសម្ព័ន្ធដែលបង្កឡើងពីទឹកជំនន់។ លើសពីនេះទៀត វាក៏ត្រូវបានគេប្រើដើម្បីគូសផែនទី ដោយបានកំណត់រាល់បញ្ហាដែលបានកើតឡើងកន្លងមកនៅលើនោះ ក៏ដូចជា បង្ហាញពីសមត្ថភាពរបស់ស្ថាប័នពាក់ពន្ធ័នានាដែលបានជួយដោះស្រាយ និងការចូលរួមរបស់សហគមន៏ ដែលរស់នៅក្នុងតំបន់ប្រឈមនឹងទឹកជំនន់ ផងដែរ ។

HVCA អាចប្រើប្រាស់សំរាប់ :

### ៣.៤.១ ការប៉ាន់ប្រមាណគ្រោះទឹកជំនន់

ការប៉ាន់ប្រមាណគ្រោះថ្នាក់ដោយទឹកជំនន់ កំណត់ពីលក្ខណៈនៃការលិចលង់ផ្អែកលើការកំណត់តាមបែបឧតុនិយមនិងជលសាស្ត្រ និងលក្ខខ័ណ្ឌអាងស្តុកទឹករបស់ទន្លេ។ ព័ត៌មាន អាចប្រើប្រាស់ដើម្បីកំណត់ពីសម្ពន្ធ័ភាពរវាងការកំណត់របស់ ឧតុនិយមនិងជលសាស្ត្រ តាមការបង្កើតឧបករណ៍វាស់ស្ទង់ទឹកជំនន់ ការកំណត់តារាងពេលវេលា និង ទំហំទឹកជំនន់។

ការប៉ាន់ប្រមាណគ្រោះទឹកជំនន់អាចធ្វើតាមមធ្យោបាយខុសៗគ្នាទៅតាមទិន្នន័យដែលមាន។ ក្រោយពីទទួលបានព័ត៌មានពីគ្រោះទឹកជំនន់ គេត្រូវធ្វើការផ្សព្វផ្សាយបន្តពីពិតមានទាំងនេះតាមមធ្យោ-បាយផ្សេងៗដែលងាយស្រួល ធ្វើយ៉ាងណាឱ្យអង្គភាពពាក់ពន្ធ័ដទៃទៀតទទួលបាននូវពិតមានឆាប់បំផុតដែរ ។ មានមធ្យោបាយជាច្រើនប្រកបដោយប្រសិទ្ធភាពក្នុងការជំនួយដល់ការបង្ហាញពីពិតមាន ដូចជាៈ ផែនទី កំណត់ហេតុស្តីពីទឹកជំនន់ និងប្រព័ន្ធព័ត៌មានទាក់ទិនភូមិសាស្ត្រ (GIS) ជាដើម។ ការបង្ហាញពីទិន្នន័យទឹកជំនន់តាមរយៈផែនទី គឺជាវិធីដែលធ្វើគេងាយយល់ និងចងចាំ ។ នៅលើផែនទី គេអាចផ្ទុកនូវពិតមានជាច្រើន ដូចជាៈ តំបន់ទឹកជំនន់ ជាដើម គឺអាចធ្វើជាសញ្ញាចំណាំ ឬដាក់ពិណ និងប្រើប្រាស់និមិត្តសញ្ញាខុសៗគ្នា ដើម្បីជាគ្រឿងសំគាល់។ ខាងក្រោមនេះ គឺប្រភេទខុសៗគ្នានៃការកំណត់ ពិតមាន/ទិន្នន័យនៅលើផែនទីៈ

- **ផែនទីបង្ហាញពីការជនលិចនៃទឹកជំនន់-** បង្ហាញពីភាពខុសគ្នានៃជំរៅទឹកជំនន់នៅ លើផ្ទៃទឹកជំនន់រាបស្មើ។ វាផ្តល់រូបភាពជំរៅមួយច្បាស់លាស់ ត្រឹមត្រូវ និងទំហំជន់លិច។
- **ផែនទីបង្ហាញពីរយៈពេលទឹកជំនន់** – គឺជាផែនទីបង្ហាញពីការជន់លិចស្រដៀងគ្នា ប៉ុន្តែវាបង្ហាញពីរយៈពេលទឹកជំនន់។ ផែនទីបែបនេះមានសារៈប្រយោជន៍ក្នុងការវាយតំលៃពីសក្តានុភាពនៃការខូចខាតដោយទឹកជំនន់ រួមទាំង ការខូចខាតផលដំណាំកសិកម្ម ផងដែរ។
- **ផែនទីបង្ហាញពីភាពប្រហាក់ប្រហែលនៃទឹកជំនន់** – បូករួមទាំង និន្នាការថ្មីៗជាមួយកត្តាជាច្រើន ដូចជា និន្នាការអភិវឌ្ឍនៅអនាគត និងទម្រង់នៃការផ្លាស់ប្តូរអាកាសធាតុ និងគំរោងស៊ីណារីយ៉ូទឹកជំនន់នាពេលអនាគត និង ភាពដែលអាចចង្អុលបង្ហាញពីសក្តានុពលនៃការជន់លិច និង រយៈពេលទឹកជំនន់ ជាដើម។
- **ផែនទីប្រៀបធៀបទឹកជំនន់** – បង្ហាញពីភាពខុសគ្នារវាងផែនទីទឹកជំនន់ពីរ។ ការប្រៀបធៀបផែនទី មាន០២ប្រភេទដែលបង្ហាញពី :
  - ឥទ្ធិពលនៃការធ្វើអន្តរគមន៍
  - ការផ្លាស់ប្តូរទឹកជំនន់តាមពេលវេលា

ខាងក្រោមនេះ គឺជាទិន្នន័យដែលអាចដកស្រង់ចេញពីការប៉ាន់ប្រមាណកន្លងមក សំរាប់ដាក់បញ្ចូលទៅក្នុងផែនការត្រៀមបង្ការទឹកជំនន់ :

ក. ប្រវត្តិគ្រោះថ្នាក់ (រួមទាំងប្រវត្តិសង្ខេបនៃទឹកជំនន់នៅក្នុងតំបន់)

ខ. មូលហេតុ និងរដូវកាល-រយៈពេលនៃទឹកជំនន់ប្រចាំឆ្នាំ (ពី ខែកក្កដា ដល់ ខែតុលា)

គ. ប្រេកង់ និងកំរិតទឹកជំនន់ (ពេលចាប់ផ្តើម ពេលឡើងដល់ចំណុចកំពូល និង ពេលស្រក)

ឃ. ឥទ្ធិពលប្រចាំឆ្នាំរបស់ទឹកជំនន់ប្រចាំឆ្នាំ(រាប់បញ្ចូលទាំងទិន្នន័យនៃទឹកជំនន់ដែល អាក្រក់បំផុតប្រចាំឆ្នាំ និងទិន្នន័យទឹកជំនន់ពីរ-បីឆ្នាំមុន ដូចជា រយៈពេលជាមធ្យមនៃការជន់លិច តំបន់ជន់លិចសរុប ការបាត់បង់ផ្ទៃដីបង្កបង្កើនផល ចំនួនមនុស្ស-គ្រួសារដែលរងផលប៉ះពាល់សរុប ការខូចខាតផ្នែកសេដ្ឋកិច្ចសរុប)។

ង. គ្រោះថ្នាក់ទីពីរ (ដូចជា ការបាក់ដីច្រាំទន្លេ ការបំពុលបរិស្ថាន ការបាត់បង់អាយុជីវិត ការរើទីកន្លែង-ចំណាកស្រុក ភាពរីករាលផ្នែកសង្គម និង ជំងឺរាតត្បាត)។

ច. ការទាយទុកពីស៊ីណារីយ៉ូអនាគត ពីព្រោះតែអាកាសធាតុផ្លាស់ប្តូរ (បើមាន)។

ឆ. គ្រោះថ្នាកផ្សេងៗ ដូចជា ទឹកជំនន់ អគ្គិភ័យ និងគ្រោះថ្នាក់ផ្សេងៗទៀតនៅក្នុងតំបន់។

### ៣.៤.២ ការប៉ាន់ប្រមាណលើ ភាពងាយរងគ្រោះ[1]

ការប៉ាន់ប្រមាណលើភាពងាយរងគ្រោះ គឺជាការកំណត់មើលពីមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធដែលងាយរង គ្រោះបំផុត និងពីសក្តានុភាពនៃការខូចខាតនៅក្នុងតំបន់ភូមិសាស្ត្រដែលអាចកើតឡើង។ ក្នុងការប៉ាន់ប្រមាណភាពងាយរងគ្រោះ វាមានសារៈសំខាន់ ត្រូវទទួលស្គាល់ថាមានភាពខុសគ្នានៃកត្តាដែលនាំទៅរកភាពងាយរងគ្រោះ ដែលរួមផ្សំ។ ភាពងាយរងគ្រោះអាចផ្លាស់ប្តូរតាមពេលវេលា- វាអាចធ្វើឱ្យកើនឬចុះថយ អាស្រ័យលើទីតាំងសហគមន៍ ឬបុគ្គល ដោយសារតែផលប៉ះពាល់នៃកត្តាដែលមើលឃើញនឹងផ្នែកផ្សេងៗពីគ្នា ដែលអាចផ្លាស់ប្តូរតាមពេលវេលាបាន។ ភាពងាយរងគ្រោះក្នុងតំបន់មិនដូចគ្នាទេ : វាខុសប្លែកពីគ្នាអាស្រ័យលើប្រាក់ចំណូល ការទទួលបាន និងកំរិតនៃការត្រៀមបង្ការ។ ខាងក្រោម គឺជាកត្តាខ្លះ ដែលអាចបណ្តាលឱ្យមានភាពងាយរងគ្រោះទឹកជំនន់ គឺ :

- ការអភិវឌ្ឍន៍គ្មានផែនការ ដែលគ្មានប្រព័ន្ធលូ និង គ្មានអនាម័យ។
- ការបង្កើតសហគមន៍សំណង់អនាធិបតេយ្យនៅលើដីដែលងាយរងគ្រោះ ដូចជា នៅលើខ្នងទំនប់ការពារទឹក ច្រាំងទន្លេ និងនៅក្នុងបណ្តាញលំហូរទន្លេ។
- ផ្ទះមិនរឹងមាំ
- ភាពក្រីក្រ
- កង្វះនូវការត្រៀមបង្ការទឹកជំនន់
- កង្វះការយល់ដឹងអំពីគ្រោះថ្នាក់ទឹកជំនន់
- កង្វះនូវប្រព័ន្ធប្រកាសអាសន្នជាមុន
- អាកាសធាតុផ្លាស់ប្តូរប៉ះពាល់ទៅលើតំបន់
- ភាពងាយរងគ្រោះខាងផ្នែកបរិស្ថាន និងភូមិសាស្ត្រ

ការប៉ាន់ប្រមាណភាពងាយរងគ្រោះ ក៏កំណត់ដឹងនូវមនុស្សដែលងាយរងគ្រោះរបស់សហគមន៍ និងមានប្រយោជន៍នៅក្នុងការប៉ាន់ប្រមាណវាផងដែរ។ ការបំរុងថវិកាទុកសំរាប់ប្រជាជនទាំងនោះ ដែល

[1] *ភាពងាយរងគ្រោះ - គឺជាសមត្ថភាពរបស់មនុស្សម្នាក់ ឬក្រុមមួយដែលគិតទុក ដោះស្រាយ ទប់ទល់ និងស្តារឡើងវិញពីគ្រោះមហន្តរាយធម្មជាតិ។ ភាពងាយរងគ្រោះ អាចបណ្តាលឱ្យមានកត្តាខុសៗគ្នាមួយចំនួន ដូចជាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គម និងនយោបាយ ផងដែរ។*

ត្រូវការជំនួយជាបន្ទាន់ ពិសេស អាចនាំមកនូវការផ្តោតការយកចិត្តទុកដាក់ និងផ្តល់អាទិភាពធនធាន សំរាប់ជាផលប្រយោជន៏របស់ពួកគេ។

ផ្នែកខាងលើ តារាងប៉ាន់ប្រមាណភាពងាយរងគ្រោះ មានបង្ហាញជូនដូចខាងក្រោម :

| **គ្រោះទឹកជំនន់** | **គ្រោះថ្នាក់សំខាន់** | **លក្ខខ័ណ្ឌគ្មានសុវត្ថិភាព** | **សម្ពាធឪណាមិក** | **ឫសគល់មូលហេតុ** |
|---|---|---|---|---|
| បណ្តាលមកពី *(ទីតាំងសហគមន៍)*<br>▪ ព្យុះ (ទឹកជំនន់កើតពីព្យុះ)<br>▪ ទឹកភ្លៀងមូសុង<br>▪ ទឹកជោរ | ▪ ផ្ទះ និងអគារ<br>▪ មនុស្ស<br>▪ សត្វពាហនៈ<br>▪ ទ្រព្យសម្បត្តិក្នុងផ្ទះ<br>▪ ដីកសិកម្ម<br>▪ ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដូចជា ស្ពាន ផ្លូវថ្នល់ ទំនប់ទឹក dykes<br>▪ ជីវភាពរស់នៅ | ▪ ផ្ទះសង់លើដីទាប លើព្រែក ព្រែកជីក លើទន្លេ និងសមុទ្រ<br>▪ សំភារៈធ្វើផ្ទះដែលងាយពុកផុយ ឬខូចខាត<br>▪ គ្មានការស្បៀងស្តុកទុក ឬសន្សំ<br>▪ គ្មានចាក់ថ្នាំបង្ការ<br>▪ មិនរាប់បញ្ចូលក្នុងការការពារទឹកជំនន់<br>▪ គ្មានទីកន្លែងសុវត្ថិភាព<br>▪ មិនអាចជំនួសទ្រព្យដែលបាត់បង់<br>▪ ជីវភាពរស់នៅត្រូវរំខាន<br>▪ ផ្ទះ និងអគារអាចជាមូលហេតុដក់ទឹក និងកើតមេរោគជំងឺ<br>▪ សុខាភិបាល និងការបំប៉ន មិនល្អ<br>▪ គ្មានទឹកស្អាត<br>▪ កង្វះសហការ-សាមគ្គីក្នុងសហគម | ▪ កំរិតចំនូលទាប ជីវភាពរស់នៅគ្មានស្ថេរភាព<br>▪ កង្វះចំនាត់ដីធ្លី ផ្ទះសម្បែងសមស្របសំរាប់អ្នកក្រីក្រ<br>▪ កង្វះការរីកចំរើនផ្នែកសេដ្ឋកិច្ចសំរាប់ជីវភាពរស់នៅ<br>▪ ការអប់រំទាបជាឧបសគ្គការងារ<br>▪ ចំនូលផ្សេងៗពីសកម្មភាពក្រៅសង្គម ឬខុសច្បាប់<br>▪ ការគំរាមកំហែងបំផ្លាញចោលបើកផ្លូវសំរាប់គំរោងអភិវឌ្ឍន៍<br>▪ ការគាំទ្រខ្សោយពីរដ្ឋដល់អ្នកក្រីក្រតាមទីក្រុង<br>▪ ជំលោះខាងនយោបាយ និងសង្គម | ▪ ចំណាកស្រុកទៅតំបន់ទីក្រុងគ្មានប្លង់ប្រឈមនឹងទឹកជំនន់<br>▪ កង្វះការអនុវត្តន៍ផែនការប្រើប្រាស់ដី ឬខ្វះការអនុវត្តន៍<br>▪ ការធ្លាក់ចុះនៃបរិដ្ឋាននាំឱ្យកើនទឹកជំនន់<br>▪ នៅមានច្រើនទៀត... |

ការកំណត់ឬសគល់នៃមូលហេតុ សំពាធឪណាមិក និងលក្ខខ័ណ្ឌគ្មានសុវត្ថិភាព អាចនាំទៅដល់ការបង្កើតសកម្មភាពទប់ទល់នឹងបញ្ហាទាំងនេះបាន។

នៅក្នុងឯកសារ FPP អាចធ្វើតារាងមួយដើម្បីបង្ហាញពីទិន្នន័យ :

- ចំនួនស្រុក ឃុំដែលងាយរងគ្រោះ និងការទំនាក់ទំនងប្រជាជន (បែងចែកជាប្រុស ស្រី មេគ្រួសារជាប្រុស មេគ្រួសារជាស្រី និងការបែងចែកអាយុប្រជាពលរដ្ឋ) ។
- មូលហេតុពីសក្តានុភាពនៃភាពងាយរងគ្រោះ
- គ្រោះថ្នាក់សំខាន់ៗ (ប្រព័ន្ធ និងប្រវែងផ្លូវថ្នល់ ព្រែកជីក ទំនប់ទឹកនៅក្នុងតំបន់ ចំនួនសាលារៀន និងមន្ទីរពេទ្យស្ថិតក្នុងតំបន់រងគ្រោះខ្ពស់ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ និងតំបន់កសិកម្ម ឬដីបង្កបង្កើនផលសរុប)

### ៣.៤.៣ ការប៉ាន់ប្រមាណសមត្ថភាព

ការប៉ាន់ប្រមាណសមត្ថភាព ជួយរៀបចំសមត្ថភាពមនុស្ស (ជំនាញ ឯកទេស) សំភារៈ និង ហិរញ្ញវត្ថុដែលមាននៅក្នុងតំបន់ ព្រមទាំងធនធានដែលត្រូវការ។ វា សំខាន់ ត្រូវធ្វើបញ្ជីធនធាន និងសមត្ថភាពទាំងនេះ ថាតើអ្វីដែលមានហើយ និងអ្វីដែលត្រូវការ។

ក. បរិក្ខាទីជំរក

- ចំនួនសរុបតំបន់ និងទីជំរកសុវត្ថិភាព
- ទីតាំងតំបន់ និងទីជំរកសុវត្ថិភាព
- ផ្លូវចូលទៅដល់

ខ. បរិក្ខាគមនាគមន៏

- ចំនួនទូក (សាធារណៈ និងឯកជន ប្រភេទទូក)
- រថយន្តដឹកអ្នកដំណើរ និងយាន្តដឹកជញ្ជូនសាធារណៈ
- រថយន្តធំ និងយាន្តដឹកជញ្ជូនសំភារៈធ្ងន់ៗផ្សេងទៀត (សំរាប់គោលបំណង ឆ្លើយតប និងការស្តារឡើងវិញ)

**គ. ប្រព័ន្ធទំនាក់ទំនង**

- ទូរស័ព្ទ និងម៉ាស៊ីនហ្វាក់
- ទូរស័ព្ទឥតខ្សែរ និងផ្កាយរណប
- អាយកូម
- សេវាទូរស័ព្ទចល័ត

- អ៊ីនធឺណែត

ឃ. បរិក្ខាការពារទឹកជំនន់

- Dykes និងទំនប់ទឹក
- ទំនប់ទឹក
- រចនាសម្ព័ន្ធផ្សេងទៀត

ង. បរិក្ខាសំរាប់ស្តុក

- ទីតាំង និង សមត្ថភាព
- របស់រក្សាទុក អង្ករ តង់ ឥន្ធនៈ ថ្នាំពេទ្យ)

ច. បរិក្ខាពេទ្យ

- ចំនួនមន្ទីរពេទ្យ និងមណ្ឌលសុខភាព (ផ្នែកទី២.៣)
- ចំនួនវេជ្ជបណ្ឌិត គិលានុបដ្ឋាកយិកា បុគ្គលិកពេទ្យ
- ចំនួនឡានពេទ្យ
- មានក្រុមពេទ្យចល័តកំឡុងពេលទឹកជំនន់

ឆ. បរិក្ខាស្ថាប័ន និងបរិក្ខាផ្សេងៗ

- មានស្ថាប័ន DM
- មានអង្គការសហគមន៍
- មានគំរោងឥណទាន
- ផែនការអភិវឌ្ឍន៏ (ដែលមានថវិកាទៀតទាត់)

ជ. ធនធានមនុស្ស

- ចំនួនអ្នកស្ម័គ្រចិត្តកាកបាទក្រហមខេត្ត-ស្រុក
- អង្គការធំៗ (សហជីពស្ត្រី សហជីពយុវជន)
- ក្រុមស្វែងរក និងសង្គ្រោះដែលមានការបណ្តុះបណ្តាល
- ប៉ូលីស និងកងកំលាំប្រដាប់អាវុធ
- យុវជនស្ម័គ្រចិត្ត
- ក្រុមប្រយុទ្ធទឹកជំនន់ (បើមាន)
- អង្គការ NGOs CBOs និងអង្គការអន្តរជាតិកំពុងធ្វើការនៅក្នុងតំបន់

ភាពងាយរងគ្រោះ និងសមត្ថភាពរបស់ប្រជាជន អាចធ្វើការវិភាគផ្អែកលើលក្ខណៈវិនិច្ឆ័យ ដែលមាននៅក្នុងតារាង :

| | ភាពងាយរងគ្រោះ | សមត្ថភាព |
|---|---|---|
| រូបវន្ត័-សំភារៈ | ▪ នៅជិត និងងាយទទួលទឹកជំនន់-រស់នៅលើផ្ទៃទឹកជំនន់ ផ្ទះចាស់<br>▪ ភាពក្រីក្រ មានជំរើសតិច ថវិកាសន្សំតិចតួច ទ្រព្យតិច<br>▪ ធនធាន បច្ចេកវិទ្យា ជំនាញ ឬការងារមានកំណត់ | ▪ តំបន់ការពារ<br>▪ លុយ ទ្រព្យសម្បត្តិ ដីធ្លី ការងារប្រាក់សន្សំ<br>▪ ការធានារ៉ាប់រង<br>▪ ការទទួលបានឥណទាន<br>▪ សុខភាពល្អ<br>▪ ជំនាញ និងឯកទេស |
| សង្គម-អង្គការ | ▪ ងាយរងគ្រោះ- ប្រជាជនមិនរាប់ចូលដោយសារតែគោលនយោបាយ សាសនា ជាតិសាសន៍ ប្រពៃណីសង្គម<br>▪ ការរៀបចំ- រចនាសម្ព័ន្ធសហគមន៍ ឬច្បាប់មានកំរិត<br>▪ ការរើសអើង-កង្វះការគាំទ្រ បន្ថយការទទួលបាននូវធនធាន និងសេវាកម្ម | ▪ គាំទ្រសហគមន៍ ភាពជាមេដឹកនាំស្ថាប័ន<br>▪ រចនាសម្ព័ន្ធនយោបាយ ការគ្រប់គ្រងគ្រាប់គ្រាន់<br>▪ ភាពចុះសម្រុងគ្នានៅសហគមន៍<br>▪ បណ្តាញការងារសង្គម<br>▪ ការឧបត្ថម្ភ |
| ការលើកទឹកចិត្ត-ឥរិយាបថ | ▪ ការយល់ដឹងពីគ្រោះថ្នាក់-បដិសេធការគំរាមកំហែង-មិនដឹងពីការគំរាមកំហែង<br>▪ ឥរិយាបថ-គ្មានទំនុកចិត្តលើសមត្ថភាព មានទស្សនៈពឹងពាក់អ្នកដទៃ កង្វះទំនុកចិត្តលើប្រព័ន្ធ និងរចនាសម្ព័ន្ធដែលមានស្រាប់ (សំរាប់ដោះស្រាយទឹកជំនន់)<br>▪ អំណាច- គ្មានឥទ្ធិពលនៅក្នុងសហគម | ▪ មានចំណេះដឹង-ដឹងពីគ្រោះមហន្តរាយកើតមាននៅក្នុងបរិដ្ឋាន និងឥទ្ធិពលរបស់វា<br>▪ មានទំនុកចិត្តដោះស្រាយវិបត្តិ<br>▪ សមត្ថភាពមានឥទ្ធិពលលើបរិដ្ឋាន<br>▪ មានជំនឿខ្លាំងលើប្រព័ន្ធដែលមានស្រាប់ និងរចនាសម្ព័ន្ធគាំទ្រ |

## ៣.៥ សំណួរសំរាប់ពិចារណា

១. ចូរគូសបញ្ជាក់ពីផ្នែកសំខាន់នៃការប៉ាន់ប្រមាណគ្រោះទឹកជំនន់?

២. ចូរពិពណ៌នាប្រភេទខុសគ្នានៃភាពងាយរងគ្រោះ និងសមត្ថភាព?

៣. តើលក្ខ័ណ្ឌមិនសុវត្ថិភាពអ្វីខ្លះដែលត្រូវធ្វើការប៉ាន់ប្រមាណ?

៤. តើមានអ្វីខ្លះដែលជាការបាត់បង់សំខាន់បំផុត ក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះ

ទឹកជំនន់?

## ៣.៦ សេចក្តីយោង


- ADPC(២00៤): ឯកសារចែកនៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគ្រោះទឹកជំនន់
- កាកបាទក្រហម ១៩៩៨ : ការបាន់ប្រមាណភាពងាយរងគ្រោះ និងសមត្ថភាព ផ្នែកទី១ : មូលហេតុដែលនាំឱ្យងាយរងគ្រោះ
- ADPC (២00៦) : ឯកសារ ស្តីពី ការគ្រប់គ្រងសមាហរណកម្មគ្រោះទឹកជំនន់ នៅអាស៊ី

# ជំពូកទី ៤

## យន្តការស្ថាប័ន និង អង្គការពាក់ព័ន្ធដទៃទៀត
## សំរាប់ការត្រៀមបង្ការ និង
## ការគ្រប់គ្រងគ្រោះទឹកជំនន់

# យន្តការស្ថាប័ន និង អន្តរការពាក់ពន្ធ័ដទៃទៀត សំរាប់ការត្រៀមបង្ការ និង ការគ្រប់គ្រងគ្រោះទឹកជំនន់

## ៤.១ ទិដ្ឋភាពរួម

ជំពូកនេះ គូសបញ្ជាក់អំពីសារៈសំខាន់នៃការមានយន្តការស្ថាប័នសំរាប់ការធ្វើផែនការត្រៀមបង្ការ និងគ្រប់គ្រង ទឹកជំនន់ ពីកំរិតថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន។ វាក៏ផ្តល់នូវទិដ្ឋភាពរួមនៃការវិភាគអ្នកដែលពាក់ព័ន្ធ និងផលប្រយោជន៍នៃ យុទ្ធវិធីតាមដែលមានការចូលរួមចំពោះការធ្វើផែនការត្រៀមបង្ការទឹកជំនន់ និងវិធីដែលល្អបំផុតដែលវាអាចគ្រប់គ្រង នៅក្នុងរចនាសម្ព័ន្ធរ្វការរបស់ភ្នាក់ងារពាក់ព័ន្ធ ដូចជា គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក(PCDM/ DCDM) នៅក្នុងប្រទេសកម្ពុជា។ គណៈកម្មាធិការខេត្ត-ស្រុកត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ (PCFSC/ DCFSC) នៅប្រទេសវៀតណាម និង គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក (PDMC/ DDMC) នៅក្នុងប្រទេស ឡាវ។

តាមការគូសបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវនៃភ្នាក់ងារនីមួយៗទាក់ទងនឹងការត្រៀមបង្ការទឹកជំនន់ ជំពូក ស្នើឱ្យការពង្រឹងយន្តការស្ថាប័ននេះសំរាប់ ធ្វើឱ្យភាពជាអ្នកដឹកនាំបានល្អប្រសើរឡើងតាមរយៈ ពង្រឹងកិច្ចសហការក្នុង ចំណោមភ្នាក់ងារនានា និងធ្វើឱ្យការទំនាក់ទំនងនៅក្នុងរចនាសម្ព័ន្ធ និងសហគមន៍បានល្អប្រសើរឡើង ដើម្បីបង្កើតនិង អនុវត្តផែនការត្រៀមបង្ការឱ្យមានប្រសិទ្ធិភាព។

## ៤.២ គោលបំណង

- ស្វែងយល់ពីរចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក ដូចជា PCDM និង DCDM នៅកម្ពុជា។ (PCFSC/ DCFSC) នៅប្រទេសវៀតណាម និង (PDMC/ DDMC) នៅប្រទេសឡាវ។
- ពិពណ៌នាពី តួនាទី និងការទទួលខុសត្រូវ របស់សមាជិកភ្នាក់ងារនីមួយៗ។
- គូសបញ្ជាក់ពីតំរូការសំរាប់ការវិភាគ និងធ្វើឱ្យមានចូលរួមពីអ្នកពាក់ព័ន្ធនៅក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់ និងការគ្រប់គ្រងគ្រោះទឹកជំនន់។

## ៤.៣ គោលគំនិតសំខាន់ៗ

- ការធ្វើផែនការត្រៀមបង្ការទឹកជំនន់ និងការគ្រប់គ្រងគ្រោះទឹកជំនន់ គួរតែមានអាណត្តិស្របច្បាប់នៅក្នុងគំរោងស្ថាប័នធំៗរបស់ការគ្រប់គ្រងគ្រោះមហន្តរាយ ដែលកំណត់ពីទំនាក់ទំនង និងទីតាំងរបស់អង្គការ និងស្ថាប័ននានាដែលមានការទទួលខុសត្រូវ ក្នុងការចូលរួមកាត់បន្ថយគ្រោះមហន្តរាយ ។
- ការធ្វើផែនការត្រៀមបង្ការទឹកជំនន់ គួរតែធ្វើឡើងផ្អែកលើការវិភាគអ្នកពាក់ព័ន្ធ និងពង្រឹងការចូលរួមរបស់អ្នកពាក់ព័ន្ធឱ្យបានច្រើនជាអតិប្បរមា ចាប់តាំងពីពេលដាក់ផែនការ រហូតដល់ពេលអនុវត្ត ផែនការត្រៀមបង្ការទឹកជំនន់ ។
- ការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ គួរតែជាភ្នាក់ងារសំខាន់ៗទទួលខុសត្រូវ ចំពោះការសំរបសំរួលត្រៀមបង្ការ ការកាត់បន្ថយទឹកជំនន់ និងមុខងារឆ្លើយតបនៅក្នុងប្រទេស ។
- តួនាទីជាគោលរបស់ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក ត្រូវតែធ្វើការត្រៀមបង្ការគ្រោះមហន្តរាយ និង សកម្មភាពឆ្លើយតប ។
- ជំពូកស្តីពីកាកបាទក្រហមក្នុងស្រុក និងបណ្តាញអ្នកស្ម័គ្រចិត្តរបស់ខ្លួន ត្រូវចូលរួមយ៉ាងសកម្មនៅសកម្មភាពគ្រប់គ្រង គ្រោះមហន្តរាយនៅតាមថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ចំពោះការប្រតិបត្តិបានជោគជ័យនៃមុខងារគ្រប់គ្រងគ្រោះ មហន្តរាយ យន្តការសំរបសំរួលមានប្រសិទ្ធិភាព រវាងភ្នាក់ងារខុសគ្នា ត្រូវតែបង្កើតឱ្យមាននៅគ្រប់កំរិតទាំងអស់ ។
- យន្តកាស្ថាប័នសំរាប់ផែនការត្រៀមបង្ការទឹកជំនន់ និងការគ្រប់គ្រងគ្រោះទឹកជំនន់ ត្រូវតែធ្វើឱ្យមានតួនាទីច្បាស់លាស់សំរាប់ភ្នាក់ងារទាំងឡាយដែលកិច្ចការជាន់គ្នាមានកំរិតទាប
  និងធ្វើឱ្យការរៀបចំចាត់ចែងសំរាប់កិច្ច សហការ និងការសំរបសំរួលរវាង :
  - ភ្នាក់ងារទាំងឡាយដែលកំពុងធ្វើការនៅតាមមូលដ្ឋាន
  - ប្រព័ន្ធ -ផែនការថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិ
  - ប្រព័ន្ធថ្នាក់មូលដ្ឋានមានទំនាក់ទំនងទៅនឹងតំបន់ដែលនៅក្បែរគ្នាផ្សេងទៀត
- នៅក្នុងរចនាសម្ព័ន្ធអន្តរភ្នាក់ងារ ដូចជាស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុក នៅកម្ពុជា និងនៅប្រទេសវៀតណាម សមាជិកធ្វើជាតំណាងឱ្យភ្នាក់ងារមួយរបស់ពួកគេផង និងធ្វើជាតំណាងឱ្យ ស្ថាប័នគ្រប់គ្រងគ្រោះ មហន្តរាយ ផង។ ពួកគេបង្ហាញពីតំរូវការ និងទស្សនៈវិស័យរបស់ស្ថាប័នពួកគេនៅចំពោះមុខស្ថាប័ន ហើយបន្ទាប់មក នាំយកនូវតំរូវការរបស់ស្ថាប័ន និងការសំរេចចិត្តរបស់ខ្លួនត្រឡប់ទៅភ្នាក់ងារនីមួយៗវិញសំរាប់ពិចារណា និងចាត់ វិធានការ ។

- ការពិនិត្យឡើងវិញឱ្យបានល្អិតល្អន់ និងបន្ទាន់មួយក្រោយពីការធ្វើលំហាត់ ការហ្វឹកហាត់ ឬគ្រាអាសន្នជាក់ស្តែងមួយ នឹងចង្អុលបង្ហាញចំណុចដែលត្រូវធ្វើការកែលំអឱ្យកាន់តែល្អប្រសើរឡើង។ ផែនការគួរតែត្រូវបានពិនិត្យឡើងវិញ នៅពេលដឹងថាមានភាពអាសន្ន យ៉ាងហោចណាស់ឱ្យបាន ០១ឆ្នាំម្តង។
- យន្តកាស្ថាប័នគួរតែលើកកំពស់ការបង្កើតទំនាក់ទំនងស្របច្បាប់ និងណែនាំឱ្យដឹងពីវិធាននៃភាពជាដៃគូក្នុងចំណោម អ្នកពាក់ព័ន្ធ និងភ្នាក់ងារផ្សេងៗដើម្បីឱ្យការធ្វើផែនការត្រៀមបង្ការទឹកជំនន់បានល្អប្រសើរ ក៏ដូចជា ការគ្រប់គ្រង គ្រោះមហន្តរាយឱ្យទទួលបានលទ្ធផលល្អ ផងដែរ។ យន្តការស្ថាប័ន ក៏អាចបញ្ចៀសជំលោះផលប្រយោជន៍រវាងមន្ទីរ និងស្ថាប័នគ្រប់គ្រងខេត្ត-ស្រុកបាន ផងដែរ។ វត្តមាននៃការរៀបចំស្ថាប័ននឹងធានាឱ្យមានយន្តការស្ថិតស្ថេរមួយ ដូចជានៅពេលដែលអាចកើតមានបញ្ហាជំលោះតម្រូវការ បញ្ហាឆ្លងកាត់ព្រំដែននៅក្នុងស្រុក-ខេត្តរបស់ប្រទេសមួយ ហើយជួនកាលរហូតដល់ព្រំដែនអន្តរជាតិទៀតផង។ វាគួរតែចងចាំទុកថា នៅពេលដែលការធ្វើការរួមគ្នា ផ្តល់ ឱកាសសំរាប់ការសំរបសំរួលបានល្អប្រសើរ វាក៏អាចបង្កើននូវគ្រោះថ្នាក់នៃរបៀបវារៈមានជំលោះផងដែរ។

ឧទាហរណ៍នៃយន្តការស្ថាប័នសំរាប់ការត្រៀមបង្ការទឹកជំនន់ នៅប្រទេសកម្ពុជា ឡាវ និង វៀតណាម មានចែងនៅ ក្នុងឧបសម្ព័ន្ធ ដែលលំអិតអំពីតួនាទីរបស់ភ្នាក់ងារជាសមាជិកដែលទទួលខុសត្រូវចំពោះការគ្រប់គ្រងគ្រោះមហន្តរាយនៅ តាមកំរិតថ្នាក់ខេត្ត និងថ្នាក់ស្រុក។ *(សូមមើលឧបសម្ព័ន្ធទី I ដល់ទី III នៅចុងជំពូកនេះ)។*

## ៤.៤ ការវិភាគអ្នកពាក់ព័ន្ធ និងផលប្រយោជន៍សំខាន់ៗនៃការចូលរួមរបស់អ្នកពាក់ព័ន្ធ

ចំពោះការធ្វើផែនការត្រៀមបង្ការទឹកជំនន់ អ្នកពាក់ព័ន្ធ អាចជាបុគ្គល ឬជាភ្នាក់ងារ/អង្គការ ទាំងនៅក្នុងនិង ក្រៅអាជ្ញាធររដ្ឋាភិបាលក្នុងមូលដ្ឋាន ដែលជាអ្នក :

- មានតំណែងនិងឥទ្ធិពលលើដំណើរការធ្វើផែនការ
- រងផលប៉ះពាល ឬនឹងត្រូវរងផលប៉ះពាល់ពីផែនការ
- អាចទាមទារចូលរួមនៅក្នុងការងារធ្វើផែនការ

ការធ្វើការវិភាគអ្នកពាក់ព័ន្ធ នៅមុនដំណើរការធ្វើផែនការជាក់ស្តែង អាចជួយកំណត់អ្នកដើរតួសំខាន់ និងបញ្ជាក់ បានច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ហើយក្នុងពេលដំណាលគ្នានេះ ធានាដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធ ទាំងអស់។ វាក៏ជួយនៅក្នុងការប៉ាន់ប្រមាណសារៈសំខាន់នៃភ្នាក់ងារផ្សេងៗ

ដែលពាក់ព័ន្ធនៅក្នុងការកាត់បន្ថយគ្រោះ មហន្តរាយ ការកំណត់លក្ខណៈនិងទំហំ ឥទ្ធិពលរបស់ពួកគេនៅក្នុងដំណើរការធ្វើផែនការ និងការចំណាត់ពួកគេជាសម្ព័ន្ធ មិត្ត ឬជាចំណុចអត់ធន់សំខាន់ៗ ផងដែរ ។

នេះនឹងជួយបញ្ជាក់ច្បាស់លាស់ ។ ការវិភាគបែបនេះ ក៏នឹងអាចធ្វើឱ្យការកំណត់នៃការប្រឈមមុខដែលអាចមាន (ភាពតានតឹង និងការជំទាស់) នៅក្នុងការធ្វើផែនការទូលំទូលាយមួយដែលត្រូវការដោះស្រាយដើម្បីបង្កើតផែនការ ត្រៀមបង្ការទឹកជំនន់ដែលអាចធ្វើបាន និងទាក់ទងគ្នា ។

វាជាសំខាន់ ត្រូវពិចារណាពីមុខងាររបស់អ្នកពាក់ព័ន្ធណាម្នាក់ដែលការទទួលខុសត្រូវរបស់គេមិនច្បាស់លាស់ ឬការទទួលខុសត្រូវអាចផ្លាស់ប្តូរឆាប់រហ័ស ។

វាជាសំខាន់ ត្រូវទទួលស្គាល់សហគមន៍ដែលទំនងជារងការប៉ះពាល់ដោតទឹកជំនន់ ជាក្រុមអ្នកពាក់ព័ន្ធសំខាន់មួយ ហើយពួកគេត្រូវតែចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការធ្វើផែនការត្រៀមបង្ការទឹកជំនន់ ។

## ៤.៥ នរណាខ្លះជាអ្នកពាក់ព័ន្ធនៅក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់?

ការទទួលខុសត្រូវសំខាន់សំរាប់ការធ្វើផែនការត្រៀមបង្ការទឹកជំនន់ ស្ថិតនៅជាមួយក្រុមសហគមន៍ និងរដ្ឋាភិបាល ជាពិសេស អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ដែលត្រូវឆ្លើយតបចំពោះព្រឹត្តិការណ៍ទឹកជំនន់ ។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន គឺជាភ្នាក់ងារនាំមុខ និងទទួលខុសត្រូវ ចំពោះការសំរប សំរួលការគ្រប់គ្រងទាំងអស់ រួមទាំង ការសំរបសំរួលការពិភាក្សារវាងដៃគូ ដើម្បីកំណត់ការទទួលខុសត្រូវ ។ នៅពេលដែលតួនាទី និងការ ទទួលខុសត្រូវ ត្រូវបានបញ្ជាក់ច្បាស់លាស់ហើយ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានត្រូវតែធានាថា សកម្មភាព ដែលបានផ្ទេរទៅឱ្យភ្នាក់ងារខុសៗគ្នា ត្រូវបានអនុវត្តជាក់ស្តែង នៅក្នុងពេលវេលាកំណត់ជាក់លាក់មួយ ។

## តើអ្នកវិភាគអ្នកពាក់ព័ន្ធដោយយ៉ាងដូចម្តេច?

ពិចារណាការបង្កើតតារាងវិភាគអ្នកពាក់ព័ន្ធ ស្រដៀងគ្នាទៅនឹងតារាងខាងក្រោម :

| GñkBak;B½n§ | អ្នកពាក់ព័ន្ធ ប្រយោជន៍នៅក្នុង FPP | កំរិតនៃ ប្រយោជន៍ | យុទ្ធសាស្ត្រមានសក្តានុភាព សំរាប់ ទទួលបានការគាំទ្រ ឬកាត់បន្ថយឧបសគ្គ |
|---|---|---|---|
| | | | |

១. រៀបចំក្រុមបំផុសគំនិត។ កំណត់រកមនុស្ស ក្រុម និងស្ថាប័នទាំងអស់ដែលនឹងធ្វើឱ្យប៉ះពាល់ ឬរងការប៉ះពាល់ពី FPP និងចុះ បញ្ជីរឈ្មោះពួកគេនៅក្នុងក្រឡោននៅក្រោម "អ្នកពាក់ព័ន្ធ" ។

២. នៅពេលអ្នកមានបញ្ជីរឈ្មោះអ្នកពាក់ព័ន្ធទាំងនេះហើយ ពិនិត្យបញ្ជីរឡើងវិញ និងកំណត់រកប្រយោជន៍ ជាក់លាក់ដែលអ្នកពាក់ព័ន្ធទាំងនេះមាននៅក្នុង FPP ។ ពិចារណាបញ្ហា ដូចជា ប្រយោជន៍របស់ FPP ចំពោះ អ្នក ពាក់ព័ន្ធ ការផ្លាស់ប្តូរដែល FPP អាចតំរូវឱ្យអ្នកពាក់ព័ន្ធធ្វើ និងសកម្មភាពអាចជាមូលហេតុធ្វើឱ្យខូចខាត ឬជា ជំលោះសំរាប់អ្នកពាក់ព័ន្ធ។ កត់ត្រាទាំងអស់នេះ នៅក្នុងក្រឡោនទី១។

៣. ឥឡូវ ពិនិត្យបញ្ជីឈ្មោះអ្នកពាក់ព័ន្ធនៅក្នុងក្រឡោនទីមួយឡើងវិញ។ សួរសំណួរ : តើប្រយោជន៍របស់អ្នកពាក់ព័ន្ធ សំខាន់យ៉ាងដូចម្តេច ចំពោះជោគជ័យនៃ ធភភ ? សូមពិចារណាលើ :

- o តួនាទីអ្នកពាក់ព័ន្ធសំខាន់ ត្រូវតែអនុវត្តFPP ជោគជ័យនិងភាពដែលធ្វើឱ្យអ្នកពាក់ព័ន្ធ នឹងអនុវត្ត តួនាទីនេះ។
- o ភាពទំនង និងឥទ្ធិពលនៃការឆ្លើយតបអវិជ្ជមានរបស់អ្នកពាក់ព័ន្ធចំពោះ FPP ។ កំណត់ អក្សរ **ក** សំរាប់សំខាន់បំផុត **ខ** សំខាន់ធម្មតា និង **គ** មិនសូវសំខាន់។ សរសេរអក្សរទាំងនេះនៅក្នុងក្រឡោន ឈ្មោះថា "កំរិតនៃប្រយោជន៍" ។

៤.ជំហានចុងក្រោយ គឺត្រូវពិចារណាពីប្រភេទកិច្ចការដែលអ្នកអាចឱ្យអ្នកពាក់ព័ន្ធគាំទ្រ និងបន្ថយការជំទាស់។ ចូរគិតពីរបៀប អ្នកចូលជិតទៅដល់អ្នកពាក់ព័ន្ធម្នាក់ៗ។ តើពួកគេនឹងត្រូវការពីមានអ្វីខ្លះ? តើការចូលរួមរបស់ អ្នកពាក់ព័ន្ធ នៅក្នុងដំណើរការធ្វើ ផែនការ មានសារៈសំខាន់ យ៉ាងដូចម្តេច? តើមានក្រុមឬបុគ្គលផ្សេងទៀត មានឥទ្ធិពលលើអ្នកពាក់ព័ន្ធដើម្បី គាំទ្រឬជំទាស់ គំនិតផ្តួចផ្តើមរបស់អ្នកដែរឬទេ? កត់ត្រាយុទ្ធសាស្ត្ររនស់អ្នកដើម្បីទទួលបានការគាំទ្រឬកាត់បន្ថយឧបសគ្គចំពោះគំរោងកម្មវិធី របស់អ្នកនៅក្នុក្រឡោនចុងក្រោយក្នុងតារាង។ ដកស្រង់ចេញពី

http://erc.msh.org/quality/ittools/itstkan.cfm

ជំហានបន្ទាប់ គឺត្រូវចងក្រងជាឯកសារនូវតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនៅកំរិតខុសៗគ្នា (ពីថ្នាក់ ជាតិដល់ថ្នាក់ខេត្ត ស្រុក ឃុំ និងភូមិ) នៅក្នុងផែនការត្រៀមបង្ការទឹកជំនន់ ដើម្បីឱ្យពួកគេអាចតាមដាន សកម្មភាព របស់ ពួកគេ ធានាការអនុវត្តន៏ទាន់ពេលវេលា និងនៅពេលចាំបាច់ ធ្វើផែនការឱ្យថ្មីឡើងវិញ ។

តារាងខាងក្រោម ផ្តល់ឧទាហរណ៏មួយស្តីពីបញ្ជីឈ្មោះរបស់អ្នកពាក់ព័ន្ធ និងសកម្មភាពត្រៀមបង្ការ ដែលអ្នក ពាក់ព័ន្ធម្នាក់ៗអាចធ្វើបាន:

| **អ្នកពាក់ព័ន្ធ** | **សកម្មភាពត្រៀមបង្ការសំខាន់ៗ** |
|---|---|
| **រដ្ឋាភិបាលក្នុងស្រុក : មន្ទីរ** | ▪ បង្កើតការត្រៀមបង្ការទាក់ទងនឹងគោលនយោបាយ និងការចេញក្រិត្យរដ្ឋាភិបាល<br>▪ ការព្យាករណ៏ និងចែកចាយព័តិមានទឹកជំនន់ដល់រដ្ឋាភិបាលក្នុងស្រុក និង អង្គការមនុស្សធម៌ |
| **រដ្ឋាភិបាលក្នុងស្រុក : (គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក និងសមាជិកភ្នាក់ងាររបស់គេ)** | ▪ ការចែកចាយការប្រកាសអាសន្នផ្អែកតាមការព្យាករណ៏<br>▪ ការត្រៀមរៀបចំសំរាប់ការស្វែងរក និងសង្គ្រោះ<br>▪ រៀបចំភស្តុភា និងដឹកជញ្ជូនទៅកន្លែងសុវត្ថិភាព<br>▪ កំណត់ រៀបចំ និងថែរក្សាតំបន់សុវត្ថិភាពទឹកជំនន់<br>▪ ផ្តល់ប្រភពទឹកនៅតំបន់សុវត្ថិភាពទឹកជំនន់ និងការធ្វើអនាម័យសមស្រប<br>▪ ត្រៀមផ្តល់ទីជំរកបណ្តោះអាសន្ន ជំនួយសង្គ្រោះ និងសេវាពេទ្យជាមូលដ្ឋាន<br>▪ ស្វែងយល់ និងប្រើប្រាស់ទំរង់សំរាប់ការប៉ាន់ប្រមាណរហ័សដើម្បីពួកគេអាច ជូនដំណឹងដល់រដ្ឋាភិបាលជាតិ និងស្នើសុំជំនួយសង្គ្រោះបន្ថែម ប្រសិនបើចាំបាច់ ។<br>▪ កំណត់រកអង្គការធនធាន និងមនុស្សធម៌សំខាន់ៗដែលនឹងជួយជំនួយសង្គ្រោះ និងសហការជាមួយពួកគេ រយៈពេលមួយឆ្នាំឬច្រើនឆ្នាំឱ្យបានញឹកញាប់មុន រដូវទឹកជំនន់ ។<br>▪ បញ្ជាក់ឱ្យបានច្បាស់លាស់ និងធ្វើជាឯកសារស្តីពីតួនាទី និងការទទួលខុសត្រូវ នៅក្នុងរដ្ឋាភិបាល ហើយផ្ទេរវាទៅឱ្យអង្គការមនុស្សធម៌<br>▪ រៀបចំធ្វើ FPP មួយសហការជាមួយអង្គការមនុស្សធម៌ ដូចជាកាកបាទក្រហម និងអង្គការក្រៅរដ្ឋាភិបាល និងអនុវត្តវឱ្យមានប្រសិទ្ធភាព<br>▪ ពិនិត្យផែនការត្រៀមបង្ការទឹកជំនន់ឡើងវិញ ក្រោយពេលទឹកជំនន់ និង កែតម្រូវឡើងវិញសំរាប់ទឹកជំនន់ដែលជិតមកដល់ និងនៅពេលសមស្រប ។ |

| | |
|---|---|
| **សហគមន៍ (គួរតែរៀបចំជាក្រុមអ្នកស្ម័គ្រចិត្ត ដូចជាក្រុមស្បៀង និងទីជំរកការជំលៀស ព័តិមាន។ល។)** | ▪ ការជំលៀសទៅតំបន់សុវត្ថិភាពនៅពេលទទួលបានការព្យាករណ៍<br>▪ ការការពារទ្រព្យសម្បត្តិផ្ទះសម្បែងដោយការទុកដាក់នៅកន្លែងខ្ពស់<br>▪ ការប្រើទូកផ្ទាល់ខ្លួនសំរាប់ជួយអ្នកដែលត្រូវការ<br>▪ បន្តរក្សាទុកស្បៀង និងក្រណាត់តង់<br>▪ ជ្រើសរើស និងចុះឈ្មោះអ្នកស្ម័គ្រចិត្តក្មេងៗ ដើម្បីពួកគេមានវត្តមានពេលស្ថានភាពមានអាសន្ន<br>▪ ជ្រើសរើស និងចុះឈ្មោះអ្នកហែលទឹកក្មេងៗ<br>▪ ជ្រើសរើស និងចុះឈ្មោះសមាជិកសហគមន៍ដែលបានទទួលការបណ្តុះបណ្តាលដែលអាចចែកចាយព័តិមានព្យាករណ៍ទឹកជំនន់ទៅដល់សមាជិកសហគមន៍បាន |
| **ភ្នាក់ងារក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងអង្គការថ្នាក់តំបន់** | ▪ ផ្តល់ជំនួយបច្ចេកទេសក្នុងការព្យាករណ៍<br>▪ ផ្តល់ជំនួយសំរាប់ដឹកជញ្ជូនទៅកាន់តំបន់សុវត្ថិភាព<br>▪ សំរបសំរួលការរៀបចំតំបន់សុវត្ថិភាពតាមរយៈការផ្តល់ទឹក អនាម័យ ទីជំរកបណ្តោះអាសន្ន តំរូវការផ្នែកពេទ្យ ឬស្បៀង ដែលត្រូវការ ឬស្នើឡើងដោយរដ្ឋាភិបាល<br>▪ ផ្តល់ជំនួយសង្គ្រោះតាមតំរូវការ ឬស្នើឡើងដោយរដ្ឋាភិបាល<br>▪ សំរបសំរួលការធ្វើផែនការត្រៀមបង្ការ |

## ៤.៦ សំណួរសំរាប់ពិចារណា

១. អធិប្បាយពីអត្ថប្រយោជន៍ជាគន្លឹះចំនួន ០៥ ទាក់ទិននឹងការបង្កើតយន្តការស្ថាប័នសំរាប់រៀបចំធ្វើផែនការត្រៀមបង្ការ និងការគ្រប់គ្រងគ្រោះទឹកជំនន់។

២. ហេតុអ្វីបានជាចំបាច់ត្រូវធ្វើការវិភាគអ្នកពាក់ព័ន្ធ? តើនរណាខ្លះ គឺជាអ្នកពាក់ព័ន្ធសំខាន់នៅក្នុងការធ្វើផែនការ? តើពេលណាដែលល្អបំផុតសំរាប់ធ្វើផែនការ និងធ្វើជាមួយនរណា?

៣. ពិពណ៌នាការប្រឈមមុខនៅចំពោះមុខមន្ត្រីមូលដ្ឋានដែលត្រូវធ្វើជាតំណាងឱ្យទាំងភ្នាក់ងាររបស់ខ្លួន ផងនិង របស់ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ស្រុកផង។

# ឧបសម្ព័ន្ធ ១ : ការរៀបចំស្ថាប័នសំរាប់កាត់បន្ថយគ្រោះមហន្តរាយនៅកម្ពុជា

## ១.១ ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយនៅកំរិតថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក

នៅក្នុង១៩៩៥ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយមួយ ហៅកាត់ថា (NCDM) ។ **ការរៀបចំ និង ការទទួលខុសត្រូវ**របស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានបង្កើតឡើង និងអនុម័ត។ នៅឆ្នាំ២០០៤ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានបង្កើតឡើង និង អនុម័តដោយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឡាយព្រះហត្ថលេខាលើរាជក្រិត្យលេខ SN/RKT/0804/234 ចុះថ្ងៃទី ៣១ ខែកញ្ញា ២០០៤ ដែលមានសមាជិកដូចខាងក្រោម :

**គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ** (NCDM)

**ព្រះរាជក្រិត្យលេខ NS/RKT/0804/236**

**សមាជិក**

| | |
|---|---|
| ១. នាយករដ្ឋមន្ត្រី | ប្រធាន |
| ២. មន្ត្រីជាន់ខ្ពស់ (Senior Minister) | អនុប្រធានទី១ |
| ៣. មន្ត្រីជាន់ខ្ពស់ (Senior Minister) | អនុប្រធានទី២ |
| ៤. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥. រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៦. រដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៨. រដ្ឋមន្ត្រី ក្រសួងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩. រដ្ឋមន្ត្រី ក្រសួងបរិស្ថាន | សមាជិក |
| ១០. រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| ១១. រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ១២. រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. រដ្ឋមន្ត្រី ក្រសួងសុខាភិបាល | សមាជិក |
| ១៤. រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍជនបទ | សមាជិក |

| | | |
|---|---|---|
| ១៥. | រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ១៦. | រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងការស្តារយុវនីតិសម្បទា | សមាជិក |
| ១៧. | រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១៨. | រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៩. | រដ្ឋមន្ត្រីក្រសួងកិច្ចការនារី | សមាជិក |
| ២០. | តំណាងអគ្គមេបញ្ជាការកងយោធិពលខេមរភូមិន្ទ | សមាជិក |
| ២១. | តំណាងប្រធានកាកបាទក្រហមជាតិកម្ពុជា | សមាជិក |
| ២២. | រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |

## បេសកកម្ម

ដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយ នៅព្រះរាជាណាចក្រកម្ពុជា។

## មុខងារ និង ការទទួលខុសត្រូវ

- សំរបសំរួលជាមួយក្រសួងនានានៃរាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និង អង្គការអន្តរជាតិ សហគមន៍អន្តរជាតិ សមាគមជាតិ និងម្ចាស់ជំនួយក្នុងស្រុកដើម្បីអំពាវនាវរកជំនួយ សំរាប់ឆ្លើយតប គ្រោះអាសន្ន និងការស្តារនិតិសម្បទាឡើងវិញ។
- ធ្វើអនុសាសន៍ទៅរាជរដ្ឋាភិបាល និងចេញគោលគាណ៍ គោលនយោបាយសំខាន់ៗ និងប្រកាសអាសន្ន ស្តីពី ការត្រៀមបង្ការ និងគ្រប់គ្រង់គ្រោះមហន្តរាយ ចាត់វិធានការសំរាប់ការឆ្លើតតបគ្រោះអាសន្ន និង អន្តរាគមន៍ជំលៀសប្រជាជនទៅកាន់កន្លែងសុវត្ថិភាព។
- បែងចែកការងារគ្រប់គ្រងគ្រោះមហន្តរាយដល់សហគមន៍ និងពង្រឹងខ្សែរយៈពីថ្នាក់ជាតិ (ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ) ដល់ថ្នាក់ខេត្ត-ក្រុង ស្រុក ឃុំជាមួយការអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងបំណងគ្រប់គ្រង ការងារគ្រោះមហន្តរាយឱ្យបានមាំទាំ និងមានប្រសិទ្ធភាព។
- ដាក់សំណើរទៅរាជរដ្ឋាភិបាល អំពីការបំរុងថវិកា ប្រេងឥន្ទនៈ មធ្យោបាយធ្វើការងារ ឧបករណ៍ និងធនធាន មនុស្ស សំរាប់ការបង្ការ និងអន្តរាគមន៍គ្រោះមហន្តរាយក្នុងការឆ្លើយតបគ្រោះអាសន្ន និងស្តារនិតិសម្បទា នៅ មុនពេល កំឡុងពេល និងក្រោយពេលគ្រោះមហន្តរាយ។

## អគ្គលេខាធិការដ្ឋាននៃ NCDM

## តួនាទី និង ការទទួលខុសត្រូវ

អគ្គលេខាធិការដ្ឋានអនុវត្តតួនាទីមួយជាទំបញ្ជាការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងមានភារកិច្ច ដូចតទៅ :

- ធានានិរន្តភាព និងមុខងាររបស់រដ្ឋបាលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- រៀបចំស្រាវជ្រាវទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ រោគរាតត្បាតនៅក្នុងតំបន់ប្រឈម និងគ្រោះថ្នាក់ផ្សេងៗ ដោយការរៀបចំធ្វើផែនការត្រៀមបង្ការ និងឆ្លើយតបគ្រោះអាសន្ន ។
- ណែនាំគណៈកម្មាធិការខេត្ត-ក្រុង ស្រុក ឃុំ គ្រប់គ្រងគ្រោះមហន្តរាយ និងសហគមន៍ជំនួយសង្គ្រោះ អំពីការងារ និងជំនាញបច្ចេកទេស ដែលជាមូលដ្ឋានប្រមូលទិន្នន័យគ្រោះមហន្តរាយ និងការប៉ាន់ប្រមាណ តំរូវការ និង រៀបចំកម្មវិធីស្តារនិតិសម្បទា និងការសាងសង់ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដោយសហការជាមួយស្ថាប័ន ភ្នាក់ងារអង្គការសហប្រជាជាតិ អន្តរជាតិ និងអង្គការពាក់ព័ន្ធនានា ។
- បង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសសំរាប់មន្ត្រីដែលបំរើមុខងារគ្រប់គ្រងគ្រោះមហន្តរាយនៅ តាម ខេត្ត ក្រុង ស្រុក ឃុំ និងជំនួយសង្គ្រោះសហគមន៍ នៅក្នុងគំរោងការណ៍នៃបណ្តុះបណ្តាលនៅក្នុង និង ក្រៅប្រទេស ។
- សំរបសំរួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអង្គការអន្តរជាតិ ដើម្បីជំលៀសប្រជាជនដែលងាយរងគ្រោះទៅកាន់ទីកន្លែងសុវត្ថិភាព និងផ្តល់ ឱ្យពួកគេនូវសន្តិសុខ ការអប់រំជាសាធារណៈ ការឆ្លើយតបគ្រោះអាសន្ន និងកម្មវិធីផ្សេងៗ ។
- ផ្តល់យោបល់អំពីឯកសារពាក់ព័ន្ធទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ និងលិខិតយល់ព្រម ។ បូកសរុប របាយការណ៍ និងដាក់ជូនទៅគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ អគ្គលេខាធិការដ្ឋាននៃ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយមាននាយកដ្ឋានចំនួន ៥ ដូចមានចែងក្នុងមាត្រាខាងក្រោម :

## ១. នាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ

### ការទទួលខុសត្រូវ គឺ :

- គ្រប់គ្រង និងផ្សព្វផ្សាយឯកសាររដ្ឋបាលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- បូកសរុបលទ្ធផលការងារគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និងសកម្មភាពផ្សេងៗទៀត
- គ្រប់គ្រងមន្ត្រីរាជការស៊ីវិលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ប្រមូលតំរូវការ បង្កើតសំណើសុំថវិកា ផែនការកម្មវិធីចំណាយ កត់ត្រា និងរំលឹកការប្រតិបត្តិរបស់ខ្លួន

- សំរបសំរួលខ្ទង់ថវិកា និងការចំណាយរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- គ្រប់គ្រងទ្រព្យសម្បត្តិដែលមិនអាចរើចេញបាន របស់ដែលអាចរើចេញ បំរុងទុករបស់របរ និងបញ្ជីរសារពើភ័ណ្ឌ របស់ខ្លួន។

## ២. នាយកដ្ឋាន ព័តិមាន និង ទំនាក់ទំនង

### ការទទួលខុសត្រូវ គឺ :

- តាមដានព័តិមានអាកាសធាតុ ស្ថានភាពឧត្តុនិយម និងជលធារសា
- សរសេរ និងចងក្រងព័តិមានគ្រោះមហន្តរាយ
- ចេញប្រកាសព័តិមានទាក់ទងនឹងគ្រោះមហន្តរាយផ្សេងៗដែលកំពុងកើតមាននៅក្នុង និងក្រៅប្រទេស តាមរយៈ ព្រឹត្តិប័ត្រ និងប្រព័ន្ធផ្សព្វផ្សាយ ។
- ផលិតផ្ទាំងរូបភាព និងខិតប័ណ្ណគ្រោះមហន្តរាយ
- ធ្វើរបាយការណ៏ស្តីពីស្ថានភាពជលធារសា និងឧត្តុនិយម ដោយសហការជាមួយក្រសួង ស្ថាប័នជំនាញ និងផ្សព្វ ផ្សាយការប្រកាសភាពអាសន្ន តំរូវការ និងវិធានការនានា។
- ទំនាក់ទំនងជាមួយបរទេស និងអង្គការអន្តរជាតិទាក់ទងនឹងការងារគ្រោះមហន្តរាយ ។

## ៣. នាយកដ្ឋានឆ្លើយតបគ្រោះអាសន្ន និង ស្តារនីតិសម្បទា

### ការទទួលខុសត្រូវ គឺ :

- បង្កើតរចនាសម្ព័ន្ធបញ្ជាការក្នុងប្រតិបត្តិការគ្រោះអាសន្នស្របទៅនឹងគោលនយោបាយជាតិសំរាប់គ្រប់គ្រងគ្រោះមហន្តរាយ ផ្អែកលើការទទួលព័តិមានស្តីពីការទាយទុកពីគ្រោះមហន្តរាយ ។
- ធ្វើផែនការត្រៀមបង្ការ កាត់បន្ថយ ជំនួយសង្គ្រោះភាពអាសន្ន និងការស្តារនិតិសម្បទាការងារ និងកម្មវិធីស្តារនីតិសម្បទា។
- សំរបសំរួលការស្រាវជ្រាវពីគ្រោះថ្នាក់ សេវាកម្ម ជំនួយសង្គ្រោះភាពអាសន្ន សុវត្ថិភាព សន្តិសុខ ការជំលៀស និងទីជំរកជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និងអង្គការជាតិនានា
- រៀបចំធ្វើការប៉ាន់ប្រមាណការខូចខាតតំរូវការនិងដឹកនាំប្រតិបត្តិការនៅពេលមានគ្រោះអាសន្នកើតឡើង

## ៤. នាយកដ្ឋានត្រៀមបង្ការ និង បណ្តុះបណ្តាល

### ការទទួលខុសត្រូវ គឺ :

- រៀបចំឧបករណ៍ សំភារៈ និងបរិក្ខាសំរាប់ឆ្លើយតបគ្រោះអាសន្ន
- បង្កើតផែនការ និងកម្មវិធីសំរាប់បណ្តុះបណ្តាលធនធានមនុស្ស ដែលបំរើមុខងារគ្រប់គ្រងគ្រោះមហន្តរាយនៅកំរិតថ្នាក់ជាតិ និងថ្នាក់ស្រុក
- ជ្រើសរើសបេក្ខជនដែលចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលនៅក្នុង និងក្រៅប្រទេស
- អប់រំ និងជូនព័ត៌មានអំពីការត្រៀមបង្ការគ្រោះមហន្តរាយដល់សហគមន៍ក្នុងស្រុក និងប្រជាជនដែលរងការប៉ះពាល់
- បោះពុម្ពឯកសាររូបភាពទាក់ទងនឹងការត្រៀមបង្ការ និងកាត់បន្ថយទឹកជំនន់ ។

## ៥. នាយកដ្ឋានស្រាវជ្រាវ និង សង្គ្រោះ

### ការទទួលខុសត្រូវ គឺ

- សំរបសំរួលការងារជាមួយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីធ្វើសកម្មភាព អនុលោមទៅតាមនីតិវិធីច្បាប់ដែលបានរៀបចំឡើង ។
- រៀបចំផែនការ និងដាក់ជូនទៅបញ្ជាការជាន់ខ្ពស់នៃកងយោធិពលខេមរភូមិន្ទ ទាក់ទងនឹងការប្រើមធ្យោបាយ កងកំលាំងអន្តរាគមន៍ SAR
- ទទួល និងបញ្ជូនព័ត៌មានអំពីគ្រោះថ្នាក់នៅលើយន្តហោះ និងនាវា និងស្នើសុំគោលការណ៍ ការអនុវត្តន៍បទបញ្ជារ និងការណែនាំពីគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទាក់ទងនឹងការសំរបសំរួលការស្រាវជ្រាវ និង សង្គ្រោះ ។
- ចេញសេចក្តីប្រកាសជាផ្លូវការអំពីទីកន្លែងឧប្បត្តិហេតុ នៅពេលត្រួតពិនិត្យព័ត៌មានឡើងវិញ ។
- រៀបចំធ្វើបែបបទ និងប្រតិបត្តិការ SAR ដោយសហការជាមួយប្រទេសជិតខាង ស្របទៅតាមកិច្ចព្រមព្រៀង ស្តីពីការស្រាវជ្រាវ និងសង្គ្រោះ ។
- សហការជាមួយមជ្ឈមណ្ឌលសំរបសំរួលគ្រោះអាសន្ននៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងកំណាត់បេសសកម្ម SAR ។

## កំរិតទាំង ៤ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា

១. គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ (NCDM)

២. គណៈកម្មាធិការខេត្ត គ្រប់គ្រងគ្រោះមហន្តរាយ (PCDM)

៣. គណៈកម្មាធិការស្រុក គ្រប់គ្រងគ្រោះមហន្តរាយ (DCDM)

៤. គណៈកម្មាធិការឃុំ គ្រប់គ្រងគ្រោះមហន្តរាយ (CCDM)

## អង្គការលេខនៃគណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ (NCDM)

**រចនាសម្ព័ន្ធអង្គការលេខរបស់ NCDM**



# ឧបសម្ព័ន្ធ ២ : ការរៀបចំស្ថាប័នសំរាប់កាត់បន្ថយគ្រោះមហន្តរាយនៅប្រទេសវៀតណាម

## ២.១ រចនាសម្ព័ន្ធរបស់គណៈកម្មាធិការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ (CFSC) ថ្នាក់ជាតិ ថ្នាក់ខេត្ត និងស្រុក

### *២.១.១ ថ្នាក់ជាតិ*

**គណៈកម្មាធិការកណ្តាលសំរាប់ត្រួតពិនិត្យទឹកជំនន់**

**និងខ្យល់ព្យុះ(CCFSC)** នៃប្រទេសវៀតណាមធ្វើសកម្មភាពដែលគ្របដណ្តប់លើ វិសាលភាពគ្រប់គ្រងគ្រោះមហន្តរាយទាំងស្រុង ពីការត្រៀមបង្ការ ការឆ្លើយតប ការធ្វើឱ្យការខូចខាត ការបាត់បង់នៅ អប្បរមា ការស្តារឡើងវិញ និងការស្តារនីតិសម្បទា ពីគ្រោះមហន្តរាយ និងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើអេកូបរិដ្ឋាន។ ភ្នាក់ងារគ្រប់គ្រងរបស់រដ្ឋសំរាប់ការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ គឺជា**គណៈកម្មាធិការត្រួត ពិនិត្យ ទឹកជំនន់ និងខ្យល់ព្យុះ** *(មានពីថ្នាក់ជាតិដល់ថ្នាក់មូលដ្ឋាន)*។

នៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការកណ្តាល CFSC **នៅថ្នាក់ជាតិ និងស្រុក និងភ្នាក់ងាររង** ត្រូវបាន បង្កើតឡើងដោយគណៈកម្មាធិការប្រជាជន(PC)។ គណៈកម្មាធិការទាំងនេះដឹកនាំដោយប្រធានគណៈកម្មាធិការ ប្រជាជនជាមួយប្រធាននាយកដ្ឋានកសិកម្ម និងអភិវឌ្ឍជនបទ (DARD)មានតួនាទីជាអនុប្រធានដឹកនាំ និងប្រធាន និង អនុប្រធាន នាយកដ្ឋានពាក់ព័ន្ធនឹងសកម្មភាពត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះមូលដ្ឋាន ជាសមាជិក។ ការិយាល័យធំ របស់ CFSC មានទីតាំងនៅក្នុងអគារ DARD ។ ថវិកាសំរាប់សកម្មភាព CFSC បានមកពីចំណែកថវិការបស់ DARD ដែលចំណាត់ ដោយគណៈកម្មាធិការប្រជាជនថ្នាក់ខេត្ត។

### *២.១.២ កំរិតថ្នាក់ខេត្ត*

នាយកដ្ឋានកសិកម្ម និងអភិវឌ្ឍជនបទ គឺជាភ្នាក់ងារដឹកនាំសំរាប់ការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះថ្នាក់ខេត្ត :

- *សំរាប់ខេត្តមាន dykes :* ការិយាល័យការពារ Dyke ត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ នៅក្រោម DARD ខេត្ត ប្រតិបត្តិជាការិយាល័យដឹកនាំរបស់គណៈកម្មាធិការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ ទទួលខុសត្រូវសំរាប់គ្រប់គ្រង មុខងាររដ្ឋលើការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ និងកាត់បន្ថយគ្រោះមហន្តរាយ។
- *សំរាប់ខេត្តផ្សេង :* នាយកដ្ឋានធារាសាស្ត្រ ត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ នៅក្រោម DARD ខេត្ត ប្រតិបត្តិការជាការិយាល័យដឹកនាំរបស់ CFSC។

### ២.១.៣ កំរិតថ្នាក់ស្រុក

**នៅថ្នាក់ស្រុក (ស្រុក ទីប្រជុំជន និងទីក្រុងនៅក្រោមការគ្រប់គ្រងថ្នាក់ខេត្ត) :** DARD ស្រុក គឺជាការិយាល័យដឹកនាំ និងផ្តល់ឱវាទដល់ CFSC ស្រុក ក្នុងការអនុវត្តន៍មុខងារគ្រប់គ្រងរដ្ឋ ទាក់ទិននឹងការត្រួតពិនិត្យ ទឹកជំនន់ និងខ្យល់ព្យុះ មូលដ្ឋាន និងការកាត់បន្ថយគ្រោះមហន្តរាយ ។

### ២.១.៤ កំរិតថ្នាក់ឃុំ

**នៅកំរិតថ្នាក់ឃុំ (ឃុំ សង្កាត់ និងទីប្រជុំជន) :** គណៈកម្មាធិការប្រជាជនឃុំចាត់តាំងបុគ្គលិកជាសមាជិកពេញម៉ោងម្នាក់ ធ្វើការងារលើការត្រួតពិនិត្យទឹកជំនន់និងខ្យល់ព្យុះ និងកាត់បន្ថយគ្រោះមហន្តរាយជាតំណែងដឹកនាំ ។

រៀងរាល់ឆ្នាំ សកម្មភាពផ្សេង១ នៅក្រោមការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ និងកាត់បន្ថយគ្រោះមហន្តរាយ និងការស្តារការខូចខាត ត្រូវតែច្របាច់បញ្ចូលគ្នា រៀបចំ និងចាត់តាំងឱ្យបានត្រឹមត្រូវនៅគ្រប់កំរិត និងផ្នែកទាំងអស់ ។

សំរាប់សកម្មភាពត្រៀមបង្ការគ្រោះមហន្តរាយនីមួយ១ ភ្នាក់ងារកណ្តាលត្រូវតែមានផែនការត្រៀមបង្ការគ្រោះមហន្តរាយដែលអនុម័តដោយ CCFSC ។ កំលាំងមានវិជ្ជាជីវៈ និងពាក់កណ្តាលវិជ្ជាជីវៈ ត្រូវតែត្រៀមដោះស្រាយជាមួយ គ្រោះអាសន្នជារចនាសម្ព័ន្ធ ហើយបទបញ្ជារ និងការទទួលខុសត្រូវរបស់កំលាំងនីមួយ១ ត្រូវកំណត់ឱ្យបានច្បាស់លាស់ ។

## ២.២ មុខងារ និងកិច្ចការរបស់គណៈកម្មាធិការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ នៅថ្នាក់ខេត្ត និងស្រុក

គណៈកម្មាធិការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ នៅថ្នាក់ខេត្ត និងស្រុក (CFSC) ជួយ គណៈកម្មាធិការប្រជាជន នៅក្នុងមុខងារគ្រប់គ្រងរដ្ឋទាក់ទងទៅនឹងការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ និងការកាត់បន្ថយគ្រោះមហន្តរាយ នៅ ក្នុងតំបន់រដ្ឋបាល ផែនការ និងឃ្លាំមើលការអនុវត្តន៍ប្រតិបត្តិការត្រៀមបង្ការគ្រោះមហន្តរាយ ការថែទាំ dyke ការឆ្លើយតបគ្រោះមហន្តរាយ ការការពារសកម្មភាពសេដ្ឋកិច្ច និងលំនៅដ្ឋាន តំបន់ និងការស្តារឡើងវិញ និង ការស្តារនីតិសម្បទាសហគមន៍ដែលរងការប៉ះពាល់ពីគ្រោះមហន្តរាយ ផងដែរ ។

កិច្ចការលំអិតរបស់ CFSC ខេត្ត ស្រុកមានពិពណ៌នាដូចខាងក្រោម :

- ធ្វើផែនការ និងណែនាំការអនុវត្តន៍ប្រព័ន្ធប្រកាសអាសន្នជាមុន ការឆ្លើយតបបង្ការមហន្តរាយ និងការ ផ្តួចផ្តើមគំនិតស្តារឡើងវិញ ។

- ចេញ និងប្រើឯកសារច្បាប់ស្តីពីការព្យាករណ៍ ការប្រកាសអាសន្នជាមុន ការឆ្លើយតបគ្រោះមហន្តរាយ និង ការស្តារឡើងវិញ
- សាងសង់ ធ្វើឱ្យថ្មី គ្រប់គ្រង និងការពារត្រៀមបង្ការគ្រោះមហន្តរាយ បរិក្ខារកាត់បន្ថយ និងហេដ្ឋារចនាសម្ព័ន្ធ ដូចជាdykes ទំនប់ទឹក ។ល ។
- ប្រមូល និងសំយោគព័ត៌មានស្តីពីទឹកជំនន់ ខ្យល់ព្យុះ និងគ្រោះមហន្តរាយផ្សេងៗ
- គ្រប់គ្រងថវិកាសំរាប់សកម្មភាពគ្រប់គ្រង និងកាត់បន្ថយគ្រោះមហន្តរាយ
- ធ្វើការសិក្សា និងប្រើប្រាស់បច្ចេកទេសទំនើបចុងក្រោយបំផុត ក្នុងការប្រកាសភាពអាសន្នជាមុន និង ប្រព័ន្ធព្យាករណ៍ និងនៅក្នុងការកាត់បន្ថយគ្រោះមហន្តរាយ និងធ្វើការបណ្តុះបណ្តាលបុគ្គលិកដែល កំពុងធ្វើការនៅក្នុងវិស័យនេះ ។
- ចែកចាយ និងផ្ទេរចំណេះដឹង បទពិសោធន៍ និងច្បាប់ នៅក្នុងការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ និង កាត់បន្ថយ គ្រោះមហន្តរាយ ។
- ធ្វើអធិការកិច្ច និងតាមដានការអនុវត្តន៍ឯកសារច្បាប់ស្តីពីការប្រកាសភាពអាសន្នជាមុន ការត្រួតពិនិត្យ ទឹកជំនន់ និងខ្យល់ព្យុះ ការស្តារការខូចខាត និងដោះស្រាយជាមួយបណ្តឹង និងការប្រកាសព័ត៌មានមិនល្អ នៅក្នុងតំបន់ ។
- ឃ្លាំមើលការវិវត្តន៍ទំនាក់ទំនងអន្តរជាតិ ។

២.៣ ដំណើរការធ្វើផែនការរបស់ **CFSC**

## ២.៣.១ ការត្រៀមបង្ការគ្រោះមហន្តរាយទូទៅ និងការកាត់បន្ថយ

ផែនការរយៈពេលវែងសំរាប់ការត្រៀមបង្ការគ្រោះមហន្តរាយទូទៅ និងការកាត់បន្ថយដែលស៊ីគ្នាទៅនឹងចរិតលក្ខណៈគ្រោះមហន្តរាយគួរតែបង្កើតឡើងដើម្បីធ្វើឱ្យការបាត់បង់ដែលអាចមានពីគ្រោះមហន្តរាយជាអប្បរមា ។ ផែនការ ទាំងនេះ គួរមើលឱ្យបានទូលំទូលាយ ទាំងនៅកំរិតថ្នាក់ជាតិ និងមូលដ្ឋាន និងប្រើប្រាស់ទាំងបច្ចេកទេសទំនើប និងចំណេះ ដឹងក្នុងស្រុក ។ កិច្ចការធ្វើផែនការ រួមមាន :

- រៀបចំ និងបង្កើតប្រព័ន្ធព័ត៌មានការផ្លាស់ប្តូរអាកាសធាតុសកល ថ្នាក់តំបន់ និងស្រុក ដំណើរការព័ត៌មាន សំរាប់ធ្វើឱ្យ ប្រសើរឡើងនូវការព្យាករណ៍ និងការប្រកាសភាពអាសន្នជាមុន ។
- បង្កើតផែនការ និងស្តង់ដារសំរាប់ការសាងសង់រចនាសម្ព័ន្ធកាត់បន្ថយទឹកជំនន់ និងការប្រើប្រាស់វិធានការ ត្រៀមបង្ការគ្រោះមហន្តរាយ ។

- រៀបចំផែនការសំរាប់ចំណាត់ថវិកាសាងសង់ dyke និង ការធ្វើឱ្យល្អប្រសើរ និងការថែទាំ ការបង្ហាប់បាតទន្លេ ការការពារ និងថែទាំព្រៃ មាត់ទន្លេ និងតំបន់មាត់សមុទ្រ។
- ផ្តល់ផែនការចំណាត់សមស្របមួយសំរាប់តំបន់លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធ និងអគារនៅតីទាំងដែល ប្រឈមមុខ នឹងគ្រោះមហន្តរាយ។
- កំណត់ឱ្យបានច្បាស់លាស់នូវមធ្យោបាយ វិធីសាស្ត្រសំរាប់ផលិតកម្មកសិកម្ម និងនេសាទដែលសមស្រប ទៅនឹង ចរិតលក្ខណៈគ្រោះមហន្តរាយក្នុងស្រុក នៅក្នុងករណីទឹកជំនន់នេះ។
- ប្រើប្រាស់វិទ្យាសាស្ត្រ និងបច្ចេកទេសជឿនលឿននៅក្នុងការអនុវត្តត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ។
- ចែកចាយ និងផ្ទេរចំណេះដឹង បទពិសោធន៍ និងនីតិកម្មទាក់ទិននឹងការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ និងការ កាត់បន្ថយគ្រោះមហន្តរាយ។
- តាមដាន និងវាយតំលៃការអនុវត្តផែនការត្រៀមបង្ការគ្រោះមហន្តរាយតាមពេលវេលា។

### ២.៣.២ ការធ្វើផែនការប្រចាំឆ្នាំសំរាប់ ការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ និងការ កាត់បន្ថយគ្រោះមហន្តរាយ

- គាំទ្រគំនិតផ្តួចផ្តើមត្រៀមបង្ការទឹកជំនន់តាមរយៈសកម្មភាពបង្ការដែលអាចរំខានដល់ការងារកាត់បន្ថយទឹកជំនន់ និងការងារផ្សេងទៀតដែលពាក់ព័ន្ធ។
- ធ្វើអធិការកិច្ច និងប៉ាន់ប្រមាណជាញឹកញាប់ពីសុវត្ថិភាពរចនាសម្ព័ន្ធកាត់បន្ថតទឹកជំនន់។ ប្រសិនបើមានការ ខូចខាត ណាមួយ ត្រូវធ្វើការជួសជុលឱ្យទាន់ពេលវេលា។ ប្រសិនបើអាជ្ញាធរមូលដ្ឋានមិនអាចដោះស្រាយការ ខូចខាតបានទេ វាត្រូវតែរាយការណ៍ទៅថ្នាក់លើ និងត្រូវជួសជុលឱ្យបានមុនរដូវភ្លៀង ឬខ្យល់ព្យុះ។
- បង្កើតផែនការសំរាប់ការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ និងការកាត់បន្ថយគ្រោះមហន្តរាយ សំរាប់តំបន់ ទាំងមូល និងសំរាប់រាល់គោលដៅ។
- រៀបចំ និងផ្តល់បរិក្ខា និងឧបករណ៍សង្គ្រោះនៅពេលមានទឹកជំនន់កើតឡើង។
- ធានាការស្តុបទុកស្បៀង ថ្នាំពេទ្យ និងភាពចាំភាច់ផ្សេងទៀតនៅតំបន់គោលដៅដែលប្រឈមនឹងទឹកជំនន់។
- រៀបចំការឆ្លើយតបគ្រោះអាសន្ន និង ក្រុមអ្នកស្ម័គ្រចិត្ត និងបណ្តុះបណ្តាលពួកគេ។

### ២.៣.៣ ការប្រកាសភាពអាសន្នជាមុន និងការសំរេចចិត្តសំរាប់ឆ្លើយតបជាបន្ទាន់ និងការត្រៀមបង្ការគ្រោះមហន្តរាយ

គណៈកម្មាធិការការត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ នៅតាមខេត្ត ក្រុង (ក្រោមការគ្រប់គ្រងផ្ទាល់របស់រដ្ឋាភិបាល) មានសិទ្ធិសំរេចចិត្តនៅក្នុងការចែកចាយការប្រកាសភាពអាសន្នជាមុន និងធ្វើការឆ្លើយ តប។ សំរាប់តំបន់ឆ្ងាយដាច់ស្រយ៉ាល នៅពេលមានតំរូវការ គណៈកម្មាធិការស្រុកត្រួតពិនិត្យទឹកជំនន់ និង ខ្យល់ព្យុះ អាចធ្វើការសំរេចចិត្ត អំពីការប្រកាសភាពអាសន្នជាមុន និងឆ្លើយតបគ្រោះមហន្តរាយ ប៉ុន្តែត្រូវរាយការណ៏ទៅគណៈកម្មាធិការខេត្ត។

គណៈកម្មាធិការស្រុក និងឃុំ ត្រួតពិនិត្យទឹកជំនន់ និងខ្យល់ព្យុះ អាចចែកចាយសារប្រកាសភាពអាសន្ន និងឆ្លើយតបនៅក្នុងតំបន់ដែលខ្លួនគ្រប់គ្រង ។ម

កិច្ចការជាក់លាក់ទាក់ទងនឹងការត្រៀមបង្ការទឹកជំនន់ មាន :

- ផ្សព្វផ្សាយព័តិមានអំពីទឹកជំនន់ និងខ្យល់ព្យុះ បង្កើត និងចែកចាយសារប្រកាសភាពអាសន្ន ប្រមូលគ្រឿងគរធនធាន និងវិធានការផ្សេងៗ។
- ធានាការទំនាក់ទំនង និងការណែនាំទៀងទាត់ ទាន់ពេលវេលា និងដោយរលូន។
- ពង្រាយកំលាំងឆ្លើយតបភាពអាសន្ន និងសំរបសំរួលការឆ្លើយតបទាន់ពេលវេលាចំពោះទឹកជំនន់។
- ការពារ និងធ្វើមុននូវការងារត្រៀមបង្ការគ្រោះមហន្តរាយដែលគំរាមកំហែង។
- ផ្តល់ជំនួយបឋមដល់អ្នករងរបួស ជំលៀសប្រជាជនចេញពីតំបន់គ្រោះថ្នាក់ និងការពារទ្រព្យសម្បត្តិរដ្ឋ និងរបស់ប្រជាជន។
- ធានាសន្តិសុខសង្គម និងសេដ្ឋកិច្ច និងសុវត្ថិភាពនៅក្នុងតំបន់រងការប៉ះពាល់។
- ណែនាំប្រជាជនក្នុងស្រុកឱ្យសំអាត និងការពារបរិដ្ឋាន និងបង្ការមេរោគ និងរោគរាតត្បាតនៅក្នុងតំបន់ដែលរងការ ប៉ះពាល់ និងនៅក្នុងតំបន់សុវត្ថិភាពដែលបានកំណត់។

### ២.៣.៤ ការស្តារ និង ស្តារនីតិសម្បទាឡើងវិញ

- ប្រមូលផ្តុំកំលាំង និងបរិក្ខាឆ្លើយតបគ្រោះអាសន្នដើម្បីសង្គ្រោះប្រជាជន និងទ្រព្យសម្បត្តិ ។
- ផ្តល់ជំនួយសង្គ្រោះនិងការគាំទ្រទាន់ពេលវេលាដល់ប្រជាជនមូលដ្ឋានឱ្យវិលត្រឡប់ទៅរកជីវភាពរស់នៅធម្មតា របស់ពួកគេវិញ តាមដែលអាចធ្វើបាន នៅក្នុងតំបន់ដែលរងការប៉ះពាល់ ។
- អនុវត្តវិធានការចាំបាច់សំរាប់ការស្តារសេដ្ឋកិច្ចក្នុងស្រុក ។
- រៀបចំការសំអាតនិងការពារបរិដ្ឋាន និងការបង្កាមេរោគ និងរោគរាតត្បាត ។
- ជួសជុលរចនាសម្ព័ន្ធកាត់បន្ថយទឹកជំនន់ (dykes ទំនប់ទឹក ។ល ។) និងអគារនានា
- ធ្វើការប៉ាន់ប្រមាណលើការបាត់បង់ និងខូចខាត ។


THE GOVERNMENT
Central Committee for Flood and Storm Control (CCFSC)
Members of the Government
Ministry of Agriculture & Rural Development
Government office
Ministry of National Defense
Ministry of Fishery
National Hydro-meteorology Center
Ministry of Investment and Planning
Ministry of Finance
Ministry of Construction
Ministry of Labor, Invalid and Social Works
Corporation of Post and Telecommunication
Ministry of Industry
Ministry of Police
Vietnam Radio Station
Vietnam Television Station
Ministry of Transportation


PROVINCIAL PEOPLE'S COMMITTEE
Provincial Committee for Flood and Storm Control (PCFSC)
Members of Provincial People's Committee
Department of Agriculture & Rural Development
The Office of Provincial People Committee
Hydro-meteorological Center
Provincial Army Command Post
Department of Police
Provincial Television and Radio Station
Department of Transportation
Department of Natural Resources & Environment
Department of Health
Department of Fishery
Department of Education and Training
Department of Electricity
Department of Post & Telecommunication
Department of Labour, Invalid and Social Works
Department of Trade
Department of Finance
Department of Investment and Planning
Department Of Construction


DISTRICT PEOPLE'S COMMITTEE
District Committee for Flood and Storm Control (DCFSC)
Members of District People's Committee
Office of Agriculture & Rural Development
Office of District People's Committee
District Army Command Post
District Police
District Television and Radio Station
Office of Transportation
Office of Natural Resources and Environment
Office of Health
Office of Fishery
Office of Education and Training
Office of Electricity
District Post Office
Office of Labor, Invalid and Social Works
Office of Trade
Office of Construction
Office of Industry
Office of Finance
Office of Investment and Planning

# ឧបសម្ព័ន្ធ ៣ : ការរៀបចំស្ថាប័នសំរាប់កាត់បន្ថយគ្រោះមហន្តរាយ នៅប្រទេសឡាវ

## ៣.១ ប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក

### ៣.១.១ ថ្នាក់ជាតិ

រដ្ឋាភិបាលឡាវ ទទួលស្គាល់ការគ្រប់គ្រងគ្រោះមហន្តរាយថាជាអាទិភាពអភិវឌ្ឍសំខាន់មួយ ដែលប្រាប់ទិសកាត់បន្ថយគ្រោះថ្នាក់ និងភាពងាយរងគ្រោះ តាមរយៈយុទ្ធសាស្ត្រត្រៀមបង្ការមានប្រសិទ្ធិភាព មានគោលបំណងកាត់បន្ថយផលប៉ះពាល់ពីមហន្តរាយធម្មជាតិ និងមហន្តរាយពីមនុស្សជាអ្នកធ្វើ ជាពិសេស នៅក្នុងតំបន់ជនបទ។ គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះមហន្តរាយ (NDMC) ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩ នៅក្រោមក្រសួង ការងារ និងសង្គមកិច្ច ជាចំណុចកណ្តាលនៃសកម្មភាពទាក់ទងនឹងការគ្រប់គ្រងគ្រោះមហន្តរាយ នៅក្នុងប្រទេស។ នាយករដ្ឋមន្ត្រី បានចេញក្រិត្យលេខ ( 158/PM ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ១៩៩៩)ជាមួយតំណាងមកពី១៣ ក្រសួង និងទីភ្នាក់ងារសំខាន់ៗ ដូចតទៅ :

| | |
|---|---|
| ១. ក្រសួង ការងារ និងសង្គមកិច្ច | ប្រធាន |
| ២. ក្រសួង កសិកម្ម និង រុក្ខាប្រម៉ាញ់ | អនុប្រធាន |
| ៣. ប្រធាន ខុទ្ទកាល័យ ក្រសួងកិច្ចការបរទេស | អនុប្រធាន |
| ៤. ប្រធាន ខុទ្ទកាល័យ ក្រសួង ការពារជាតិ | សមាជិក |
| ៥. ប្រធាន ខុទ្ទកាល័យ ក្រសួងមហាផ្ទៃ | សមាជិក |
| ៦. ប្រធាន នាយកដ្ឋានថវិកា ក្រសួងហិរញ្ញវត្ថុ | សមាជិក |
| ៧. ប្រធាន នាយកដ្ឋាន ក្រសួងទូរគមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍ និងសំណង | សមាជិក |
| ៨. ប្រធាននាយកដ្ឋានឧស្សាហកម្ម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ៩. ប្រធាននាយកដ្ឋានអនាម័យ ក្រសួងសុខាភិបាល | សមាជិក |
| ១០. ប្រធាន នាយកដ្ឋានប្រព័ន្ធផ្សព្វផ្សាយ ក្រសួងព័ត៌មាន និងវប្បធម៌ | សមាជិក |
| ១១. ប្រធាន ខុទ្ទកាល័យ ក្រសួងអប់រំ | សមាជិក |
| ១២. ប្រធានកាកបាទក្រហមឡាវ | សមាជិក |
| ១៣. ប្រធាននាយកដ្ឋានសង្គមកិច្ច | សមាជិក |

ការបង្កើត NDMC ហើយបន្ទាប់មក កំណត់ហេតុយុទ្ធសាស្ត្រសំរាប់ប្រទេស ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (លេខ 1139/MLSW ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ ២០០៣) បានជួយប្រទេសឡាវ មានប្រសិទ្ធិភាពច្រើនថែមទៀត លើ DM និងសកម្មភាពជំនួយសង្គ្រោះ។

តួនាទី និងការទទួលខុត្រូវរបស់ NDMC គឺ :

១. ទទួលខុសត្រូវការត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ ជាចំណុចកណ្តាលនៃការសំរបសំរួល សកម្មភាព DM ប្រចាំប្រទេស ។

២. រៀបចំធ្វើគោលនយោបាយ និងបង្ហាញទៅរដ្ឋាភិបាលសំរាប់ពិចារណា ។

៣. ទទួលខុសត្រូវការប្រមូលព័ត៌មាន និងទិន្នន័ ឬ គ្រោះមហន្តរាយ និងការរៀបចំរបស់ផែនការកាត់បន្ថយ ។

៤. ត្បៀងគរការគាំទ្រថវិកា ជំនួយបច្ចេកទេស និងសំភារៈពីបុគ្គល អង្គការ និងផ្នែកសាធារណៈរបស់ សកម្មភាព DM នៅក្នុង និងក្រៅប្រទេស ។

៥. ទទួលខុសត្រូវការលើកកំពស់ការយល់ដឹងជាសាធារណៈ និងសកម្មភាពអប់រំសាធារណៈជន ដើម្បីពង្រឹង ការត្រៀមបង្ការ និងកាត់បន្ថយផលប៉ះពាល់ខូចខាតនៃគ្រោះមហន្តរាយ ។

៦. ទទួលខុសត្រូវចំពោះការអនុម័តគោលគោលគំនិតការពារបរិដ្ឋាន គ្រប់គ្រងគ្រោះមហន្តរាយទៅក្នុងកម្មវិធី អប់រំ ។

៧. ទទួលខុសត្រូវចំពោះការរៀបចំសង្គ្រោះ សកម្មភាពជំនួយសង្គ្រោះ និងគំរោងកម្មវិធីផ្សេងទៀតសំរាប់ ការបង្ការ ការឆ្លើយតប ការកាត់បន្ថយដោយប្រើថវិការដ្ឋ និងជំនួយមកពីរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការឯកជន និង អង្គការនានា ។

៨. ផ្តល់អនុសាសន៏ដល់អភិបាលខេត្តដើម្បីបង្កើតគណៈកម្មាធិការខេត្ត គ្រប់គ្រងគ្រោះមហន្តរាយ និង គណៈកម្មាធិការស្រុក គ្រប់គ្រងគ្រោះមហន្តរាយ និងជួយពង្រឹងសមត្ថភាពរបស់ពួកគេ ។

ការិយាល័យជាតិគ្រប់គ្រងគ្រោះមហន្តរាយ គឺជាលេខាធិកាដ្ឋានរបស់ គណៈកម្មាធិការជាតិ គ្រប់គ្រងគ្រោះ មហន្តរាយ ហើយតួមានទី និងការទទួលខុសត្រូវរបស់វាមានកំណត់ច្បាស់លាស់ដូចតទៅ :

- ឃ្លាំមើលការសំរបសំរួល និងប្រតិបត្តិការរបស់សកម្មភាពគ្រប់គ្រងគ្រោះមហន្តរាយជាមួយទាំងដៃគូរជាតិ និងដៃគូរអន្តរជាតិ ។
- លើកកំពស់ឱ្យមានការផ្តល់យោបល់ពីអ្នកឯកទេសទៅដល់ the NDMC
- លើកកំពស់ការសំរបសំរួលជាមួយមនុស្សគោលដៅរបស់ក្រសួង និងដៃគូរ ។
- លើកកំពស់សកម្មភាពកាត់បន្ថយ និងត្រៀមបង្ការគ្រោះមហន្តរាយនៅកំរិតមូលដ្ឋាន ។

- អនុវត្តសកម្មភាពលើកកំពស់ការយល់ដឹងរបស់សហគមន៍។
- ផ្តល់ការបណ្តុះបណ្តាល ការណែនាំនិងផែនការធ្វើយ៉ាងណាឱ្យការគ្រប់គ្រងគ្រោះមហន្តរាយមាន ប្រសិទ្ធិភាព។
- បង្កើតក្រុមអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក។

### ៣.១.២ នៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់ឃុំ

#### នៅថ្នាក់ខេត្ត

អភិបាលខេត្តមានអំណាចបង្កើតគណៈកម្មាធិការខេត្ត គ្រប់គ្រងគ្រោះមហន្តរាយ គណៈកម្មាធិការស្រុក គ្រប់គ្រងគ្រោះមហន្តរាយ និងជួយពង្រឹងសមត្ថភាពរបស់ពួកគេ។ អាទិភាពរបស់គណៈកម្មាធិការខេត្ត គ្រប់គ្រងគ្រោះមហន្តរាយមាន ៖

១. បង្កើតយុទ្ធសាស្ត្រមានប្រសិទ្ធិភាពសំរាប់ការគ្រប់គ្រងគ្រោះទឹកជំនន់ និងរាំងស្ងួត។

២. ផ្តោតលើការកសាងសមត្ថភាពមន្ត្រីរដ្ឋាភិបាលថ្នាក់ខេត្ត និងបុគ្គលិករបស់ភ្នាក់ងារពាក់ព័ន្ធពីកិរិតសហគមន៍ និងការចងក្រងសហគមន៍ មានន័យថា ការលើកទឹកចិត្ត និងគាំទ្រសហគមន៍ឱ្យរៀបចំ និងចាត់វិធានការសមស្របដើម្បីការពារខ្លួន ទ្រព្យសម្បត្តិ និងសហគមន៍របស់ពួកគេទប់ទល់នឹងគ្រោះថ្នាក់។

#### នៅថ្នាក់ស្រុក ថ្នាក់មូលដ្ឋាន

នៅថ្នាក់ខេត្ត ថ្នាក់ស្រុក និងថ្នាក់មូលដ្ឋាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានបង្កើតឡើងដោយមានតំណាងពាក់ព័ន្ធរបស់ស្ថាប័នរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ គណៈកម្មាធិការខេត្ត គ្រប់គ្រងគ្រោះមហន្តរាយដឹកនាំដោយអភិបាលរង មានសមាជិកដែលជាប្រធានមន្ទីរសង្គមកិច្ចខេត្ត មន្ទីរសេវាកម្មជលធារសា និងឧត្តុនិយម មន្ទីរកសិកម្ម និងរុក្ខាប្រម៉ាញ់ មន្ទីរអប់រំ មន្ទីរសុខាភិបាល មន្ទីរឧស្សាហកម្ម មន្ទីរព័ត៌មាន មន្ទីរថវិកា មន្ទីរដឹកជញ្ជូន កងទ័ព និងកាកបាទក្រហមឡាវ។ នៅថ្នាក់ស្រុក DDMC ដឹកនាំដោយអភិបាលស្រុក។ នៅថ្នាក់ភូមិ អង្គការភាពការពារភូមិ (VPU) ត្រូវបានបង្កើតឡើងដោយមានទំនាក់ទំនងទៅនឹងគណៈកម្មាធិការអភិវឌ្ឍមូលដ្ឋាន និងស្រុក។

រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយនៅប្រទេសឡាវ មានសង្ខេបនៅក្នុងតារាងខាងក្រោម ៖

## រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ នៅប្រទេសឡាវ




## ៣.២ ដំណើរការធ្វើផែនការថ្នាក់ខេត្ត សំរាប់គ្រប់គ្រងគ្រោះមហន្តរាយ

ការរៀបចំផែនការគ្រោះមហន្តរាយថ្នាក់ខេត្ត មាននៅក្នុងឯកសារយុទ្ធសាស្ត្រសំរាប់ប្រទេសស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ គឺស្រដៀងគ្នានឹងដំណើរការដែលគេប្រើនៅក្នុងការអភិវឌ្ឍន៍ផែនការថ្នាក់ជាតិ ធានាពីដំណើរការមានការចូលរួម និងការពិគ្រោះយោបល់អ្នកពាក់ព័ន្ធ និងភាពជាម្ចាស់របស់សហគមន៍។

គណៈកម្មាធិការខេត្ត គ្រប់គ្រងគ្រោះមហន្តរាយ ទទួលខុសត្រូវចំពោះផែនការថ្នាក់ខេត្ត តាមបីដំណាក់កាលខុសៗគ្នា ដូចមានចែងខាងក្រោម :

### ***៣.២.១ ដំណាក់កាលទី១ - មុនពេលគ្រោះមហន្តរាយ***

## ក. វិធានការត្រៀមបង្ការ

### ការប៉ាន់ប្រមាណគ្រោះថ្នាក់

- កំណត់ ប៉ាន់ប្រមាណ និងតាមដានគ្រោះភ័យ គ្រោះថ្នាក់ជាសក្តានុភាព និងភាពងាយរងគ្រោះ ។
- ពិពិណនាផលប៉ះពាល់ជាសក្តានុភាពលើសហគមន៍ ទ្រព្យសម្បត្តិ សេវាកម្ម សេដ្ឋកិច្ច និងបរិដ្ឋាន ។
- កំណត់ពីតម្រូវការធនធាន
- ប៉ាន់ប្រមាណភាពងាយរងគ្រោះជាទៀតទាត់ ។

### ការប្រកាសអាសន្នជាមុន

- ធ្វើកម្មវិធីអប់រំសាធារណៈជន
- ប្រកាសអាសន្នជាមុនទៅដល់សហគមន៍ដែលមានសក្តាភាពរងការប៉ះពាល់ ។

### ការទំនាក់ទំនង

- បង្កើតទំនាក់ទំនងមានប្រសិទ្ធិភាពរវាង NDMO និងមជ្ឈមណ្ឌលជាតិ ប្រតិបត្តិកាគ្រោះអាសន្ន (OEC)
- បង្កើត និងសាកល្បង EOC ថ្នាក់ខេត្ត
- កំណត់ប្រព័ន្ធគាំទ្រការទំនាក់ទំនងដែលមានទាំងអស់ ( រដ្ឋ និងផ្នែកឯកជន)
- បង្កើតប្រព័ន្ធគាំទ្រការទំនាក់ទំនងគ្រោះអាសន្ន

## ខ. ការប្រើប្រាស់ធនធានដែលមាន

### បុគ្គលិក

- កំណត់ និងកត់ត្រាធនធានមនុស្សទាំងអស់ដែលមាននៅក្នុងរដ្ឋាភិបាលថ្នាក់ខេត្ត
- បញ្ជាក់ឱ្យច្បាស់ពីតួនាទី និងមុខងាររបស់សមាជិក PDMC ភ្នាក់ងារ និងអង្គការផ្សេងៗ
- កំណត់តំរូវការបណ្តុះបណ្តាល
- ធ្វើកម្មវិធីបណ្តុះបណ្តាលទៀតទាត់ ។

### ចលភាព

- កំណត់មធ្យោបាយដឹកជញ្ជូនដែលមាននៅពេលគ្រាអាសន្ន
- កំណត់ផ្លូវសង្គ្រោះ និងជំលៀស
- កំណត់ និងរៀបចំឃ្លាំងសំរាប់ធនធានគាំទ្រថ្នាក់ជាតិ ។

### ការជំលៀស

- កំណត់ និងរៀបចំចំណុច និងតំបន់ជំលៀស

- ស្តុបទុកជំនួយសង្គ្រោះសំខាន់ៗ
- កំណត់ចំណុច និងតំបន់ចែកចាយជំនួយសង្គ្រោះ ។
- រៀបចំបញ្ជីរធនធានក្នុងស្រុកដែលមាន ។

**សំភារៈ និងឧបករណ៏**

- រៀបចំបញ្ជីរធនធាននៅតាមខេត្ត ស្រុក និងតាមមូលដ្ឋាន ។

**គ. ការបណ្តុះបណ្តាល ការលើកកំពស់ការយល់ដឹងជាសាធារណៈ និង ការអប់រំ**

- កំណត់តំរូវការបណ្តុះបណ្តាលការគ្រប់គ្រងគ្រោះមហន្តរាយ
- បង្កើត និងរក្សាកម្មវិធីបណ្តុះបណ្តាលការគ្រប់គ្រងគ្រោះមហន្តរាយមានប្រសិទ្ធិភាព
- បង្កើត និងអនុវត្តកម្មវិធីលើកកំពស់ការយល់ដឹងជាសាធារណៈ
- ណែនាំការបណ្តុះបណ្តាលការយល់ដឹងពីគ្រោះមហន្តរាយនៅតាមសាលារៀន
- បង្កើត និងផ្សព្វផ្សាយព័តិមានការយល់ដឹងអំពីគ្រោះមហន្តរាយ

### *៣.២.២ ដំណាក់កាលទី ២ - ការឆ្លើយតបគ្រោះអាសន្ន*

តំរូវការគ្រប់គ្រងការឆ្លើយតបសំរាប់ដំណាក់កាលគ្រោះអាសន្ន ទាក់ទងនឹងការរួមសាមគ្គីគ្នានៅក្នុងបណ្តាញសមាហរណកម្មអង្គការរបស់ភ្នាក់ងារជាច្រើនដែលអាចចាត់វិធានការសមស្រប និងទាន់ពេលវេលាសំរាប់សកម្មភាពដូចតទៅ :

ការបញ្ជារ ការត្រួតពិនិត្យ និង ការសំរបសំរួល

- ធានាពីភ្នាក់ងារទីមួយ និងភ្នាក់ងារគាំទ្រ គឺស្ថិតនៅក្នុងគំរូប្រចាំការ ឬត្រូវបានជូនដំណឹង និងឆ្លើយតបគ្រោះអាសន្ន ។
- ធានាការត្រួតពិនិត្យមានប្រសិទ្ធិ ត្រូវបានបង្កើតឡើងនៅកន្លែងគ្រោះអាសន្ន ។
- ធ្វើឱ្យមជ្ឈមណ្ឌលប្រតិបត្តិការគ្រោះអាសន្នថ្នាក់ខេត្តមានដំណើរ (EOC)
- ធានាការសំរបសំរួលធនធាន និង សេវាកម្មសមស្រប ។
- បញ្ជូនរបាយការណ៏ព័តិមានទៀងទាត់ទៅ NDMO
- ធានាថា មានការគិតគូរប្រកាសអាសន្នឱ្យសហគមន៏ដឹងសំរាប់បង្កើតនីតិវិធីគ្រប់គ្រងការខូចខាត ។
- គិតគូរពីតំរូវការសំរាប់ជំនួយអន្តរជាតិ ។

**ការស្វែងរក និង ការសង្គ្រោះ**

- ធ្វើប្រតិបត្តិការស្វែងរក និងសង្គ្រោះតាមការចាំបាច់ ។

**ការជំលៀស និងជំនួយសង្គ្រោះ**

- ដំណើរការចំណុច និងតំបន់ជំលៀស និងបែងចែកការផ្គត់ផ្គង់ជំនួយសង្គ្រោះ
- ផ្តល់ជំនួយសង្គ្រោះ និងផ្គត់ផ្គង់ថ្នាំពេទ្យដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ ។
- ធ្វើសកម្មភាពស្តារនីតិសម្បទាឡើងវិញ ។

**ការស្តារឡើងវិញ**

- កំណត់សេចក្តីត្រូវការបន្ទាន់របស់សហគមន៍ និងបុគ្គល
- បង្កើតផែនការស្តារឡើងវិញផ្អែកលើតំរូវការសហគមន៍ និងអាទិភាព
- អនុវត្តការរៀបចំគ្រប់គ្រងការស្តារឡើងវិញដែលបានព្រមព្រៀងគ្នា តាមការចាំបាច់
- រៀបចំរបាយការណ៍ប៉ាន់ប្រមាណការខូចខាត ។

**៣.២.៣ ដំណាក់កាលទី៣ - ដំណាក់កាលក្រោយគ្រោះមហន្តរាយ**

នៅពេលស្ថានភាពគ្រោះអាសន្នត្រូវបានគ្រប់គ្រង សកម្មភាពក្រោយគ្រោះមហន្តរាយ គួរតែអនុវត្តសកម្មភាពដូចតទៅនេះ :

- ការផ្តល់ជំនួយសង្គ្រោះ និងសេវាកម្មស្តារឡើងវិញ តាមភាពចាំបាច់
- ការផ្តល់ជំនួយស្តារឡើងវិញ និងការស្តារនីតិសម្បទាដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ
- ការចុះបញ្ជីរសារពើភ័ណ្ឌធនធាន
- ការធ្វើរបាយការណ៍វាយតំលៃ និងការអនុវត្តន៍យុទ្ធសាស្ត្រធ្វើឱ្យល្អប្រសើរឡើង ។

**ដំណើរការពិនិត្យផែនការឡើងវិញ**

គណៈកម្មាធិការខេត្ត គ្រប់គ្រងគ្រោះមហន្តរាយ ទទួលខុសត្រូវចធានាថា ផែនការថ្នាក់ខេត្ត ត្រូវបានសាកល្បងលើមូលដ្ឋានទៀងទាត់ ដែលអាចធ្វើបាន និងមានប្រសិទ្ធិភាព ហើយការពិនិត្យឡើងវិញក្រោយពេលគ្រោះមហន្តរាយនោះ មានភាពល្អិតល្អន់ និងត្រឹមត្រូវ និងអនុវត្តតាមផែនការ ។

# ជំពូកទី ៥

## ឯកសារយោងរបស់ស្ថាប័ន

## សំរាប់ធ្វើផែនការត្រៀមបង្ការទឹកជំនន់

# ឯកសារយោងរបស់ស្ថាប័ន សំរាប់ធ្វើផែនការត្រៀមបង្ការទឹកជំនន់

## ៥.១ ទិដ្ឋភាពរួម

ជំពូកនេះ
ពិភាក្សាអំពីឯកសារយោងរបស់ស្ថាប័នសំរាប់ការត្រៀមបង្ការទឹកជំនន់និងអំពីសារៈសំខាន់របស់វា ចំពោះការបែងចែកការងារនៅក្នុងចំណោមស្ថាប័នផ្សេងៗ ដើម្បីធានាបាននូវគុណភាពនិងប្រសិទ្ធភាព។ នៅទីបញ្ចប់ នៃឯកសារយោងរបស់ផ្នែកនេះ គឺបានគូសបញ្ជាក់ពី តួនាទី ភារកិច និងការទទួលខុសត្រូវរបស់ស្ថាប័ន គ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុក ព្រមទាំងមន្ទីរ និងក្រុមការងារដូចបានកំណត់យ៉ាងលំអិត នៅក្នុងការអនុវត្តន៏សំរាប់០៣ដំណាក់កាលៈ មុនពេលទឹកជំនន់ ក្នុងអំឡុងពេល និង ក្រោយពេលទឹកជំនន់។

## ៥.២ គោលបំណង

- ស្វែងយល់ពីអ្វីជាឯកសារយោងខុសៗគ្នា សំរាប់ក្រុម
និងភ្នាក់ងារពាក់ព័ន្ធនៅក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់
- កំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ក្រុម- ភ្នាក់ងារនីមួយៗ និង
របៀបប្រតិបត្តិនៅក្នុង០៣ដំណាក់កាល នៃការគ្រប់គ្រង
គ្រោះទឹកជំនន់ ខាងលើ។

## ៥.៣ គោលគំនិតសំខាន់ៗ

- ឯកសារយោងបំរើជាឧបករណ៏មូលដ្ឋានមួយពន្យល់ការធ្វើប្រតិបត្តិការ និងការទទួលខុសត្រូវរបស់ភ្នាក់ងារការដឹកនាំ និងគាំទ្រ ដែលត្រូវចូលរួមនៅក្នុងការត្រៀមបង្ការ និងឆ្លើយតប លើបញ្ហាទឹកជំនន់។
- ឯកសារយោងលំអិតពីដំណើរការការងារដែលត្រូវធ្វើ ឬធ្វើតាមសំរាប់សកម្មភាពត្រៀមបង្ការ និងឆ្លើយតប។ ទន្ទឹមនឹងនោះដែរ ឯកសារនៅបានចងក្រងពីរបៀបអនុវត្តកម្មភាពផងដែរ។
- តំលៃនៃឯកសារយោង គឺមានដែនកំណត់មួយ ប្រសិនបើមិនចងក្រងជាឯកសារឱ្យបានត្រឹមត្រូវនោះ។ ម្យ៉ាងវិញទៀត ឯកសារ យោងដែលសរសេរបានល្អបំផុត និងបរាជ័យ ប្រសិនបើវាមិនត្រូវបានគេអនុវត្តដោយការប្រុងប្រយ័ត្នទេនោះ។
- នៅកំរិតខេត្ត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងសមាជិករបស់ខ្លួន គួរតែមានតួនាទី និងការទទួលខុសត្រូវ ជាក់លាក់ និងមានចងក្រងទុកជាឯកសារបានសព្វគ្រប់
ជាមួយធនធានមនុស្សដែលបានកំណត់ ដើម្បីអនុវត្តសកម្មភាពទៅតាម ឯកសារយោងពាក់ព័ន្ធ។

## ៥.៤ ផ្នែកសំខាន់នៃតើឯកសាយោងរបស់ស្ថាប័ន គឺជាអ្វី?

ឯកសារយោងរបស់ស្ថាប័ន គឺជាការកំណត់នូវការណែនាំសំរាប់ភ្នាក់ងារ អង្គការ នាយកដ្ឋាន ក្រុម ដែលនិយាយអំពី សកម្មភាព សហការដែលត្រូវធ្វើដោយភ្នាក់ងារ នៅក្នុងកំឡុងពេល និងក្រោយពេល គ្រោះមហន្តរាយ ។ គោលបំណងនៃការបង្កើត ឯកសារយោងរបស់ស្ថាប័ន គឺដើម្បីធានាជំនួយទាន់ពេលវេលា និងមានប្រសិទ្ធិភាពចំពោះសហគមន៍ដែលរងការប៉ះពាល់ ក្នុងលក្ខណៈ សហការ ធានាការការពារអាយុជីវិត ទ្រព្យសម្បត្តិ និងសុខភាព ជាអតិប្បរមា ។

## ៥.៥ ហេតុអ្វីបានជាឯកសារយោងរបស់ស្ថាប័នមានសារៈសំខាន់?

ឯកសារយោងរបស់ស្ថាប័ន គឺជាកត្តានាំផ្លូវសំរាប់ការអនុវត្តន៏កម្មវិធីត្រៀមបង្ការទឹកជំនន់ជោគជ័យ ពីព្រោះវាកំណត់ជាមុន នូវសកម្មភាពអាទិភាព និងរបៀបដែលភ្នាក់ងារនីមួយៗ ត្រូវតែ និងអាចឆ្លើយតប ចំពោះស្ថានភាពទឹកជំនន់ ចាប់តាំងពីពេលដែល ឯកសារយោងចែងយ៉ាងច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ភ្នាក់ងារនីមួយៗ នៅក្នុងការត្រៀមបង្ការទឹកជំនន់ និងគ្រប់គ្រង គ្រោះថ្នាក់ ។

នៅថ្នាក់ខេត្ត ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយខេត្តមានអាណត្តិរៀបចំគោលការណ៏ និងបទបញ្ជារសំរាប់ឱ្យស្រុកសំរប សំរួលសកម្មភាពត្រៀមបង្ការទឹកជំនន់មុនរដូវទឹកឡើង ។ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយស្រុក នៅពេលដែលទទួលបានបទបញ្ជារពី អាជ្ញាធរខេត្ត នឹងចេញបទបញ្ជារជាបន្តទៅដល់ថ្នាក់ឃុំ (សកម្មភាពមានចែងច្បាស់នៅក្នុងបទបញ្ជារថ្នាក់ខេត្ត) និងចេញពីថ្នាក់ឃុំ ទៅភូមិ ។

## ៥.៦ ផ្នែកសំខាន់នៃ SOP

ខាងក្រោមនេះ គឺជាគំរូឯកសារយោងល្អបំផុតរបស់ប្រទេសកម្ពុជា ស្តីពីការរៀបចំបង្កើតសមាសភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត និងស្រុក ក៏ដូចជា តួនាទី-ភារកិច និងការទទួលខុសត្រូវទាក់ទិនទៅនឹងសកម្មភាពត្រៀមបង្ការ ទឹកជំនន់ ខេត្តព្រៃវែង នាឆ្នាំ២០០៦ :

***តួនាទី និង ការទទួលរបស់ក្រុមគ្រប់គ្រងគ្រោះមហន្តរាយខេត្ត***

| ក្រុម ស្រាវជ្រាវ និង សង្គ្រោះបន្ទាន់ | |
|---|---|
| ***សមាជិក*** | ***តួនាទី និង ការទទួលខុស*** |
| ១. ប្រតិបត្តិកាសីកខេត្ត<br>២. ប៉ូលីសខេត្ត<br>៣. កងអាវុធហត្ថខេត្ត | • តាមដានស្ថានភាពនិងឥទ្ធិពលទកជំនន់ដើម្បីត្រៀមបង្ការ និងឆ្លើយតបមានប្រសិទ្ធិភាព<br>• ផ្តល់ជំនួយដល់ប្រជាជនងាយរងគ្រោះ និងជនរងគ្រោះ |

| | |
|---|---|
| ៤. មន្ទីរសុខាភិបាលខេត្ត<br>៥. មន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត<br>៦. មន្ទីរអប់រំ យុវជន និងកីឡាខេត្ត<br>៧. មន្ទីរហិរញ្ញវត្ថុខេត្ត<br>៨. សាខាកាកបាទក្រហមខេត្ត<br>៩. អាជ្ញាធរអគ្គិសនីខេត្ត<br>១០. មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត<br>១១. មន្ទីរព័ត៌មានខេត្ត<br>១២. អង្គការផ្សេងៗ | • កំណត់រកប្រជាជនងាយរងគ្រោះបំផុតដែលរស់នៅក្នុង ក្នុងតំបន់គ្រោះថ្នាក់ខ្ពស់<br>• ផ្តល់ជំនួយដល់ក្រុមផ្សេង និងក្រុមស្វែងរក និង សង្គ្រោះ តាមការចាំបាច់<br>• ផ្តល់សន្តិសុខដល់ជនរងគ្រោះរស់នៅក្នុងតំបន់ សុវត្ថិភាព និងការពារទ្រព្យសម្បត្តិរបស់ពួកគេ<br>• សង់និងចាត់ចែងជំរកបណ្តោះអាសន្នលើតំបន់សុវត្ថិភាព<br>• ចែករំលែកព័ត៌មានពាក់ព័ន្ធជាមួយក្រុមផ្សេង ភ្នាក់ងារ និងអង្គការក្រៅរដ្ឋាភិបាល<br>• សហការជាមួយអង្គការផ្សេងៗក្នុងការសំរបសំរួល ជំលៀសជនរងគ្រោះ<br>• សំរបសំរួល និងការពារមធ្យោបាយដឹកជញ្ជូន សំរាប់ ជំនួយសង្គ្រោះគ្រោះអាសន្ន<br>• កំនត់ឧបករណ៍ និងសំភារៈសំរាប់ការជំលៀស និង សំរាប់សកម្មភាពស្វែងរក និងសង្គ្រោះ<br>• ចែករំលែកព័ត៌មាន បទពិសោធន៍ និងមេរៀនជាមួយ សមាជិក PCDM ទាំងអស់ និងចូលរួមប្រជុំពិភាក្សា ក្រោមការត្រួតពិនិត្យមើលរបស់ PCDM<br>• អនុវត្តភារៈកិច្ចផ្សេងៗដូចបានកំន់នៅក្នុងផែនការ ត្រៀមបង្ការទឹកជំនន់ ។ |

| **ក្រុម សុខភាព អនាម័យ និង ទឹកស្អាត** | |
|---|---|
| ***សមាជិក***<br>១. មន្ទីរសុខាភិបាលខេត្ត<br>២. មន្ទីរបរិដ្ឋានខេត្ត<br>៣. មន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត<br>៤. មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទខេត្ត<br>៥. មន្ទីរធនធានទឹកខេត្ត<br>៦. មន្ទីរផែនការខេត្ត<br>៧. មន្ទីរហិរញ្ញវត្ថុខេត្ត<br>៨. មន្ទីរសង្គមកិច្ចខេត្ត<br>៩. មន្ទីរអភិវឌ្ឍជនបទខេត្ត<br>១០. មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល<br>១១. សាខាកាកបាទក្រហមខេត្ត<br>១២. អង្គការផ្សេងៗ | ***តួនាទី និង ការទទួលខុសត្រូវ***<br>• ផ្តល់ការអប់រំសុខភាព ការចែកចាយព័ត៌មាន (អំពីការ ថែទាំសុខភាព អនាម័យ ទឹកស្អាត) និងបង្ការការឆ្លង មេរោគដែលកើតពីទឹក<br>• រៀបចំការបណ្តុះបណ្តាលសង្គ្រោះបឋមដល់ក្រុម ស្វែង រក និងសង្គ្រោះ និងក្រុមអ្នកស្ម័គ្រចិត្តតាម សហគមន៍<br>• ផ្តល់ជំនួយពេទ្យពេលគ្រោះអាសន្ន និងការព្យាបាល (ឧ. ពស់ចឹក គ្រោះថ្នាក់ ។ល ។)<br>• តាមដានស្ថានភាពសុខភាពលើអនាម័យ ទឹកស្អាត និងមូលហេតុជាសក្តានុភាពនៃមេរោគកើតពីទឹក ដែល អាចបណ្តាលមកពីគ្រោះថ្នាំផ្សេងៗ<br>• ប៉ាន់ប្រមាណឥទ្ធិពល និងតំរូវការលើការថែទាំសុខភាព និងជំងឺ<br>• ធ្វើរបាយការណ៏ស្ថានភាពដាក់ជូនទៅ PCDM និង សមាជិក<br>• សហការ និងសំរបសំរួលជាមួយអង្គការពាក់ព័ន្ធ ដើម្បី ផ្តល់ការថែទាំសុខភាពដល់ជនរងគ្រោះ<br>• ចែករំលែកព័ត៌មាន បទពិសោធន៏ និងមេរៀនជាមួយ សមាជិក PCDM និងចូលរួមប្រជុំពិភាក្សា ក្រោមការ ត្រួតពិនិត្យមើលរបស់ PCDM<br>• អនុវត្តភារកិច្ចដូចបានកំនត់នៅក្នុងផែនការត្រៀម បង្ការ ទឹកជំនន់ខេត្ត ។ |

| **ក្រុម គ្រប់គ្រងពតិមាន** | |
|---|---|
| ***សមាជិក***<br>១. មន្ទីរធនធានទឹកខេត្ត<br>២.មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទខេត្ត<br>៣. មន្ទីរព័ត៌មានខេត្ត | ***តួនាទី និង ការទទួលខុសត្រូវ***<br>• តាមដានស្ថានភាព និងឥទ្ធិពលទឹកជំនន់<br>• ចែកចាយ- ផ្សព្វផ្សាយការព្យាករណ៏ទឹកជំនន់និងប្រកាស |

| | |
|---|---|
| ៤. មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត<br>៥. មន្ទីរសុខាភិបាលខេត្ត<br>៦. មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត<br>៧. មន្ទីរផែនការខេត្ត<br>៨. មន្ទីរហិរញ្ញវត្ថុខេត្ត<br>៩. មន្ទីរអភិវឌ្ឍជនបទ<br>១១. មន្ទីរអប់រំ យុវជន និងកីឡា<br>១២. សាខាកាកបាទក្រហមខេត្ត<br>១៣. អង្គការផ្សេងៗ | ភាពអាសន្នអំពីព័ត៌មានទឹកជំនន់ជាមុន<br>• ប៉ាន់ប្រមាណការខូចខាតនិងតំរូវការរបស់សក្នុងកំឡុងពេល និងក្រោយពេលទឹកជំនន់<br>• រក្សារនិងធ្វើឱ្យទិន្នន័យគ្រោះមហន្តរាយថ្មី<br>• សហការនិងសំរបសំរួលជាមួយអង្គការពាក់ព័ន្ធក្នុងការប៉ាន់ ប្រមាណការខូចខាតនិងតំរូវការរបស់<br>• ប្រមូលនិងចងក្រងព័ត៌មានអំពីក្រុមងាយរងគ្រោះបំផុត និងតំបន់ប្រឈមនឹងទឹកជំនន់នៅតាមខេត្ត<br>• សហការជាមួយក្រុមផ្សេង តាមការចាំបាច់<br>• ចូលរួមកិច្ចប្រជុំពិភាក្សានិងចែកព័ត៌មានបទពិសោធន៍ជាមួយ សមាជិកមន្ទីរ PCDM និងអង្គការ អ្នកពាក់ព័ន្ធផ្សេងទៀត<br>• ធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងជាសាធារណៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលមានស្រាប់នៅតាមខេត្ត<br>អនុវត្តភារកិច្ចផ្សេងទៀតដូចបានកំនត់ច្បាស់នៅក្នុងផែនការត្រៀមបង្ការទឹកជំនន់ |
| **ក្រុម ប្រតិបត្តិការ ឆ្លើយតបសង្គ្រោះបន្ទាន់** | |
| ***សមាជិក*** | ***តួនាទី និង ការទទួលខុសត្រូវ*** |
| ១. សាខាកាកបាទក្រហមខេត្ត<br>២. មន្ទីរសង្គមកិច្ចខេត្ត<br>៣. មន្ទីរសុខាភិបាលខេត្ត<br>៤.មន្ទីរកិច្ចការនារី និងអតីតយុទ្ធជនខេត្ត<br>៥. មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត<br>៦. មន្ទីរហិរញ្ញវត្ថុខេត្ត<br>៧. មន្ទីរពាណិជ្ជកម្មខេត្ត<br>៨. មន្ទីរធម្មការ និងសាសនា<br>៩. មន្ទីរអប់រំ យុវជន និងកីឡា | • តាមដានព័ត៌មាននិងរាយការណ៍អំពីស្ថានភាពនិងឥទ្ធិពលទឹកជំនន់<br>• ប្រមូលព័ត៌មាននិងរបាយការណ៍ពីក្រុមផ្សេងដើម្បីពិនិត្យ<br>ឡើងវិញនូវលទភាពក្នុងការចែកចាយជំនួយសង្គ្រោះពេល មានភាពអាសន្ន<br>• ប៉ាន់ប្រមាណតំរូវការរបស់ជនរងគ្រោះដើម្បីធ្វើការសំរេច ចិត្តក្នុងការផ្តល់ជំនួយសង្គ្រោះភាពអាសន្ន<br>• ប្រមូលព័ត៌មាននិងទិន្នន័យអំពីជនរងគ្រោះនៅក្នុង |

| | |
|---|---|
| ១០.អង្គភាពរតនាគារខេត្ត<br>១១. ធនាគារខេត្ត<br>១២. អង្គការផ្សេងៗ | តំបន់<br>សុវត្ថិភាពនិងជ្រើសរើសអ្នកទទួលផលសំរាប់ការបែងចែក ជំនួយសង្គ្រោះភាពអាសន្ន<br>• ចាត់ចែងនិងរក្សាសំភារៈជំនួយសង្គ្រោះ<br>• ផ្តល់ការដឹកជញ្ជូននិងចែកសំភារៈជំនួយសង្គ្រោះដល់ជនរងគ្រោះ<br>• ទំនាក់ទំនងនិងអំពាវនាវទៅអង្គការមនុស្សធម៌និងសប្បុរសនិង អង្គការផ្សេងៗឱ្យគាំទ្រនិងបរិច្ចាក។<br>• សំរបសំរួលនិងប្រាប់ទីតាំងរបស់ជនរងគ្រោះទៅទីភ្នាក់ងារមនុស្សធម៌និងសប្បុរសដែលប្តេជ្ញាផ្តល់ជំនួយសង្គ្រោះបន្ថែម<br>• តាមដានស្ថានភាពនិងតំរូវការរបស់ជនរងគ្រោះបន្ថែម<br>• ចូលរួមក្នុងកិច្ចប្រជុំពិភាក្សានិងចែកព័ត៌មានបទពិសោធន៍ជាមួយសមាជិកមន្ទីរ PCDM និង អង្គការ អ្នកពាក់ព័ន្ធផ្សេងៗ<br>• អនុវត្តភារកិច្ចផ្សេងទៀតដូចបានកំនត់ច្បាស់នៅក្នុងផែនការ ត្រៀមបង្ការទឹកជំនន់។ |

***ឯកសារយោង សំរាប់ មន្ទីរនីមួយៗ***

| ***ការត្រៀមបង្ការ (មុន)*** | ***ការឆ្លើយតប (កំឡុងពេល)*** | ***ការជួសជុល និងស្តារឡើងវិញ (ក្រោយ)*** |
|---|---|---|
| **មន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទខេត្ត** | | |
| ១.ផ្តល់មតិនិងអនុសាសន៍លើការផ្លាស់ ប្តូរការរុះរើកម្មវិធី<br>នៃគំរូដោះស្រាយ<br>២.ផ្តល់ការចាក់ថ្នាំបង្ការសំរាប់សត្វ<br>៣.សង្កេតជលធារសានិងរាយការណ៍ទៅក្រសួងកសិកម្ម | ១. ជ្រើសតាំងបុគ្គលិកសំរាប់តាមដានទឹកជំនន់រយៈពេល២៤លើ២៤ម៉ោង<br>២. ផ្តល់ការចាក់ថ្នាំបង្ការសំរាប់សត្វ<br>៣. សង្កេតជលធារសានិងរាយ | ១. ធ្វើរបាយការណ៍អំពីការខូចខាតនិងតំរូវការហើយដាក់ជូនទៅ PCDM និង MOWRAM<br>២. លើកទឹកចិត្តកសិករឱ្យដាំដុះឡើងវិញ |

| | ការណ៏ទៅមន្ទីរខេត្តដែលពាក់ព័ន្ធ | |
|---|---|---|
| **មន្ទីរធនធានទឹកខេត្ត** | | |
| ១.តាមដានកំរិតទឹក<br>២.ត្រៀមឧបករណ៏( ម៉ាស៊ីនបូមទឹក)<br>បូមទឹកដាក់ស្រែ<br>នៅពេលខ្វះទឹក<br>៣.ជីកព្រែកនាំទឹកពីអាសស្តុកទឹកទៅតំបន់រាំងស្ងួត<br>៤. ស្នើអាជ្ញាធរមូលដ្ឋានឱ្យចែកចាយព័តិមានអំពីប្រព័ន្ធ<br>ធារាសាស្ត្រដែល ខូចខាត ។<br>៥. ត្រៀមបាវដីខ្សាច់( បង្ការទប់ទឹកចូល)<br>និងម៉ាស៊ីនបូម<br>ទឹកអន្តរាគម នៅពេល ទឹកស្រក | ១.ឆ្លើយតបតាមកំរិតទឹកជាក់លាក់ និងរាយការណ៏ទៅមន្ទីរពាក់ព័ន្ធ<br>២.ផ្តល់ម៉ាស៊ីនបូមទឹកដើម្បីបូមទឹកពីកន្លែងសាធារណៈ ដូចជាទីផ្សារជាដើម<br>៣.សហការជាមួយមន្ទីរពាក់ព័ន អង្គការនិងកាកបាទក្រហមកម្ពុជា<br>៤.ត្រួតពិនិត្យប្រព័ន្ធធារាសាស្ត្រ នៅពេលទឹកស្រក | ១.ប៉ាន់ប្រមាណការខូចខាតនិងតំរូវការ ហើយរាយការណ៏ទៅការិយាល័យខេត្តនិង MOWRAM<br>២.ប៉ាន់ប្រមាណការខូចខាត<br>ហេដ្ឋា<br>រចនាសម្ព័ន្ធនិងប្រព័ន្ធធារាសាស្ត្រ<br>៣.ចូលរួមក្នុងកិច្ចប្រជុំជាមួយ PCDM និងអង្គការពាក់ព័ន្ធផ្សេងៗ<br>៤.កំនត់ផ្នែកអាទិភាពសំរាបការ ស្តារនិតិសម្បទាឡើងវិញ<br>៥.ស្តារនិងជួសជុលឡើងវិញនូវប្រព័ន្ធធារាសាស្ត្រដែលខូចខាត<br>៦.សង់ប្រព័នធារាសាស្ត្រដែលបានអនុម័តថ្មីនិងរៀបចំផែនការសំរាប់ ឆ្នាំបន្ទាប់ |
| **មន្ទីរសុខាភិបាលខេត្ត** | | |
| ១.បង្កើតក្រុមចល័តមួយនៅតាមមណ្ឌលប្រតិបត្តិការស្រុកនិងមណ្ឌលសុខភាពដើម្បីផ្តល់ការព្យាបាលដល់ ជនរងគ្រោះ<br>២.តាមដានស្ថានភាពសុខភាពទូទៅ ឧ. តាមដានការរាតត្បាតនៃមេរោគ<br>៣.រៀបចំសំភារៈសង្គ្រោះបឋម ថ្នាំរាគនិងថ្នាំ<br>ប្រឆាំងពស់ចឹក<br>៣.ត្រៀមទូក កាណូត និងកាណូត<br>លឿនសំរាប់អន្តរាគមគ្រោះអាសន្ន<br>៤.ទំនាក់ទំនងជាមួយអង្គការពាក់ព័ន | ១. បញ្ជូនក្រុមចល័តទៅតំបន់សុវត្ថិភាព<br>២. ប៉ាន់ប្រមាណស្ថានភាពសុខភាពទូទៅ<br>៣. ត្រៀមធ្វើអន្តរាគមន៏ប្រសិនបើមានជំងឺរាតត្បាតកើតឡើង<br>៤. រាយការណ៏ទៅក្រសួងសុខាភិបាល<br>៥. ចុះតាមមូលដ្ឋានយ៉ាងហោចណាស់ម្តង | ១. ប៉ាន់ប្រមាណឥទិពលលើសុខភាព ទឹកនិងអានម័យ<br>២.ធ្វើអន្តរាគមជាបន្ទាន់នៅពេល មានជំងឺរាតត្បាត<br>៣.ធ្វើរបាយការណ៏<br>គំរោងសំណើ និងដាក់ទៅអង្គការ ភ្នាក់ងារអង្គការសហប្រជាជាតិនិងក្រសួងសុខាភិបាលសុំជំនួយបន្ថែម<br>៤. ធ្វើផែនការសំរាប់ឆ្នាំបន្ទាប់ |

| | | |
|---|---|---|
| អង្គការដៃគូរសំរាប់ការចូលរួម និង គាំទ្រ<br>៥. ចូលរួមកិច្ចប្រជុំ PCDM<br>៦. ផ្តល់ការអប់រំសុខភាពដល់សាធារណៈជន<br>៧. បណ្តុះបណ្តាលបុគ្គលិកពេទ្យនិងបុគ្គលិក សុខាភិបាល | | ៥. ប៉ាន់ប្រមាណឥទ្ធិពល និង សមិទ្ធិផល |
| **មន្ទីរសង្គមកិច្ចខេត្ត** | | |
| ១.ជួយប្រជាជនដែលរងគ្រោះខ្លាំងបំផុត<br>២.លើកកំពស់ការយល់ដឹងជសាធារណៈ<br>៣.ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ក្រុមខ្សោយ<br>៤.ជួយគ្រួសារក្រីក្រដែលមានមេគ្រួសារជាស្ត្រីមេម៉ាយ<br>៥.ប្រមូលព័ត៌មានអំពីជនរងគ្រោះ | ១. ប្រមូលនិងចែកចាយទិន្នន័យជាមួយ PCDM, NGOs និងមន្ទីពាក់ព័ន្ធ<br>២. ធ្វើសំណើគាំទ្រថវិកាសំរាប់សកម្មភាពរបស់មន្ទីរ<br>៣. ជំរុញបុគ្គលិកឱ្យចូលរួមជាមួយអង្គការផ្សេងទៀត<br>៤. ចែករំលែកធនធានមនុស្សជាមួយ PCDM | ១. ឃ្លាំមើលនិងតាមដានស្ថានភាពប្រជាជនដែលរងគ្រោះខ្លាំងបំផុត<br>២. សរុបការខូចខាតទាំងអស់ (ជីវិតមនុស្សនិងទ្រព្យសម្បត្តិ) របស់ប្រជាជនដែលរងគ្រោះខ្លាំង បំផុត<br>៣. ចំណាត់ថវិកាសំរាប់ប្រជាជនដែលរងគ្រោះខ្លាំងបំផុត |
| **មន្ទីរផែនការខេត្ត** | | |
| ១.ចាត់តាំងបុគ្គលិកឱ្យចូលរួមក្រុមស្វែងរកនិងសង្គ្រោះ របស់ PCDM.<br>២.គៀងគរធនធាន(ស្បៀង ថ្នាំពេទ្យ ការដឹកជញ្ជូន) | ១. ត្រៀមសំភារៈនិងឧបករណ៍សំរាប់ ឆ្លើយតបភាពអាសន្ន<br>២. ក្រុមទទួលខុសត្រូវចែកប្រេងឥន្ទនៈទៅតំបន់រងគ្រោះ | ១. សហការជាមួយមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់និងនេសាទ សំរាប់ចែក ស្រូវពូជ និងប្រេង<br>២. ចូលរួមក្នុងកិច្ចប្រជុំក្រោយទឹក ជំនន់ជាមួយ PCDM |
| **មន្ទីរអប់រំ យុវជន និង កីឡាខេត្ត** | | |
| ១. ប្រើព័ត៌មានទឹកជំនន់ដូចជាការប្រកាសអាសន្ន មុនដើម្បីបិទសាលារៀនជាបណ្តោះអាសន្ន<br>២. រាយការណ៍ទៅ PCDM អំពីការខូចខាតជា សក្តានុភាពចំពោះសាលារៀនដោយសារទឹកជំនន់<br>៣. ជូនដំណឹងដល់គ្រូនិងសិស្សពីការទទួលខុសត្រូវ | ១. គៀងគរធនធានមនុស្សសំរាប់ធ្វើអន្តរាគមក្នុងកំឡុងពេលទឹកជំនន់<br>២. ជូនដំណឹងអំពីទឹកជំនន់តាមរយៈវិទ្យុនិងឧបករណ៍ទំនាក់ទំនងផ្សេងទៀតដល់សាលារៀនដែល | ១. ប្រមូលព័ត៌មានសាលរៀនដែលខូចខាត<br>២.ផ្តល់ជំនួយដល់គ្រូដែលរងគ្រោះដោយទឹកជំនន់(ខ្វះស្បៀង ជំរក)<br>៣. |

| | | |
|---|---|---|
| ថែទាំសំភារៈនិងឯកសារនៅកន្លែងសុវត្ថិភាព (ឧ. នៅវត្តអារាម) កំឡុងពេលទឹកជំនន់<br>៤. ត្រៀមការដឹកជញ្ជូនជំលៀសសិស្សនិងគ្រូពីសាលារៀនទៅតំបន់សុវត្ថិភាព<br>៥. ជូនដំណឹងអំពីសាលារៀនដែលងាយរងគ្រោះតាមរយៈអេកូម និង វិទ្យុ | ស្ថិតនៅក្នុងតំបន់គ្រោះថ្នាក់ខ្ពស់ (កំពស់ទឹក)<br>៣. ប្រមូលព័ត៌មានពីសាលារៀនលិចទឹក | ប្រមូលព័ត៌មានពីឥទ្ធិពលនៃគ្រោះទឹកជំនន់លើសុខភាពរបស់ គ្រូនិងសិស្ស(ថែទាំផ្លូវចិត្ត) |
| **មន្ទីរកិច្ចការនារី និង អតីតយុទ្ធជនខេត្ត** | | |
| ១. សហការយ៉ាងជិតស្និទ្ធិជាមួយមន្ទីរពាក់ព័ន្ធ<br>២. ចែកចាយព័ត៌មានអំពីការប្រែប្រួលផលដំណាំ<br>៣. ចូលរួមក្នុងសកម្មភាពដូចជាកិច្ចប្រជុំ PCDM ការចែកចាយព័ត៌មាននិងជំនួយសង្គ្រោះបន្ទាន់ | ១. បញ្ជូនបុគ្គលិកទៅអប់រំសាធារណៈជន (ជាពិសេសស្ត្រី) អំពីការថែទាំសុខភាព អនាម័យ និងទឹកស្អាត<br>២. ចូលរួមក្នុងការជំលៀសជនរងគ្រោះ ទៅតំបន់សុវត្ថិភាព | ១. សហការជាមួយមន្ទីរពាក់ព័ន្ធ ដើម្បីអប់រំប្រជាជន<br>២. ចែកចាយព័ត៌មានអំពីការដាំដុះឡើងវិញ |
| **មន្ទីររៀបចំនគរូបនីយកម្ម ផែនការ និងសំណង់ខេត្ត** | | |
| ១. ជំរុញការិយាល័យស្រុកឱ្យចែកចាយព័ត៌មាន អំពី ការត្រៀមបង្ការទឹកជំនន់<br>២. ចំណាត់ថវិកាសំរាប់ PCDM<br>៣. សហការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីត្រៀមតំបន់សុវត្ថិភាព<br>៤. ការពារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ដូចជាផ្លូវថ្នល់ និងទំនប់ទឹក<br>៥. កំណត់រកតំបន់សុវត្ថិភាព (ថ្មីនិងមានស្រាប់) | ១. ការពារប្រជាជនមិនឱ្យទៅតំបន់និង តាមដានស្ថានភាពទឹកជំនន់ជាក់ស្តែង<br>២. បាវដីខ្សាច់<br>៣. ជួយជំលៀសប្រជាជនទៅតំបន់សុវត្ថិភាព | ១. ផ្តល់ការដឹកជញ្ជូនសំរាប់ប្រជាជនដែលវិលត្រឡប់ទៅផ្ទះវិញ ក្រោយពេលទឹកជំនន់<br>២. ការិយាល័ស្រុកត្រូវធ្វើការងារ យ៉ាងជិតស្និទ្ធិជាមួយ DCDM.<br>៣. ចូលរួមក្នុងកិច្ចប្រជុំក្រោយពេលទឹកជំនន់ PCDM |
| **មន្ទីរធម្មការ និង សាសនាខេត្ត** | | |
| ១. អប់រំព្រះសង្ឃអំពីរបៀបប្រើបរិក្ខារអនាម័យ<br>២. អប់រំព្រះសង្ឃអំពីរបៀបជៀសវាងការប្រកាន់ ពូជសាសន៍និងឥរិយាបថជ្រុលនិយម (ទាក់ទងនឹង សាសនា) ។ល។<br>៣. ចូលរួមធ្វើផែនការ PCDM | ១. ប្រមូលព័ត៌មានពីវត្តអារាមនិង<br>ប្រាសាទដែលរងការប៉ះពាល់និងខូចខាត<br>២. ជំរុលព្រះសង្ឃឱ្យចែកចាយ | ១. ជំរុញព្រះសង្ឃនិងគណៈកម្មាធិការ វត្តឱ្យថែរក្សាតំបន់សុវត្ថិភាព (សំអាត)<br>២. ដាំដំណាំក្នុងបរិវេណវត្ត<br>៣. ជួសជុលវត្តដែលរងគ្រោះ |

| | | |
|---|---|---|
| និងសកម្មភាពរំរែអង្គាស<br>ថវិកា<br>៤. រៀបចំទីធ្លាវត្តអារាមនិងប្រាសាទដែលត្រូវប្រើសំរាប់ជាតំបន់សុវត្ថិភាព | ឬផ្តល់ជំនួយជាមូលដ្ឋាន( ឧ.ចំណីអាហារ ទឹកដល់ជនរងគ្រោះ)<br>៣. ជំរុញព្រះសង្ឃនិងគណៈកម្មាធិការវត្តឱ្យទទួលថែរក្សាតំបន់សុវត្ថិភាព | ដោយគ្រោះទឹកជំនន់<br>៤. ផ្តល់ការអប់រំនិងចែកចាយព័តិមានដល់សាធារណៈជនក្នុងស្រុកអំពីការត្រៀមបង្ការនិងកាត់បន្ថយគ្រោះមហន្តរាយ |
| **កាកបាទក្រហមខេត្ត** | | |
| ១. អនុវត្តកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយសហគមន៍<br>២. ផ្តល់ការបណ្តុះបណ្តាលអំពីចលនាកាកបាទក្រហមការសង្គ្រោះបឋមរបស់សហគមន៍និងការគ្រប់គ្រងគ្រោះមហន្តរាយ<br>៣. រៀបចំកិច្ចប្រជុំប្រចាំឆ្នាំក្នុងចំណោមអ្នកពាក់ព័ន្ធ( ឃុំ ស្រុកនិងកាកបាទក្រហមខេត្ត) អំពីវិធានការត្រៀមបង្ការទឹកជំនន់<br>៤. ប្រមូលព័តិមានទឹកជំនន់និងតាមរយៈ EWS ឥទ្ធពលនៃកំរិតទឹកជំនន់ខុសៗគ្នាដែលបានកំនត់<br>៥. ផ្តល់ការអប់រំសាធារណៈអំពីការថែទាំសុខភាព អនាម័យ ទឹកស្អាត និងការធ្វើអនាម័យ | ១. ប្រមូលព័តិមានទឹកជំនន់និងឥទ្ធិពល និងប៉ាន់ប្រមាណតំរូវការ<br>២. សហការជាមួយមន្ទីរពាក់ព័ន្ធខេត្ត និងអង្គការ<br>៣. ផ្តល់ជំនួយសង្គ្រោះភាពអាសន្ន ( ដូចជាស្បៀង ទឹកស្អាតប្រេង សំលៀកបំពាក់)<br>៤. ប្រមូលព័តិមានទឹកជំនន់ជាក់ស្តែង រួមទាំងឥទ្ធិពលនិងកំរិតទឹកនៅពេលជាក់លាក់តាមរយៈគំរោង EWS<br>៥. ផ្តល់ការអប់រំជាសាធារណៈអំពីការថែទាំសុខភាព អនាម័យទឹក | ១. ស្តារនិទិសម្បទានៃហេដ្ឋារចនាសម្ព័ន្ធរងគ្រោះឡើងវិញ (ខ្ទាតតូច)<br>២. ផ្តល់ស្បៀងសំរាប់ពលកម្ម |
| **កងយោធាខេត្ត** | | |
| ១. ការពារផ្លូវថ្នល់ពីទឹកជំនន់( ឧ.បាវខ្សាច់និងការពង្រឹងទំនប់ទឹក)<br>២. ផ្តល់ការបណ្តុបណ្តាលដល់ទាហាននិងកំនត់តួនាទី និងការទទួលខុសត្រូវរបស់ទាហានដែលប្រចាំការនៅក្នុងតំបន់ប្រឈមនឹងទឹកជំនន់<br>៣. ចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ PCDM<br>៤. ចូលរួមកិច្ចប្រជុំទៀតទាត់ជាមួយ DCMD ដើម្បីផ្តល់មតិនិងអនុសាសន៍ | ១. ស្វែងរក និងសង្គ្រោះ<br>២. ជំលៀជនរងគ្រោះទៅទីសុវត្ថិភាព<br>៣. ផ្តល់សេវាសន្តិសុខដល់មន្ទីរផ្សេងដែលកំពុងធ្វើការក្នុងតំបន់រង គ្រោះ<br>៤. ជួយមន្ទីរផ្សេងទៀត<br>៥. ប៉ាន់ប្រមាណកាខូចខាតនិង | ១. សហការនិងសំរបសំរួលជាមួយ មន្ទីរពាក់ព័ន្ធខេត្តផ្សេង<br>២. ជួសជុលផ្លូវថ្នល់និងទំនប់ទឹកដែលខូចខាតឡើងវិញបើចាំបាច់<br>៣. ស្ទាបស្ទង់ការខូចខាតនិងឥទ្ធិពលទាំងអស់<br>និងប្រមូល |

| | | |
|---|---|---|
| ៥. ចូលរួមជាមួយ PCDM ក្នុងការបង្កើតផែនការ<br>៦. ត្រៀមសំភារៈចាំបាច់ ការងារ មធ្យោបាយដឹកជញ្ជូននិងសំភារៈសំរាប់អន្តរាគមគ្រោះអាសន្ន | តំរូវការ | និង ចងក្រងទិន្នន័យ |
| **កងអាវុធហត្ថខេត្ត** | | |
| ១. ចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំរបស់ PCDM<br>២. ត្រៀមក្រុមសំរាប់អន្តរាគមគ្រោះអាសន្ន<br>៣. ការពារសាលារៀននិងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗពីទឹកជំនន់<br>៤. ដាក់បាវខ្សាច់ទប់និងតាមដានមើលតំបន់ប្រឈម នឹងទឹកជំនន់<br>៥. ជំលៀសជនរងគ្រោះនិងផ្តល់ជំនួយផ្សេងៗតាមការចាំបាច់<br>៦. ផ្តល់សន្តិសុខក្នុងទីជំរកបណ្តោះអាសន្ន | ១. ដាក់បាវដីខ្សាច<br>២. ត្រៀមក្រុមសំរាប់ជំលៀសជនរងគ្រោះឬសត្វពាហនៈទៅតំបន់សុវត្ថិភាព<br>៣. ជំលៀសជនរងគ្រោះ<br>៤. ចែកជំនួយគ្រោះអាសន្ន<br>៥. ប្រើប្រាស់សំភារៈ និងឧបករណ៍ដែលមានដើម្បីសង្គ្រោះប្រជាជននិង សត្វពាហនៈ (ស្វែងរកនិងសង្គ្រោះ) | ១. រក្សាសន្តិសុខ<br>២. ប៉ាន់ប្រមាណការខូចខាតនិង តំរូវការនិងរាយការណ៍ទៅ PCDM<br>៣. ស្តារ និងស្តារនីតិសម្បទាហេដ្ឋារចនាសម្ព័ន្ធដែលខូចខាតឡើងវិញ<br>៤. ស្តុបទឹកជំនន់ទុកសំរាប់សកម្មភាពកសិកម្ម |
| **អធិការដ្ឋាននគរបាលខេត្ត** | | |
| ១. ចែកចាយព័តិមានអំពីវិធានការកាត់បន្ថយដល់ អ្នករស់នៅក្នុងស្រុក ដូចជា :<br>ក. ហាមប្រាមការដឹកទំនិញលើសចំណុះតាមទូក<br>ខ. ប្រើពោងសង្គ្រោះជីវិត<br>គ. ផ្តល់ការប្រកាសអាសន្ន ការណែនាំដល់អ្នកធ្វើដំណើរ | ១. ជួយប្រជាជនក្នុងតំបន់រងគ្រោះ<br>២. ប្រមូលទិន្នន័យនៃការខូចខាត និង ការស្លាប់<br>៣. ដាក់បាវដីខ្សាច់និងការពារទំនប់ទឹក<br>៤. ជំលៀសជនរងគ្រោះ ទ្រព្យសម្បត្តិនិងសត្វពាហនៈទៅតំបន់សុវត្ថិភាព<br>៥. អប់រំប្រជាជនពីសុខភាពនិងអនាម័យ<br>៦. ផ្តល់សន្តិសុខនៅក្នុងតំបន់សុវត្ថិភាព | ១. ផ្តល់សន្តិសុខក្នុងតំបន់សុវត្ថិភាព<br>២. សហការជាមួយ PCDM<br>៣. ប្រមូលព័តិមាននៃការខូចខាតនិងតំរូវការសំរាប់ស្តារឡើងវិញ |

| | | |
|---|---|---|
| | ៧. ជួយចែកជំនួយសង្គ្រោះភាពអាសន្ន | |
| **មន្ទីរវប្បធម៌ និង វិចិត្រសិល្បៈខេត្ត** | | |
| ១. រៀបចំតំបន់សុវត្ថិភាពដោយណែនាំពី PCDM<br>២. ជួយ PCDM ជំលៀសជនរងគ្រោះទៅកន្លែងសុវត្ថិភាព<br>៣. ត្រួតពិនិត្យនិងការពារតំបន់ប្រឈមនឹងទឹកជំនន់ ( តំបន់ប្រវត្តិសាស្ត្រនិងវប្បធម៌)<br>៤. ហាមការជីកកកាយខុសច្បាប់នៅក្នុងតំបន់សុវត្ថិភាព ( តំបន់ប្រវត្តិសាស្ត្រនិងវប្បធម៌) ដើម្បីរកវត្ថុបុរាណ | ១. ដឹកជនរងគ្រោះទៅទីសុវត្ថិភាព<br>២. ជួយដាក់បាវដីខ្សាច់និងការពារទំនប់ ទឹកឬផ្លូវថ្នល់ | ១. ប្រមូលទិន្នន័យអំពីជនរងគ្រោះដែលកំពុងរស់នៅក្នុងតំបន់សុវត្ថិភាព<br>២. ការពារតំបន់ប្រវត្តិសាស្ត្រដែល បានចុះបញ្ជីរ |
| **មន្ទីរហិរញ្ញវត្ថុខេត្ត** | | |
| ១. ចូលរួមកិច្ចប្រជុំជាមួយ PCDM<br>២. ចែករំលែកគំនិតអំពីការបង្ការគ្រោះមហន្តរាយ<br>៣. ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពរៃអង្គាសថវិកា | ១. ចូលរួមក្នុងសកម្មភាពស្វែងរកនិងសង្គ្រោះដោយសហការជាមួយមន្ទីរពាក់ព័ន្ធខេត្ត និងអង្គការ<br>២. ចែកជំនួយសង្គ្រោះភាពអាសន្ន<br>៣. រៀបចំនិងដាក់បាវដីខ្សាច់<br>៤. ចូលរួមក្នុងសកម្មភាពរៃអង្គាសថវិកា<br>៥. កៀរគរធនធានមនុស្សនៅក្នុងមន្ទីរសំរាប់ប្រតិបត្តិការស្វែងរកនិងសង្គ្រោះ | ១. ចូលរួមប្រមូលទិន្នន័យនៃការខូចខាត<br>២. ចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពស្តារឡើងវិញនិងការស្តារនីតិសម្បទាឡើងវិញ |
| **មន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត** | | |
| ១. ការពារផ្លូវថ្នល់និងស្ពាន<br>២. ត្រៀមរថយន្តធំដឹកជញ្ជូនដីនិងខ្សាច់សំរាប់ត្រៀម ធ្វើបាវដីខ្សាច់<br>៣. ហ៊ុំព័ទ្ធតំបន់ការពារ<br>៤. បង្កើតយុទសាស្ត្រត្រៀមបង្ការទឹកជំនន់យ៉ាងហោច ណាស់ឱ្យបានមួយខែមុន។ | ១. ចែកជំនួយសង្គ្រោះ<br>២. ផ្តល់ការដឹកជញ្ជូនដល់បុគ្គលិកសុខាភិបាលទៅតំបន់សុវត្ថិភាព<br>៣. ជួសជុលផ្លូវថ្នល់និងស្ពាន | ១. បង្កើតផែនការស្តារនីតិសម្បទា ហេដ្ឋារចនាសម្ព័ន្ធរួមទាំង ផ្លូវថ្នល់ ស្ពាន និងផ្លូវជាតិ |
| **មន្ទីរអភិវឌ្ឍជនបទខេត្ត** | | |

| | | |
|---|---|---|
| ១. ផ្តល់ការបណ្តុះបណ្តាលអំពីការធ្វើផែនការទាក់ ទងនឹងជំនួយសង្គ្រោះភាពអាសន្ននៅតាមសហគមន៍<br>២. សង់បង្គន់ និងអណ្តូងទឹកក្នុងតំបន់សុវត្ថិភាព<br>៣. រៀបចំវគ្គបណ្តុះបណ្តាលអំពីការសង្គ្រោះបឋម សំរាប់អ្នកភូមិ<br>៤. រៀបចំវគ្គបណ្តុះបណ្តាលសំរាប់សហគមន៍អំពីការថែទាំសុខភាពនិងអនាម័យ | ១. ចូលរួមជាមួយ PCDM<br>២. ប្រមូលព័ត៌មានទឹកជំនន់និងការខូច ខាតនិងរាយការណ៍ទៅអ្នកពាក់ព័ន្ធ<br>៣. ផ្តល់សេវាកម្មដឹកជញ្ជូននិងប្រេង<br>៤. ធ្វើសំណើរសុំនិងដាក់ទៅម្ចាស់ជំនួយ<br>៥. ផ្តល់ស្បៀងដល់ប្រជាជន | ១. ស្តារ និងជួសជុលអណ្តូងទឹកឡើងវិញ<br>២. រៀបចំវគ្គបណ្តុះបណ្តាលអំពី សង្គ្រោះបឋមសំរាប់អ្នកភូមិ<br>៣. រៀបចំវគ្គបណ្តុះបណ្តាលសំរាប់ សហគមន៍ស្តីពីការថែទាំសុខភាព និងអនាម័យ<br>៤. ស្តារ និងជួសជុលហេដ្ឋារចនា សម្ព័ន្ធដែលខូចខាតទាំងអស់ឡើង វិញ រួមទាំងផ្លូវថ្នល់ ស្ពាននិងទ្វារទឹក |
| **មន្ទីរពាណិជ្ជកម្មខេត្ត** | | |
| ១.<br>តាមដានមើលអង្ករនិងប្រេងឥន្ទនៈមានក្នុងស្តុក<br>២. ផ្តល់ជំនួយដល់អភិបាលខេត្តសំរាប់ការគ្រប់គ្រងស្បៀងនិងប្រេងឥន្ទនៈ | ១.<br>រក្សាកំនត់ហេតុនិងគ្រប់គ្រងការប្រើ អង្ករពីខាងក្រៅនិងប្រេងមកពីរោង ម៉ាស៊ីនឯកជននិងពីស្ថានីយ៍ប្រេង<br>២. ផ្តល់ជំនួយនិងការស្នើសុំទៅអភិបាលខេត្តពីការចែកទំនិញ (ស្បៀងនិង ប្រេង) | |
| **មន្ទីរព័ត៌មានខេត្ត** | | |
| ១. គ្រប់គ្រងព័ត៌មាន<br>២. ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនតាមរយៈប្រព័នផ្សព្វផ្សាយ ដូចជាវិទ្យុនិងទូរទស្សន៍ | ១.គ្រប់គ្រងព័ត៌មាន<br>២.ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនតាមរយៈប្រព័នផ្សព្វផ្សាយ ដូចជា វិទ្យុ និងទូរទស្សន៍ | ១.គ្រប់គ្រងព័ត៌មាន<br>២.ផ្សព្វផ្សាយព័ត៌មានដល់សាធារណជនតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដូចជាវិទ្យុ និងទូរទស្សន៍ |
| **មន្ទីរបរិស្ថានខេត្ត** | | |

| | | |
|---|---|---|
| ១. ចែកចាយព័ត៌មានដល់សាធារណៈជនអំពីការគ្រប់គ្រងការបំពុលទឹកទឹកនិងការសំណល់<br>២. សហការជាមួយអាជ្ញាធរមូលដ្ឋាននិងអង្គការដើម្បីចាក់ដីបំពេញជាថ្មី<br>៣. បញ្ជូនកាកសំណល់ទៅតំបន់ឆ្ងាយដាច់ស្រយាល ពីតំបន់លំនៅដ្ឋាន។ | ១. លើកកំពស់ការយល់ដឹងអំពីការបោះ ចោលនិងគ្រប់គ្រងកាកសំណល់<br>២. ជំរុញឱ្យក្រុមហ៊ុនឯកជនដឹកកាក សំណល់ទៅចាក់បំពេញដី | ១. លើកកំពស់ការយល់ដឹងជាសាធារណៈអំពីការបោះចោលនិងការគ្រប់គ្រងកាកសំណល់<br>២. ផ្តល់ឱវាទអាជ្ញាធរមូលដ្ឋាននិងអង្គការអំពីការគ្រប់គ្រងកាកសំណល់<br>៣. តាមដានការអនុវត្តន៍ការគ្រប់គ្រងកាកសំណល់នៅតាមផ្ទះនិងផ្តល់អនុសាសន៍។ |

*ប្រភពពិតមាន : កម្មវិធីត្រៀមបង្ការទឹកជំនន់ខេត្តព្រៃវែង ឆ្នាំ២០០៦*

## ៥.៧ សំណួរសំរាប់ការពិចារណា

១.តើឯកសារយោងរបស់ស្ថាប័ន គឺជាអ្វី? ហេតុអ្វីបានជាគេចាត់ទុកថាវាមានសារៈសំខាន់?

២.ដើម្បីត្រៀមរៀបបង្ការទឹកជំនន់ តើក្រុមគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងមន្ទីរពាក់ព័ន្ធ ត្រូវមានតួនាទីភារកិច និង ការទទួលខុសត្រូវអ្វីខ្លះ?

១. តើអ្នកដឹងថាមានការប្រឈមមុខសំខាន់ៗអ្វីខ្លះ នៅក្នុងដំណាក់កាលឆ្លើយតបបន្ទាន់នៃគ្រោះទឹកជំនន់ ដើម្បីធានាថា តួនាទី ភារកិច និងការទទួលខុសត្រូវ ត្រូវបានរៀបចំតាមលំនាំនៃឯកសារយោងមកខាងលើ?

២. តើស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយណាមួយ ដែលគួរបង្កើតឱ្យមានឯកសារយោងសំរាប់ការកាត់បន្ថយគ្រោះទឹកជំនន់?

## ៥.៨ សេចក្តីយោង


- DMB : ប្រទេសបង់ក្លាដេស(១៩៩៩) បទដ្ឋាន ស្តីពីការត្រៀមបង្ការគ្រោះមហន្តរាយផ្សេងៗ
- NIDM ឥណ្ឌា(២០០៥) : ផែនការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក(DDMP): ឯកសារគំរូ

# ជំពូកទី ៦

## វិធានការកាត់បន្ថយគ្រោះទឹកជំនន់ដែលត្រូវអនុវត្ត
## នៅមុនពេល ក្នុងពេល និង ក្រោយពេលទឹកជំនន់

# វិធានការកាត់បន្ថយគ្រោះទឹកជំនន់ដែលត្រូវអនុវត្ត នៅមុនពេល ក្នុងពេល និង ក្រោយពេលទឹកជំនន់

## ៦.១ ទិដ្ឋភាពរួម

ជំពូកនេះថ្លែងអំពីបច្ចេកទេសសង្ខេបស្តីពីវិធានការធ្វើឱ្យឥទ្ធិពលផ្ទុយគ្នាពេលពេលមុន ក្នុងកំឡុងពេល និងក្រោយពេលទឹកជំនន់កើតឡើង ទៅជាអប្បរមា។ ទាំងអស់នេះ រួមមាន វិធានការគ្រប់គ្រងទឹកជំនន់ ដូចជា វិធានការត្រៀមបង្ការ ប្រតិបត្តិការឆ្លើយតប ការស្តារឡើងវិញ ការស្តារនីតិសម្បទា និងវិធានការកាត់បន្ថយទឹកជំនន់។ វានឹងសំរបសំរួលការយល់ដឹងរបស់អ្នកធ្វើផែនការដែលកំពុងធ្វើការនៅក្នុងតំបន់ និងបង្កើតជាវិសាលភាពកម្រងបញ្ហានៃកម្មវិធីកាត់បន្ថយគ្រោះទឹកជំនន់ ដែលត្រូវបង្កើតឡើង-ធ្វើបច្ចុប្បន្នភាព-ពិនិត្យឡើងវិញ ដែលជាប្រភេទនៃវិធានការត្រៀមបង្ការអាចត្រូវពិចារណា រៀបចំការឆ្លើយតប ការស្តារឡើងវិញ និងការស្តារនីតិសម្បទា ដែលអាចមើលឃើញ និងវិធានការកាត់បន្ថយដែលបានស្នើឡើង។

## ៦.២ គោលបំណង

- ស្វែងយល់ពីវិធានការខុសៗគ្នាត្រៀមបង្ការទឹកជំនន់សំរាប់ការឆ្លើយតបល្អប្រសើរ និងរបៀបរៀបចំទាំងអស់នេះ នៅតាមថ្នាក់ខេត្ត និងថ្នាក់ស្រុក។
- កំណត់យន្តការឆ្លើយតបគ្រោះអាសន្នទឹកជំនន់ ទាក់ទិនទៅនឹងតួណាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរថ្នាក់ខេត្ត និងអាជ្ញាធរថ្នាក់ស្រុក។

## ៦.៣ គោលគំនិតសំខាន់ៗ

- *ត្រៀមបង្ការទឹកជំនន់* និយាយពីសកម្មភាពជាច្រើនដែលបានកំណត់ និងគ្រោងទុកមុនបានយ៉ាងល្អ នៅមុនទឹកជំនន់ ដើម្បីកាត់បន្ថយឥទ្ធិពលទឹកជំនន់លើសហគមន៍ សេដ្ឋកិច្ច និងធនធានផ្សេងៗទៀត។ ទាំងនេះ រួមមាន សកម្មភាពត្រៀមបង្ការគ្រោះមហន្តរាយទូទៅ ដូចជាការធ្វើឱ្យមានការយល់ដឹង ការប្រកាសអាសន្នមុន ការជំលៀស ការផ្តល់ទីជំរក ការប្រយុទ្ធនឹងទឹកជំនន់និងការអនុវត្តន៍ផែនការឆ្លើយតបគ្រោះមហន្តរាយ។ល។ សកម្មភាពត្រៀមបង្ការ កំណត់វិធានការជាក់លាក់ និងផ្ទេរតួនាទី និងការទទួលខុសត្រូវទៅដល់មន្ទីរ-នាយកដ្ឋាននានារបស់រដ្ឋាភិបាល អង្គការនិងក្រុមអ្នកស្ម័គ្រចិត្តគ្រប់គ្រងគ្រោះមហន្តរាយ ដូចមានអធិប្បាយនៅក្នុងជំពូកទី៤និងទី៥នៃឯកសារមេរៀននេះ។ ជាពិសេស ដំណាក់កាលត្រៀមបង្ការងាចធ្វើឱ្យអ្នកធ្វើផែនការទាយទុកមុនពីតម្រូវការផ្សេងៗដែលត្រូវឆ្លើយតប និងដោះស្រាយជាមួយទឹកជំនន់។

- *ការឆ្លើយតបទឹកជំនន់* សំដៅលើសកម្មភាពគ្រោះអាសន្នដែលធ្វើឡើងក្នុងកំឡុងពេលស្ថានភាពទឹកជំនន់ ដើម្បីធ្វើឱ្យឥទ្ធិពលអវិជ្ជមាននៃទឹកជំនន់ថយចុះជាអប្បរមា។ វាមានពីរផ្នែកសំខាន់ៗ : ប្រតិបត្តិការគ្រោះអាសន្ន និងការគ្រប់គ្រងភស្តុភា។ ប្រសិទ្ធិភាពនៃការឆ្លើយតបទឹកជំនន់ គឺពឹងផ្អែកលើរបៀបដែលតួនាទី និងការទទួលខុសត្រូវបានចែងយ៉ាងច្បាស់លាស់នៅក្នុងផែនការត្រៀមបង្ការទកេជំនន់ និងត្រូវបានអ្នកដើរតួសំខាន់ៗយល់ថា នរណានឹងជាអ្នកអនុវត្តសកម្មភាពនៅក្នុងកំឡុងពេលគ្រោះអាសន្ន។
- *ការស្តារ និងការស្តារនីតិសម្បទាឡើងវិញ* មានគោលបំនងស្តារឱ្យមានភាពប្រក្រតីឡើងវិញ និងជួយប្រជាជនឱ្យទទួលបានការចូលរួមនៅក្នុងសកម្មភាពសង្គម និងសេដ្ឋកិច្ចដូចធម្មតាឡើងវិញ។
- *វិធានការកាត់បន្ថយទឹកជំនន់* ជាធម្មតា ត្រូវធ្វើឡើងជាមួយទស្សនៈវិស័យរយៈពេលវែង ដើម្បីកាត់បន្ថយគ្រោះថ្នាក់ទាំងមូលនៃទឹកជំនន់។ វាអាច និងគួរតែជាផ្នែកមួយមានសារៈសំខាន់របស់សកម្មភាពកាត់បន្ថយគ្រោះទឹកជំនន់ទាំងអស់ ចាប់ពីការត្រៀមបង្ការឆ្លើយតបដល់វិធានការស្តារនីតិសម្បទាឡើងវិញ។ ទាំងនេះអាច*ជារចនាសម្ព័ន្ធផង និងក្រៅរចនាសម្ព័ន្ធផង*។ វិធានការបែបរចនាសម្ព័ន្ធសំដៅលើការសាងសង់ និងការគ្រប់គ្រង ព្រែកជីក ទំនប់ទឹក អាងរក្សាទឹក ប្រព័ន្ធធារាសាស្ត្រ ផ្ទះលើទឹក ការធ្វើផ្ទះធន់នឹងទឹកជំនន់ ។ល។ វិធានការក្រៅរចនាសម្ព័ន្ធសំដៅលើការមានការកសាង និងការបណ្តុះបណ្តាលសមត្ថភាពរបស់អ្នកពាក់ព័ន្ធ ការធ្វើផែនការ ការលើកកំពស់ការយល់ដឹង ការផ្លាស់ប្តូរ-ការធ្វើកម្មវិធីប្រតិទិននៃការដាំដុះឡើងវិញ ។ល។

| **ត្រៀមបង្ការទឹកជំនន់** | **ការឆ្លើយតបទឹកជំនន់** |
|---|---|
| លទ្ធភាពទាយទុកជាមុន ការឆ្លើយតប និងដោះស្រាយផលប៉ះពាល់ទឹកជំនន់។ | ប្រតិបត្តិការគ្រោះអាសន្នដើម្បីធ្វើឱ្យឥទ្ធិពលអវិជ្ជមានមកលើសហគមន៍ថយចុះជាអប្បរមា។ |
| **ការស្តារ និង ស្តារនីតិសម្បទាឡើងវិញ** | **ការកាត់បន្ថយទឹកជំនន់** |
| សកម្មភាពបង្កើតឡើងដើម្បីនាំយកធនធានសហគមន៍ និងធនធានផ្សេងៗត្រឡប់មកមានភាពជាធម្មតាវិញ។ | វិធានការរយៈពេលវែងធ្វើឡើងដើម្បីកាត់បន្ថយគ្រោះថ្នាក់ទឹកជំនន់ទាំងមូល។ |

# ផ្នែកទី១ : វិធានការត្រៀមបង្ការទឹកជំនន់

## I ការលើកកំពស់ការយល់ដឹងជាសាធារណៈ

ការលើកកំពស់ការយល់ដឹងជាសាធារណៈ គឺជាដំណើរការមួយដែលប្រជាជនរស់នៅក្នុងតំបន់ប្រឈមនឹងទឹកជំនន់ ត្រូវតែដឹងអំពីគ្រោះថ្នាក់ជាក់លាក់ដែលបណ្តាលមកពីទឹកជំនន់។ វាមាន ដូចជាការអប់រំ ការជូនដំណឹង និងការប្រកាសភាពអាសន្នដល់សហគមន៍អំពីទឹកជំនន់ និងការជួយពួកគេឱ្យត្រៀមបង្ការឱ្យបានល្អប្រសើរសំរាប់ឆ្លើយតបនឹងស្ថានភាពគ្រោះអាសន្នទឹកជំនន់ ដែលពឹងផ្អែកតិចតួចលើជំនួយ ឬអន្តរាគមន៍ពីខាងក្រៅ តាមរយៈវិធានការសមស្រប ដើម្បីបង្ការការបាត់បង់អាយុជីវិតមនុស្ស និងការខូចខាតទ្រព្យសម្បត្តិជាអប្បរមា។

គោលបំណងនៃការលើកកំពស់ការយល់ដឹងជាសាធារណៈអំពីទឹកជំនន់ គឺត្រូវ :

- បង្កើនចំណេះដឹងសាធារណជមអំពីទឹកជំនន់ លក្ខណៈ ផលវិបាក និងឥទ្ធិពលរបស់វាដែលអាចមាន។
- ធ្វើឱ្យចំណេះដឹងសាធារណជនអំពីវិធានការត្រៀមបង្ការជាក់ស្តែងមានភាពល្អប្រសើរឡើង នៅតាមផ្ទះដែលសហគមន៍អាចអនុវត្តដោយខ្លួនឯង។
- ជូនដំណឹងអំពីប្រព័ន្ធប្រកាសអាសន្នមុនទឹកជំនន់ និងមធ្យោបាយទំនាក់ទំនងផ្សេងៗដើម្បីទទួលសញ្ញាប្រកាសអាសន្ន និងព័ត៌មានទឹកជំនន់។
- ផ្សព្វផ្សាយព័ត៌មានអំពីកម្មវិធីត្រៀមបង្ការទឹកជំនន់របស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយខេត្ត និងស្រុក រួមទាំងផែនការត្រៀមបង្ការទឹកជំនន់ និងកៀងគរការគាំទ្រសំរាប់សកម្មភាពសហការឆ្លើយតបទឹកជំនន់។

## II *វិធីសាស្ត្រលើកកំពស់ការយល់ដឹងជាសាធារណៈ*

តទៅនេះ គឺជាយាន្តខ្លះដែលអាចប្រើប្រាស់សំរាប់ការរៀបចំយុទ្ធនាការលើកកំពស់ការយល់ដឹង :

- ប្រព័ន្ធសារព័ត៌មាន-វិទ្យុ ទូរទស្សន៍ កាសែត វីដេអូខ្លីៗ រូបថត ប្រដាប់ថតសំលេង។
- សារព័ត៌មានបោះពុម្ព-ខិតប័ណ្ណ ប័ណ្ណព័ត៌មាន សៀវភៅតូច ផ្ទាំងរូបភាព ប៉ាណូរូបភាព
- សកម្មភាពសហគមន៍-ការប្រជុំ ការពិភាក្សាថ្នាក់សហគមន៍
- កម្មវិធីតំរង់ទិសពិសហគមន៍ ដូចជា ការសំដែងតាមដងផ្លូវ ការចែកខិតប័ណ្ណ យុទ្ធនាការនៅតាមផ្ទះនិងកម្មវិធីតាមសាលារៀន។

អង្គការអ្នកស្ម័គ្រចិត្តដែលធ្វើការនៅក្នុងតំបន់ជាក់លាក់មួយឬធ្វើការយ៉ាងជិតស្និទ្ធិជាមួយសហគមន៍មាន

ទំនាក់ទំនង និងការយល់ដឹងល្អអំពីសហគមន៍។ ដូច្នេះ ការយល់ដឹងដែលបានកើនឡើងនៅក្នុងចំណោមអង្គការអ្នកស្ម័គ្រចិត្តដើម្បីកាត់បន្ថយគ្រោះទឹកជំនន់ ទាំងនេះ ជាមួយនឹងការអភិវឌ្ឍន៍ថ្មីៗនៅតាមមូលដ្ឋាន គឺជាជំហានពិតប្រាកដមួយឆ្ពោះទៅរកការបង្កើនការយល់ដឹងរបស់សហគមន៍ទាំងមូល។

*បញ្ហាសំខាន់ៗនៅក្នុងកម្មវិធីលើកកំពស់ការយល់ដឹងអំពីទឹកជំនន់ :* កម្មវិធីលើកកំពស់ការយល់ដឹង គួរតែបង្កើតឡើងតាមមធ្យោបាយមួយដែលវាជាក់លាក់ទៅនឹងគ្រោះទឹកជំនន់របស់តំបន់ភូមិសាស្ត្រគោលដៅ។ ដើម្បីសំរេចបាន សំណួរដូចតទៅនេះគួរតែលើកឡើងក្នុងការធ្វើនិងអនុវត្តន៍កម្មវិធី :

- តើនរណាខ្លះជាប្រជាជនគោលដៅ(សាធារណជនទូទៅឬក្រុមគោលដៅជាក់លាក់)?
- តើត្រូវផ្សព្វផ្សាយសារអ្វីខ្លះ(ការយល់ដឹងអំពីទឹកជំនន់ឬសារជាក់លាក់ផ្សេងទៀត ដូចជាសុខភាព ជំរក)?
- តើត្រូវប្រើវិធីសាស្ត្រទំនាក់ទំនងប្រភេទអ្វីសំរាប់ការផ្សព្វផ្សាយសារ(ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបោះពុម្ព សកម្មភាពសហគមន៍)?
- តើត្រូវធ្វើយុទ្ធនាការនៅពេលណា (មុនឬកំឡុងពេលរដូវទឹកឡើង ប៉ុន្មានដង)?
- តើនរណានឹងរៀបចំធ្វើយុទ្ធនាការ (អាជ្ញាធរខេត្ត-ស្រុកដោយសហការជាមួយសមាជិកមន្ទីររបស់ខ្លួនឬជាមួយអង្គការ ឬសហការជាមួយភ្នាក់ងារដែលបានលើកឡើងខាងលើ)?

ដោយសារតែយុទ្ធនាការ និងកម្មវិធីលើកកំពស់ការយល់ដឹងភាគច្រើនបំពេញបំណងទស្សនិកជនក៏ដោយ វាត្រូវតែធានាថា សារងាយយល់(ទោះជាលាល័ក្សអក្សរឬក្រាហ្វិកក្តី)នៅពេលផ្សព្វផ្សាយ។ វាត្រូវចងចាំថា មនុស្សខ្លះ មិនអាចទទួលព័ត៌មានបានពីទូរទស្សន៍ កុំព្យូទ័រ កុន វិទ្យុ។ល។ ទេ ហើយមនុស្សខ្លះមិនចេះអានអក្សរ។ ដូច្នេះ គួរតែប្រើវិធីសាស្ត្ររួមផ្សំដើម្បីចូលដល់ក្រុមមនុស្សដែលមិនអាចទទួលព័ត៌មានបាន។

***តួនាទី និងការទទួលខុសត្រូវសំខាន់ៗក្នុងការលើកកំពស់ការយល់ដឹងពីទឹកជំនន់ :*** នៅតាមថ្នាក់ខេត្តនិងថ្នាក់ស្រុក អ្នកពាក់ព័ន្ធទាំងអស់ ដូចជា អ្នកដឹកនាំសហគមន៍ អង្គការ ប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក គ្រូបង្រៀន អ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយ និងសហគមន៍ត្រូវតែចូលរួមនៅក្នុងការបង្កើតនិងអនុវត្តសកម្មភាពលើកកំពស់ការយល់ដឹងពីគ្រោះទឹកជំនន់។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុក គួរតែសហការជាមួយភ្នាក់ងារពាក់ព័ន្ធ ដូចជា មន្ទីរវប្បធម៌ ព័ត៌មាន និងអប់រំ ជាដើម។ វាបំរើគោលបំណងពីរយ៉ាង អំពីការការលើកកំពស់ការចូលរួមធំទូលាយរបស់មន្ទីរពាក់ព័ន្ធដែលជាទូទៅមិនចូលរួមសកម្មក្នុងមុខងារកាត់បន្ថយគ្រោះទឹកជំនន់ ហើយក្នុងពេលដំណាលគ្នានេះ បង្កើនប្រភពធនធានសំរាប់ត្រៀមបង្ការទឹកជំនន់។ ក្នុងនាមជាភ្នាក់ងារសំរបសំរួល អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយអាចដើរតួនាទីដូចតទៅ :

- បង្កើតយុទ្ធសាស្ត្រលើកកំពស់ការយល់ដឹងអំពីទឹកជំនន់របស់ខេត្តឬស្រុក ដែលមានការចូលរួមពីមន្ទីរ និងភ្នាក់ងារពាក់ព័ន្ធ ។
- ពិគ្រោះយោបល់ជាមួយក្រុមអ្នកស្ម័គ្រចិត្ត អង្គការ(ជាតិនិងអន្តរជាតិ) និងពិភាក្សាយុទ្ធសាស្ត្រ លើកកំពស់ការយល់ដឹងអំពីទឹកជំនន់ខេត្តនិងស្រុកឱ្យមានការទំនាក់ទំនងល្អប្រសើរ(ទៅនឹងកម្មវិធីរបស់អង្គការដែលមានស្រាប់) និងការគ្របដណ្តប់ភូមិសាស្ត្រ និងក៏កៀរគធនធានពីគំរោងដែលកំពុងដំណើរការបន្តរបស់ផ្នែកក្រៅរដ្ឋាភិបាល ។
- បង្កើតក្រុម និងគណៈកម្មាធិការពិសេស ហើយបណ្តុះបណ្តាលពួកគេឱ្យបង្កើត និងអនុវត្តយុទ្ធនាការលើកកំពស់ការយល់ដឹងអំពីទឹកជំនន់ ។
- អនុវត្តការធ្វើអន្តរាគមន៍សាកល្បង ដូចជា ការដាក់ឱ្យប្រើប្រាស់សប្តាហ៍ត្រៀមបង្ការទឹកជំនន់ ការរៀបចំការប្រកួតប្រជែងសិល្បៈតាមកម្រងបញ្ហា-តែងសេចក្តី ស្តីពីមហន្តរាយទឹកជំនន់នៅតាមសាលារៀន យុទ្ធនាការ និងការប្រជុំជាសាធារណៈ ។

ទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយខេត្តឬស្រុកតែម្យ៉ាង មិនអាចធានាការយល់ដឹងទូលំទូលាយអំពីមហន្តរាយបានទេ ។ ដូច្នេះ ការខិតខំប្រឹងប្រែងសហការគួរតែធ្វើឡើងដើម្បីឱ្យមានការប្រជុំរួមគ្នាជាមួយទីភ្នាក់ងារពាក់ព័ន្ធ អង្គការសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល(ទាំងក្នុងស្រុកនិងអន្តរជាតិ) រួមទាំងសាខាកាកបាទក្រហម និងក្រុមអ្នកស្ម័គ្រចិត្តដែលមានមូលដ្ឋាននៅក្នុងតំបន់គោលដៅ និងអង្គការធំៗ(ដូចជា ក្រុមស្ត្រីកសិករនិងសមាគមន៍យុវជន) ។ វាគឺជាការសហការណ៍មានការធានាគ្រប់គ្រាន់និងពង្រីកដើម្បីគ្របដណ្តប់តំបន់ភូមិសាស្ត្រទូលំទូលាយ ។ ភាពជាដៃគូរ គួរតែធ្វើជាមួយអង្គការពាណិជ្ជកម្មនានាក្នុងតំបន់ ដូចជា ក្រុមហ៊ុនធានារ៉ាប់រង ស្ថាប័នហិរញ្ញវត្ថុ ដូចជា ធនាគារ និងសហគ្រាសឯកជនសំរាប់មូលដ្ឋានធនធានធំធេង ។

## III *ការបង្កើតប្រព័ន្ធមួយសំរាប់ការផ្សព្វផ្សាយការព្យាករណ៍ទឹកជំនន់ និង ការប្រកាសអាសន្នមុន*

ការព្យាករណ៍ និងការប្រកាសអាសន្នទឹកជំនន់ គឺជាព័ត៌មានសំខាន់សំរាប់ការប្រតិបត្តិទាន់ពេលវេលារបស់កម្មវិធីត្រៀមបង្ការទឹកជំនន់ ជាពិសេស ក្នុងការអនុវត្តន៍សកម្មភាពសំខាន់ៗទាន់ពេលវេលា ដូចជា ការរើទីលំនៅរបស់ប្រជាជនទៅតំបន់សុវត្ថិភាព និងការពង្រាយធនធានសំរាប់សកម្មភាពឆ្លើយតបទឹកជំនន់ ។ ដូច្នេះ ការបង្កើតប្រព័ន្ធមួយដែលធានា និងសំរបសំរួលចលនាព័តិមានសំខាន់ៗក្នុងកំឡុងពេលវិបត្តិ គួរតែជាការត្រៀមបង្ការទឹកជំនន់ឈានមុខគេ ។

***ប្រព័ន្ធប្រកាសអាសន្នមុនទឹកជំនន់*** *(EWS)* អាចសំរបសំរួលការផ្សព្វផ្សាយព័តិមានសំខាន់ៗអំពីស្ថានភាទឹកជំនន់

អំពីពេលវេលា និងទីកន្លែងដែលទឹកជំនន់នឹងកើតឡើង ដើម្បីឱ្យការសំរេចចិត្តយកវិធានការការពារទាន់ពេល

វេលា និងស្របទៅតាមកំរិតប្រកាសអាសន្នគ្រោះថ្នាក់ដែលដឹង ។ EWS ដែលសាមញ្ញនិងមានប្រសិទ្ធិភាព គឺមានផ្នែកសំខាន់បួនយ៉ាងដូចតទៅ :

១. ការតាមរកឱ្យឃើញ និងការព្យាករណ៍គ្រោះទឹកជំនន់
២. ការបង្កើតសារប្រកាសអាសន្ន
៣. ការផ្សព្វផ្សាយសារប្រកាសអាសន្ន
៤. ការឆ្លើយតបរបស់សហគមន៍

វាមានសារៈសំខាន់ស្មើគ្នាដើម្បីបញ្ជាក់ថា ការព្យាករណ៍ទឹកជំនន់ផ្សាយបន្តពីប្រភពមួយដែលគួរឱ្យជឿទុកចិត្ត និងមានការអនុញ្ញាត្តិ ។ ព័ត៌មានប្រកាសអាសន្ន ធ្វើឡើងផ្អែកលើការព្យាករណ៍ គួរតែបញ្ជូនទៅទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយក្នុងស្រុកពាក់ព័ន្ធ ដែលអាចធ្វើការសំរេចចិត្ត និងផ្តួចផ្តើមសកម្មភាពដែលបានកំណត់ក្នុងផែនការត្រៀមបង្ការទឹកជំនន់ ។

មណ្ឌលឧត្តុនិយមជលសាស្ត្រជាតិ និងទីភ្នាក់ងារពាក់ព័ន្ធរបស់គេនៅក្នុងបណ្តាប្រទេសអាងទន្លេ មេគង្គជាបឋម ទទួលខុសត្រូវចំពោះការប្រមូល ការបង្កើត និងការផ្សព្វផ្សាយទិន្នន័យព្យាករណ៍ និងប្រកាស អាសន្នទឹកជំនន់ ដូចមាននៅក្នុងគោលការណ៍និងបទបញ្ជារដែលមាននៅក្នុងប្រទេសនីមួយៗ ។ បន្ថែមលើនេះ គណៈកម្មការទន្លេមេគង្គ (MRC) តាមរយៈមណ្ឌល គ្រប់គ្រងនិងកាត់បន្ថយទឹកជំនន់ថ្នាក់តំបន់របស់ខ្លួន (RFMMC) ក៏ទទួលបានទិន្នន័យទាន់ពេលវេលាពីប្រទេសជាសមាជិក (តាមរយៈមណ្ឌលឧត្តុនិយម ជលសាស្ត្រជាតិ) និងពីប្រភពផ្សេងទៀតដើម្បីធ្វើការព្យាករណ៍ទឹកជំនន់ ។ អាស័យដ្ឋានវេបសាយខ្លះ ទាក់ទងនឹង ការព្យាករណ៍និងប្រកាសអាសន្នទឹកជំនន់នៅក្នុងអាងទន្លេមេគង្គក្រោម មានផ្តល់ឱ្យនៅក្នុងប្រអប់ខាងក្រោម :

**វេបសាយសំខាន់ៗសំរាប់ទទួលបានព័ត៌មានព្យាករណ៍ទឹកជំនន់**

- http://ffw.mrcmekong.org/ (គណៈកម្មការទន្លេមេគង្គ)
- http://www.hydrologycambodia.50megs.com/ (Hydro-Met, កម្ពុជា)
- http://www.nchmf.gov.vn (Hydro-Met, វៀតណាម)
- http://www.tmd.go.th (Hydro-Met, វៀតណាម)
- http://www.hko.gov.hk/contente.htm (Hong Kong Observatory)
- http://www.cma.gov.cn (ចិន)
- https://www.fnmoc.navy.mil/PUBLIC (ទាហានជើងទឹកអាមេរិក)
- http://www.bom.gov.au (អូស្ត្រាលី)

***តួនាទី និងការទទួលខុសត្រូវរបស់ប្រព័ន្ធប្រកាសអាសន្នមុនទឹកជំនន់*** *(EWS):* មណ្ឌលឧត្តុនិយមជលសាស្ត្រជាតិនៅក្នុងបណ្តារប្រទេសអាងទន្លេមេគង្គក្រោម មានតួនាទីចំបងប្រមូល បង្កើត និងផ្សព្វផ្សាយទិន្នន័យព្យាករណ៍ទឹកជំនន់ តាមរយៈបណ្តាញរបស់គេ (មន្ទីរនៅក្រោមក្រសួងដូចគ្នា) ក្នុងខេត្ត ស្រុកនិងភូមិ។ ដូចគ្នានេះដែរ បណ្តាញថ្នាក់តំបន់ ដូចជា មណ្ឌលគ្រប់គ្រង និងកាត់បន្ថយទឹកជំនន់របស់ MRC និងទីភ្នាក់ងារអន្តរជាតិ ដូចជា Hong Kong Observatory កងទ័ពជើងទឹកអាមេរិក និងផ្សេងៗទៀត ក៏វិភាគទិន្នន័យទឹកជំនន់ ផងដែរ ដោយប្រើព័ត៌មានតាមផ្កាយរណប និងការចេញការប្រកាសអាសន្នទឹកជំនន់ នៅពេលមានគ្រោះអាសន្ន។

តួនាទី និងការទទួលខុសត្រូវដែលរំពឹងទុកខ្លះសំរាប់ EWS នៅកំរិតខុសៗគ្នា មានពិពណ៌នាដូចខាងក្រោម :

| ***ភាគីទទួលខុសត្រូវ*** | ***តួនាទី និងការទទួលខុសត្រូវ*** |
|---|---|
| ***សហគមន៍*** | ▪ ប្រយ័ត្នមានគ្រោះថ្នាក់នៅក្នុងតំបន់និងគ្រោះថ្នាក់ទាក់ទង និងឥទ្ធិពល<br>▪ អាចចាត់វិធានការជាក់លាក់ដោយខ្លួនឯងពេលទទួលបានការប្រកាសអាសន្ន |
| ***អាជ្ញាធរមូលដ្ឋាន(អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត ឬស្រុក)*** | ▪ ស៊ាំជាមួយនឹងគ្រោះថ្នាក់ដែលកើតឡើង និងឥទ្ធិពល<br>▪ អាចបកស្រាយព័ត៌មានបច្ចេកទេសនិងព័ត៌មានណែនាំដែលទទួលបាន<br>▪ ផ្តល់ការណែនាំដល់សហគមន៍មូលដ្ឋាន<br>▪ សំរបសំរួលសកម្មភាពឆ្លើយតបថ្នាក់មូលដ្ឋាន |
| **រដ្ឋាភិបាលជាតិ (ស្ថាប័នជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង មណ្ឌលឧត្តុនិយមជលសាស្ត្រ)** | ▪ ត្រូវទទួលខុសត្រូវចំពោះការត្រៀមបង្ការនិងការចេញប្រកាសអាសន្នក្នុងលក្ខណៈទាន់ពេលវេលានិងមានប្រសិទ្ធិភាព។<br>▪ ធានាការប្រកាសអាសន្ននិងគោលការណ៍ណែនាំសំរាប់វិធានការការពារចំពោះប្រជាពលរដ្ឋដែលងាយរងគ្រោះខ្លាំងបំផុត។<br>▪ ផ្តល់ការគាំទ្រដល់អាជ្ញាធរមូលដ្ឋានដើម្បីប្រើប្រាស់ព័ត៌មាននិងកសាងសមត្ថភាពប្រតិបត្តិការ។ |
| **ស្ថាប័នថ្នាក់តំបន់ (*MRC* *និងអ្នកផ្សេង*)** | ▪ ផ្តល់ចំណេះដឹងឯកទេស ឱវាទ ឬប្រយោជន៍នៃបទពិសោធន៍ក្នុងការគាំទ្រកិច្ចប្រឹងប្រែងថ្នាក់ជាតិសំរាប់ប្រទេសដែលមានបរិយាកាសភូមិសាស្ត្រដូចគ្នា<br>▪ ផ្តល់ការទំនាក់ទំនងទៅនឹងសមត្ថភាពអន្តរជាតិខ្នាតធំចំពោះតំរូវការពិសេសរបស់ប្រទេសនីមួយៗ។ |
| **ទីភ្នាក់ងារអន្តរជាតិ** | ▪ លើកកំពស់ការផ្លាស់ប្តូរទិន្នន័យ និងចំណេះដឹងក្នុងចំណោមពួកគេ និងរវាងទីភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយដែលធ្វើការតាមកំរិតខុសៗគ្នា។<br>▪ ផ្តល់ការគាំទ្រដល់អាជ្ញាធរឬទីភ្នាក់ងារជាតិដែលទទួលខុសត្រូវប្រកាសអាសន្នមុន។ |

***ការយល់ដឹងជាសាធារណៈអំពីការប្រកាសអាសន្នទឹកជំនន់*** : វាសំខាន់ត្រង់ថា ប្រជាជនដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងទឹកជំនន់ មានរូបភាពច្បាស់លាស់និងចំណេះដឹងគ្រប់គ្រាន់អំពីគ្រោះថ្នាក់ដែលពួកគេប្រឈម និងចូលរួមយ៉ាងសកម្មក្នុងការបង្កើតនិងអនុវត្តប្រព័ន្ធប្រកាសអាសន្នមុន។ សំរាប់សហគមន៍ដែលស្ថិតក្នុងស្ថានការណ៍ត្រៀមបង្ការ មធ្យោបាយដូចតទៅនេះ អាចដាក់ពង្រាយដើម្បីលើកកំពស់ការយល់ដឹងអំពីការប្រកាសអាសន្នទឹកជំនន់ ដែលពួកគេប្រហែលជានឹងទទួល :

- ការដាក់គំនូសញ្ញាទឹកជំនន់(បោះបង្គោលបញ្ឈរទោល ឬនៅលើបង្គោលទូរស័ព្ទឬអាគារដែលអាចមើលឃើញពីចំងាយ)។
- អត្ថបទសារព័ត៌មានលើកាសែតក្នុងស្រុក ស្តីពីប្រព័ន្ធប្រកាសអាសន្នដែលមានស្រាប់ និងជំហានត្រូវធ្វើនៅករណីមានទឹកជំនន់។
- ការផ្តល់វិធានគោលការណ៍ណែនាំទឹកជំនន់តាមទម្រង់ជូនដំណឹងលើក្តារខៀន ផ្ទាំងរូបភាព ឯកសារ និងសៀវភៅតូចដល់សាលារៀន និងបណ្ណាល័យ ឬបិតវានៅទីកន្លែងសាធារណៈនានា។
- ការប្រជុំតាមពេលកំនត់សំរាប់សហគមន៍ (យន្តការមួយដែលអាចដាក់ពង្រាយដើម្បីពិនិត្យប្រព័ន្ធដែលមានស្រាប់ឡើងវិញ និងរបៀបធ្វើវាឱ្យល្អប្រសើរ)។
- ការហ្វឹកហាត់តាមពេលកំណត់។

***ការបញ្ជូនទឹកជំនន់*** គឺជាសកម្មភាពមួយដែលអាចធ្វើឡើងនៅសហគមន៍ ដើម្បីឱ្យសមាជិកសហគមន៍ព្យាករណ៍ទឹកជំនន់។ វាមានប្រយោជន៍បំផុតសំរាប់សហគមន៍នៅតាមព្រែកឬទន្លេតូចៗជាប់ទន្លេធំប្រឈមនឹងទឹកជំនន់ ប៉ុន្តែមិនគ្របដណ្តប់នៅក្រោមបណ្តាញព្យាករណ៍ថ្នាក់ជាតិ។ វាពាក់ព័ន្ធសកម្មភាពដូចតទៅនេះ :

- ការដាក់គំនូសសញ្ញាកំរិតទឹក(ឬប្រដាប់វាស់កំរិត)នៅតាមទន្លេឬតាមដៃទន្លេដែលនៅក្បែរភូមិ-ឃុំ។
- បង្កើតការព័ត៌មានដាក់នៅចំណុចយុទ្ធសាស្ត្រ ដូចជា ទីផ្សារ ផ្លូវបំបែកសំខាន់ៗ(កន្លែងដែលប្រជាជនអាចឆ្លងកាត់ឃើញវា)។
- ការបណ្តុះបណ្តាលជនបង្គោលនៅក្នុងសហគមន៍ដើម្បីអាចប្រើ និងថែរក្សាឧបករណ៍ដែលត្រូវដាក់។
- បង្កើតប្រព័ន្ធទំនាក់ទំនងត្រឹមត្រូវមួយដើម្បីទទួលព័ត៌មានទឹកជំនន់(ការព្យាករណ៍និងការប្រកាសអាសន្ន)ពីថ្នាក់ជាតិ ដើម្បីឱ្យមណ្ឌលឧត្តុនិយមជលសាអាចព្យាករណ៍ទឹកជំនន់សំរាប់តំបន់។

ប្រព័ន្ធបញ្ជូនទឹកជំនន់នៅតាមសហគមន៍អាចធ្វើឡើងជាផ្នែកមួយរបស់ប្រព័ន្ធព្យាករណ៍ទឹកជំនន់ខេត្ត។

## IV ***ផែនការជំលៀស និង គ្រប់គ្រងទីជំរកបណ្តោះអាសន្ន***

ផែនការជំលៀស គឺជាសកម្មភាពមានអាទិភាពខ្ពស់របស់ផែនការត្រៀមបង្ការទឹកជំនន់ ដែលត្រូវធ្វើឡើង

មុនដោយភ្នាក់ងាររដ្ឋាភិបាលក្នុងស្រុក និងអង្គការពាក់ព័ន្ធ រួមជាមួយនិងក្រុមអ្នកស្ម័គ្រចិត្តសហគមន៍។ ដើម្បីសំរបសំរួលផែនការជំលៀស ផែនការត្រៀមបង្ការទឹកជំនន់ត្រូវតែមានការកំនត់តំបន់ដែលងាយរងគ្រោះតាមទម្រង់ផែនទីគ្រោះទឹកជំនន់។ បញ្ហាសំខាន់ត្រូវដោះស្រាយសំរាប់ផែនការជំលៀស គឺ :

- **ការបង្កើត និងការថែរក្សាតំបន់សុវត្ថិភាព :** ជំហានដំបូងគឺត្រូវកំណត់តំបន់សុវត្ថិភាព (ថ្មីនិងមានស្រាប់) ក្នុងសហគមន៍ឱ្យបានមុន។ នៅពេលធ្វើរួចហើយ ភ្នាក់ងារពាក់ព័ន្ធដែលទទួលខុសត្រូវជាមួយនិងក្រុមអ្នកស្ម័គ្រចិត្តត្រូវរៀបចំនិងចាត់ចែងទីជំរក ឬតង់បណ្តោះអាសន្ន។ នៅពេលដែលពេលវេលាទឹកលិចវែង ប្រជាជនដែលរងការប៉ះពាល់ត្រូវការមានបរិក្ខា ពោលគឺ អណ្តូងទឹក បង្គន់ ជំរកសំរាប់សត្វពាហនៈ កន្លែងស្តុកស្បៀងគ្រាអាសន្ន។ល។ ជាកត្តាមួយដែលត្រូវការគិតគូរនៅក្នុងកំឡុងពេលរៀបចំតំបន់សុវត្ថិភាព។ ខណៈពេលដែលការរៀបចំនិងការថែទាំតំបន់សុវត្ថិភាព ត្រូវធានាចំណុចដូចតទៅនេះ :

១. ការជ្រើសរើសទីតាំងខ្ពស់សមល្មមសំរាប់តំបន់សុវត្ថិភាពថ្មី (ដីខ្ពស់ជាងកំរិតទឹកជំនន់ដែលអាក្រក់បំផុតកាលពីលើកមុនៗ និងបិទផ្លូវធំដើម្បីងាយស្រួលចូលដល់) ឬលើកដីតំបន់សុវត្ថិភាពឱ្យខ្ពស់។
២. ការបំពាក់បរិក្ខាទឹកស្អាតនិងអនាម័យ។
៣. ធ្វើការរៀបចំសំរាប់ការផ្គត់ផ្គង់ជាយថាភាពនៃប្រេង ឈើ និងរបស់របរជាមូលដ្ឋាន (ពាង ឆ្នាំង ។ល។) សំរាប់ការចំអិនអាហារ។
៤. ស្តុកបរិក្ខារថ្នាំពេទ្យសំរាប់ជំងឺកើតពីទឹក ឬជំងឺរ៉ិកទ័រ ដូចជា ជំងឺរាគ និងគ្រុនចាញ់ និងបរិក្ខាពេទ្យសំរាប់គោក្របី មាន់ទា និងសត្វពាហនៈផ្សេងទៀត។
៥. ស្តុកការផ្គត់ផ្គង់ស្បៀង (សំរាប់គ្រួសារនីមួយៗនិងសហគមន៍) និងចំណីសត្វ (សំរាប់សត្វពាហនៈ)។
៦. ផ្តល់ឧបករណ៍នេសាទត្រីនិងការផ្គត់ផ្គងផ្សេងទៀតសំរាប់ធ្វើឱ្យជីវភាពរស់នៅមាននិរន្តរភាព។
៧. ផ្តល់គ្រាប់ពូជនិងឧបករណ៍សំរាប់សួនដាំបន្លែតាមផ្ទះលើតំបន់សុវត្ថិភាព (ផ្អែកលើរយៈពេលទឹកជំនន់)។
៨. បង្កើតគណៈកម្មាធិការរៀបចំសហគមន៍សំរាប់ការថែទាំតំបន់សុវត្ថិភាព។
៩. ក្នុងករណីដែលរចនាសម្ព័ន្ធសាលារៀននិងសហគមន៍ត្រូវបានប្រើសំរាប់ការជំលៀស វិធានការសមស្របត្រូវតែអនុវត្តដើម្បីកែប្រែការប្រើប្រាស់ជំរកសុវត្ថិភាព។

វារំពឹងថា តំបន់សុវត្ថិភាពមានប្រសិទ្ធិភាព និងការធ្វើផែនការជំរកបណ្តោះអាសន្ន ប្រជាជននឹងអាចដឹងមុនអំពីស្ថានភាពទឹកជំនន់ និងកន្លែងដែលពួកគេត្រូវទៅ។ ពួកគេអាចដឹងថាផ្លូវណាដែលពួកគេត្រូវទៅដល់ទីដៅ។

- **ការរៀបចំផ្លូវជំលៀសនិងមធ្យោបាយដឹកជញ្ជូន :** ការកំនត់រកផ្លូវជំលៀសជំនួសច្រើនជាងមួយទៅតំបន់សុវត្ថិភាព ឬកំនត់រកទីជំរកសុវត្ថិភាព គឺមានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យពេលវេលាដឹកនាំនៅតិចក្នុងកំឡុងពេលជំលៀស។ វាមិនត្រឹមតែជួយសហគមន៍មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយក្រុមឆ្លើយតបផ្សេងៗដែលតែង

តែមានមកពីខាងក្រៅដើម្បីអនុវត្តប្រតិបត្តិការសង្គ្រោះនិងការបែងចែកជំនួយសង្គ្រោះ។ ការពិចារណា ដូចត ទៅនេះ ត្រូវទុកក្នុងចិត្តនៅពេលធ្វើផែនការសំរាប់ផ្លូវជំលៀសទៅកាន់តំបន់សុវត្ថិភាព :

១. កំនត់ចំណុចជំលៀសឬតំបន់សុវត្ថិភាពដែលនៅជិតបំផុត(វត្តអារាមឬសាលារៀននៅលើដីខ្ពស់)។

២. កំនត់រកផ្លូវមានសុវត្ថិភាពបំផុតនិងខ្លីបំផុតទៅតំបន់សុវត្ថិភាព និងផ្លូវជំនួស ក្នុងករណីមិនបានគិតទុកអំពី ផ្លូវទាល់ ជៀសវាងតំបន់ដែលមានចរន្តទឹកខ្ពស់ ឬតំបន់ទឹកដក់ដែលមិនដឹងជំរៅទឹក។

៣. ដាក់ផ្លាកសញ្ញា ឬគំនូសនៅតាមផ្លូវសំរាប់ងាយស្គាល់និងចំណាំ។

៤. ការជូនដំណឹងសាធារណជនអំពីទីតាំងតំបន់សុវត្ថិភាព និងផ្លូវទៅដល់របស់ពួកគេ។

៥. ត្រៀមទូកនិងមធ្យោបាយដឹកជញ្ជូនផ្សេងៗ។ វាសំខាន់ ត្រូវត្រួតពិនិត្យលក្ខខ័ណ្ឌដំណើរការរបស់ ឧបករណ៍ តាមពេលវេលា។

តាមកាលវេលាសមស្រប ត្រូវរើផ្ទះដែលងាយរងគ្រោះបំផុតដែលនៅជិតតំបន់សុវត្ថិភាពមុនគេ។

## V ការធ្វើផែនការស្វែងរក និងសង្គ្រោះ

ការធ្វើផែនការស្វែងរកនិងសង្គ្រោះមុនទឹកជំនន់ គឺជាលំហាត់កសាងសមត្ថភាពសំរាប់ភ្នាក់ងារពាក់ព័ន្ធ និងក្រុមស្ម័គ្រចិត្ត ព្រមទាំងតំរូវការឧបករណ៍សមស្របសំរាប់ស្វែងរកនិងសង្គ្រោះ ដែលអាចធ្វើឱ្យពួកគេឆ្លើយតប មានប្រសិទ្ធិភាពចំពោះគ្រោះអាសន្នគំរាមកំហែងលើអាយុជីវិតនៅក្នុងកំឡុងពេលទឹកជំនន់។

ក្នុងករណីភាគច្រើន កងទ័ពធ្វើការបណ្តុះបណ្តាលអំពីការសង្គ្រោះជីវិត(សង្គ្រោះបឋម សង្គ្រោះតាមជើង ទឹក។ល។)សំរាប់បុគ្គលិករបស់ខ្លួនតាមកំរិតផ្សេងៗគ្នា។ នៅក្នុងកំឡុងពេលទឹកជំនន់ ការលង់ទឹកកើតឡើងនៅ ក្នុងតំបន់ដែលមិនមានវត្តមានប៉ុស្តិ៍កងទ័ព។ នៅប្រទេសវៀតណាមមាន "ប៉ុស្តិ៍សង្គ្រោះ" គ្រប់គ្រងដោយអ្នក ស្ម័គ្រចិត្តកាកបាទក្រហម និងក្រុមយុវជនផ្សេងទៀតនៅក្នុងសហគមន៍។ ក្នុងករណីមិនមានវត្តមានកងទ័ព អ្នកស្ម័គ្រចិត្តនិងក្រុមយុវវ័យអាចជាសក្តិភាពធនធានសំខាន់ ប្រសិនបើបានបណ្តុះបណ្តាលទឹមត្រូវ ជាពិសេស ការសង្គ្រោះបឋម។ ការបណ្តុះបណ្តាលបែបនេះ គួរតែស្របគ្នាជាមួយទស្សនៈកសាងសមត្ថភាពរបស់ពួកគេ ដល់ កំរិត "អ្នកបណ្តុះបណ្តាល" ដើម្បីពួកគេធ្វើការបណ្តុះបណ្តាលថែមទៀតនៅកំរិតឃុំនិងភូមិ។

## VI ការធ្វើផែនការពេទ្យ អនាម័យ និងការថែទាំសុខភាព

ការប្រឈមមួយដែលអ្នកអនុវត្តការឆ្លើយតបគ្រោះអាសន្នប្រឈមមុខកំឡុងពេលទឹកជំនន់ គឺការទទួល បានទឹកស្អាត និងបរិក្ខាអនាម័យ។ ការប៉ាន់ប្រមាណរហ័យត្រូវតែធ្វើឡើងក្នុងកំឡុងពេលដំណាក់កាលធ្វើផែនការ ត្រៀមបង្ការដើម្បីកំនត់សមត្ថភាពសំរបសំរួលដែលមានស្រាប់ និងតំរូវការសំរាប់ការធ្វើឱ្យប្រសើរឡើងសំរាប់

ប្រព័ន្ធផ្គត់ផ្គង់ទឹកសមស្រប។ ការផ្គត់ផ្គង់ទឹក និងមន្ទីរសាធារណការ ត្រូវតែធ្វើការងារជិតស្និទ្ធិជាមួយភ្នាក់ងារជាតិ និងអន្តរជាតិសំរាប់ការធានាឱ្យមានទឹកស្អាតសំរាប់ផឹក ចំអិន បោកគក់និងសំរាប់សត្វ។

ការប្រើប្រាស់ទឹកឬការឆ្លងជំងឺពីទឹក គឺគ្រោះថ្នាក់ដល់សុខភាព ដែលបណ្តាលមកពីទឹក។ ទឹកមានមេរោគកើតឡើងដោយសារមូលហេតុផ្សេងៗ។ ការផ្គត់ផ្គង់ទឹកស្អាតតែងតែមានមេរោគនៅក្នុងពេលទឹកជំនន់ហូរមកពីប្រព័ន្ធលូទឹកសំអុយ និងកសិកម្មនិងអនុផលនានា។ បន្ថែមលើនេះ ទំនងជាមានមេរោគពីខ្លួនហូរចូលទៅក្នុងទឹកស្អាត។ បើទោះជា ស្បែកប៉ះពាល់ជាមួយទឹលជំនន់មិនមានគ្រោះថ្នាក់ដល់សុខភាពធ្ងន់ធ្ងរក្តី ក៏មានគ្រោះថ្នាក់ដែលក្លាយជាឈឺដោយសារការបរិភោគអ្វីមួយដែលមានមេរោគពីទឹកជំនន់ដែរ។ ការថែទាំត្រឹមត្រូវត្រូវតែបូមទឹកដែលមានមេរោគនោះចេញ ហើយដោយសារតែវាមានជំងឺឆ្លង ត្រូវរកពេទ្យមកព្យាបាលជាបន្ទាន់។

**តួនាទីរបស់ PCDM និង DCDM សំរាប់ផ្តល់ទឹកស្អាត អនាម័យកំឡុងពេលទឹកជំនន់**

- ជំរុញអង្គការ-ភ្នាក់ងារពាក់ព័ន្ធ ពោលគឺមន្ទីរសុខាភិបាលខេត្តក្រុងនិងមណ្ឌល សុខភាពផ្តល់សេវាសុខភាពតាមរយៈក្រុមចល័តឱ្យទៅជនរងគ្រោះដែលកំពុងរស់នៅក្នុងតំបន់សុវត្ថិភាព។
- ក្រុមសុខាភិបាលនិងអនាម័យខេត្តត្រូវជួយក្រុមថែទាំសុខភាពស្រុកក្នុងការលើកកំពស់ការយល់ដឹងរបស់ប្រជាជនក្នុងមូលដ្ឋានអំពីការថែទាំសុខភាពនិងអនាម័យជាមូលដ្ឋាន។
- ក្រុមសុខភាពនិងអនាម័យមកពីខេត្ត-ស្រុក ត្រូវធ្វើការប៉ាន់ប្រមាណជាមូលដ្ឋានអំពីឥទ្ធិពលលើសុខភាព និងការឆ្លងជំងឺនៅក្នុងតំបន់លិចទឹក។
- ក្រុមសុខភាពនិងអនាម័យស្រុកត្រូវរាយការណ៍ជាទៀងទាត់អំពីស្ថានភាពសុខភាពទូទៅ អនាម័យ និងទឹកស្អាតនៅក្នុងតំបន់លិចទឹក ជូនទៅមន្ទីរសុខាភិបាលខេត្ត ក្រសួងសុខាភិបាល និងអង្គការពាក់ព័ន្ធ។
- ក្រុមសុខភាពនិងអនាម័យខេត្ត និងមន្ទីរសុខាភិបាលខេត្ត ត្រូវតែស្នើសុំជំនួយបន្ថែមពីក្រសួងសុខាភិបាលនៅពេលចាំបាច់។
- DCDM ត្រូវតែធ្វើការជាមួយអាជ្ញាធរមូលដ្ឋានដើម្បីស៊ើបអង្កេតស្ថានភាពសុខភាព ជំងឺឆ្លង និងជំងឺរាតត្បាតដែលទាក់ទងនឹងអានម័យ និងនៅក្នុងទំបនរបស់ខ្លួន។

ដូច្នេះ ការពិចារណាសំខាន់ៗក្នុងការធ្វើផែនការសំរាប់ការផ្គត់ផ្គង់ទឹកស្អាត គឺ :

១. ការធានាផ្គត់ផ្គង់ទឹកហូបក្នុងជំរុំសង្គ្រោះ តំបន់សុវត្ថិភាព និងប្រជាជនដែលនៅតាមផ្ទះផ្ទាល់ខ្លួនក្នុងកំឡុងពេលគ្រោះអាសន្ន។

២. ការស្តារប្រព័ន្ធផ្គត់ផ្គង់ទឹកឡើងវិញ ដូចជា អណ្តូងស្នប់ ឧបករណ៍ស្តុកទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹកជ្រៅក្នុង

កំឡុងដំណាក់កាលស្តារឡើងវិញ។

អនាម័យគឺជាចំណុចសំខាន់ក្នុងការគ្រប់គ្រងទឹកជំនន់។ អាជ្ញាធរខេត្ត-ក្រុង ដែលមានការជួយពីក្រុមអ្នកស្ម័គ្រចិត្តមូលដ្ឋាន ត្រូវតែធានាបរិក្ខាអនាម័យល្អប្រសើរនៅតាមជំរុំសង្គ្រោះក្នុងតំបន់និងជំរកសុវត្ថិភាពនិងផ្តល់បង្គន់សមរម្យ ប្រព័ន្ធបង្ហូរទឹក និងប្រដាប់សំលាប់មេរោគធ្វើឱ្យតំបន់ស្អាត។

ការរាតត្បាតនៃជំងឺឆ្លងក្រោយពេលទឹកជំនន់គឺមិនធម្មតា ប៉ុន្តែមិនត្រូវព្រងើយកន្តើយ ចំពោះលទ្ធភាពដែលអាចកើតឡើងដោយសារតែបរិក្ខាអនាម័យខូចខាត ឬភាពចង្អៀតក្នុងចំណោមប្រជាជនផ្លាស់ទីភាសឹកតាមទីជំរកឬតំបន់សុវត្ថិភាពឡើយ។ ថ្នាំពេទ្យសំរាប់គ្រាអាសន្ន ត្រូវរក្សាទុកជាស្រេចនៅតាមមណ្ឌលសុខភាពនិងអុនសាសន៏ជាក់លាក់សំរាប់ការចាក់ថ្នាំបង្ការត្រូវតែមានតាមករណី ឬបានកំនត់ដោយមន្ទីរសុខាភិបាលខេត្ត និងមូលដ្ឋាន។

បន្ថែមលើនេះ សុខភាពរាងកាយ ផែនការស្តីពីការផ្តល់ការថែទាំនិងគាំទ្រផ្លូវចិត្តដល់ប្រជាជនរងគ្រោះ (ជាពិសេសកុមារ) ត្រូវតែគិតគូរ។

## VII ការធ្វើផែនការជីវភាពរស់នៅ

ដើម្បីធ្វើឱ្យផលប៉ះពាល់វិខាននៃទឹកជំនន់តិចបំផុតលើសកម្មភាពរកចំណូលរបស់សហគមន៏ ការគ្រប់គ្រងមុន ត្រូវតែធ្វើឡើងដើម្បីធានាឱ្យមានជំរើសសំរាប់ជីវភាពរស់នៅក្នុងកំឡុងពេលទឹកជំនន់ និងដើមីសំរបសំរួលការស្តារមុខងារសេដ្ឋកិច្ចរហ័សឡើងវិញក្រោពេលទឹកជំនន់(ប្រកបមុខរបរមុនពេលទឹកជំនន់ឡើងវិញ)។ នេះ មានសារៈសំខាន់បំផុត ជាពិសេស ក្នុងករណីដែលរយៈពេលទឹកជំនន់វែងនិងជំរើស "ការរស់នៅជាមួយទឹកជំនន" ត្រូវតែជំលៀសចេញ។ ភ្នាក់ងារសំខាន់ៗដែលត្រូវដឹកនាំដំណើរការនេះគឺសហគមន៏មូលដ្ឋានឬអង្គការធំៗ ដូចជាក្រុមកសិករ ឬសមាគមន៏អ្នកនេសាទ ដែលកំពុងធ្វើការនៅក្នុងតំបន់និងស៊ាំជាមួយនឹងប្រជាជនមូលដ្ឋាននិងស្ថានភាពរស់នៅរបស់ពួកគេ។ វិធីសាស្ត្រមានការចូលរួមមានសារៈសំខាន់ចាប់ពីពេលចាប់ផ្តើមដំណើរការដើម្បីធានាថា អ្នកទទួលការគ្រប់គ្រងតាមផែនការមានសំលេងលើបញ្ហាដែលកើតមានចំពោះជីវិតរបស់ពួកគេ។ ទាក់ទិននឹងអាជ្ញាធរមូលដ្ឋាន និងសហគមន៏ អង្គការមូលដ្ឋានអាចគូសផែនទីនិងអនុវត្តសកម្មភាពខុសៗពីគ្នាដូចបានចែងនៅខាងក្រោម :

- ការកាប់រានដីដាំដំណាំ ជាពិសេស នៅលើដីខ្ពស់
- ការបង្កើតធានាគារស្រូវនិងគ្រាប់ធញ្ញជាតិ
- គំរូវការបងនេសាទ(គ្រួសារដែលរស់នៅក្នុងផ្ទះសង់ផុតពីទឹកអាចធ្វើនេសាទកំឡុងពេលទឹកឡើង)
- ការផ្តល់ការបណ្តុះបណ្តាលអំពីរបៀបធ្វើសិប្បកម្មសំរាប់ស្ត្រីនិងសមាជិកសហគមន៏ដែលមានរបួសផ្លូវចិត្តឱ្យមានជំរើសរកចំណូលកំឡុងពេលទឹកជំនន់។

- បង្កើតថវិកាសំរាប់កសិកម្មនៅនៅក្នុងសហគមន៍ ។
- ការរៀបចំសួនដាំបន្លែ ។
- ការផ្តួចផ្តើមគំនិតពិភាក្សាជាមួយទីប្រជុំជន ឃុំ ភូមិសំរាប់បង្កើតការទទួលបានទីផ្សារនៅក្នុងតំបន់របស់ពួកគេដើម្បីលក់ផលិតផល ។
- បង្កើតក្រុមស្តារឡើងវិញសេដ្ឋកិច្ចសហគមន៍ និងផែនការស្តារជីវភាពសហគមន៍រហ័ស ។
- ការត្រៀមប្រតិទិនរដូវដាំដុះផ្អែកលើព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ និងការព្យាការណ៍ថ្មីៗ ។

ស្ថាប័នរដ្ឋពាក់ព័ន្ធអាចដើរតួជាទីប្រឹក្សាសំខាន់ក្នុងការធ្វើផែនការនិងអនុវត្តសកម្មភាពតាំងនេះ ។ ឧទាហរណ៍ មន្ទីរកសិកម្មអាចជួយផ្តល់ការណែនាំក្នុងការរៀបចំប្រតិទិនរដូវដាំដុះ រួមគ្នាជាមួយមន្ទីរគ្រប់គ្រងធនធានទឹក រីឯមន្ទីរកិច្ចការនារីនិងសង្គមកិច្ចអាចផ្តល់ការបណ្តុះបណ្តាលជំនាញល្អប្រសើរសំរាប់ប្រជាជនមូលដ្ឋាន ។

## *VIII **លំហាត់** Drills **និង** Mock*

លំហាត់ Drills និង Mock បំរើគោលបំនងលើកកំពស់ការយល់ដឹងរបស់សហគមន៍និងកសាងសមត្ថភាពត្រៀមបង្ការនៅតាមមូលដ្ឋាន ។ ត្រូវបង្កើតស៊ីណារីយ៉ូសប្បនិមិត្តស្រដៀងគ្នានឹងស្ថានភាពពិតនិងហាត់ធ្វើ Mock Drills ដើម្បីបង្ហាញបច្ចេកទេស ដែលប្រជាជនអាចត្រៀមបង្ការដោយខ្លួនឯងបានល្អបំផុតទប់ទល់នឹងគ្រោះមហន្តរាយទាំងនេះ ។ លំហាត់ទាំងនេះ កសាងជំនាញពិសេសរបស់សហគមន៍ ដូចជា :

- ការជំលៀសពេលគ្រោះអាសន្ន
- ការទទួលស្គាល់ ការស្វែងយល់ ការឆ្លើយតប និងការប្រកាសអាសន្នសមស្របនិងត្រៀមរួចជាស្រេច ដែលមាននៅតាមមូលដ្ឋានកំឡុងពេលមានគ្រោះអាសន្ន ។
- ដឹងច្បាស់អំពីតំបន់សុវត្ថិភាព-មណ្ឌលជំលៀស និងផ្លូវដែលមាន ។
- បង្កើតឱ្យមានការស្ម័គ្រចិត្ត ។

លំហាត់ Drills និង mock exercises របស់ក្រុមគ្រប់គ្រងគ្រោះអាសន្នជាក់លាក់ ត្រូវបានអនុវត្តនៅក្នុងព្រឹត្តិការណ៍សាធារណៈសំរាប់ឱ្យសាធារណៈជនមើល សំរាប់ការលើកទឹកចិត្ត និងការយល់ដឹងរបស់សាធារណជនទូទៅ ។

# ផ្នែកទី២ : ប្រតិបត្តិការឆ្លើយតបទឹកជំនន់

ប្រសិទ្ធិភាពនៃការឆ្លើយតបទឹកជំនន់ គឺស្ថិតនៅលើផ្នែកសំខាន់ៗដូចតទៅនេះ :

**ក. ការសហការមានប្រសិទ្ធិភាព :** ការសហការទូលំទូលាយក្នុងចំណោមភ្នាក់ងារទាំងអស់ដែលចូលរួមក្នុងសកម្មភាពឆ្លើយតប កត់ត្រាទុកភាពជោគជ័យរបស់ប្រតិបត្តិការឆ្លើយតបគ្រោះអាសន្នណាមួយ ការធានាភាពជាន់គ្នានៃតួនាទីនិងការទទួលខុសត្រូវឱ្យមានជាអប្បរមា និងការប្រើប្រាស់ធនធានដែលមានស្រាប់ឱ្យមានប្រសិទ្ធិភាព ។ ដាក់ពង្រាយភ្នាក់ងារបង្គោលមួយ ជាស្ថាប័នសំរបសំរួលគោល ។

**ខ. ការគ្រប់គ្រងភស្តុភាមានប្រសិទ្ធិភាព :** ចំពោះស្ថានការគ្រោះអាសន្នធំៗ ត្រូវកំនត់ធនធានដែលត្រូវការឱ្យបាន ឆាប់រហ័សក្នុងពេលទឹកជំនន់ ពោលគឺ ក្រុមឆ្លើយតប សំភារៈនិងរបស់ប្រើប្រាស់ ព្រមទាំងគ្រឿងគរ និងដឹកជញ្ជូនវា ទៅកន្លែងត្រឹមត្រូវឱ្យចំពេល ។ ប្រការពីរយ៉ាងធ្វើវាឱ្យកើតឡើងគឺ :

- <u>ការប៉ាន់ប្រមាណពេលវេលានិងបញ្ជីរដាក់ពង្រាយ</u> : បញ្ជីរអាទិភាពមួយនៃធនធានសំភារៈសំខាន់បំផុតធ្វើនៅមុនព្រឹត្តិការណ៍ ។
- <u>ការសំរបសំរួលដល់ការធ្វើចលនា</u> : តំរូវការសេវាកម្មដឹកជញ្ជូននិងការសំរបសំរួលចរន្តដឹកជញ្ជូនធនធាននៅក្នុងនិងនៅជុំវិញតំបន់ទឹកលិចប្រើបញ្ជីរអាទិភាព ការរាយការណ៍ជាបន្តអំពីចលនាធនធានដែលបានដឹកជញ្ជូនចេញនិងចូលតំបន់ទឹកជំនន់ ការតាមដានផលប៉ះពាល់របស់ទឹកជំនន់លើប្រព័ន្ធដឹកជញ្ជូននិងការដោះស្រាយផ្លូវ ឬបញ្ហាទៅដល់គោលដៅ ។

**គ. កិរិតការឆ្លើយតបរបស់សហគមន៍ :** សហគមន៍យល់ដឹងអំពីគ្រោះថ្នាក់ដែលពួកគេប្រឈមមុខទាក់ទងនឹងទឹកជំនន់ និងវិធាការដែលត្រូវធ្វើបានកាន់តែច្រើន ធ្វើឱ្យឥទ្ធិពលការឆ្លើយតបអាសន្នកាន់តែមានប្រសិទ្ធិភាព ។

ការឆ្លើយតបទឹកជំនន់ ត្រូវធ្វើឡើងជាមួយតួនាទី និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់ ដូចបានចែងក្នុងផែនការត្រៀមបង្ការទឹកជំនន់ និងយល់ដោយអ្នកអនុវត្តសំខាន់ៗដែលនឹងធ្វើវិធានការ ដែលបានស្នើរឡើងក្នុងពេលគ្រោះអាសន្ន ។

ការគ្រប់គ្រងគ្រោះអាសន្ន តំរូវឱ្យមានការសំរបសំរួល និងការសហការគ្នារវាងអ្នកអនុវត្តថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុកនិងថ្នាក់ឃុំ ។ ព័ត៌មានដើរតួសំខាន់ក្នុងការសំរេចចិត្តលើទំហំឆ្លើយតប និង ការដាក់ពង្រាយធនធាន ។ ជាញឹកញាប់ ប្រព័ន្ធឆ្លើយតបបរាជ័យដោយសារតែកង្វះការយល់ដឹងរវាងអ្នកពាក់ព័ន្ធផ្សេងៗគ្នា និងការសហការរវាងភ្នាក់ងារឆ្លើយតបធំៗ ដូចជា យោធានិងប៉ូលីស មន្ទីរគ្រប់គ្រងព័ត៌មាននិងអាជ្ញាធរមូលដ្ឋានគ្រប់គ្រងគ្រោះមហន្តរាយ ។

រឿងសំខាន់បំផុត ត្រូវទទួលស្គាល់នៅក្រោមដំណាក់កាលឆ្លើយតប គឺថាការផ្តល់ជំនួយ( ហិរញ្ញវត្ថុ សំភារៈ) ត្រូវតែបញ្ឈប់នៅត្រង់ចំណុចណាមួយក្នុងពេលការពារភាពពឹងផ្អែកទាំងស្រុងរបស់សាធារណជនលើការគាំទ្រពីខាងក្រៅ។ សំណួរដែលត្រូវសួរគឺ :

- តើគួរតែបន្តសកម្មភាពឆ្លើយតបអ្វីខ្លះ?
- តើនរណាគួរតែសំរបសំរួលសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលដែលបន្តធ្វើការងារនៅក្នុងពេលនេះ?
- តើត្រូវមានដំណោះស្រាយអ្វីដើម្បីធ្វើការងារបន្ត?
- តើកម្មវិធីរយៈពេលខ្លីបណ្តោះអាសន្នអាចក្លាយជាការស្តារនីតិសម្បទាឡើងវិញបានយ៉ាងដូចម្តេច?

សកម្មភាពសំខាន់៧នៃការឆ្លើយតបគ្រោះទឹកជំនន់មានពិពិណនានៅខាងក្រោម :

## I. *ការតាមដានទឹកជំនន់*

កំឡុងពេលឆ្លើយតបទឹកជំនន់ ស្ថានការណ៍ស្ងួនស្ញោនិងច្របូកច្របល់កើតមាន។ នេះ អាចដោះស្រាយបានដោយការបង្កើតប្រព័ន្ធតាមដានទឹកជំនន់ឱ្យបានគ្រប់គ្រាន់នៅតាមមូលដ្ឋាន។ ការតាមដានទឹកជំនន់ ធ្វើឡើងចាប់តាំងពីពេលព័ត៌មានទឹកជំនន់សំរាប់អ្នកគ្រប់គ្រងគ្រោះមហន្តរាយនៅតាមមូលដ្ឋាន ផ្តល់ឧបករណ៏ឱ្យពួកគេត្រួតពិនិត្យលើប្រតិបត្តិការគ្រោះអាសន្នឱ្យទាន់ពេលវេលា។ សកម្មភាពធ្វើទាន់ពេលវេលាមានដូចជា ការប្រកាសភាពអាសន្នទឹកជំនន់ ការជំលៀសប្រជាពលរដ្ឋដែលងាយរងគ្រោះទៅកាន់តំបន់សុវត្ថិភាព ការដាក់ពង្រាយក្រុមស្វែងរកនិងសង្គ្រោះ ពឹងផ្អែកលើព័ត៌មានទាន់ហេតុការណ៏ អំពីកំរិតទឹកចុងក្រោយបំផុតនៅតាមទន្លេ ជាចំណុចពិសេសមួយ។

ការតាមដានគ្រោះទឹកជំនន់ក្នុងកំឡុងពេលភាពអាសន្ន ជាធម្មតាធ្វើឡើងដោយភ្នាក់ងារដូចគ្នាដែលទទួលខុសត្រូវខាងការព្យាករណ៏និងប្រកាសភាពអាសន្ន ។ ក្នុងករណីបណ្តាប្រទេសដែលស្ថិតនៅតាមអាងទន្លេមេគង្គក្រោម មន្ទីរខុទ្ទនិយមជលសាស្ត្រក្នុងមូលដ្ឋាននឹងធ្វើជាភ្នាក់ងារដឹកនាំ។ តែទោះជាយ៉ាងណាក៏ដោយ ការតាមដានបន្តត្រូវតែមានក្នុងកំឡុងពេលវិបត្តិ ដែលអាចលើសពីសមត្ថភាពរបស់មន្ទីរផងដែរ។ នៅក្នុងកាលៈទេសៈបែបនេះ គណៈកម្មាធិការ ឬក្រុមឃ្លាំមើលទឹកជំនន់មូលដ្ឋាន ក៏អាចឃ្លាំមើលទឹកជំនន់រយៈពេល២៤ម៉ោងនៅក្នុងភូមិបានផ្សព្វផ្សាយព័ត៌មានត្រឹមត្រូវប្រកាសភាពអាសន្នឱ្យសាធារណៈជនបានដឹង *(សេចក្តីលំអិតថែមទៀតមាននៅក្នុងផ្នែកស្តីពីការព្យាករណ៏និងផ្សព្វផ្សាយភាពអាសន្នមុន ភាគទី២)* ។

## II. ការព្យាករណ៏ និងការផ្សព្វផ្សាយគ្រោះអាសន្នមុន

ដូចបាននិយាយថាជាផ្នែកនៃវិធានការត្រៀមបង្ការក្នុងជំពូកនេះ សារប្រកាសភាពអាសន្នទឹកជំនន់ ត្រូវតែត្រឹមត្រូវនិងងាយយល់ដោយសហគមន៍ និងមន្ត្រីដែលនឹងអនុវត្តសកម្មភាព។ ព័តិមានត្រូវផ្អែកលើស្ថានភាពពិតតាមពេលវេលា(ព័តិមានផ្ដល់ឱ្យតាមរយៈការតាមដាន និងការបញ្ជូនទឹកជំនន់)។

តួនាទីរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយ គឺត្រូវសហការជាមួក្រុមឆ្លើយតប និងភ្នាក់ងារដែលទទួលខុសត្រូវចំពោះការចេញប្រកាសភាពអាសន្ន(មន្ទីរឧត្តុនិយមជលសាស្ត្រ)ស្ថានភាពទឹកជំនន់ (មន្ទីរព័តិមានទូរទស្សន៍ និងកាសែត)និងធានាថា ប្រជាជនដែលកំពុងទទួលបានសារប្រកាសភាពអាសន្ន បានទទួលទៀងទាត់និងចេះមានវិធានការ។ នៅតាមថ្នាក់ភូមិ ឬថ្នាក់ទាបជាងភូមិ ក្រុមអ្នកស្ម័គ្រចិត្តអាចជួយផ្សព្វផ្សាយព័តិមានបានតាមរយៈឧបករណ៍បំពងសំលេង។

## III ប្រតិបត្តិការជំលៀស

**ការអំពាវនាវជំលៀស**

- **ប្រសិនបើគេឱ្យជំលៀស ត្រូវធ្វើតាមភ្លាម។**
- **ការជំលៀសងាយស្រួល និងសុវត្ថិភាពជាងនៅមុនពេលទឹកជំនន់ឡើងកាន់តែជ្រៅ សំរាប់យានដ្ឋធម្មតាបើកាត់។**
- **ស្ដាប់វិទ្យុអំពីការណែនាំឱ្យជំលៀស។**
- **ទៅតាមផ្លូវដែលស្នើឱ្យជំលៀស ផ្លូវកាត់អាចបិទ។**
- **ចាកចេញឱ្យឆាប់មុន ជៀសវាងការជាប់គាំងដោយទឹកជំនន់។**

*FEMA, 1993*

ផែនការត្រៀមបង្ការទឹកជំនន់ល្អមួយ ត្រូវមានកំណត់ទីតាំងជំលៀស ផ្លូវនិងជំរកមានសុវត្ថិភាព មានប្រយោជន៍ដើម្បីជំលៀសប្រជាជនដែលរងគ្រោះចេញពីតំបន់លិចទឹកទៅកាន់តំបន់សុវត្ថិភាព។ ផែនទីមានប្រយោជន៍ខ្លាំងបំផុតសំរាប់សកម្មភាពនេះ។

ពេលវេលា គឺជាកត្តាសំខាន់ក្នុងកំឡុងពេលជំលៀសប្រជាជនទៅកន្លែងសុវត្ថិភាព។ អាជ្ញាធរមូលដ្ឋានគឺជាចៅក្រមល្អបំផុតកំនត់ពេលវេលាត្រឹមត្រូវសំរាប់ការជំលៀសផ្អែកលើការប្រកាសភាពអាសន្នមុន និងស្ថានភាពទឹកជំនន់ចុងក្រោយបំផុត(ការតាមដានទឹកជំនន់អាចផ្ដល់ឱ្យព័តិមានពាក់ព័ន្ធ)។ ប្រសិនបើការសំរេចចិត្តជំលៀសមិនធ្វើទាន់ពេលវេលាទេ ការបាត់បង់ជីវិតនិងទ្រព្យសម្បត្តិអាចខ្ពស់។

ប្រសិនបើការជំលៀសតំរូវឱ្យមានទ្រង់ទ្រាយធំ ប្រតិបត្តិការ ជាធម្មតា ត្រូវធ្វើឡើងដោយបុគ្គលិកដែលទទួលបានការបណ្ដុះបណ្ដាល ដូចជា ភ្នាក់ងារ ជាអង្គការកាកបាទក្រហមជាតិ កងកំលាំងយោធានិងប៉ូលីសមូលដ្ឋាន សហការជាមួយអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន។ គ្រួសារនីមួយៗ នៅពេលបានដឹងអំពីគ្រោះថ្នាក់ជាយូរមកហើយ អាចរៀបចំជំលៀសដោយខ្លួនឯងទៅកាន់កន្លែងដែលពួកគេត្រូវទៅ(ជំរកសុវត្ថិភាពផ្ទះសាច់ញាតិ)។ ត្រូវផ្ដល់អាទិភាពនិងការថែទាំពិសេសឱ្យទៅប្រជាជនដែលត្រូវជំលៀសដែលពឹងផ្អែកលើអ្នកដទៃសំរាប់ការធ្វើដំណើរដោយសារតែមូលហេតុរាងកាយ សេដ្ឋកិច្ច សង្គមឬវប្បធម៌ ដូចជា មនុស្សចាស់ជរាជនពិការ ស្ត្រីមានផ្ទៃពោះ ជនក្រីក្រ កុមារនិងក្រុមជនជាតិភាគតិច។

## IV. តំបន់សុវត្ថិភាព និងការគ្រប់គ្រងជំរកបណ្ដោះអាសន្ន

ដើម្បីផ្តល់ទីសុវត្ថិភាពដល់ប្រជាជនរងគ្រោះទឹកជំនន់ដែលស្ថិតនៅក្នុងស្ថានភាពអសន្តិសុខ គ្មានផ្ទះសម្បែង និងប្រញាប់ប្រញាល់ មុនការកំនត់រកតំបន់ដីខ្ពស់ ដែលមានសុវត្ថិភាពសំរាប់ការស្នាក់នៅជាបណ្តោះអាសន្នក្នុងកំឡុងពេលទឹកជំនន់ ត្រូវបានចាត់ទុកថាជាសកម្មភាពមួយសំខាន់បំផុតនៅក្នុងផ្នែកទី១នៃជំពូកនេះ។ នៅពេលទឹកជំនន់ឡើងដល់កំពូល ហើយអ្នកសហគមន៍ដែលងាយរងគ្រោះត្រូវបានជំលៀសទៅតំបន់សុវត្ថិភាព ការគ្រប់គ្រងតំបន់ទាំងនេះក្លាយជាអាជ្ញាបញ្ជារ។

ជំហានដំបូង ត្រូវធានាឱ្យមានសំភារៈចាំបាច់។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន រួមជាមួយអង្គការក្រៅរដ្ឋាភិបាល និងក្រុមស្ម័គ្រចិត្ត ត្រូវតែប្រមែប្រមូលតង់បណ្តោះអាសន្ន ក្រណាត់កៅស៊ូនិងផ្ទះចល័ត ហើយដឹកជញ្ជូនវាទៅតំបន់សុវត្ថិភាព។ វាក៏មានសំខាន់ផងដែរ ត្រូវបំពាក់បរិក្ខាដែលមានស្តង់ដារនិងមូលដ្ឋានអប្បរមា ដូចជាស្បៀង ទឹកផឹក បរិក្ខាអនាម័យនៅតាមតំបន់សុវត្ថិភាព។ ប្រព័ន្ធចំរោះទឹក ក៏ត្រូវតែគិតគូរនិងបំពាក់នៅតាមទីជំរកបណ្តោះអាសន្ន។

សន្តិសុខគឺជាការព្រួយបារម្ភសំខាន់មួយសំរាប់ប្រជាជនដែលបានជំលៀស ជាពិសេស ស្ត្រីងាយរងគ្រោះទៅនឹងការបៀតបៀនលើផ្លូវភេទ។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានត្រូវតែផ្តល់វិធានការសន្តិសុខជាមួយជំនួយពីប៉ូលីស យោធាឬប៉ូលីសឃុំដើម្បីធានាសន្តិសុខនិងសុវត្ថិភាពនៅក្នុងតំបន់សុវត្ថិភាព។ ការថែទាំកុមារគឺជាបញ្ហាសំខាន់មួយទៀតនៅឯជំរកបណ្តោះអាសន្ន ដោយសារតែមានករណីស្លាប់ដោយលង់ទឹកត្រូវបានរាយការណ៍ពីគ្រួសារដែលបានជំលៀសទៅកាន់តំបន់សុវត្ថិភាព។ ការបង្កើតសាលាមត្តេយ្យបណ្តោះអាសន្នដោយមានជំនួយមកពី ក្រុមស្ត្រីនិងអង្គការក្រៅរដ្ឋាភិបាល គឺជាជំរើសមួយល្អបំផុតដើម្បីធានាសុវត្ថិភាពកុមារក្មេងៗ។ នៅក្នុងតំបន់ដីសណ្តរមេគង្គនៃប្រទេសវៀតណាម សាលាមត្តេយ្យគ្រាអាសន្ន គ្រប់គ្រងដោយសហជីពស្ត្រី សហការជាមួយមន្ទីរអប់រំ គណៈកម្មាធិការប្រជាជន គ្រួសារនិងកុមារ និងគណៈកម្មាធិការទឹកជំនន់និងខ្យល់ព្យុះនៅថ្នាក់ខេត្ត។

## V. ប្រតិបត្តិការស្វែងរក និង សង្គ្រោះ

ក្នុងការអនុវត្តន៏ប្រតិបត្តិការស្វែងរកនិងសង្គ្រោះ វាសំខាន់ត្រង់ថា ក្រុមស្វែងរកនិងសង្គ្រោះ ត្រូវតែដឹកនាំដោយការបញ្ជារតែមួយ។ ក្រុមត្រូវតែកំនត់អាទិភាពលើទីតាំងចំណុចដែលងាយរកគ្រោះខ្លាំងបំផុតនៅក្នុងតំបន់ ហើយប៉ុស្តិ៍សង្គ្រោះត្រូវតែបង្កើតឡើង។ នៅក្នុងតំបន់ដីសណ្តរមេគង្គនៃប្រទេសវៀតណាម ប៉ុស្តិ៍សង្គ្រោះត្រូវបានបង្កើតឡើងតាមឥទ្ធិពលនៃព្រែកជីកនិងទន្លេនិងតាមកន្លែងដែលចរាចរទឹកខ្លាំងបំផុត។

វាត្រូវតែប្រាកដថា ឧបករណ៏ស្វែងរកនិងសង្គ្រោះ ដូចជា ទូក ខ្សែរពួរ ពោងបណ្តែត និងអាវពោងសង្គ្រោះ មានក្នុងដៃគ្រប់ពេល។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ត្រូវធានាថា បញ្ជីរធនធាន(បញ្ជីរសារពើភ័ណ្ឌធនធាន) មានថ្មីជានិច្ច ហើយឧបករណ៏នៅប្រើការបាន។ សំរាប់សេចក្តីលំអិតនៃឧបករណ៏នេះ សូមមើលទៅផ្នែកទី៧នៃផែនការត្រៀមបង្ការទឹកជំនន់ ស្តីពីបញ្ជីរសារពើភ័ណ្ឌ។

## VI ការថែទាំសុខភាព និង ប្រតិបត្តិការផ្នែកសុខាភិបាល

**ការសង្គ្រោះបឋមសំរាប់អ្នកលង់ទឹក**

**ក្នុងសៀវភៅសង្គ្រោះបឋម**

- ដំបូង ព្យាយាមចូលឱ្យដល់មនុស្សជាមួយឈើមួយឬហុចដៃឱ្យចាប់។ ប្រសិនបើអ្នកមិនអាចទៅដល់ទេប្រើខ្សែរពួរ។
- ប្រសិនបើមនុស្សនៅឆ្ងាយពីអ្នក អ្នកអាចចូលឱ្យដល់និង ហើយអ្នកអាចសំរេចចិត្តចុះទៅក្នុងទឹក ចូលឱ្យដល់មនុស្ស ដោយប្រុងប្រយ័ត្ន និងទៅពីខាងក្រោយ។ ព្យាយាមនិយាយជាមួយគេ ធ្វើឱ្យគេស្ងប់អារម្មណ៍ ហើយរំកិលចូលជិត។ ធ្វើឱ្យគេនិយាយ។ បើគ្មានបញ្ហាទេ ប្រាប់គាត់ឱ្យធ្វើតាមការណែនាំរបស់អ្នក។
- ចាប់ទាញអាវ ឬដាក់ដៃទ្រចង្ការគាត់ ហើយទាញគាត់មកច្រាំងវិញ។
- ប្រាប់គាត់ឱ្យដកដៃចេញពីអ្នក។ បន្តនិយាយឱ្យគាត់បានស្ងប់ចិត្តឡើងវិញ។
- ចាប់ផ្តើមសង្គ្រោះឱ្យដកដង្ហើម ប្រសិនបើគាត់ឈប់ដកដង្ហើម។
- នៅពេលជិតលងទឹក តើគាត់មានជំងឺក្អកឬឈឺសាច់ដុំដែរឬទេ?
- ជនរងគ្រោះទាំងអស់ត្រូវតែទៅជួបគ្រូពេទ្យ ព្រោះបញ្ហាសួតតែងតែកើតមាន នៅពេលលង់ទឹក។
- យកជនរងគ្រោះចេញពីទឹក ប្រសិនបើអ្នកអាចធ្វើបានដោយសុវត្ថិភាព និងធ្វើ Do Cardiopulmonary Resuscitation (CPR)
- ប្រសិនបើគាត់មិនដកដង្ហើម ប៉ុន្តែមានជីពចរ ចាប់ផ្តើមការដងដង្ហើមមាត់ទល់នឹងមាត់។
- ប្រសិនជងរងគ្រោះដកដង្ហើម មានជីពចរ ធ្វើឱ្យគាត់ដឹងខ្លួនឡើងវិញតាមរបៀប Recovery position របៀបនេះធ្វើឱ្យមានផ្លូវខ្យល់ចេញចូល និងលេបទឹកឬក្អួតចេញ។
- ដោះខោអាវទទឹកចេញពីជនរងគ្រោះ ហើយយកអ្វីផ្សេងមកដណ្តប់ជំនួស ការពារការចុះកំដៅអស់ពីខ្លួន។

នៅក្នុងតំបន់ជាច្រើន ការដាក់ពង្រាយនៃក្រុមសង្គ្រោះបឋម ជួនកាល ដើរតួមុនគេជាក្រុមស្វែងរកនិងសង្គ្រោះ មើលព្យាបាលប្រជាជន និងសត្វពាហនៈមានរបួស។ ក្រុមស្វែងរកនិងសង្គ្រោះ ត្រូវមានបុគ្គលិកពេទ្យដែលអាចធ្វើការសង្គ្រោះបឋមបាន។

ក្នុងកំឡុងពេលទឹកជំនន់ ការលងលទឹកគឺជាមូលហេតុសំខាន់នៃការស្លាប់ ហើយគោលការណ៏សង្គ្រោះបឋមខ្លះសំរាប់ករណីលង់ទឹកមានពន្យល់នៅក្នុងប្រអប់ខាងលើ។ គ្រប់ជំរកសុវត្ថិភាព ត្រូវមានឧបករណ៏សង្គ្រោះបឋម ថ្នាំពេទ្យ និងកន្លែងពេទ្យដើម្បីផ្តល់តំរូវការខាងសុខាភិបាលពិសេសក្នុងកំឡុងពេលគ្រោះអាសន្ន។ ដូចមានចែងនៅក្នុងជំពូកទី៥នៃឯកសារមេរៀននេះ ក្រុមពិសេសមួយដែលផ្តោតលើបញ្ហាសុខភាពនិងអនាម័យអាចបង្កើតឡើងនៅតាមថ្នាក់មូលដ្ឋាន។ ក្រុមអាចមានតំណាងមកពីមន្ទីរសុខាភិបាល-គ្លីនិកមូលដ្ឋាន និងសាខាកាកបាទក្រហម។

ជាបន្ថែម ក្រុមសុខាភិបាល ត្រូវតែផ្តល់ការថែទាំសុខភាព ក៏ដូចជាមើលខុសត្រូវលើផ្នែកទឹក និងអនាម័យការបង្ការជំងឺបណ្តាលមកពីទឹក រោគរាតត្បាតនៅក្នុងតំបន់លិចទឹក។ កិច្ចការរបស់គេមាន ការផ្តល់បរិក្ខារផ្គត់ផ្គង់

ទឹកស្អាតនៅតាមជំរកសុវត្ថិភាព ការអប់រំសាធារណជនអំពីផលប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត និងការជំរុញឱ្យមន្ទីរពាក់ព័ន្ធរបស់រដ្ឋាភិបាលផ្សេងទៀតរួមចំណែកដល់បញ្ហាសុខភាពនិងអនាម័យ តាមមធ្យោបាយដែលពួកគេអាចធ្វើបាន។ ក្នុងពេលដំណាលគ្នានេះដែរ ក្រុមសុខាភិបាល ត្រូវតែស្វែងរកលទ្ធភាពផ្តល់ការថែទាំខាងចិត្តសាស្រ្តសង្គមដល់ប្រជាពលរដ្ឋដែលរងគ្រោះដោយទឹកជំនន់ ដើម្បីជួយព្យាបាលភាពតានតឹងផ្លូវចិត្តរបស់ពួកគេ។

## VII. ***ការប៉ាន់ប្រមាណរហ័សអំពីការខូចខាត និងតំរូវការ***

ក្នុងការឆ្លើយតបគ្រោះទឹកជំនន់ ភ្នាក់ងាររដ្ឋាភិបាលមូលដ្ឋាននីមួយៗ ដែលមានកិច្ចការជាក់លាក់នៅក្នុងផែនការត្រៀមបង្ការទឹកជំនន់ មានសិទ្ធិចាត់វិធានការដោះស្រាយជាមន្ទាន់ដើម្បីបំពេញនូវសេចក្តីត្រូវការបន្ទាន់របស់សហគមន៍ដែលរងគ្រោះ។ នៅពេលដែលស្ថានភាពទឹកជំនន់ក្លាយជាធ្ងន់ធ្ងរ ការប៉ាន់ប្រមាណរហ័សមួយ អំពីស្ថានភាពចុងក្រោយ ត្រូវអនុលោមទៅតាមតំរូវការបន្ទាន់ ដែលមានធ្វើបច្ចុប្បន្នភាពជាញឹកញាប់ថាជា ស្ថានភាពវិវត្តន៍។ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានត្រូវធានាថា ទម្រង់និងគោលការណ៍ចាំបាច់បានផ្តល់ទៅឱ្យក្រុមប៉ាន់ប្រមាណរហ័សនិងព័ត៌មានដើម្បីកត់ត្រា និងរាយការណ៍បានត្រឹមត្រូវអំពីការខូចខាត និងតំរូវការបន្ទាន់។

ក្នុងកំឡុងដំណាក់កាលឆ្លើយតប ការខ្វះការសំរបសំរួល ការសហការ និងការផ្លាស់ប្តូរព័ត៌មានក្នុងចំណោមភ្នាក់ងារ ក្រុមឆ្លើយតប និងក្រុមអ្នកស្ម័គ្រចិត្តអាចនាំទៅរកស្ថានភាពមិនធម្មតា។ ហេតុដូច្នេះ សហគមន៍ខ្លះទទួលសំភារៈជំនួយច្រើនពេក រីឯអ្នកផ្សេងទៀត គេមិនយកចិត្តទុកដាក់។ នៅពេលដំណាលគ្នានេះ ព័ត៌មានមិនត្រឹមត្រូវ ឬមិនសព្វគ្រប់អំពីការខូចខាតបានកើតឡើងអាចជាលទ្ធផលមិនអាចជួសជុលហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗឱ្យមានប្រសិទ្ធិភាពបាន។ ការប៉ាន់ប្រមាណការខូចខាត និងតំរូវការ អាចដោះស្រាយបញ្ហាទាំងនេះបាន ដោយការធ្វើឱ្យព័ត៌មានអំពីការខូចខាត និងតំរូវការពិតជាក់ស្តែងអាចជឿទុកចិត្តបាន នៅក្នុងតំបន់រងគ្រោះដោយទឹកជំនន់។

ការប៉ាន់ប្រមាណ ត្រូវតែធ្វើឡើងដោយទាំងភ្នាក់ងាររដ្ឋាភិបាល និងភ្នាក់ងារក្រៅរដ្ឋាភិបាលនៅថ្នាក់សហគមន៍ ក្រោមការដឹកនាំរបស់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ឬភ្នាក់ងារដែលបានជ្រើសតាំង ដោយផ្តោតលើការលើកកំពស់ការប៉ាន់ប្រមាណតាមបែបមានការចូលរួម។ ការប៉ាន់ប្រមាណរហ័សមួយត្រូវចេញជាលទ្ធផលអំពីការបែងចែងសំភារៈសង្គ្រោះ និងការបង្កើតអាទិភាពជួយ។ វាគាំទ្រការប្រើប្រាស់ជាអតិប្បរមានូវធនធានដែលមានស្រាប់នៅតាមមូលដ្ឋាន។

## VIII. ***ការសំរបសំរួល និងការគ្រប់គ្រងជំនួយសង្គ្រោះ***

នៅពេលទឹកជំនន់កើតឡើង សំភារៈជំនួយសង្គ្រោះរាប់តោន មានន័យថាជាការជួយបន្ទាន់ឬសហគមន៍រងគ្រោះមកដល់តំបន់ដែលរងគ្រោះ ដែលបានប្រមូលកៀងគរដោយភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល កាកបាទក្រហម និងក្រុមអ្នកស្ម័គ្រចិត្តផ្សេងទៀត។ ការបែងចែក ជាធម្មតា ធ្វើឡើង

តាមរយៈបណ្តាញដែលមានរបស់ភ្នាក់ងារដែលបានលើកឡើងពីខាងលើ។ ទោះជាយ៉ាងនេះក៏ដោយ ក៏មានករណីដែលជំនួយសង្គ្រោះមិនបានទៅដល់ប្រជាជនដែលរងគ្រោះឱ្យបានគ្រប់គ្រាន់នោះទេ ទាំងបរិមាណ និងពេលវេលា ពីព្រោះតែកង្វះនូវការសហការក្នុងចំណោមអ្នកពាក់ព័ន្ធសំខាន់ៗ។ ដូចនេះ ការសហការនិងការគ្រប់គ្រងប្រតិបត្តិការជំនួយសង្គ្រោះក្នុងកំឡុងពេលគ្រោះមហន្តរាយគឺជាស្នូលនៃភាពជោគជ័យរបស់ប្រតិបត្តិការស្តារឡើងវិញ។

អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋានត្រូវតែចាប់យកតួនាទីដឹកនាំមុខគេក្នុងការសំរបសំរួលជំនួយសង្គ្រោះ និងធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមស្របទៅតាមការប៉ាន់ប្រមាណពីតំរូវការ និងដំណើរការជ្រើសរើសអ្នកទទួលផល។ កិច្ចប្រជុំសំរបសំរួលជាមួយ អ្នកពាក់ព័ន្ធទាំងអស់ និងអ្នកដឹកនាំក្រុមបែងចែកជំនួយសង្គ្រោះត្រូវតែធ្វើឡើង យ៉ាងហោចណាស់មួយថ្ងៃម្តងដើម្បីពិនិត្យការបែងចែកជំនួយសង្គ្រោះឡើងវិញ និងកំនត់តំរូវការសំរាប់អនាគត។ អាជ្ញាធរថ្នាក់ជាតិ ត្រូវតែចូលរួមធានាការគាំទ្រខាងផ្នែកនយោបាយ។ ក៏ត្រូវមានកម្មវិធីមួយចែងច្បាស់លាស់អំពីពេលវេលាដកដំណាក់កាលឆ្លើយតបចេញ(ការបន្តការបែងចែកជំនួយសង្គ្រោះ) និងពេលចាប់ផ្តើមធ្វើដំណើរការស្តារនីតិសម្បទា។

បញ្ជីរសារពើភ័ណ្ឌធនធានដែលបានបង្កើតឡើង បំរើជាឯកសារសំខាន់មួយដល់ការឃ្លាំមើលការសំរបសំរួលនិងបែងចែកជំនួយសង្គ្រោះ ព្រោះវាមានព័ត៌មានអំពីកន្លែងស្តុកទុក ចំណុះនិងសំភារៈដែលមាននៅក្នុងតំបន់។ ដើម្បីជៀសវាងការចោទប្រកាន់អំពីការអនុវត្តន៍មិនល្អនៅក្នុងការបែងចែកជំនួយសង្គ្រោះ ប្រព័ន្ធកត់ត្រាត្រឹមត្រូវមួយត្រូវមាននៅនឹងកន្លែង។

ផ្នែកមួយនៃការសំរបសំរួលនិងគ្រប់គ្រងជំនួយសង្គ្រោះដែលត្រូវការការប្រុងប្រយ័ត្នខ្ពស់ គឺការដោះស្រាយជាមួយប្រព័ន្ធសារព័ត៌មាន។ នៅពេលដែលឥទ្ធិពលទឹកជំនន់លើសលប់លើលទ្ធភាពរបស់អាជ្ញាធរមូលដ្ឋាននិងសហគមន៍ គួរតែផ្តល់សញ្ញាចេញទៅឱ្យអ្នកដើរតួខាងក្រៅ។ នេះ អាចធ្វើបានតាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗដែលមានមកពីបណ្តាញរដ្ឋវិការ ដើម្បីប្រកាសជូនដំណឹងអំពាវនាវលើទូរទស្សន៍ជាតិ។ ក្នុងករណីខ្លះ ត្រូវប្រុងប្រយ័ត្នមិនឱ្យស្ថានភាពស្មុគ្រស្មាញពេក ហើយលើកយកតែការពិតជាក់ស្តែងមកនិយាយដើម្បីសុំជំនួយជាក់លាក់។ ពេលនោះ ភ្នាក់ងារផ្តល់ជំនួយខាងក្រៅអាចយល់បានពីតំរូវការនិងផ្តល់ឱ្យនូវធនធានតាមតំរូវការបាន។

# ផ្នែកទី៣ : វិធានការស្តារឡើងវិញ និងការស្តារនីតិសម្បទាទឹកជំនន់

ដំណាក់កាលស្តារនិងស្តារនីតិសម្បទាទឹកជំនន់ឡើងវិញមានគោលបំណងធ្វើឱ្យមានភាពជាធម្មតាឡើងវិញនិងជួប្រជាជនត្រឡប់ទៅរកមុខរបរខាងផ្នែកសេដ្ឋកិច្ចនិងសង្គមដូចពីមុនឡើងវិញរបស់ពួកគេ។

វាសំខាន់ត្រង់ថា អកពាក់ព័ន្ធទាំងអស់ រួមទាំងភ្នាក់ងារនិងក្រសួងពាកព័ន្ធជាមួយនឹងការបង្កើតនិងទិសដៅកម្មវិធីស្តារឡើងវិញយល់ច្បាស់អំពីលក្ខណៈនៃការស្តារឡើងវិញ។ ផ្នែកភាគច្រើននៃការស្តារឡើងវិញប្រើចំពោះការស្តារឡើងវិញ ការសាងសង់និងការស្តនីតិសម្បទាសហគមន៏រយៈពេលវែង។ ដូចនេះ ដំណើរការស្តារឡើងវិញមានភាពចំរុះនិងទូលំទូលាយ វាអាចបង្កើតជាបញ្ហាទ្វេរដង ដែលក្នុងនោះនឹងចាំបាច់ផ្លាស់ប្តូរផែនការដើមដែលជាដំណើរការស្តារឡើងវិញឱ្យទៅមុខ។ តំរូវការអនុវត្តកម្មវិធីស្តារទឹកជំនន់ឡើងវិញ តែងតែមានការពាក់ព័ន្ធជាមួយផែនការអភិវឌ្ឍថ្នាក់ជាតិ និងថ្នាក់ស្រុក។ បើអាចធ្វើទៅបាន វាប្រាថ្នាចង់បង្រួបបង្រួមវិស័យសមស្របរបស់ការស្តារឡើងវិញជាមួយការធ្វើផែនការអភិវឌ្ឍ។

នៅថ្នាក់ខេត្តនិងថ្នាក់ស្រុក កម្មវិធីស្តារឡើងវិញភាគច្រើន ជាពិសេស កម្មវិធីដែលទាក់ទងនឹងការសាងសង់ធំៗ តែងតែមានតំលៃច្រើន។ ក្នុងដំណាក់កាលដំបូងនៃដំណើរការស្តារឡើងវិញ វាសំខាន់ ត្រូវបង្កើតធនធានហិរញ្ញវត្ថុដែលមានដើម្បីអនុវត្តកម្មវិធីទាំងនេះ។ ស្រដៀងគ្នានេះ ការប៉ាន់ប្រមាណតំរូវការធនធាន(ដូចជាឧបករណ៏ សំភារៈ បុគ្គលិកមានជំនាញ)និងអ្វីដែលមានស្រាប់ហើយ។ វិស័យទាំងនេះមានសារៈសំខាន់សំរាប់កំនត់ទំហំនិងទ្រង់ទ្រាយនៃកម្មវិធីស្តារឡើងវិញជារួម។ ការប៉ាន់ប្រមាណក្រោយពេទ្យគ្រោះមហន្តរាយអំពីការខូចខាតនិងការបាត់បង់ គឺជាគន្លឹះចំពោះវិធានការស្តារឡើងវិញនិងការស្តារនីតិសម្បទា និងត្រូវអនុវត្តឡើងតាមបែបវិទ្យាសាស្ត្រគ្របដណ្តប់លើផ្នែកសំខាន់ៗទាក់ទងនឹងវិស័យសង្គម សេដ្ឋកិច្ច បរិដ្ឋាននិងរូបសាស្ត្រ។

ការចូលរួមរបស់សហគមន៏ក្នុងគ្រប់វិស័យទាំងអស់នៃផែនការស្តារឡើងវិញនិងការអនុវត្តមានសារៈសំខាន់។ វាមានប្រយោជនច្រើនដូចតទៅ :

- ធ្វើឱ្យមានការកំនត់បញ្ហានិងឱកាសបានត្រឹមត្រូវនិងមធ្យោបាយមានប្រសិទ្ធិភាពភាគច្រើនដោះស្រាយស្ថានភាពចាប់តាំងពីការផ្អែកលើនិយមន័យរបស់ប្រជាជនផ្ទាល់អំពីតំរូវការនិងអាទិភាពពិតប្រាកដ។
- ធានាថា សកម្មភាពមានការសំរបសំរួលតាមមធ្យោបាយជាប់ទាក់ទងគ្នានិងត្រូវគ្នាជាមួយគោលដៅនិងសកម្មភាពអភិវឌ្ឍសហគមន៏ ការបង្ការជំលោះនិងការកាត់បន្ថយតំលៃអនុវត្តន៏។
- អប់រំសហគមន៏អំពីធនធាននិងសមត្ថភាពដែលមាន។

- កសាងការគាំទ្រនិងភាពជាម្ចាស់របស់ផែនការត្រៀមបង្ការទឹកជំនន់ ដូច្នេះ ត្រូវបង្កើនលទ្ធភាពសំរាប់និរន្តរភាពនៃការធ្វើអន្តរាគមន៍និងលើកកំពស់ការប្តេជ្ញាចិត្ត ។

ប្រព័ន្ធគាំទ្រការស្តារឡើងវិញដែលត្រូវបានគេប្រើជាទូទៅនៅក្នុងប្រទេសមួយ គឺត្រូវផ្តល់ការគាំទ្រខាងផ្នែកហិរញ្ញវត្ថុ ជំនួយឥតសំណង និងអ្នកស្ម័គ្រចិត្តដើម្បីកសាងជីវភាពរបស់អ្នករស់រានមានជីវិតឡើងវិញ និងធ្វើឱ្យជីវភាពរស់នៅជាមូលដ្ឋានរបស់ពួកគេបានល្អប្រសើរ ។ ទម្រង់ជំនួសនៃការគាំទ្រមួយ អាចជាការផ្តល់មូលនិធិនិងប្រាក់កំចី ការចែកចាយសំភារៈសំណង់និងដីធ្លី និងការចែកគ្រាប់ពូជនិងសំភារៈកសិដ្ឋានចាំបាច់នានា ។

## I. *ការប៉ាន់ប្រមាណការខូចខាតក្រោយពេលគ្រោះមហន្តរាយ*

ការប៉ាន់ប្រមាណការខូចខាតជួយក្នុងការកំនត់កម្មវិធីស្តារឡើងវិញជាក់លាក់ ។ ប្រព័ន្ធការប៉ាន់ប្រមាណមួយដែលបំពាក់ទៅដោយគោលការណ៏ណែនាំនិងបច្ចេកទេសត្រឹមត្រូវ ត្រូវតែមាននៅតាមថ្នាក់ខេត្តនិងស្រុក ដើម្បីអាចឱ្យក្រុមប៉ាន់ប្រមាណផ្តល់ទិន្នន័យជាមូលដ្ឋានសំរាប់ការបង្កើតកម្មវិធីស្តារ និងការស្តារនីតិសម្បទាឡើងវិញ ។

សំណួរជាគន្លឹះមុនធ្វើការប៉ាន់ប្រមាណ គឺព័ត៌មានទាក់ទងនិងរបៀបវាយតំលៃព័ត៌មាន ។ សំណួរទាំងនេះគឺ :

- តើត្រូវការទិន្នន័យអ្វីខ្លះដើម្បីបង្កើតជាព័ត៌មាន?
- តើទិន្នន័យបានមកពីណា?
- តើទិន្នន័យមាននៅពេលណា?
- តើប្រភពទិន្នន័យគួរឱ្យទុកចិត្តបានដែរឬទេ?
- តើព័ត៌មានត្រូវការមានទំរង់ជាអ្វី?
- តើព័ត៌មានទាក់ទងនឹងគោលដៅដែរឬទេ?
- ទើព័ត៌មានត្រឹមត្រូវ ច្បាស់លាស់ និងទាន់ពេលវេលាដែរឬទេ?

ការរៀបចំស្ថាប័នដើម្បីធ្វើការប៉ាន់ប្រមាណមានសារៈសំខាន់ណាស់ ដោយសារវាតំរូវឱ្យមានការចូលរួមរបស់មន្ទីរពាក់ព័ន្ធរដ្ឋាភិបាលនៅតាមខេត្តនិងស្រុក ។ ដូចមានអធិប្បាយនៅក្នុងជំពូកទី៥នៃឯកសារមេរៀននេះ ការកំណត់របស់ក្រុមប៉ាន់ប្រមាណការខូចខាតមានសារៈសំខាន់និងការបណ្តុះបណ្តាលអំពីការប្រើបច្ចេកទេសប៉ាន់ប្រមាណ និងទម្រង់ស្តង់ដារ ត្រូវតែមាន ។ ប្រការសំខាន់នៃការប៉ាន់ប្រមាណការខូចខាតក្រោយពេលទឹកជំនន់មានសង្ខេបនៅខាងក្រោម :

- ***ស្តង់ដារទម្រង់ លេខកូដការប៉ាន់ប្រមាណនិងនិតិវិធី*** សំរាប់ការប៉ាន់ប្រមាណនិងរាយការណ៍ការខូចខាត សំរាប់ធ្វើជាតំណាង។ វាសំខាន់ត្រូវសំរេចឥទ្ធិពលទាំងមូលលើផ្នែកទាំងអស់និងធ្វើឱ្យទម្រង លេខកូដ និងនិតិវិធីមានស្តង់ដារ ត្រូវតែចែករំលែកនៅគ្រប់កំរិតផ្នែករដ្ឋបាលទាំងអស់។
- ***ការបង្កើតជនបង្គោល*** នៅតាមមន្ទីរពាក់ព័ន្ធនីមួយៗ។
- ***ការបង្កើតបញ្ជីសារពើភ័ណ្ឌបឋម*** នៃធនធាននៅក្នុងមន្ទីរនីមួយនិងធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។
- ***ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រោះមហន្តរាយនិងឥទ្ធិពល*** សំរាប់ការវិភាគការខូចខាតងាយស្រួលដើម្បីជំរាបទៅអ្នកសំរេចចិត្ត។
- ***ការបណ្តុះបណ្តាលបុគ្គលិកសំខាន់ៗ*** ក្នុងការប្រើប្រាស់ទម្រង់ស្តង់ដារ
- ***រយៈពេល*** សំរាប់ការប៉ាន់ប្រមាណការខូចខាតនិងសំរាប់ការបង្ហាញការរកឃើញ។ វាសំខាន់ត្រូវបញ្ចប់ដំណើរការប៉ាន់ប្រមាណ ដើម្បីឱ្យអាជ្ញាធរជាតិនិងខេត្តផ្តួចផ្តើមគំនិតធ្វើកម្មវិធីស្តារឡើងវិញ និងស្តារហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។
- ***ការប៉ាន់ប្រមាណតាមផ្ទះ*** ក៏ត្រូវតែធ្វើឡើងផងដែរ។
- ***ការផ្តោតលើឥទ្ធិពលរយៈពេលខ្លី និងវែង*** ត្រូវតែមាន។
- ***ការបាត់បង់បន្ទាប់បន្សំ និងការបាត់បង់ទាំងស្រុង*** ដូចជា ផលិតកម្មកសិកម្ម និងសេដ្ឋកិច្ចផ្នែកកសិកម្ម ក៏ត្រូវតែធ្វើការវិភាគដើម្បីឱ្យដឹងពីឥទ្ធិពលប៉ះពាល់ទាំងនេះមកលើសុខុមាលភាព។
- ***ការភ្ជាប់ការទំនាក់ទំនងជាពហុវិស័យ និងឥទ្ធិពល*** ក៏ត្រូវតែគិតគូរដើម្បីប៉ាន់ប្រមាណការភ្ជាប់ការទំនាក់ទំនងការអភិវឌ្ឍទាំងមូល។

វាសំខាន់ ត្រូវកំនត់មន្ត្រីដែលមានបទពិសោធន៍ពីគ្រោះមហន្តរាយពីអតីតកាល និងចាត់តាំងការទទួលខុសត្រូវដើម្បីប្រមូលព័តិមានការខូចខាត។ ជនបង្គោលបែបនេះ ត្រូវតែទទួលបានការបណ្តុះបណ្តាលអំពីបច្ចេកទេសប៉ាន់ប្រមាណការខូចខាត។ តួនាទីរបស់ជនបង្គោលមានដូចតទៅ :

១. ប្រើវិធីសាស្ត្រដែលត្រូវការសំរាប់ការប៉ាន់ប្រមាណការខូចខាត។

២. បណ្តុះបណ្តាលបុគ្គលិកផ្សេងទៀតនៅក្នុងមន្ទីរអំពីការប្រើប្រាស់វា។

៣. បញ្ជាក់និងប្រើប្រាស់វិធីសាស្ត្រ ឱ្យត្រូវទៅនឹងតំរូវការរបស់មន្ទីរ។

៤. បង្កើតនិងរក្សាបញ្ជីសារពើភ័ណ្ឌនៃទ្រព្យសម្បត្តិមន្ទីរ និងទិន្នន័យនៃការខូចខាតពីអតីតកាល។

តួនាទីរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយ ក្នុងការសំរបសំរួលសកម្មភាពប៉ាន់ប្រមាណការខូចខាត ជួយកំនត់តំរូវការរបស់សហគមន៍សំរាប់ការស្តារឡើងវិញក្រោយពេលទឹកជំនន់ ពោលគឺ ផ្ទះ ការថែទាំសុខភាព ការអប់រំ សង្គម សេដ្ឋកិច្ច ។ល ។ ស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយទាំងនេះ ក៏ធ្វើផែនការសមរាប់ការស្តារឡើងវិញ ផ្អែកលើការកៀងគរធនធានពីខាងក្រៅមានប្រសិទ្ធិភាព ។

**ឧទាហរណ៍ទិន្នន័យដែលត្រូវការ សំរាប់រចនាសម្ព័ន្ធប៉ាន់ប្រមាណ**

ទីតាំង

ទ្រព្យសម្បត្តិជារចនាសម្ព័ន្ធ

តំលៃហិរញ្ញវត្ថុ

លក្ខណៈនៃការខូចខាត

ទំហំទឹកជំនន់

អាគារ

ផ្លូវថ្នល់

ស្ពាន

ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ការប្រើប្រាស់

រចនាសម្ព័ន្ធត្រួតពិនិត្យទឹកជំនន់

ទឹកជំនន់អាចធ្វើឱ្យប្រជាជនរងគ្រោះ លើផ្ទះ ទ្រព្យសម្បត្តិ របស់របរ ជីវភាពរស់នៅ( កសិកម្ម ផលិតផលជលវប្បកម្ម មុខរបរ ផ្សេងៗ) ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មសង្គម ( មន្ទីរពេទ្យ មណ្ឌលថែទាំសុខភាព ការផ្គត់ផ្គង់អគ្គិសនី និងទឹក) និងការដឹកជញ្ជូន ។

## II ***ការសំអាតបរិដ្ឋាន***

ដោយមានបំណងបង្ការការរាតត្បាតជំងឺ ឬរបួសស្នាមថែមទៀតដែលបណ្តាលមកពីសំណល់បាក់បែក ដំណើរការសំអាតត្រូវធ្វើឡើងជាបន្ទាន់ក្រោយពីទឹកជំនន់ស្រក ។ ការសំអាតក្រោយពីទឹកជំនន់ ត្រូវការពេលវេលាច្រើន ការអត់ធ្មត់និងជំនាញ ។ ពេលគ្រួសារនីមួយៗទទួលការសំអាតផ្ទះរបស់គេ សំអាតនៅតាមទីសាធារណៈអាចធ្វើឡើងបានដោយក្រុមដែលមានការរៀបចំឡើងបានល្អ( យោធា ប៉ូលីស កាកបាទក្រហម អ្នកស្ម័គ្រចិត្ត) នៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ។ ការថែទាំត្រូវតែធ្វើឡើងដើម្បីប្រើប្រាស់ឧបករណ៍សមស្រប ដូលជា ឈើវែងដើម្បីយកចេញខ្សែរភ្លើងដែលដួល ស្បែកជើងកវែងដើរក្នុងទឹក ។ល ។

សំរាប់ក្រុមសំអាត វាសំខាន់ ត្រូវប្រយ័ត្នគ្រោះថ្នាក់ជាសក្តានុភាពដែលអាចកើតមានក្នុងកំឡុងពេលដំណើរការសំអាត ជៀសវាងមានគ្រោះថ្នាក់ ។ វាមាន :

- ប្រដាប់កាត់ផ្តាច់អគ្គិសនី ឬបន្ទត់អគ្គិភ័យដោយសារតែខ្សែរភ្លើងធ្លាក់ចូលក្នុងទឹក
- សត្វមានពិស
- ប៉ះពាល់ទឹកមានមេរោគ
- ប៉ះពាល់សំភារៈដែលមានជាតិគីមីប្រកបដោយគ្រោះថ្នាក់
- ឧប្បត្តិហេតុលើផ្លូវនិងតំបន់លិចទឹក

អណ្តូងនិងប្រភពទឹកអាចមានមេរោគដោយសារតែទឹកជំនន់ ហើយវាត្រូវបូមចេញ សំលាប់មេរោគជាមួយថ្នាំសំលាប់មេរោគ និងទុកឱ្យមានទឹកតាមធម្មជាតិវិញនិងពិនិត្យសាកមើលសិនមុននឹងបរិភោគឬដាំស្លរ ។ ប្រសិនបើមានការព្រួយបារម្ភពីសុខភាព ត្រូវទំនាក់ទំនងជាមួយមន្ទីរសុខាភិបាលសាធារណៈមូលដ្ឋាន ហើយសាធារណៈត្រូវតែមានការផ្តល់ឱ្យនូវការទំនាក់ទំនងលំអិតរបស់មន្ទីរពាក់ព័ន្ធ ។

ពេលកំពុងសំអាត វាសំខាន់ត្រូវឃ្លាំមើលគ្រោះថ្នាក់ដែលអាចកើតមានជាលើកទីពីរ ។ ការចាក់ចោលសំណល់បាក់បែក ត្រូវមានផែនការប្រកបដោយការប្រុងប្រយ័ត្ន ដើម្បីកុំឱ្យវាក្លាយជាគ្រោះថ្នាក់លើកទីពីរទៀត ជាពិសេស ប្រសិនបើសំភារៈនោះមានសក្តានុភាពគ្រោះថ្នាក់ជីវសាស្ត្រ ។ ដូចគ្នានេះដែរ ប្រសិនបើសំណល់បាក់បែកត្រូវដុតចោល ត្រូវមានការគិតគូរជាពិសេសដើម្បីជ្រើសរើសកន្លែងត្រឹមត្រូវ ដូចជាមិននៅជិតតំបន់លំនៅដ្ឋាន ឬព្រៃឬរោងចក្រណាមួយ ។ ក្នុងពេលដំណាលគ្នានេះដែរ ត្រូវធ្វើការស៊ើបអង្កេត កុំឱ្យបង្កើតជាការបំពុលខ្យល់អាកាសដោយសារតែផ្សែង ។ ត្រូវមានការប្រយ័ត្នប្រយែងចំពោះសត្វមានពិសដែលអាចមកជាមួយទឹកជំនន់ ហើយត្រូវរកមើលវានិងយកវាចេញ ។

## III. ការស្តារហេដ្ឋារចនាសម្ព័ន្ធខាងមូលដ្ឋានឡើងវិញ

ការសាងសង់ឡើងវិញផ្តល់ឱកាសធំធេងដើម្បីកាត់បន្ថយភាពងាយរងគ្រោះដែលមិនអស់ថ្លៃឬអស់ថ្លៃបន្តិចបន្តួច ។ ដំណាក់កាលនេះ គឺជាការប្រឈមមុខពិសេសចំពោះអាជ្ញាធរមូលដ្ឋាន ដោយសារតែរយៈពេលសាងសង់ដែលមានសុវត្ថិភាពមានកំរិតខ្ពស់និងមានស្ថេរភាព ត្រូវការពេលវេលាធ្វើការផែនការឆ្លើយតបនឹងតំរូវការបន្ទាន់របស់ប្រជាជនរងគ្រោះ ។

ក្រោយពេលទឹកជំនន់ភ្លាមៗ ការខូចខាតណាមួយចំពោះហេដ្ឋារចនាសម្ព័ន្ធសំខាន់ ត្រូវតែជួសជុលឡើងឱ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន ។ ហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានដែលត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់ រួមមាន :

- កន្លែងផលិតអគ្គិសនី និងបណ្តាញរបស់វា
- កន្លែងបែងចែកទឹក ប្រព័ន្ធបង្ហូរទឹកសំអុយ លូរ ទំនប់ទឹក ព្រែកនិងរចនាសម្ព័ន្ធការពារទឹកផ្សេងៗ
- កន្លែងអប់រំ ដូចចាសាលារៀន
- កន្លែងសុខាភិបាល ដូចជាមន្ទីរពេទ្យនិងគ្លីនិក
- កន្លែងសាសនា ដូចជា ប្រសាទ និងវត្តអារាម
- កន្លែងទូរគមនាគមន៍
- កន្លែងដឹកជញ្ជូន ដូចជា ផ្លូវថ្នល់និងស្ពាន
- ផ្ទះដែលខូចខាត។

នៅពេលដែលតំរូវការជាមូលដ្ឋានបានសំរេច គោលដៅ និងផែនការអភិវឌ្ឍរយៈពេលវែងសំរាប់ការសាងសង់ត្រូវតែគិតគូរ។ រយៈពេលស្តារឡើងវិញ ត្រូវមើលឃើញថាជាឱកាសមួយដើម្បីស្វែងរកភាពធ្វើឱ្យល្អប្រសើរថែមទៀត រួមផ្សំជាមួយភាពដែលធ្វើឱ្យងាយសំរេចបាននូវទ្រព្យសម្បត្តិដែលត្រូវសាងសងឡើងវិញទាំងអស់។ វាសំខាន់ត្រង់ថា ដំណើរការសាងសង់ប្រើសំភារៈក្នុងស្រុកដែលមានស្រាប់ ជាមួយនឹងការកំលាំងពលកម្ម និងធនធានក្នុងស្រុក ដែលនាំឱ្យមានការស្តារសេដ្ឋកិច្ចឡើងវិញ។ ការមាននូវធនធាន លក្ខខ័ណ្ឌសេដ្ឋកិច្ចសង្គម របៀបវារៈនយោបាយ និងស៊ីណារីយ៉ូការអភិវឌ្ឍន៍របស់ជាតិមួយ គឺជាកត្តាសំខាន់ក្នុងការកំនត់ថាតើដំណើរការស្តារឡើងវិញ ជារបស់រដ្ឋឬជារបស់អ្នករងគ្រោះ។ វានឹងជាកាសំរបសំរួលថែមទៀត ឬជាកត្តាបំពេញបន្ថែមដើម្បីកាត់បន្ថយភាពងាយរងគ្រោះក្នុងកំឡុងពេលដំណើការស្តារឡើងវិញ។

## ផ្នែកទី៤ : វិធានការកាត់បន្ថយទឹកជំនន់

ពាក្យថា ការកាត់បន្ថយទឹកជំនន់ សំដៅលើវិធានការរយៈពេលវែងដែលអាចធ្វើតាមដើម្បីកាត់បន្ថយឥទ្ធិពលនៃគ្រោះទឹកជំនន់។ វិធានការទាំងនេះអាច*ជាបែបរចនាសម្ព័ន្ធ និង ក្រៅរចនាសម្ព័ន្ធ* ។ វិធានការបែបរចនាសម្ព័ន្ធ សមដៅលើការសាងសង់និងការគ្រប់គ្រងព្រែកជីក ទំនប់ទឹក អាងស្តុកទឹក ប្រព័ន្ធធារាសាស្ត្រ ការតាំងទីលំនៅលើដីខ្ពស់ ធ្វើផ្ទះ។ល។ វិធានការក្រៅរចនាសម្ព័ន្ធ រួមមាន ការបណ្តុះបណ្តាល ការលើកកំពស់ការយល់ដឹង ការផ្លាស់ប្តូរទម្រង់ផលិតកម្មកសិកម្ម ដំណាំធននឹងទឹកជំនន់។ល។ ការកំនត់សកម្មភាពកាត់បន្ថយសំខាន់ៗនៅក្នុងផែនការត្រៀមបង្ការទឹកជំនន់ គឺជាតំរូវការមុនដើម្បីជួយភ្នាក់ងារដែលពាក់ព័ន្ធផ្តួចផ្តើមសកម្មភាពសមស្រប។ សកម្មភាពទាំងនេះមានអធិប្បាយដូចខាងក្រោម :

### *I. ការការពារទឹកជំនន់*

ការការពារទឹកជំនន់ គឺជាការផ្តល់នូវវិធានការបែបរចនាសម្ព័ន្ធរយៈពេលវែង ដែលជារូបសាស្ត្រ បង្ការទឹកជំនន់បានខ្លះ ឬបានទាំងអស់មិនឱ្យចូលតំបន់ដែលបានគ្រោងទុក។ ការការពារទឹកជំនន់ មិនចាំបាច់មានន័យថាការពារទាំងស្រុងពីទឹកជំនន់នោះទេ ប៉ុន្តែអាចធ្វើជាមធ្យោបាយផ្តល់ការត្រួតពិនិត្យទឹកជំនន់និងលូរបង្ហូរ។ គោលបំនងនៃការការពារទឹកជំនន់ គឺដើម្បីធានាថា សកម្មភាពសង្គមនិងសេដ្ឋកិច្ចមានភាពល្អប្រសើរឡើង អាចបន្តនៅក្នុងតំបន់គ្រោងទុកក្នុងកំឡុងពេល និងក្រោយពេលព្រឹត្តិការណ៍ទឹកជំនន់។ នៅប្រទេសវៀតណាម កម្ពុជា និងឡាវ វិធានការការពារទឹកជំនន់ ទាក់ទងនឹងការពង្រឹងមាត់ច្រាំង ការសាងសង់និងពង្រឹងព្រែកជីកនិងការសាងសង់មុខទឹកចេញ-ចូល ដើម្បីធ្វើឱ្យចរន្តទឹកក្នុងលូរបង្ហូរល្អប្រសើរឡើង។ ផ្នែកសំខាន់នៃវិធានការការពារទឹកជំនន់ គឺជាការបន្តនូវប្រតិបត្តិការនិងការថែទាំកន្លែងដែលបានសាងសង់រួច។ការការពារទឹកជំនន់ តំរូវឱ្យមាននិតិវិធីថែទាំ និងថវិកាស្ថិតស្ថេរ និងបន្តការប៉ាន់ប្រមាណដំណើរការទឹកន្លែង។

វិធានការការពារទឹកជំនន់ ត្រូវអនុវត្តជាសំខាន់ដោយមន្ទីរធនធានទឹក និងមន្ទីរសាធារណការ នៅក្រោមសកម្មភាពអភិវឌ្ឍជាទៀងទាត់។ ក្នុងការបញ្ចូលកត្តាគ្រោះទឹកជំនន់ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានត្រូវចាប់យកតួនាទីគន្លឹះក្នុងការកំនត់ទីតាំងការពារទឹកជំនន់ជាអាទិភាព និងសកម្មភាព។ ឯកសារត្រៀមបង្ការទឹកជំនន់ ត្រូវតែកំនត់លំអិតពីទីតាំងដូចជាតំបន់ដែលងាយរងគ្រោះដែលចាំបាច់ត្រូវមានការងារការពារទឹកជំនន់។

## II. ការទប់ទឹកជំនន់

ការទប់ទឹកជំនន់ គឺជាវិធានការកាត់បន្ថយជាទូទៅបំផុតមួយ និងសំដៅលើការផ្តល់វិធានការរយៈពេលវែងក្រៅរចនាសម្ព័ន្ធឬរចនាសម្ព័ន្ធខាតតូច ដើម្បីធ្វើឱ្យផលប៉ះពាល់ពីទឹកជំនន់មានតិចជាអប្បរមា។ វាអាចកំណត់ថាជាការថ្លឹងថ្លែងតូចឬធំ ឬការបញ្ជាក់ពីរចនាសម្ព័ន្ធ និងមាតិការដែលមានស្រាប់ ដែលធ្វើឡើងឬប្រើដើម្បីកាត់បន្ថយការខូចខាតដោយទឹកជំនន់។

វិធានការទប់ទឹកជំនន់អាចប្រើបានចំពោះរចនាសម្ព័ន្ធសាធារណៈ ដូចជា សាលារៀន និងមណ្ឌលថែទាំសុខភាព វត្តអារាម ប្រាសាទ និងផ្ទះរបស់បុគ្គល ដែលតែងតែប្រើធ្វើជាទីជំរកបណ្តោះអាសន្នក្នុងកំឡុងពេលទឹកជំនន់។

ការទបលទឹកជំនន់ជួយឱ្យជៀសវាងការបាត់បង់អាយុជីវិតមនុស្សនិងការបន្ថយការរំខានដល់សកម្មភាពជាធម្មតាក្នុងកំឡុងពេល និងក្រោយពេលទឹកជំនន់ និងផ្តល់ឱ្យប្រជាជននូវសន្តិសុខ និងការជំរុញលើកទឹកចិត្តជាចាំបាច់ដើម្បីធ្វើ និងរក្សារឱ្យបាននូវភាពល្អប្រសើរក្នុងផ្នែកសេដ្ឋកិច្ចនិងសង្គមកិច្ច និងសំរេចបាននូវភាពចំរើនរុងរឿងក្នុងបរិយាកាសប្រឈមនឹងទឹកជំនន់។ វិធានការទប់ទឹកជំនន់ អាចធ្វើឡើងដោយទ្រព្យសម្បត្តិផ្ទាល់របស់បុគ្គលដោយគ្មានការរង់ចាំវិធានការពីរដ្ឋាភិបាល។

**វិធីសាស្រ្តទប់ទឹកជំនន់ :** ការទប់ទឹកជំនន់អាចចំណាត់ជាវិធីសាស្រ្តចំបងបីប្រភេទ : អចិន្ត្រៃយ៍ សមាយាត និងភាពអាសន្ន។

*វិធានការអចិន្ត្រៃយ៍* ផ្តល់ការការពាររយៈពេលវែងទប់នឹងទឹកជំនន់ ដែលវាបង្កើតឡើងនិងមិនពឹងផ្អែកលើការព្យាករណ៍ទឹកជំនន់ ឬវិធានការដាក់វាឱ្យមានជាធរមាន។ *វិធានការសមាយាត* មិនមានប្រសិទ្ធិភាពទេ លុះត្រាតែទទួលបានការប្រកាសភាពអាសន្នឬការព្យាករណ៍ សកម្មភាពត្រូវធ្វើឱ្យវិធានការអាចប្រតិបត្តិការបាន។ វិធានការភាពអាសន្ន គឺជាវិធានការធ្វើឡើងក្នុងកំឡុងពេលទឹកជំនន់ជាក់ស្តែងឬធ្វើឡើងមុនផែនការសកម្មភាពគ្រោះអាសន្ន។

*ការទប់ទឹកជំនន់របស់អាគារ ឬអង្គភាពនីមួយៗ*

នៅថ្នាក់សហគមន៍ តំលៃនៅតែជាកត្តាសំខាន់ក្នុងការកំណត់ប្រភេទទប់ទឹកជំនន់ដែលធ្វើឡើងដោយអង្គភាពនីមួយៗ។ មានយុទ្ធវិធីជាច្រើនទប់ទឹកជំនន់របស់អាគារឬអង្គភាពនីមួយដែលមានសង្ខេបដូចខាងក្រោម :

១. ការលើកអាគារ ដើម្បីកុំឱ្យទឹកជំនន់ឡើងដល់ដែលអាចធ្វើឱ្យខូចខាតផ្នែកណាមួយនៃអាគារ។




(i) (ii)

*គំនូស ៤.១.១ : ផ្ទះលើកឱ្យខ្ពស់ (១) ជើងសរស និង(២) ចាក់ដីបំពេញ។*

អាគារឬអង្គភាពនីមួយអាចលើកឡើងមកនៅលើដីចាក់បំពេញ ជើងសរស ឬ ជញ្ជាំង។ កំពស់ដែលលើកត្រូវតែតែសមល្មមដើម្បីធានាថា អាគារនៅលើទឹក។ បែបនេះ ធ្វើឱ្យទឹកឆ្លងកាត់អាគារ មានការខូចខាតតិចតួច ឬគ្មាន។ ត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះការសង់គ្រឹះ ជៀសវាងការតាំងលំនៅលើ ឬធ្វើឱ្យអាគារបាក់រលំ។



*គំនូស ៤.១.២ ផ្ទះនៅលើដីខ្ពស់*

២. ការសង់របាំងចន្លោះរវាងអាគារនិងទឹកជំនន់

ការខូចខាតខ្លះមកពីទឹកជំនន់អាចធ្វើឱ្យមានតិចតួចដោយវិធានការសមស្របដើម្បីបង្ការទឹកជំនន់ចូលក្នុងទ្រព្យសម្បត្តិ។ របាំង (ទំនប់ទឹកឬសង់ជញ្ជាំងបាំងទឹកជំនន់) អាចធ្វើឡើងនៅជុំវិញអាគារឬនៅចំហៀងអាគារដែលបែរទៅរកទឹកជំនន់ ដើម្បីការងាររចនាសម្ព័ន្ធកុំឱ្យខូចខាត ដោយទឹកជំនន់។ វាអាចធ្វើពីដី ស៊ីម៉ងត៍ឬដែក។ ត្រូវធ្វើការថែទាំដើម្បីឱ្យធានាថា វាមិនជ្រាបទឹក។

នៅក្នុងវិធីនេះ តំបន់ទាំងអស់ដែលនៅពីក្រោមកំពស់ការពារទឹកជំនន់ធ្វើឡើងពីជញ្ជាំងមិនជ្រាបទឹក ដូចជាស្រោបផ្លាស្ទិក ហើយកន្លែងដែលចំហរ ដូចជា ទ្វារ បង្អួច រន្ធលូរបង្ហូរទឹក និងប្រឡោះខ្យល់ ត្រូវបិទជាបណ្តោះអាសន្ន ដោយប្រើបាវដីខ្សាច់ឬប្រដាប់បិទដែលអាចយកចេញបានឬឆ្នុក ដើម្បីធ្វើយ៉ាងណាឱ្យអាគារទប់ទល់នឹងទឹកជំនន់ហូរចូល។ វិធីសាស្ត្រការពារបែបនេះ ត្រូវមានលូរបង្ហូរទឹកគ្រប់គ្រាន់ដើម្បីយកទឹកចេញពីអាគារ។




*គំនូស ៤.១.៣ ការសង់របាំងចន្លោះរវាងអាគារនិងទឹកជំនន់*

## ១. "ការទប់ទឹកជំនន់" ឬ "ការបិទ"

វិធីសាស្ត្រនេះមានអំពីការធ្វើជញ្ជាំងអាគារនិងកំរាលឥដ្ឋមិនឱ្យជ្រាបទឹក ដើម្បីកុំឱ្យទឹកចូលហើយ វិធីសាស្ត្រ អាចប្រើបានតែនៅក្នុងតំបន់ទឹកលិចរាក់ ទើបអាចបិទទឹកមិនឱ្យលិចអាគាររឿនទាំងស្រុង

ពោលគឺ ក្នុងតំបន់ដែលកំពស់ទឹកជំនន់មិនលើសពីមួយម៉ែត្រនិងទឹកឡើងមានកំរិតតិច។ ការដាក់បាវខ្សាច់ក៏ការពារជំនួសជាបណ្តោះអាសន្ន ដែលអាចប្រើដើម្បីបិទកន្លែងចំហរ ឬការពារផ្នែករចនាសម្ព័ន្ធ ដែលងាយរងគ្រោះ។

## ២. ការការពារកន្លែងផ្សេងទៀត

- *ការរើតវ៉ាន់ចេញជាបណ្តោះអាសន្ន :* នៅក្នុងតំបន់ខ្លះ ការរើតវ៉ាន់ សំភារៈ និងគ្រឿងឧបភោគបរិភោគជាបណ្តោះអាសន្ន ក្នុងករណីមានអាសន្ន អាចកាត់បន្ថយការខូចខាតបានមួយកំរិត។
- *កន្លែងស្តុកទំនិញមិនជ្រាបទឹក :* អាងស្តុកនៅក្នុងតំបន់ប្រឈមនឹងទឹកជំនន់ បិទគំរបមិនឱ្យជ្រាបទឹក អាចការពារតវ៉ាន់និងសំភារៈមិនឱ្យខូចខាតពីទឹកជំនន់បាន។
- *ការបោះយុថ្កា :* ក្នុងកំឡុងពេលទឹកជំនន់ សំភារៈខ្លះ និងរចនាសម្ព័ន្ធដែលអណ្តែ(ឧ. ឈើ) អាចអណ្តែតតាមទឹកជំនន់ មិនត្រឹមត្របាត់បង់ប៉ុណ្ណោះទេ ប៉ុន្តែក៏ខាចខូចខាតហើយសំណល់បាក់បែកទៅកកស្ទះដល់ខ្សែទឹកខាងក្រោមទៀតផង។ ការបោះយុថ្កា អាចកាត់បន្ថយការខូចខាតបាន។
- ការការពារអគ្គីភ័យ : មូលហេតុចំបងមួយនៃការបាត់បង់ទ្រព្យសម្បត្តិ គឺអគ្គីភ័យដោយសារតែការផ្ទុះសេខ្សែរភ្លើងប៉ះជាមួយទឹក។ ការផ្តាច់ចរន្តអគ្គិសនីបានត្រឹមត្រូវសំរាប់អាគារនីមួយៗអាចបន្ថយការកើតមានអគ្គីភ័យបាន។ នេះ ក៏ផ្តល់ការការពារទប់ទល់នឹងការឆក់ខ្សែរភ្លើងផងដែរ។
- *សេវាប្រើប្រាស់ :* ដូចជា ការផ្គត់ផ្គង់ទឹក និងប្រព័ន្ធផ្គត់ផ្គង់ទឹក ត្រូវតែពិនិត្យក្រែងមានការលេចហើយជួសជុលជាប្រចាំការពារកុំឱ្យមានឆ្លងមេរោគដែលកើតមកពីទឹកជំនន់។

## III. *ការកំនត់តំបន់ទំនាបទឹកលិច*

នៅក្នុងស៊ីណារីយ៉ូកាត់បន្ថយទឹកជំនន់ បញ្ហាគ្រប់គ្រងដីធ្លីផ្តោតលើ (១)ការរៀបចំសកម្មភាបអភិវឌ្ឍនៅលើដីទំនាបទឹកលិច និង(២) ការធានាសុវត្ថិភាពរបស់អ្នករស់នៅលើដីទំនាបទឹកលិចពីការខូចខាតធ្ងន់ធ្ងរ ដោយទឹកជំនន់។ ការគ្រប់គ្រងការប្រើប្រាស់ដីព្យាយាមធ្វើឱ្យត្រូវគ្នាដែលមាន ជាមួយសកម្មភាពប្រើប្រាស់ដីនៅពេលអនាគត(ការធ្វើកសិដ្ឋាន សំណង់)។ សកម្មភាពអភិវឌ្ឍ ប្រសិនបើមិនធ្វើដោយប្រុងប្រយ័ត្ន អាច និងរំខានដល់ការបង្ហូរទឹកដោយធម្មជាតិ ប្រព័ន្ធទប់ទឹកជំនន់ ដូចជា តំបន់ដីសើមនិងវាលភក់ និងការចុះថយការច្រោបទឹកភ្លៀងចូលទៅក្នុងដី ដោយសារតែការធ្វើទីក្រុង។ ជាពិសេស នៅក្នុងតំបន់ដែលកើតទីក្រុងឆាប់រហ័សគោលនយោបាយទាក់ទងនឹងការគ្រប់គ្រងទីជំរាល ការធ្វើសមាហរណកម្មគ្រប់គ្រង និងការការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជា ផ្លូវថ្នល់ លើតំបន់ទំនាបលិចទឹក តាមរយៈបទបញ្ញត្តិមានសារៈសំខាន់។

ទំបន់ទំនាបលិចទឹក ដែលកំរិតនៃគ្រោះថ្នាក់ទឹកជំនន់នៅក្នុងតំបន់ឆ្លងកាត់គ្នា ត្រូវបញ្ចូលគ្នាដោយប្រុងប្រយ័ត្នជាមួយវិធានការប្រើប្រាស់ដីសមស្របអាចជាវិធានការក្រៅប្រព័ន្ធមួយដែលសំខាន់បំផុត។ គ្រោះទឹកជំនន់

និងផែនទីគ្រោះទឹកជំនន់ ដែលផ្តល់ព័ត៌មានអំពីប្រវត្តទឹកជំនន់ពីអតីតកាលឬទំហំជាសក្តានុភាពនៃទឹកជំនន់ នៅអនាគត រួមផ្សំជាមួយនឹងព័ត៌មានពាក់ព័ន្ធផ្សេងទៀត អាចជួយបានយ៉ាងច្រើនក្នុងការធ្វើតំបន់ទឹកជំនន់។

ក្នុងករណីជាច្រើន ការផ្តល់ការលើកទឹកចិត្ត និងការដូរចេញ អាចមានប្រសិទ្ធិភាព។ ការធ្វើផែនការអភិវឌ្ឍទីក្រុងនៅអនាគត អាចត្រួតពិនិត្យបាន តាមរយៈការមិនលើកទឹកចិត្ត ឬការលើកទឹកចិត្តសមរាប់អ្នកអភិវឌ្ឍ។ អ្នកអភិវឌ្ឍដែលបានត្រៀមបញ្ចូលលក្ខណៈជាក់ស្តែងនៅក្នុងការងាររបស់ពួកគេ នឹងបន្ថយចរន្តឡើងដល់កំពូល អាចមានការបន្ធូរបន្ថយការបង់ពនដី។ កម្មវិធីបង់ពន្ធដី អាចប្រើជាមួយអ្នកដែលមានកម្មសិទ្ធិដីរួចហើយ ឬអ្នកដែលមានផែនការទិញដីនៅក្នុងតំបន់លិចទឹកត្រូវតែបង់ពន្ធខ្ពស់ជាង។ នេះជាមធ្យោបាយមួយបង្អាក់ទឹកចិត្តប្រជាជនពីការរស់នៅក្នុងតំបន់ដែលប្រឈមនឹងទឹកជំនន់។ ច្បាប់ប្រើប្រាស់ដីធ្លី អនុបញ្ញត្តឱ្យបង្កើតស្តង់ដារសំរាប់ប្រើអភិវឌ្ឍ និងការពារដី តាមមធ្យោបាយនេះ ព្រោះវាធ្វើឱ្យគ្រោះមានតិចតួចចំពោះប្រជាពលរដ្ឋនិងការងារធនធានធម្មជាតិពីការបំផ្លិចបំផ្លាញក្នុងពេលទឹកជំនន់។ ការរើទីលំនៅសហគមន៍បានដោះស្រាយរួចហើយក្នុងតំបន់ប្រឈមនឹងទឹកជំនន់ ពួកគេអាចទទួលបានដីមួយប្លង់នៅក្នុងតំបន់សុវត្ថិភាព ដែលមានជីវភាពរស់នៅសមរម្យ និងមានការភ្ជាប់ទំនាក់ទំនងការដឹកជញ្ជូនទៅកសិដ្ឋានរបស់ពួកគេ ឬមធ្យោបាយមុខរបរផ្សេងៗទៀត។

តែទោះជាយ៉ាងណាក៏ដោយ វិធានការទាំងនេះអាចជោគជ័យបាននៅនឹងកន្លែងជាមួយនឹងការបង្កើតវិធានធ្វើផែនការប្រើប្រាស់ដីធ្លី និងបទបញ្ញត្តិ និងការអនវត្តន៏មានប្រសិទ្ធិភាពនៅលើដី។ ការអនុវត្តច្បាប់បានត្រឹមត្រូវអាចជួយរឹតបន្តឹងសកម្មភាពខុសច្បាប់ ដូចជា ការរានដីខុសច្បាប់នៅតាមទន្លេ ដែលងាចផ្លាស់ប្តូរផ្លូវទន្លេនិងបង្ករការគំរាមកំហែងដល់ដងទន្លេសហគមន៏។ ការចូលរួមរបស់អ្នកពាក់ព័ន្ធមានសារៈសំខាន់ក្នុងការសំរេចចិត្តប្រភេទវិធានការគ្រប់គ្រងការប្រើប្រាស់ដី ដែលត្រូវអនុម័តចាប់តាំងពីពេលពួកគេជាអ្នកទទួលផលចុងក្រោយ និងអាចមានប្រយោជន៏ក្នុងការអនុវត្តន៏បទបញ្ញត្តិទាំងនេះ។ ការអនុវត្តច្បាប់ត្រឹមត្រូវ ការអប់រំ និងគំរោងលើកទឹកចិត្តត្រូវការជាចាំបាច់។

## IV. ការកសាងសមត្ថភាព និងការលើកកំពស់ចំណេះដឹង និងការអនុវត្តន៏ក្នុងស្រុក

ការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធក្នុងការកាត់បន្ថយទឹកជំនន់ ការវិភាគប្រុងប្រយ័ត្នមួយត្រូវការជាចាំបាច់សំរាប់អ្នកពាក់ព័ន្ធផ្សេងៗគ្នា ផលកំរៃ សេចក្តីត្រូវការ ភាពខ្វះចន្លោះក្នុងជំនាញ ចំណេះដឹង និងសមត្ថភាពរបស់ពួកគេ។ តំលៃកម្មវិធីអប់រំ និងការកសាងសមត្ថភាព ត្រូវតែទទួលស្គាល់ថាជា "ថ្លៃថែរក្សា"របស់ការគ្រប់គ្រងទឹកជំនន់មានប្រសិទ្ធិភាព ហើយក៏ដូចគ្នានឹងថវិកាផងដែរ។

ការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធ ត្រូវពិចារណាលើកំរិតបីយ៉ាង : ស្ថាប័ន សហគមន៏ និង បុគ្គល។

*ការកសាងសមត្ថភាពស្ថាប័ន* ទាក់ទងនឹងការណែនាំឱ្យស្គាល់ពីការផ្លាស់ប្តូរជាមូលដ្ឋានតាមមធ្យោបាយស្ថាប័នធ្លាប់ធ្វើតាមមុខងារ ពីការដាក់នីតិវិធីមុន ដល់ការផ្តោតលើទំលាប់ និងការដាក់ប្រជាជនមុនគេ។ តាមដំណើរការនេះ ការពង្រឹងស្ថាប័នដែលមានស្រាប់ក្នុងការធ្វើផែនការតាមបែបការចូលរួម និងការគ្រប់គ្រង ត្រូវតែភ្ជាប់ជាមួយការកសាងសមត្ថភាពអំពីការធ្វើផែនការ និងការគ្រប់គ្រងជាយុទ្ធសាស្ត្រ ដែលមិនត្រឹមតែលើកកំពស់ការងារ និងការរៀនសូត្រតាមរយៈការអនុវត្តន៏គោលនយោបាយប៉ុណ្ណោះទេ ប៉ុន្តែក៏អនុញ្ញត្តឱ្យធនធានដែលមានកម្រ ផ្តោតលើតំបន់អាទិភាពនៃការកសាងសមត្ថភាពទៀតផង។ បច្ចេកទេសដែលអាចប្រើ រួមមានការបណ្តុះបណ្តាលផ្លូវការ ការរៀនសូត្រតាមការអនុវត្តន៏(កសាងជំនាញបានច្រើន ជាផ្នែកមួយនៃដំណើរការ) និងការកែទម្រង់អង្គការ។

*ការកសាងសមត្ថភាពសហគមន៍* ផ្តោតលើការធ្វើឱ្យសហគមន៍ដឹងនិងយល់ពីគ្រោះទឹកជំនន់ ធ្វើផែនការនិងអនុវត្តសកម្មភាពកាត់បន្ថយទឹកជំនន់ ដោយខ្លួនឯង។ នេះ អាចសំរេចបានតាមរយៈវិធានការខុសៗគ្នា រួមទាំងការបណ្តុះបណ្តាល សិក្ខាសាលា យុទ្ធនាការលើកកំពស់ការយល់ដឹងថ្នាក់សហគមន៍ និងការ លើកកំពស់ការរៀនសូត្រទៅវិញទៅមករវាងសហគមន៍ និងរៀបចំទស្សនកិច្ចកម្មសិក្សាទៅសហគមន៍ ផ្សេងទៀតដែលមានកម្មវិធីថ្មីអនុវត្តដោយជោគជ័យ។ កម្មវិធីកសាងសមត្ថភាពសហគមន៍ ត្រូវតែធ្វើឡើងដើម្បីលើកកំពស់ចំណេះដឹង និងការអនុវត្តន៏ក្នុងស្រុក ជាជាងការណែនាំសមត្ថភាពបច្ចេកទេសថ្មី។

*ការកសាងសមត្ថភាពបុគ្គល* ផ្តោតលើការបង្កើតឱកាសសំរាប់បុគ្គលទាំងឡាយណា ដែលបានដើរតួនាទីសំខាន់ៗរួចមកហើយក្នុងមន្ទីររដ្ឋាភិបាល RBOs, CBOs, NGOs និងអាចធ្វើឱ្យពួកគេបង្កើតមូលដ្ឋានការយល់ដឹង ចំណេះដឹង និងជំនាញជាអ្នកដឹកនាំ។ នេះ អាចសំរេចបានតាមរយៈកម្មវិធីបណ្តុះបណ្តាលផ្លូវការ ទស្សនៈកិច្ចសិក្សា ការចុះជាប់ជាមួយ និងហាត់ការនៅតាមអង្គការដែលស្រដៀងគ្នាផ្សេងទៀត។ ការកសាងសមត្ថភាពរបស់បុគ្គល ត្រូវធ្វើឡើងក្នុងទម្រង់ប្រមូលផ្តុំនៃជំនាញឆ្ពោះទៅរកការអភិវឌ្ឍន៏អង្គការ។ សមាជិកសហគមន៍ដែលមានឥទ្ធិពលផ្នែកសង្គម និងគុណភាពដឹកនាំ អាចត្រូវបានជ្រើសរើសឱ្យធ្វើជាអគ្គរដ្ឋទូតព័ត៌មាន។

## V. ការលើកកំពស់ការយល់ដឹងជាសាធារណៈ

ដូចបានពន្យល់រួចមកហើយនៅក្នុងផ្នែកទី១នៃជំពូកនេះ ការលើកកំពស់ការយល់ដឹងជាសាធារណៈ គឺជាដំណើរការបន្តដែលត្រូវការធនធានជានិរន្ត។ តាមទស្សនវិស័យកាត់បន្ថយទឹកជំនន់ ការបង្កើនការយល់ដឹងធ្វើឡើងដោយមានគោលដៅខ្ពស់អំពីការសំរេចការផ្លាស់ប្តូរឥរិយាបថ និងការប្រព្រឹត្តរបស់សហគមន៍ដែលងាយរងគ្រោះ ចំពោះការកាត់បន្ថយគ្រោះទឹកជំនន់ ដែលនាំឱ្យមានការចូលរួម និងការប្តេជ្ញាចិត្តខ្ពស់ពីសហគមន៍។ ការលើកកំពស់ការយល់ដឹង អាចសំរេចបានតាមរយៈមធ្យោបាយខុសៗគ្នា : ការផ្សព្វផ្សាយ សំភារៈលើកកំពស់

ការយល់ដឹង( ឯកសារបោះពុម្ព) ការប្រជុំរបស់សហគមន៍ រៀបសាយ កម្មវិធី ទូរទស្សន៍ វិទ្យុ ការគំរប់ខួប ព្រឹត្តិការណ៍ទឹកជំនន់ និងកម្មវិធីគាំទ្រនានា។

នៅពេលលើកកំពស់ការយល់ដឹងជាសាធារណៈអំពីគ្រោះទឹកជំនន់ វាសំខាន់ត្រូវមានអ្នកពាក់ព័ន្ធចូលរួមមកពីតំបន់នៅខាងដើមនិងនៅចុងទន្លេ។ ឧទាហរណ៍ ក្នុងស្ថានភាពមួយ ដែលការកាប់ឆ្ការព្រៃនិងដុតដើម្បីដាំដំណាំ កសិករនៅតាមតំបន់ដើមទន្លេ អាចដឹងពីឥទ្ធិពលនៃសកម្មភាពបែបហ្នឹងទៅលើសហគមន៍នៅចុងទន្លេ និងដោយមានជំនួយពីរដ្ឋាភិបាល និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗ ត្រូវតែរៀបចំជីវភាពរស់នៅជាជំនួសសំរាប់ពួកគេ។

## ៦.៤ បញ្ហាសំរាប់ពិចារណា

១. ហេតុអ្វីបានជាភាពខុសគ្នាក្នុងចំណោមការត្រៀមបង្ការ ការឆ្លើយតប ការស្តារនិងការស្តារនីតិសម្បទា និងវិធានការកាត់បន្ថយមានសារៈសំខាន់សំរាប់ការរៀបចំផែនការត្រៀមបង្ការទឹកជំនន់?

២. សូមអធិប្បាយអំពីវិធានការត្រៀមបង្ការទឹកជំនន់ និងពីរបៀបវិធានការទាំងនេះ អាចមានតំលៃ ក្នុងការសង្គ្រោះធនធានមនុស្សនិងសំភារៈក្នុងករណីទឹកជំនន់?

៣. កំនត់សំណួរសំខាន់ៗសំរាប់ការប៉ាន់ប្រមាណការខូចខាតរហ័ស។

៤. តើគួរស្នើអ្វីដល់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្តនិងថ្នាក់ស្រុកដើម្បីរៃអង្គាសថវិកា សំរាប់វិធានការកាត់បន្ថយ?

៥. ប្រៀបធៀបស៊ីណារីយ៉ូរបស់សហគមន៍ពីរ អំពីវត្តមាន អវត្តមាននៃប្រព័ន្ធប្រកាសភាពអាសន្នមុនក្នុងមូលដ្ឋាន។

## ៦.៥ សេចក្តីយោង


- វិស័យសង្គម និងការចូលរួមរបស់អ្នកពាក់ព័ន្ធក្នុងសមាហរណកម្មគ្រប់គ្រងទឹកជំនន់ WMO, 2006
- ក្រុមប្រឹក្សាគ្រប់គ្រងកសិកម្មនិងធនធានរបស់ប្រទេសអូស្ត្រាលីនិងញូហ្ស៊ីឡែន ២០០០ *ការគ្រប់គ្រងតំបន់លិចទឹកនៅប្រទេសអូស្ត្រាលី :គោលការណ៍និងការណែនាំការអនុវត្តល្អបំផុត* SCRAM Report 73.
- គណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ សំរាប់អាស៊ីនិងប៉ាស៊ីភិច (UNESCAP) ២០០៣។ *គោលការណ៍ណែនាំស្តីពី ការធ្វើផែនការនិងការគ្រប់គ្រងតាមបែបមានការចូលរួមសំរាប់កាត់បន្ថយ និងត្រៀមបង្ការទឹកជំនន់* Water Resources Series No.82

# ជំពូកទី ៧

## ការរៀបចំ និង ការថែរក្សាបញ្ជីធនធាន

# ការរៀបចំ និង ការថែរក្សាបញ្ជីធនធាន

## ៧.១ ទិដ្ឋភាពរួម

ជំពូកនេះ អធិប្បាយអំពីការវិភាគធនធាន និងរបៀបដែលវារួមចំណែកដល់ការកំនត់ធនធានដែលត្រូវការបន្ថែមពីលើធនធានដែលមាននៅតាមមូលដ្ឋាន។ ការកំនត់ក៏មានការវាយតំលៃធនធានទាំងនេះសំរាប់ការប្រើ ប្រាស់មានប្រសិទ្ធិភាព ក្នុងករណីមានទឹកជំនន់។

ផលប្រយោជន៍សំខាន់មួយនៃការរៀបចំធ្វើបញ្ជីរសារពើភ័ណ្ឌធនធាន គឺអាចឱ្យអ្នកធ្វើផែនការពិនិត្យបានយ៉ាងច្បាស់លាស់ ថាតើធនធានដែលមានស្រាប់ ពោលគឺសំភារៈ ធនធានមនុស្ស និងហិរញ្ញវត្ថុមានគ្រាប់គ្រាន់ដើម្បីដោះស្រាយជាមួយគ្រោះមហន្តរាយជាសក្តានុភាពបណ្តាលមកពីទឹកជំនន់។ ប្រសិនបើធនធានមិនគ្រប់គ្រាន់ការរៀបចំយថាភាព ក៏អាចត្រូវកំណត់ផងដែរ។ ការវិភាគ និងការវាយតំលៃធនធានទាំងអស់នេះ ត្រូវចងក្រងទុកជាឯកសារ តាមទម្រង់បញ្ជីរធនធាន ជាផ្នែកមួយនៃផែនការត្រៀមបង្ការទឹកជំនន់។

## ៧.២ គោលបំណង

- កំណត់ប្រភេទ ភាពដែលមាន និងទីតាំងរបស់ធនធានដែលមាននៅតាមមូលដ្ឋានសំរាប់ការឆ្លើយតបទឹកជំនន់មានប្រសិទ្ធិភាព។
- កំណត់ធនធានដែលត្រូវការពីខាងក្រៅ បន្ថែមលើធនធានដែលមាននៅក្នុងមូលដ្ឋាន។
- បង្កើតបញ្ជីរសារពើភ័ណ្ឌធនធាន។

## ៧.៣ គោលគំនិតសំខាន់ៗ

- បញ្ជីរសារពើភ័ណ្ឌធនធានកំណត់និងផ្តល់អាទិភាពធនធាន ការកំណត់ការប្រើប្រាស់ធនធានដែលមានឱ្យមានប្រសិទ្ធិភាពនៅក្នុងតំបន់ ព្រមទាំងប្រមើលពីតម្រូវការសំរាប់ជំនួយពីខាងក្រៅ ក្នុងពេលមានគ្រោះអាសន្ន។
- បញ្ជីរសារពើភ័ណ្ឌធនធាន ត្រូវផ្តល់អាទិភាពក្នុងការកំណត់ធនធានដែលមានក្នុងមូលដ្ឋានដែលអាចប្រើប្រាស់បានឬកៀងគរបាន និងនៅលើកឡើងធនធានទាំងនោះដែលអាចមាន ប៉ុន្តែត្រូវខូចខាតឬមិនដំណើរការ។
- ការធ្វើបច្ចុប្បន្នភាពនៃបញ្ជីរសារពើភ័ណ្ឌធនធាន ត្រូវធ្វើជាទៀងទាត់ មុនទឹកជំនន់កើតឡើង ដើម្បីពិនិត្យស្ថានភាពធនធានឡើងវិញ។ នេះមានសារៈសំខាន់ក្នុងការបង្កើតបញ្ជីរសារពើភ័ណ្ឌលំអិតនៃប្រព័ន្ធបែបនេះជា

បរិក្ខារទំនាក់ទំនង ស្តុបទុក ដឹកជញ្ជូន សុខាភិបាល ទីជំរកសុវត្ថិភាព និងបរិក្ខារដែលពាក់ព័ន្ធ ។ល។ ដើម្បីធានា ការឆ្លើយតបទឹកជំនន់មានប្រសិទ្ធិភាព ។

- ភ្នាក់ងារគ្រប់គ្រងគ្រោះមងន្តរាយដែលមាន (ទាំងរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល) និងវត្តមានរបស់ក្រុមអ្នកស្ម័គ្រចិត្ត ក៏ត្រូវពិចារណាថាជាធនធានមានតំលៃផងដែរ ។

## ៧.៤ បញ្ជីរធនធានសំរាប់ការត្រៀមបង្ការទឹកជំនន់

បញ្ជីរសារពើភ័ណ្ឌធនធានមួយដែលបានបង្កើតឡើងសំរាប់ការធ្វើផែនការត្រៀមបង្ការទឹកជំនន់កំនត់ភាពដែលមាននៃធនធានដូចតទៅ :

- ធនធានមនុស្ស - ឧ. អ្នកស័គ្រចិត្ត ក្រុមពន្លត់អគ្គីភ័យ អ្នកមានវិជ្ជាជីវៈខាងវេជ្ជសាស្រ្ត អ្នក ជំនាញខាងស្រាវជ្រាវ និងបុគ្គលិកសង្គ្រោះ ។
- ធនធានសំភារៈ - ឧ. ធនធានផ្នែកដឹកជញ្ជូន ការទំនាក់ទំណង ទីជំរក និងធនធានផ្សេងៗ ប្រព័ន្ធស្តុបទុក ប្រព័ន្ធសុខាភិបាល និងផ្សេងៗ ។
- ធនធានហិរញ្ញវត្ថុ - ឧ. ថវិកាឆ្លើយតបគ្រោះអាសន្នគ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋានសំរាប់ការប៉ាន់ប្រមាណរប៉ាសនៅពេលទឹកជំនន់ ដែលបរិច្ចាកពីប្រភពធនធានឯកជន ។

បញ្ជីរសារពើភ័ណ្ឌធនធានបំរើជាឯកសារមូលដ្ឋានមួយក្នុងការកំនត់ថាតើធនធានដែលមានគ្រប់គ្រាន់ដោះស្រាយជាមួយនឹងគ្រោះមហន្តរាយជាសក្តានុភាពបណ្តាលដោយទឹកជំនន់ និងកំណត់អ្វីដែលជាធនធានខាងក្រៅអាចត្រូវការ ។ វាត្រូវតែថែរក្សានិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ឆ្លុះបញ្ចាំងពីកន្លែងនិងទីតាំងពិតរបស់ធនធាន ។ បញ្ជីរសារពើភ័ណ្ឌធនធានរបស់តំបន់ពិសេស ឆ្លុះបញ្ចាំងពីធនធានដែលមាននៅក្នុងអនុតំបន់របស់វា ។ ឧទាហរណ៍ បញ្ជីរសារពើភ័ណ្ឌធនធានខេត្ត គឺជាការចងក្រងបញ្ជីរសារពើភ័ណ្ឌធនធានទាំងឡាយមកពីបញ្ជីរសារពើភ័ណ្ឌធនធានតាមស្រុក ហើយបញ្ជីរសារពើភ័ណ្ឌធនធានស្រុក គឺជាការប្រមូលផ្តុំបញ្ជីរសារពើភ័ណ្ឌធនធានទាំងឡាយមកពីឃុំដែលមាននៅក្នុងស្រុក ។ល។

ក្នុងការរៀបចំបញ្ជីរសារពើភ័ណ្ឌធនធាន តួនាទីរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុក គឺជាស្នូលក្នុងការសំរបសំរួលការសហការក្នុងចំណោមអ្នកពាក់ព័ន្ធ( ភ្នាក់ងារពាក់ព័ន្ធនិងអង្គការផ្សេងៗ) ដើម្បីថែរក្សានិងធ្វើបច្ចុប្បន្នភាពបញ្ជីរសារពើភ័ណ្ឌ ។

## ៧.៥ ការវិភាគធនធាន

ឧទាហរណ៏នៃធនធានខុសៗគ្នាដែលមាននៅកំរិតខុសៗគ្នា : តាមផ្ទះសម្បែង ថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ មានក្នុងបញ្ជីរដូចខាងក្រោម ។

### *ធនធានតាមផ្ទះសម្បែង ថ្នាក់ភូមិ និងថ្នាក់ឃុំ :*

- *ធនធានមនុស្ស* - អ្នកស្ម័គ្រចិត្តកាកបាទក្រហម ក្រុមឆ្លើយតបគ្រោះមហន្តរាយនៅក្នុងភូមិ សមាជិកសហជីពស្ត្រី គណៈកម្មាធិការឃុំ អាជ្ញាធរ-ភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ក្រុមសុខាភិបាលថ្នាក់ភូមិ ឬក្រុមសង្គ្រោះបឋម។
- *ធនធានសំភារៈ*
    - o ការដឹកជញ្ជូន — នៅជិតផ្លូវថ្នាល់ ចំនួនផ្លូវថ្នល់ខាងលើប៉ាន់ប្រមាណកំរិតទឹក ម៉ូតូ ទុក ឡាន រទេះ ផ្លូវទៅតំបន់សុវត្ថិភាព។
    - o ការទំនាក់ទំនង - ឧបករណ៏វិទ្យុ ទូរទស្សន៏ ទូរស័ព្ទ ហ្វាក់ ប្រដាប់បំពងសំលេង។
    - o ទីជំរកនិងធនធានដែលពាក់ព័ន្ធ - ចំនួន ទីតាំង និងសមត្ថភាពរបស់តំបន់សុវត្ថិភាព-ទាំងអ្វីដែលមានស្រាប់និងអ្វីដែលជាសក្តានុភាព ដូចជា ដីទួលសាលារៀន វត្តអារាម ឬប្រាសាទ តង់បរិក្ខាជាមូលដ្ឋាន នៅតំបន់សុវត្ថិភាព។
    - o ប្រព័ន្ធស្តុបទុក- ចំនួនឃ្លាំង ឬតំបន់ស្តុបទុកដែលអាចជំនួស និងចំណុះរបស់វា។
    - o ប្រព័ន្ធសុខាភិបាល- ចំនួននិងទីតាំងគ្លីនិកឬកន្លែងថែទាំសុខភាពផ្សេងទៀតនៅក្នុងតំបន់ជុំវិញ។
    - o ផ្សេងៗ-ចំនួនឧបករណ៏ដែកប្រហោងមានរុន្ធ បង្គន់ ចំនួនស្នាមទឹកឡើង មណ្ឌលប្រកាសអាសន្ននៅក្នុងភូមិ ចំនួននិងទីតាំងប៉ុស្តិ៍ស្វែងរកនិងសង្គ្រោះ។
- *ធនធានហិរញ្ញវត្ថុ* —ចំនួនស្ថាប័នហិរញ្ញវត្ថុនៅក្នុងតំបន់ ការមានថវិកាមូលដ្ឋានសំរាប់គ្រោះអាសន្ន ម្ចាស់ជំនួយ-អ្នកបរិច្ចាកជាសក្តានុភាពដែលមាន ក្នុងករណីគ្រោះអាសន្ន។

### *ធនធាននៅថ្នាក់ស្រុក :*

- *ធនធានមនុស្ស* —គណៈកម្មាធិកា-ភ្នាក់ងារទទួលខុសត្រូវការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ស្រុក (ឧ.គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក DCDM គណៈកម្មាធិការកាកបាទក្រហមស្រុក ភ្នាក់ងារគ្រប់គ្រងធនធានទឹកនិងឧត្តុនិយម) អង្គការធំៗ(ឧ.សហជីពស្ត្រី ក្រុមអ្នកស្ម័គ្រចិត្ត ក្រុមយុវជន

ក្រុមកសិករ) បុគ្គលិកសុខាភិបាល បណ្តាញការងារអ្នកស្ម័គ្រចិត្តទទួលខុសត្រូវការផ្សព្វផ្សាយគ្រោះអាសន្ន អង្គការក្រៅរដ្ឋាភិបាល ។

- ***ធនធានសំភារៈ***
  - o ការដឹកជញ្ជូន-លើកផ្លូវ សេវាកម្មរថយន្ត-រទេះភ្លើងសាធារណៈ បណ្តាញផ្លូវល្អ ការទៅដល់តំបន់សុវត្ថិភាព ទូកនិងបណ្តាញទឹក ឡាន ម៉ូតូ រទេះ ។
  - o ការទំនាក់ទំនង-បណ្តាញព័ត៌មានសាធារណៈ (ឧ.បណ្តាញអ្នកស្ម័គ្រចិត្តកាកបាទក្រហម បណ្តាញសហជីពស្រ្តី) ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ម៉ាស៊ីនហ្វាក់ ក្តាររូបភាព និងឧបករណ៍ក្រិតទឹកជំនន់ ។
  - o ទីជំរកនិងធនធានដែលទាក់ទង- ចំនួននិងទីតាំងជំរកសុវត្ថិភាព( មានស្រាប់និងជាសក្តានុភាព) និងចំណុះរបស់វា បរិក្ខាជាមូលដ្ឋាននៅតំបន់សុវត្ថិភាព ។
  - o ប្រព័ន្ធស្តុបទុក ។
  - o ប្រព័ន្ធសុខាភិបាល-ចំនួននិងទីតាំងមន្ទីរពេទ្យនិងសេវាសុខាភិបាល ។
  - o ផ្សេងៗ-ការប្រើប្រាស់សេវា ដូចជា( ប្រព័ន្ធអាងស្តុកទឹក ប្រព័ន្ធចែកចាយទឹក) និងរោងចក្រផលិតអគ្គិសនី ប្រព័ន្ធលូរបង្ហូរទឹកសំអុយ ទំនប់ទឹកនិង dykes ។
- *ធនធានហិរញ្ញវត្ថុ*— ចំនួនស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារនៅក្នុងតំបន់ ការមានថវិកាគ្រោះអាសន្នមូលដ្ឋានម្ចាស់ ជំនួយ-អ្នកបរិច្ចាកជាសក្តានុភាពដែលមាន ក្នុងករណីគ្រោះអាសន្ន ។

## ***ធនធាននៅថ្នាក់ខេត្ត :***

- *ធនធានមនុស្ស* — គណៈកម្មាធិការទទួលខុសត្រូវការគ្រប់គ្រងគ្រោះមហន្តរាយ( ឧ. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត PCDM) អង្គការជាតិនិងអន្តរជាតិដែលធ្វើការនៅក្នុងតំបន់ សាខាកាកបាទក្រហមខេត្ត និងអ្នកស្ម័គ្រចិត្ត អង្គការធំៗ (ឧ. សហជីពស្រ្តីខេត្ត សហជីពកសិករនិងយុវជនក្រុមអ្នកស្ម័គ្រចិត្ត) អង្គការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត បណ្តាញអ្នកស្ម័គ្រចិត្តក្នុងមូលដ្ឋានទទួលខុសត្រូវការប្រកាសអាសន្ន ។

- *ធនធានសំភារៈ*
  - o ការដឹកជញ្ជូន-លើកផ្លូវ សេវាកម្មរថយន្ត-រទេះភ្លើងសាធារណៈ បណ្តាញផ្លូវល្អ ការទៅដល់តំបន់សុវត្ថិភាព ទូកនិងបណ្តាញទឹក ឡាន ម៉ូតូ រទេះ ។
  - o ការទំនាក់ទំនង-បណ្តាញព័ត៌មានសាធារណៈ (ឧ.បណ្តាញអ្នកស្ម័គ្រចិត្តកាកបាទក្រហម បណ្តាញសហជីពស្រ្តី) ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ម៉ាស៊ីនហ្វាក់ ក្តាររូបភាព និងឧបករណ៍វាស់ទឹកជំនន់ ។

- o ទីជំរកនិងធនធានដែលទាក់ទង- ចំនួនទីតាំងជំរកសុវត្ថិភាព( មានស្រាប់និងជាសក្តានុភាព) និងចំណុះរបស់វា បរិក្ខាជាមូលដ្ឋាននៅតំបន់សុវត្ថិភាព ។
- o ប្រព័ន្ធស្តុបទុក ។
- o ប្រព័ន្ធសុខាភិបាល-ចំនួននិងទីតាំងមន្ទីរពេទ្យនិងសេវាសុខាភិបាល ។
- o ផ្សេងៗ-ការប្រើប្រាស់សេវា ដូចជា( ប្រព័ន្ធអាងស្តុកទឹក ប្រព័ន្ធចែកចាយទឹក) និងរោងចក្រផលិតអគ្គិសនី ប្រព័ន្ធលូរបង្ហូរទឹកសំអុយ ទំនប់ទឹកនិង dykes ។

- ធនធានហិរញ្ញវត្ថុ - ចំនួនស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារនៅក្នុងតំបន់ ការមានថវិកាគ្រោះអាសន្នមូលដ្ឋាន ម្ចាស់ជំនួយ-អ្នកបរិច្ចាកជាសក្តានុភាពដែលមាន ក្នុងករណីគ្រោះអាសន្ន ។

## ***ធនធាននៅថ្នាក់ជាតិ :***

ធនធានជាតិគួរតែទទួលបានយ៉ាងងាយស្រួលដោយសហគមន៍គោលដៅនៅពេលមានគ្រោះមហន្តរាយកើតឡើង និងឥទ្ធិពលលើសពីសមត្ថភាពដោះស្រាយរបស់សហគមន៍ ។ ធនធានជាតិអាចបែងចែកបន្តទៀតទៅក្នុង ធនធានរដ្ឋាភិបាល និងអង្គការ ។

ធនធានរដ្ឋាភិបាល គឺ :

- *ធនធានមនុស្ស*- ក្រុមប្រឹក្សា-គណៈកម្មាធិការ- ក្រសួងគ្រប់គ្រងគ្រោះមហន្តរាយជាតិ ឬថ្នាក់កណ្តាលទទួលខុសត្រូវលើសេវាកម្មការពារជាតិ ឧត្តុនិយមជលសាស្ត្រ សេវាកម្មផ្លូវច្បាប់ ភ្នាក់ងារគ្រប់គ្រងកសិកម្មនិងធនធានទឹក ស្ថាប័នអប់រំ ការដឹកជញ្ជូន ប្រៃសនីយ៍និងទូរគមនាគមន៍ ការិយាល័យឬមជ្ឈមណ្ឌលព័ត៌មាន អង្គការសង្គមកិច្ច និងអាជ្ញាធរអាកាសចរណ៍ស៊ីវិល និងការហោះហើរ ។
- *ធនធានសំភារៈ* គ្របដណ្តប់លើធនធានដឹកជញ្ជូន ការទំនាក់ទំនង ទីជំរក និងធនធានទាក់ទង ប្រព័ន្ធស្តុកទុក ប្រព័ន្ធសុខាភិបាលនិងផ្សេងៗ ។
- *ធនធានហិរញ្ញវត្ថុ*- ស្ថាប័នហិរញ្ញវត្ថុថ្នាក់ជាតិ ថវិកាគ្រោះអាសន្នជាតិ ។

ធនធានក្រៅរដ្ឋាភិបាល គឺជាទ្រព្យសម្បត្តិគ្រប់គ្រងជាម្ចាស់និងប្រតិបត្តិដោយដោយសង្គមស៊ីវិល ដូចជា :

- *ធនធានមនុស្ស* —អ្នកមើលការខុសត្រូវវិទ្យុ អង្គការឯកជន-អង្គការពាណិជ្ជកម្ម ក្រុមសាសនា អ្នកលក់ដុំនិងអ្នកផ្គត់ផ្គង់ស្បៀងសង្គ្រោះបន្ទាន់ បុគ្គលិកពេទ្យឯកជន ក្រុមសាធារណៈ ដូចជាកាកបាទក្រហម អង្គការអឌ្ឍច័ន្ទក្រហមនៅថ្នាក់ជាតិ អង្គការសង្គមកិច្ច អ្នកស្ម័គ្រចិត្ត ជាពិសេសសកម្មជនយុវវ័យ ។

- *ធនធានសំភារ:* គ្រប់ដណ្តប់លើធនធានដឹកជញ្ជូន ការទំនាក់ទំនង ទីជំរកនិងធនធានទាក់ទង ប្រព័ន្ធស្តុកទុក និងប្រព័ន្ធសុខាភិបាលនិងផ្សេងៗ ។
- *ធនធានហិរញ្ញវត្ថុ* — ស្ថាប័នហិរញ្ញវត្ថុឯកជន ថវិកាដែលមានតាមរយៈកម្មវិធីអនុវត្តដោយភ្នាក់ងារកាត់បន្ថយគ្រោះមហន្តរាយនិងការអភិវឌ្ឍន៍ចំណុច ។

ក៏នៅមាន **ធនធានអន្តរជាតិ** ដែលជាមធ្យោបាយខាងក្រៅដែលប្រទេសមួយអាចទទួលបានដើម្បីជាបំណងកាត់បន្ថយគ្រោះមហន្តរាយ ។ ការប្រើប្រាស់ធនធានអន្តរជាតិដោយប្រទេសអាចពឹងផ្អែកលើកត្តាដូចតទៅ :

- កិច្ចព្រមព្រៀងជំនួយទ្វេភាគីដែលមានស្រាប់ ជាមួយអង្គការ ភ្នាក់ងារ ប្រទេសផ្តល់ជំនួយ ។
- ភាពទាក់ទងខាងផ្នែកនយោបាយ ពីទស្សនៈរបស់ប្រទេសជាអ្នកទទួល ក្នុងការទទួលជំនួយពីខាងក្រៅ ។
- ស្ថេរភាពនៃធនធានអន្តរជាតិ ជាពិសេស ស្ថានភាពគ្រោះមហន្តរាយ( ពីទស្សនៈរបស់ម្ចាស់ជំនួយ) ។

## ៧.៦ សំណួរសំរាប់ពិចារណា

១. តើធនធានសំខាន់អ្វីខ្លះដែលមាននៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក ដែលអាចប្រើប្រាស់ដើម្បីត្រៀមចំឆ្លើយ តបទៅនឹងទឹកជំនន់ ។

២. ហេតុអ្វីបានជាត្រូវយកចិត្តទុកដាក់ពិសេសចំពោះធនធានដែលមាននៅតាមផ្ទះ និងថ្នាក់ឃុំ?

៣. តើចំណាត់ថ្នាក់សំខាន់ៗអ្វីខ្លះដែលធនធាននៅគ្រប់កំរិតអាចត្រូវវាយតំលៃ?

# ជំពូកទី ៨

## ការវាយតំលៃ និង ការធ្វើបច្ចុប្បន្នភាព
## នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

# ការវាយតំលៃ និង ការធ្វើវឌ្ឍនភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

## ៨.១ ទិដ្ឋភាពរួម

ដំណើរការធ្វើការវាយតំលៃ ដែលពិចារណានៅទីនេះ គឺជាទម្រង់មួយនៃការតាមដានមើលការរីកចំរើនលើការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ជាមួយសកម្មភាពនិងដំណើរការ ព្រមទាំងលទ្ធផល និង សមិទ្ធផល។ ការធ្វើវឌ្ឍនភាព រួមបញ្ចូលការថ្លឹងថ្លែងការផ្លាស់ប្តូរពតិមានតាមពេលវេលានៅក្នុងខ្លឹមសារ នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់។ សារៈសំខាន់នៃការវាយតំលៃបែបមានការចូលរួមសំរាប់ការពិនិត្យឡើងវិញ ត្រូវបានសង្កត់ធ្ងន់ ថាជាការធ្វើដំណោះស្រាយ ការពិនិត្យគុណភាពនិងគណនេយ្យភាព។

## ៨.២ គោលបំណង

- ស្វែងយល់ពីសារៈសំខាន់នៃការវាយតំលៃទៀងទាត់លើផែនការត្រៀមបង្ការគ្រោះទឹកជំនន់។
- បង្កើតបញ្ជីរត្រួតពិនិត្យសំរាប់ធានាគុណភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់។
- ធ្វើការតាមដាននិងវាយតំលៃជាទៀងទាត់លើផែនការត្រៀមបង្ការគ្រោះទឹកជំនន់។
- រកមើលលំងាកវាងសកម្មភាព ដែលមានចែងក្នុងផែនការត្រៀមបង្ការគ្រោះទឹកជំនន់ និង ការអនុវត្តន៍ជាក់ស្តែង និង កំនត់រកវិធានការតម្រង់ទិស។
- ពិនិត្យផែនការត្រៀមបង្ការគ្រោះទឹកជំនន់ឡើងវិញជាទៀងទាត់ ផ្អែកលើមេរៀនដែលបានរៀនសូត្រ។

## ៨.៣ គោលគំនិតសំខាន់ៗ

១. ការវាយតំលៃនិងការធ្វើវឌ្ឍនភាព គឺជាផ្នែកសំខាន់នៅក្នុងដំណើរការអនុវត្តផែនការត្រៀមបង្ការគ្រោះទឹកជំនន់ដើម្បីសំរេចគោលបំណងនិងបេសសកម្មរបស់ខ្លួន។

២. ដំណើរការវាយតំលៃលើកកំពស់ការយល់ដឹងអំពីរបៀបធ្វើការតាមផែនការត្រៀមបង្ការគ្រោះទឹកជំនន់ និងជួយកំណត់រកបញ្ហា កំហុសឆ្គង ភាពខ្លាំង ភាពខ្សោយ និង មេរៀននៅក្នុងកំឡុងពេលរីកលូតលាស់នៃការអនុវត្តរបស់ខ្លួន។

៣. ដំណើការវាយតំលៃ និង ការធ្វើវឌ្ឍនភាព លើកកំពស់សកម្មភាពសហប្រតិបត្តិការក្នុងចំណោមអ្នកជាម្ចាស់ផែនការដំបូង ពោលគឺអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាននិងថ្នាក់ជាតិ និងអ្នកទទួលផលពោលគឺសហគមន៍ ដោយការស្វែងរកការចូលរួម និង ការឆ្លុះបញ្ចាំងពីសហគមន៍។

៤. ការវាយតំលៃលើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ គឺជាដំណើរការបន្តនិងជាម្ចាស់ទីមួយនៃ ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដែលទទួលខុសត្រូវក្នុងការអនុវត្តន៍សកម្មភាពដែលត្រូវការ។

៥. ការធ្វើវឌ្ឍនភាពលើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ អាចធ្វើឡើងមួយឆ្នាំម្តងៗ។

## ៨.៤ តើអ្វីជាការវាយតំលៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់?

គោលបំណងនៃការវាយតំលៃ គឺដើម្បីការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ឱ្យបានល្អប្រសើរ ដោយជូនដំណឹងអ្នកធ្វើផែនការ និង អ្នកធ្វើការសំរេចចិត្ត អំពីការរីកចំរើនដើម្បី សំរបសំរួលការប្រមែប្រមូល ហិរញ្ញវត្ថុ និង ធនធានចាំបាច់ផ្សេងទៀត និង ដើម្បីបង្កើតនូវវប្បធម៌មួយនៃការធ្វើឱ្យល្អប្រសើរជាបន្ត និង មាន គណនេយ្យភាព។ ដំណើរការមានប្រព័ន្ធត្រឹមត្រូវរបស់វា ជាមួយនឹងការសង្កត់ធ្ងន់លើការបញ្ជាក់តាមបែបការ ចូលរួមនៃគោលបំណងដែលបាន គ្រោងទុកទល់នឹងឥទ្ធិពលជាក់ស្តែងរបស់ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដោយអ្នកពាក់ព័ន្ធទាំងអស់ ផ្តល់ឱ្យអ្នកវាយតំលៃ នូវឱកាសឆ្លុះបញ្ចាំងពីរបៀបដែលផែនការត្រៀមបង្ការគ្រោះ ទឹកជំនន់ អាចផ្តល់ឱ្យបានល្អបំផុត និង បន្ទាប់មក ប្រើព័ត៌មាននោះដើម្បីធ្វើឱ្យដំណើរការអនុវត្ត បានល្អប្រសើរ ជាងមុន។

## ៨.៥ តើអ្វីជាវឌ្ឍនភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់?

នៅក្នុងដំណើរការធ្វើវឌ្ឍនភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ត្រូវពិនិត្យផែនការឡើងវិញ និងធ្វើ វឌ្ឍនភាពឬកែសំរួលឡើងវិញ ប្រសិនបើមានការងាកចេញពីសកម្មភាព ដែលបានកំនត់នៅក្នុងផែនការឬដំណើរ ការ ដែលបានរកឃើញតាមរយៈការវាយតំលៃនិងវិធានការដោះស្រាយ នឹងត្រូវបញ្ចូលនៅក្នុងវឌ្ឍនភាព នៃផែន ការត្រៀមបង្ការគ្រោះទឹកជំនន់សំរាប់ការអនុវត្តន៍ថែមទៀត។ វាគឺជាអនុសាសន៍ស្នើឡើង ដើម្បីធ្វើវឌ្ឍនភាពផែន ការត្រៀមបង្ការគ្រោះទឹកជំនន់ តាមចន្លោះពេលទៀងទាត់ ដែលត្រូវកំនត់ដោយអាជ្ញាធរ ដែលទទួលខុសត្រូវ ឃ្លាំ មើលការអនុវត្តន៍។ ការធ្វើវឌ្ឍនភាពផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ក៏ធ្វើឱ្យមានការថ្លឹងថ្លែងតាមពេលវេលា នៃបរិមាណមូលដ្ឋានពត៌មានរបស់ផែនការ ដូចជាសាវតាខេត្ត-ស្រុក បញ្ជីរសារពើភ័ណ្ឌ ធនធាន លទ្ធផលនៃការ វាយតំលៃលើមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះនិងសមត្ថភាព ព្រមទាំងទិន្នន័យផ្នែកប្រតិបត្តិការនិងរដ្ឋបាល ។

**ចំណុចសំខាន់ៗសំរាប់ការវាយតំលៃ**

ការវាយតំលៃគួរតែធ្វើឡើងដោយផ្អែកលើ :

១. **វិនិយោគ** : វាយតំលៃប្រសិទ្ធិភាពនិងភាពត្រឹមត្រូវនៃធនធានមនុស្ស សំភារៈ និងហិរញ្ញវត្ថុ និង ដាក់ ពង្រាយនៅក្នុងផែនការត្រៀមបង្ការគ្រោះទឹកជំនន់។

២. **សកម្មភាពនិងដំណើរការ :** វាយតំលៃមធ្យោបាយអនុវត្តកិច្ចការខុសៗគ្នា ( មានកំណត់នៅក្នុង ផែនការ ត្រៀមបង្ការគ្រោះទឹកជំនន់)

៣. **ទិន្នផល :** វាយតំលៃលទ្ធផលភ្លាមៗ ដែលសំរេចបានដោយការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់

៤. **ឥទ្ធិពល (លទ្ធផល):** វាយតំលៃការផ្លាស់ប្តូរជាដុំកំភួនឬចុងក្រោយក្នុងជីវភាពរស់នៅរបស់ប្រជាជន ការសំរេចបានពីការអនុវត្តន៍ផែនការត្រៀមបង្ការទឹកជំនន់។

## ៨.៦ ការវាយតំលៃនិងការវឌ្ឍនភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

ប្រព័ន្ធការវាយតំលៃនិងការធ្វើវឌ្ឍនភាព គួរតែបង្កើតឡើង និង ចែងអោយច្បាស់នៅក្នុងផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដើម្បី :

- ផ្តល់ឱ្យអ្នកចូលរួមនូវព័តិមានដែលចាំបាច់ដើម្បីណែនាំពួកគេឆ្ពោះទៅសំរេចគោលដៅនិងគោលបំណងរបស់ផែនការ ត្រៀមបង្ការគ្រោះទឹកជំនន់ ។
- ផ្តល់ការប្រកាសអាសន្នជាមុន សំរាប់សកម្មភាពដែលមានបញ្ហា វាយតំលៃឥទ្ធិពលនៃសកម្មភាពដែលបានអនុវត្តកន្លងមក និង ដំណើរការដែលត្រូវការវិធានការកែតំរូវ ។
- ធានាប្រតិបត្តិការគំរោងមានប្រសិទ្ធិភាព ។
- វាយតំលៃការរីកចំរើនសំរាប់គណនេយ្យភាព ។

ប្រព័ន្ធការវាយតំលៃនិងការធ្វើវឌ្ឍនភាពមួយ មានប្រសិទ្ធិភាពសំរាប់ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ខេត្ត-ស្រុក គួរតែមានលក្ខណៈដូចតទៅ :

- អ្នកពាក់ព័ន្ធសំខាន់ៗនិងតួនាទីជាក់លាក់របស់ពួកគេ ។
- ប្រើឧបករណ៏វាយតំលៃដែលមានភាពទាក់ទាញ ភ្ជាប់ជាមួយប្រព័ន្ធប្រមូលនិងគ្រប់គ្រងទិន្នន័យមាន ប្រសិទ្ធិភាព និង ទាន់ពេលវេលា ។
- សូចនាករណ៏ (ឧបករណិ) សំរាប់វាស់វែងឥទ្ធិពល ។
- យន្តការបែបមានការចូលរួមសំរាប់បង្កើតវិធានការកែលំអ ។

## ៨.៧ សំណួរសំរាប់ពិចារណាអំពីការធ្វើវឌ្ឍភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

១. តើមានតារាងកាលវិភាគ ដើម្បីអនុវត្តការការវាយតំលៃ និង ការធ្វើវឌ្ឍនភាព ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដែរឬទេ?
២. តើមន្ទីរពាក់ព័ន្ធដែលធ្វើការជាមួយ គណៈកម្មាធិការខេត្ត និង ស្រុកគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានចាត់ចែងឱ្យមានការទទួលខុសត្រូវជាក់លាក់សំរាប់ការវាយតំលៃដែរឬទេ?
៣. តើគោលដៅនិងគោលបំណងទាំងនេះ ពិតប្រាកដឬទេ ? គួរតែត្រូវវបានកែសំរួល?
៤. តើគោលដៅ នឹងអាចបានសំរេចទៅតាមកាលវិភាគដែលបានចែងនៅក្នុងផែនការត្រៀមបង្ការ គ្រោះទឹកជំនន់ដែរឬទេ? បើមិនបាន ហេតុអ្វី និង សំរេចបានយ៉ាងដូចម្តេច?
៥. ក្នុងករណីមានការពន្យារពេល តើពេលកំនត់សំរាប់បញ្ចប់គួរតែត្រូវបានផ្លាស់ប្តូរដែរឬទេ ឬក៏មានមធ្យោបាយណាមួយដើម្បីពន្លឿនដំណើរការអនុវត្តន៏នេះ?

៦. តើធនធានដែលបានបែងចែកគ្រប់គ្រាន់ដើម្បីសំរេចគោលដៅដែរឬទេ? បើមិនគ្រប់គ្រាន់ តើត្រូវការប៉ុន្មានទៀត?

៧. តើសូចនាករណ៍ (ឧបករណ៍ចង្អុលបង្ហាញ) អ្វីខ្លះ អាចប្រើប្រាស់បានដើម្បីវាស់ស្ទង់ឥទ្ធិពលនៃការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់?

៨. តើអ្វីខ្លះ ដែលអាចរៀនសូត្របានពីដំណើការវាយតំលៃនិងធ្វើវឌ្ឍនភាព ដើម្បីធ្វើឱ្យសកម្មភាពធ្វើផែនការអនាគត ព្រមទាំងកិច្ចប្រឹងប្រែងធ្វើការវាយតំលៃនិងធ្វើវឌ្ឍនភាព បានល្អប្រសើរ?

## ៨.៨ ជំហានការវាយតំលៃនិងការធ្វើវឌ្ឍនភាពដែលត្រូវតាមដាន

- លើកគំរោងនិងបង្កើតផែនការមួយ សំរាប់វាយតំលៃនិងធ្វើវឌ្ឍនភាព នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដោយគូសបញ្ជាក់ពីភ្នាក់ងារទទួលខុសត្រូវ សកម្មភាពធ្វើមួយជំហានម្តងៗ ថវិកា ពេលវេលា និង លទ្ធផលរំពឹងទុក ។
- ធានាថា មន្ទីរ (រដ្ឋាភិបាល) ដែលពាក់ព័ន្ធទាំងអស់ ដែលជាសមាជិករបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយតំបន់ លៃលកពេលវេលានិងធនធានទុកគ្រប់គ្រាន់សំរាប់ការវាយតំលៃនិងធ្វើវឌ្ឍនភាព ។
- បង្កើតវិធីសាស្ត្ររាយការណ៍អំពីការវាយតំលៃ និង តំរូវការនៃការរាយការណ៍ ។
- រៀបចំធ្វើការពិនិត្យឡើងវិញបែបមានការចូលរួមទៀងទាត់ ផ្អែកលើរបាយការណ៍វាយតំលៃ ។ ធ្វើឱ្យអង្គការ និង សហគមន៍ចូលរួមនៅក្នុងការវាយតំលៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ។
- ធ្វើឱ្យមានការឯកភាពគ្នាលើវិធានការដែលត្រូវការ ដើម្បីឱ្យការអនុវត្តន៍វិធានការបានល្អប្រសើរឡើង ។
- ពិនិត្យមេរៀនបទពិសោធន៍ឡើងវិញ សំរាប់ការធ្វើគោលនយោបាយត្រៀមបង្ការគ្រោះទឹកជំនន់ និង ការធ្វើផែនការអនាគត ។

## ៨.៩ អ្នកពាក់ព័ន្ធ និង តួនាទីសំខាន់ៗរបស់ពួកគេក្នុងការវាយតំលៃនិងធ្វើវឌ្ឍនភាព

ការវាយតំលៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ គួរតែជាដំណើរការបែបមានការចូលរួម ។ ការវាយតំលៃបែបនេះ ទើបអាចឱ្យអ្នកពាក់ព័ន្ធដឹងពីបញ្ហានិងដឹងពីគ្នាទៅវិញទៅមកបាន ដើម្បីធ្វើឱ្យការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់កាន់តែមានប្រសិទ្ធិភាពឡើង ។ តារាងខាងក្រោម ផ្តល់នូវឧទាហរណ៍មួយអំពីបញ្ជីរឈ្មោះរបស់អ្នកចូលរួមសំខាន់ៗ របស់ផែនការត្រៀមបង្ការគ្រោះទឹកជំនន់នៅថ្នាក់ខេត្តនិងស្រុក និង តួនាទីលំអិតនៅក្នុងការវាយតំលៃ និង មុខងារក្នុងការធ្វើវឌ្ឍនភាព ។

| ល.រ | អ្នកពាក់ព័ន្ធ | តួនាទីនៅក្នុងការវាយតំលៃនិងការធ្វើវឌ្ឍនភាព |
|---|---|---|
| ១ | លេខាធិការដ្ឋាន PCDM/DCDM | ▪ លើកគំរោងនិងបង្កើតប្រព័ន្ធវាយតំលៃមួយ<br>▪ បង្កើតឧបករណ៍វាយតំលៃនិងកាលវិភាគសំរាប់សកម្មភាព |

| | | |
|---|---|---|
| | | ▪ ពិនិត្យឡើងវិញនិងអនុម័តសកម្មភាព<br>▪ ឃ្លាំមើលចរន្តហិរញ្ញវត្ថុដើម្បីធានាការគ្រប់គ្រងហិរញ្ញវត្ថុមានប្រសិទ្ធិភាព<br>▪ ទទួលព័ត៌មានពីដៃគូរអនុវត្ត( អង្គការមូលដ្ឋាន)<br>▪ ធានាការរាយការណ៍មានគុណភាពទៅភ្នាក់ងារខាងក្រៅ ( ឱ. ម្ចាស់ជំនួយ) និងអ្នកពាក់ព័ន្ធផ្សេងទៀត ។<br>▪ រៀបចំធ្វើការវាយតំលៃផែនការអនុវត្តតាមពេលកំណត់<br>▪ ធ្វើការសំរេចចិត្តជាចុងក្រោយលើវិធានការកែតំរូវ ដោយពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធផ្សេងទៀតតាមរយៈកិច្ចប្រជុំពិនិត្យឡើងវិញនិងតាមមធ្យោបាយផ្សេង១ |
| ២ | សមាជិកមន្ទីរពាក់ព័ន្ធរបស់អាជ្ញាធរ<br>គ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន | ▪ អនុវត្តសកម្មភាពដែលពាក់ព័ន្ធ<br>▪ ផ្តល់គំនិតឬយោបល់ត្រឡប់ លើឥទ្ធិពលរបស់សកម្មភាព<br>▪ ចូលរួមនៅក្នុងការពិនិត្យនិងការវាយតំលៃតាមពេលកំណត់ |
| ៣ | អង្គការមូលដ្ឋាន-អង្គការក្នុងស្រុក | ▪ ចូលរួមក្នុងដំណាក់កាលលើកគំរោងផែនការ<br>▪ អនុវត្តផែនការដៃគូរ<br>▪ សំរបសំរួលការវាយតំលៃបែបមានការចូលរួម និង ដំណើរការធ្វើបច្ចុប្បន្នភាព<br>▪ ប្រមូលព័ត៌មានអំពីការរីកលូតលាស់នៃការអនុវត្តន៍ផែនការ |
| ៤ | ទីប្រឹក្សា-ទីប្រឹក្សាបច្ចេកទេស | ▪ ជួយអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋានក្នុងការបង្កើតប្រព័ន្ធវាយតំលៃនិងឃ្លាំមើលប្រតិបត្តិការ ។<br>▪ ធ្វើការវាយតំលៃសកម្មភាព ជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់តាមពេលកំនត់ ។ |
| ៥ | ប្រជាជនក្នុងស្រុក | ▪ ផ្តល់យោបល់ត្រឡប់ លើដំណើរការអនុវត្តនិងឥទ្ធិពលរបស់វាតាមរយៈក្រុមពិគ្រោះយោបល់ កិច្ចប្រជុំពិនិត្យឡើងវិញ និងការវាយតំលៃបែបមានការចូលរួម ។ |
| ៦ | អាជ្ញាធរជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ▪ បង្កើតប្រព័ន្ធវាយតំលៃនិងវឌ្ឍភាពរួមនៅថ្នាក់ជាតិស្របទៅតាម ផែនការអភិវឌ្ឍជាតិ ដើម្បីធានាថាការត្រៀមបង្ការគ្រោះទឹក ជំនន់បានបញ្ចូលនៅក្នុងផែនការ ។ |

| | | |
|---|---|---|
| | | ▪ ចំនាត់ធនធាន សំរាប់អនុវត្តផែនការត្រៀមបង្ការគ្រោះទឹកជំនន់<br>▪ កត់ត្រាការរីកចំរើនខាងការអនុវត្តផែនការត្រៀមបង្ការគ្រោះទឹកជំនន់ នៅថ្នាក់មូលដ្ឋាន។<br>▪ ចូលរួមនៅក្នុងការពិនិត្យនិងវាយតំលៃតាមពេលវេលាកំនត់<br>▪ ជួយអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយក្នុងការអនុវត្តវិធានការកែតំរូវដោយការប្រមូលធនធានដែលចាំបាច់។ |

ក្រុមការងារបច្ចេកទេស ក្រុម ឬ គណៈកម្មាធិការពិសេស អាចបង្កើតឡើងដើម្បីវាយតំលៃ និង ធ្វើវឌ្ឍនភាព ដោយមានតំណាងពីអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយ មន្ទីរជាសមាជិក និង អ្នកដឹកនាំសហគមន៍របស់ពួកគេ។

## ៨.១០ ការប្រមូលនិងការគ្រប់គ្រងពត៌មានមានប្រសិទ្ធិភាពនិងទាន់ពេលវេលា

ពតិមានដែលអាចជឿទុកចិត្តបាន ត្រឹមត្រូវ និងមានពេលវេលាច្បាស់លាស់ គឺមានសារៈសំខាន់នៅក្នុងដំណើរការវាយតំលៃនិងការធ្វើវឌ្ឍភាព។ ចំនុចសំខាន់ៗខាងក្រោមនេះ គួរតែត្រូវបានពិចារណា ដើម្បីធានាការប្រមូល និង គ្រប់គ្រងពតិមាន មានប្រសិទ្ធិភាពនិងទាន់ពេលវេលា។

១. កំនត់ពតិមានដែលត្រូវប្រមូល (ឥទ្ធិពល រយៈពេល ការរីកចំរើននៃសកម្មភាពប្រតិបត្តិការប្រចាំថ្ងៃ មេរៀន បទពិសោធន៍ពីឆ្នាំមុនៗ។ល។)
២. ពិនិត្យមើល ក្រែងមានក្រុម-អង្គការណាមួយដែលមានពតិមានចាំបាច់រួចស្រេចហើយ។
៣. ត្រូវដឹងឱ្យប្រាកដអំពីពតិមានពិតដែលត្រូវការ។
៤. កំនត់វិធីសាស្ត្រប្រមូលពតិមាន (ឧ. បុគ្គលឬក្រុមផ្អែកលើវិធីសាស្ត្រ វិភាគអ្នកពាក់ព័ន្ធ កម្រងសំណួរ ការវាយតំលៃបែបមានការចូលរួម)។ ធ្វើឱ្យប្រាកដថា វាអាចមើលឃើញតាមបច្ចេកទេសនិងហិរញ្ញវត្ថុសំរាប់ភាគីប្រមូលទិន្នន័យ។
៥. កំណត់ក្រុម-បុគ្គលគោលដៅសំរាប់ធ្វើការវាយតំលៃឥទ្ធិពល។
៦. កំនត់ភាពញឹកញាប់នៃការប្រមូលទិន្នន័យ។
៧. ពិចារណារបៀបរួមចំណែកធ្វើកិច្ចការប្រមូល និង វិភាគទិន្នន័យ នៅក្នុងចំណោមភ្នាក់ងារ-ដៃគូរអនុវត្តផ្សេងៗគ្នា ដើម្បីធ្វើឱ្យកំហុសឆ្គងមានកំរិត។
៨. ធានាពីភាពច្បាស់លាស់នៃភាសា។
៩. កំនត់វិធីសាស្ត្រចែករំលែកទិន្នន័យដែលប្រមូលបាន (ឧ. រូបាយការណ៍ កិច្ចប្រជុំពិនិត្យឡើងវិញ សិក្ខាសាលា និង ការជូនដំណឹងជាសាធារណៈ) សំរាប់ការចែករំលែកជាមួយអ្នកពាក់ព័ន្ធផ្សេងទៀត។
១០. ស្វែងរកមតិនិងយោបល់ត្រឡប់ ពីអ្នកពាក់ព័ន្ធផ្សេងៗ នៅពេលដែលពតិមានបានចែកចាយរួច ។

## ៨.១១ ការពិនិត្យឡើងវិញ និង ការធ្វើវឌ្ឍនភាព នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

ដើម្បីពិនិត្យផែនការត្រៀមបង្ការគ្រោះទឹកជំនន់ឡើងវិញ ការអនុវត្តធ្វើការពិភាក្សាមួយ អាចរៀបចំឡើង ដោយ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាននៅក្នុងចន្លោះមុនការកំនត់ តាមទម្រង់កិច្ចប្រជុំប្រចាំឆមាស ឬ ប្រចាំឆ្នាំ។ ជាធម្មតា វាមានការចូលរួមពីតំណាងមកពីភ្នាក់ងារពាក់ព័ន្ធ អង្គការ ព្រមទាំងអ្នកវាយតំលៃ មកពី ខាងក្រៅ។ ការផ្លាស់ប្តូរដែលអាចមាន គឺ :

- ការរៀបចំអនុវត្តផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាលទ្ធផលនៃបទពិសោធន៍ក្រោយពេលទឹកជំនន់ ឬ ការ អនុវត្ត ដែលបង្ហាញឱ្យឃើញពីភាពកម្សោយនៅក្នុងសកម្មភាពពីលើកមុនៗ។
- ការងារត្រួតពិនិត្យឬកាត់បន្ថយគ្រោះទឹកជំនន់
- ការធ្វើឱ្យប្រសើរឡើងនូវលទ្ធភាពព្យាករណ៍ទឹកជំនន់
- សាវតាតំបន់ និង លទ្ធផលនៃការវាយតំលៃមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព ។

គេត្រូវតែទទួលស្គាល់ថា ការផ្លាស់ប្តូរដែលបានបញ្ចូលទៅក្នុងផែនការត្រៀមបង្ការគ្រោះទឹកជំនន់ នឹងមានឥទ្ធិពល លើសមត្ថភាពរបស់ភ្នាក់ងារដើម្បីឆ្លើយតបទៅនឹងការទាមទាររបស់ផែនការ ត្រៀមបង្ការគ្រោះទឹកជំនន់។ ផែនការត្រៀមបង្ការទឹកជំនន់ គួរតែត្រូវបានធ្វើអោយប្រសើរឡើង ផ្អែកលើលទ្ធផលត្រួតពិនិត្យ។ ការផ្លាស់ប្តូរ ដែលមានទម្រង់ជាវិធានការកែតម្រូវ ត្រូវបានបង្កើតឡើងនិងអនុវត្តផ្អែកលើយោបល់ត្រឡប់ មតិ និង លទ្ធផល នៃការប្រមូលទិន្នន័យ និងដំណើរការពិគ្រោះយោបល់របស់អ្នកពាក់ព័ន្ធ។ វិធានការ គួរតែឆ្លុះបញ្ចាំងពីសកម្មភាព ដែលបានគ្រោងទុកពីខាងដើម និង បង្កើតឡើងជាមួយគោលបំណងដឹកនាំការអនុវត្តន៍ តាមផែនការដើម តាម ដែលអាចធ្វើទៅបាន នៅពេលតែមួយដែលអនុញ្ញាតឱ្យមានភាពបត់បែន ដើម្បីដោះស្រាយជាមួយស្ថានភាពផ្លាស់ប្តូរ នៅជុំវិញគ្រោះទឹកជំនន់។

នៅក្នុងវគ្គពិនិត្យឡើងវិញ គួរតែលើកលើងនូវសំណួរទាំងនេះ :

- តើសកម្មភាពត្រៀមបង្ការបានអនុវត្តដល់ណាហើយ ចាប់តាំងពីការអនុវត្តផែនការលើកមុនមក?
- តើសកម្មភាពបានបញ្ចប់ទៅតាមកាលវិភាគទុកមុនកំនត់ដែរឬទេ?
- តើសកម្មភាពត្រៀមបង្ការអ្វីខ្លះត្រូវការអនុវត្តបន្តមុនរដូវទឹកជំនន់បន្ទាប់?
- តើមានការសន្និដ្ឋានយ៉ាងដូចម្តេចលើដំណើរកាវាយតំលៃចុងក្រោយបំផុត?
- តើឥទ្ធិពលជាក់ស្តែង និង លទ្ធផលរំពឹងទុកងាកខុសចេញពីគ្នាក្នុងករិតណា?
- តើវិធានការកែតំរូវអ្វីខ្លះដែលបានកំនត់?
- តើអាចធ្វើសមាហរណកម្មអ្វីខ្លះទៅក្នុងផែនការដើម្បីធានាការសំរេចគោលបំណងបាន?
- តើមានតំរូវការសំរាប់ធនធានបន្ថែមដែរឬទេ (សំរាប់អនុវត្តវិធានការកែតំរូវ)?

- បើមាន តើអាចរកធនធានបានមកពីកន្លែងណា? នរណានឹងទទួលខុសត្រូវឃ្លាំមើលការអនុវត្តន៏វិធានការកែតំរូវ?
- តើត្រូវការផ្លាស់ប្តូរអ្វីខ្លះដើម្បីធ្វើវឌ្ឍភាពផែនការ ដើម្បីធានាការអនុវត្តន៏កាន់តែមានប្រសិទ្ធិភាពសំរាប់រដូវទឹកជំនន់ដែលនឹងមកដល់?
- តើបានរៀនសូត្របទពិសោធន៏អ្វីខ្លះពីរដូវទឹកជំនន់ឆ្នាំមុន?
- តើវិធានការផ្លាស់ប្តូរ-ភាពល្អប្រសើរអ្វីខ្លះដែលបានអំពាវនាវ(ផ្អែកលើមេរៀនបទពិសោធន៏) ដើម្បីធានាការធ្វើផែនការកាន់តែមានប្រសិទ្ធិភាពសំរាប់គ្រោះអាសន្នទឹកជំនន់និងការឆ្លើយតបទឹកជំនន់?
- តើវិធានការសំរាប់ធ្វើឱ្យប្រសើរឡើងអ្វីខ្លះត្រូវបានកំនត់?
- តើវាអាចធ្វើសមាហរណកម្ម ទៅក្នុងផែនការត្រៀមបង្ការទឹកជំនន់យ៉ាងដូចម្តេច ដើម្បីធានាការសំរេចគោលបំណងបាន?
- តើមានតំរូវការសំរាប់ធនធានបន្ថែម(ដើម្បីអនុវត្តវិធានការធ្វើឱ្យប្រសើរឡើង) ដែរឬទេ?
- បើមាន តើអាចរកធនធានបានមកពីកន្លែងណា? នរណានឹងទទួលខុសត្រូវឃ្លាំមើលការអនុវត្តន៏វិធានការកែតំរូវ?
- តើត្រូវការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីធ្វើអោយផែនការត្រៀមបង្ការគ្រោះទឹកជំនន់ បានប្រសើរឡើង ក្នុងការធានាការអនុវត្តន៏កាន់តែមានប្រសិទ្ធិភាព សំរាប់រដូវទឹកជំនន់ឆ្នាំបន្ទាប់?

## ៨.១២ សំណួរសំរាប់ពិចារណា

១. ហេតុអ្វីបានការវាយតំលៃនិងការធ្វើវឌ្ឍភាព មានសារៈសំខាន់សំរាប់ផែនការត្រៀមបង្ការគ្រោះទឹកជំនន់?

២. តើនរណាខ្លះ ជាអ្នកពាក់ព័ន្ធសំខាន់ៗ?

៣. លើកឡើងពីសំណួរសំខាន់ៗ ដែលត្រូវដោះស្រាយនៅក្នុងការពិនិត្យការវាយតំលៃឡើងវិញ។

## ៨.១៣ សេចក្តីយោង


- ការគ្រប់គ្រងគ្រោះមហន្តរាយ ប្រទេសអូស្ត្រាលី(១៩៩៩)ៈគោលការណ៏ណែនាំលេខ៤ : ការត្រៀមបង្ការគ្រោះទឹកជំនន់-សេរីឯកសារមេរៀនស្តីពីគ្រោះមហន្តរាយ ភាគ III
- ADPC
- VNRC , ឯកសារមេរៀនស្តីពីការត្រៀមបង្ការគ្រោះមហន្តរាយ

# ជំពូកទី ៩

## ការបញ្ជ្រាបតំរូវការពិសេស
## របស់ក្រុមដែលងាយរងគ្រោះ
## នៅក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់

# ការបញ្ជ្រាបតំរូវការពិសេស របស់ក្រុមដែលងាយរងគ្រោះ នៅក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់

## ៩.១ ទិដ្ឋភាពរួម

ជំពូកនេះ ទាក់ទាញការយកចិត្តទុកដាក់របស់យើង ពិចារណាពីតំរូវការពិសេសរបស់ក្រុមដែលងាយរងគ្រោះបំផុតនៅក្នុងសហគមន៍-ស្ត្រី កុមារ មនុស្សចាស់ជរា ជនពិការ ជនជាតិភាគតិច និងជនក្រីក្រ។ ទាំងនេះ គឺជាសមាជិករបស់សហគមន៍ ដែលជាទូទៅ ទំនងជាករណីរងការប៉ះពាល់ខ្លាំងបំផុតពីគ្រោះមហន្តរាយ ពីព្រោះពួកគេត្រូវបានដកហូតសិទ្ធិពីការទទួលបានធនធាន ដូចជា បណ្តាញការងារសង្គម ឥទ្ធិពល ការដឹកជញ្ជូន ព័ត៌មាន ជំនាញ(រួមទាំងអក្ខរកម្ម) និងការងារ ការចល័តជាបុគ្គល សុវត្ថិភាពផ្ទះសម្បែង ការត្រួតពិនិត្យលើការសំរេចចិត្ត និងលើដីធ្លី ធនធានសេដ្ឋកិច្ចផ្សេងទៀត និងការពឹងផ្អែកលើអ្នកដទៃ។ អ្នកប្រឆាំងការបញ្ចូលផ្នែកសង្គម នឹងធ្វើឱ្យការធ្វើផែនការត្រៀមបង្ការ អាចផ្តល់កិរិតគួរឱ្យពិចារណាបាន មិនត្រឹមតែឆ្លើយតបទៅនឹងស្ថានភាពទឹកជំនន់ទេ ប៉ុន្តែក៏អាចលើកកំពស់ស្ថានភាពរបស់ក្រុមដែលងាយរងគ្រោះទាំនេះ។

## ៩.២ គោលបំណង

- ស្វែងយល់ពីមូលហេតុពិចារណាលើតំរូវការពិសេសរបស់ក្រុមដែលងាយរងគ្រោះ គឺមានសារៈសំខាន់ក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់។
- លើកឡើងពីភាពពិតនៃសង្គមនៃសហគមន៍មួយជាមួយការផ្តោតបច្ចុប្បន្ននៃការធ្វើផែនការត្រៀមបង្ការលើវិស័យរូបសាស្ត្រ
- ពន្យល់ពីតំរូវការពិសេសនៃក្រុមខុសៗគ្នានិងការធ្វើផែនការដែលមានបែបសង្គម
- រកមើលមធ្យោបាយធ្វើសមាហរណកម្មតំរូវការពិសេសរបស់ក្រុមដែលងាយរងគ្រោះទៅក្នុង FPP.
- សង្កត់ធ្ងន់លើការធ្វើឱ្យសំរេចបាននូវសមភាពយេនឌ័រនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបញ្ជ្រាបយេនឌ័រទៅក្នុងគ្រប់វិស័យ ចាប់ពីគោលនយោបាយនិងយុទ្ធសាស្ត្រដល់ផែនការត្រៀមបង្ការទឹកជំនន់។
- លើកឡើងថា ការបញ្ជ្រាបតំរូវការពិសេសទៅក្នុងការធ្វើផែនការត្រៀមបង្ការ គឺជាតំលៃនៃការអភិវឌ្ឍច្រើនជាងសីលធម៌។

## ៩.៣ គោលគំនិតសំខាន់ៗ

- សហគមន៍គឺជាចំណែកមួយជានិច្ច។ វាបង្ហាញនៅពេលទឹកជំនន់កើតឡើង មានក្រុមជាក់លាក់ដែលអាចស្ថិតនៅក្នុងគ្រោះថ្នាក់ខ្ពស់ជាងអ្នកផ្សេង ពីព្រោះតែស្ថានភាពសង្គម-សេដ្ឋកិច្ចនិងរូបសាស្ត្រ អាយុឬចរិត

លក្ខណៈចិត្តសាស្ត្រ។ ទាំងនេះ រួមមាន ស្ត្រី កុមារ មនុស្សចាស់ជរា ជនពិការ ជនជាតិភាគតិចនិងជនក្រីក្រ។

- ក្រុមដែលងាយរងគ្រោះគឺមិនមែនជាក្រុមតែមួយនោះទេ។ អាចមានការបែងចែកថែមទៀតនិងសមាសភាពនៅក្នុងក្រុមទាំងនេះដែលធ្វើឱ្យភាពទន់ខ្សោតកើនឡើង។ ឧទាហរណ៍ ទាំងនេះ អាចជាមនុស្សចាស់ជរា ក៏ជាអ្នកក្រីក្រឬជាជនពិការឬជាស្ត្រី ឬដែលរួមផ្សំគ្នាទាំងអស់។
- ដើម្បីបញ្ច្រៀបតំរូវការពិសេសរបស់ពួកគេ គឺត្រូវគិតពីភាពដែលងាយរងគ្រោះជាក់លាក់របស់ពួកគេ និងឱ្យពួកគេចូលរួមធ្វើផែនការត្រៀមបង្ការ។
- មូលហេតុនៃភាពដែលងាយរងគ្រោះអាចខុសគ្នាពីវេជ្ជសាស្ត្រ វប្បធម៌ ការដឹង ពូជសាសន៍ រូបសាស្ត្រ ឬការរួមផ្សំទាំនេះ។
- អ្នកធ្វើផែនការនឹងត្រូវកំណត់និងឱ្យអាទិភាពអ្នកដែលនៅក្នុងចំណោមក្រុមដែលងាយរងគ្រោះត្រូវការការយកចិត្តទុកដាក់ និងការថែទាំជាពិសេសរបស់យើង។
- ដោយសារតែលក្ខណៈជីវសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ពួកគេ បុរសនិងស្ត្រីដែលរងគ្រោះខុសៗគ្នាដោយសារគ្រោះមហន្តរាយទាំងនៅក្នុកំឡុងពេលនិងក្រោយពេលព្រឹត្តិការណ៍។ស្ត្រីងាយរងគ្រោះជាងដោយសារតែភាពទន់ខ្សោយខាងរាងកាយ។ ពួកគេត្រូវទទួលខុសត្រូវការងារផ្ទះ និងត្រូវគោរពតាមសាសនានិងប្រពៃណីវប្បធម៌ផ្សេងៗ។ ជាបន្ថែម ការងារផ្ទះរបស់ពួកគេ រួមមាន ការថែទាំកូនៗនិងមនុស្សចាស់ជរាទៀតផង។ បើទោះជាជាប់រវល់ក្នុងការងារក្តី ស្ត្រីភាគច្រើនចូលរួមវិស័យកសិកម្មធ្វើការងារខ្លួនឯង ឬសេដ្ឋកិច្ចក្រៅផ្លូវការ មានសន្តិសុខតិចតួចនិងគ្មានកំរៃ។ វិស័យទាំងនេះ ជាទូទៅ រងការប៉ះពាល់ខ្លាំងបំផុតពីទឹកជំនន់ គ្មានការធានាសងជំងឺចិត្ត ធ្វើឱ្យស្ត្រីគ្មានការងារធ្វើ។ មូលហេតុដើមនៃភាពងាយរងគ្រោះរបស់ស្ត្រី គឺស្ថានភាពសង្គមនិងការចែករំលែកតិចតួចនៅក្នុងតុល្យភាពអំណាច។ ពួកគេ ត្រូវចំណាយពេលច្រើននៅក្នុងផ្ទះ ការធ្វើដំណើររបស់ពួកគេត្រូវបានហាមឃាត់ ការរួមចំណែកខាងសេដ្ឋកិច្ចរបស់ពួកគេ មិនត្រូវបានគេឱ្យតំលៃ ហើយស្ថានភាពរបស់គេនៅក្នុងផ្ទះសម្បែងនិងក្នុងសង្គមគឺនៅទាបជាងបុរស។ ភាពងាយរងគ្រោះទាំងនេះ គួរតែត្រូវបានប៉ាន់ប្រមាណ និងកំណត់វិធានការសមស្រប។
- ការវិភាគយេនឌ័រមានសារៈសំខាន់ដើម្បីស្វែងយល់ពីទំនាក់ទំនង និងតួនាទីយេនឌ័រ និងវិធីដែលវាមានទំនាក់ទំនងទៅនឹងដំណើរការគ្រប់គ្រងគ្រោះមហន្តរាយនិងការអភិវឌ្ឍន៍ ដើម្បីយុទ្ធសាស្ត្រមានប្រសិទ្ធិភាពជាច្រើនអាចអាចត្រូវបានកំនត់សំរាប់ជាប្រយោជន៍របស់ស្ត្រី បុរស ក្មេងស្រី និងកុមារា។

- កុមាររងាយរងគ្រោះខាងសុខភាពនិងបរិដ្ឋានជាមនុស្សពេញវ័យ ។ កុមារត្រូវការការការហូបចុកពិសេស ហើយពួកគេ ជាទូទៅ ពឹងផ្អែកលើគ្រួសាររបស់ពួកគេ ខាងសំភារៈ ផ្លូវអារម្មណ៏ និងការគាំទ្រខាងភស្តុភា សំរាប់ការធ្វើដំណើររបស់ពួកគេ ។ ទាំងនេះ កាន់តែអាក្រក់ទៅៗដោយសារតែភាពក្រីក្រនៅក្នុងស្ថានភាព ទឹកជំនន់ ។
- មនុស្សចាស់អាចពិបាកធ្វើដំណើរ ភាពទន់ខ្សោយខាងរាង្គកាយ ភាពឯកកោពីសង្គមឬបន្ទុកការងារនៅឯ ផ្ទះដែលត្រូវបំផ្លាញដោយសារតែទឹកជំនន់ ។
- ជនពិការងាយរងគ្រោះខ្លាំងបំផុតពីព្រោះតែបញ្ហាធ្វើដំណើរឬការព្យួរការថែទាំពិសេស ជាពិសេស តំរូវការផ្អែកអនាម័យនិងសុខភាព
- ក្រុមជនជាតិភាគតិចដែលមានជំនឿនិងវប្បធម៌ដើមកំនើត ( ភាសានិងសាសនា) រស់នៅក្នុងតំបន់ឆ្ងាយ ដាច់ស្រយាលដែលមានសក្តានុភាពទឹកជំនន់ អាចនៅតែឯកកោពីសង្គម ។ នេះអាចជាឧបសគ្គដល់ពួកគេ មិនឱ្យទទួលបានអំណាច ធនធាននិងការចូលរួមនៅក្នុងដំណើរការសំរេចចិត្ត ។ តំរូវការផ្អែកវប្បធម៌ និង សាសនា គួរតែត្រូវបានប៉ាន់ប្រមាណនិងបញ្ចូលទៅក្នុងផែនការត្រៀមបង្ការទឹកជំនន់ ។
- ប្រជាជនក្រីក្រ បើទោះបីជា ការគ្រោះថ្នាក់នៅក្នុងវិបត្តិភ័យធំជាងគេក្តី ក៏អាចត្រូវបានគេមិនរាប់បញ្ចូល នៅក្នុងផែនការត្រៀមបង្ការនិងមិនអាចទទួលបានធនធាននៅក្នុងស្ថានភាពគ្រោះអាសន្ន ។

## ៩.៤ ការកំណត់ក្រុមដែលងាយរងគ្រោះនៅក្នុងស្ថានភាពទឹកជំនន់

ក្រុមដែលងាយរងគ្រោះ គឺស្ថិតក្នុងគ្រោះថ្នាក់ខ្ពស់ពីទឹកជំនន់ ពីព្រោះពួកគេមានស្ថានភាព :

- តំបន់រូបសាស្ត្រ( ឧ. ស្ត្រីមេផ្ទះរវល់តែការងារផ្ទះអាចជាមនុស្សត្រូវជំលៀសក្រោយគេ)
- មានលទ្ធភាពតិចទប់ទល់នឹងជំងឺ របួសឬការស្លាប់មុនអាយុ( មនុស្សដែលមិនអាចមានលទ្ធភាព ទទួលបានការព្យាបាលពីវេជ្ជបណ្ឌិតឬថ្នាំពេទ្យ ទារកស្ថិតនៅក្នុងគ្រោះថ្នាក់ស្លាប់ច្រើនពីជំងឺរាគរូស និងជំងឺប្រព័ន្ធដកដង្ហើមជាងក្រុមមនុស្សចាស់ ។
- រាងកាយទន់ខ្សោយ ( ឧ. បញ្ហាផ្លូវចិត្ត កុមារនិងមនុស្សចាស់ស្ថិតនៅក្នុងសភាពទ្រុឌទ្រោមខាងរាង កាយ និងត្រូវការការថែទាំនឹងកន្លែងនិងមិនអាចរើចេញបាន) ។
- រូបសាស្ត្របរិយាកាស ( ឧ. រស់នៅក្នុងលំនៅដ្ឋានដែលខ្វះវិធានការការពារទឹកជំនន់ជារចនាសម្ព័ន្ធ បរិក្ខារសំរាប់ទឹកស្អាត អនាម័យនិងប្រព័ន្ធលូរបង្ហូរទឹកសំអុយ ។
- អ្នករស់នៅក្នុងតំបន់ឆ្ងាយដាច់ស្រយាល( ឧ. ជនជាតិភាគតិចដែលរស់នៅក្នុងតំបន់ឆ្ងាយដាច់ ស្រយាល ដែលក្រុមប្រតិបត្តិការជំនួយសង្គ្រោះមិនអាចទៅដល់ភ្លាមៗ) ។

- កង្វះជំនាញជាក់លាក់ (ឧ. ប្រជាជនដែលពិបាករៀននិងមិនចេះអក្សរមិនអាចអានសញ្ញាប្រកាសអាសន្ន។ ប្រជាជនដែលមិនមានការអប់រំបានត្រឹមត្រូវអាចមានការលំបាកស្វែងរកការងារធ្វើក្នុងពេលមានវិបត្តិ) ។
- កង្វះការទទួលបានធនធាន(ឧ. ស្ថានភាពខ្ពង់ខ្ពស់របស់ក្រុមផ្សេងនៅក្នុងសហគមន៍អាចលើសលប់លើពួកគេក្នុងការទទួលបានធនធានចាប់ពីជំនួយសង្គ្រោះ សំភារៈ ប្រាក់កំចី និងរហូតដល់ដំណើរការសំរេចចិត្ត។ ក្រុមទាំងនេះ អាចមានដូចជា អ្នកសុំសិទ្ធិជ្រកកោននិងជនភៀសខ្លួន អ្នកធ្វើដំណើរ (ទេសចរណ៍) ប្រជាជនគ្មានផ្ទះសម្បែង ស្ត្រី កុមារ ជនក្រីក្រនិងជនជាតិភាគតិច) ។

ក្រុមដែលងាយរងគ្រោះអាចកំនត់បានថែមទៀតដោយកត្តា-ការយល់ឃើញដែលមានចែងក្នុងតារាងខាងក្រោមៈ

| **កត្តា-ការយល់ឃើញ** | **ភាពងាយរងគ្រោះខាងសង្គមកើនឡើង (+)** | **ភាពងាយរងគ្រោះខាងសង្គមថយចុះ (-)** |
|---|---|---|
| ស្ថានភាពសេដ្ឋកិច្ចសង្គម (ចំនួល អំនាចនយោបាយ កិត្តិនាម)) | ចំនួលទាបនិងស្ថានភាព | ទ្រព្យសម្បត្តិនិងស្ថានភាពខ្ពស់ |
| យេនឌ័រ | ស្រី | ប្រុស |
| អាយុ | មនុស្សចាស់-កុមារ | យុវជននិងវ័យកណ្តាល |
| តំបន់ភូមិសាស្ត្រ | តំបន់គ្មានការការពារ (ដីទឹកលិចនៅជិតប្រភពទឹក) | តំបន់មានការការពារ (ការពារដោយមនុស្សឬដោយធម្មជាតិ) |
| កំណើនប្រជាជន | ប្រជាជនកើនឡើងរហ័ស | ប្រជាជនកើនឡើងតាមសមាមាត្រសេដ្ឋកិច្ចកើនឡើង |

តាមការសង្កេត យេនឌ័រគឺជាបញ្ហាប្រទាក់ក្រឡាក្នុងចំណោមក្រុមដែលងាយរងគ្រោះទាំងងស់។ ការសិក្សាបង្ហាញថា បទពិសោធន៍របស់ស្ត្រី ជាពិសេស ស្ត្រីជាម្តាយហើយស្ថិតក្នុងតួនាទីបែបប្រពៃណីនៅផ្ទះនិងគ្រួសារ ធ្វើឱ្យពួកគេដឹងយ៉ាងច្បាស់ជាងបុរសអំពីតំរូវការរបស់មនុស្សផ្សេង ហេតុដូច្នេះហើយទើបត្រូវយកចិត្តទុកដាក់គិតគូរពីការងារ តំរូវការនិងសិទ្ធិរបស់ស្ត្រី កុមារ មនុស្សចាស់ ជនពិការ ជនជាតិភាគតិច និងអ្នកដែលទន់ខ្សោយ។

ជាទូទៅ ស្ត្រីទំនងជាមានភាពប្រាកដប្រជានិងជាក់ស្តែងជាងនៅក្នុងការងាររបស់ពួកគេ អាចផ្តួចផ្តើមគំនិត និងទទួលការផ្លាស់ប្តូរច្រើនតាមវិធីសាស្ត្រនិងគោលដៅ និងមានឆន្ទៈធ្វើការងារជារួមច្រើន។ ជាទូទៅ ស្ត្រីត្រូវបានគេមើលឃើញ និងអាចធ្វើបានច្រើននៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ ចំណែកឯបុរសសង្កត់ធ្ងន់លើបញ្ហាសេដ្ឋកិច្ច ឯស្ត្រីវិញពាក់ព័ន្ធច្រើនជាមួយតំរូវការជាក់ស្តែងនិងតំរូវការអារម្មណ៏របស់គ្រួសារ ដូចជា ចំណីអាហារ ទឹក សុវត្ថិភាពកូនៗ មនុស្សចាស់និងកូនស្រី បញ្ហាសុខភាពបណ្តាលមកពីលក្ខខ័ណ្ឌគ្មានអនាម័យ តំរូវការរបស់ស្ត្រីមានផ្ទៃពោះ ការថែទាំស្ត្រីសំរាលកូន ការសង់ផ្ទះ និងការរំជួលចិត្តអំពីអនាគត។

តាមន័យនេះ ការវិភាគយេនឌ័រអាចជាការសរុបគ្រប់គ្រាន់មួយដើម្បីប៉ាន់ប្រមាណភាពពិតនៃសង្គម និងទំនាក់ទំនងអំណាចនៅក្នុងសង្គមពិសេសមួយ ហើយវាត្រូវបានគេបដិសេធពីតំរូវការលើកកំពស់របស់ក្រុមដែលងាយរងគ្រោះនិងទន់ខ្សោយ។

## ៩.៥ វិធានការត្រៀមបង្ការដើម្បីដោះស្រាយតំរូវការពិសេស

ការត្រៀមបង្ការត្រូវតែសំរបសំរួល[2] :

***ក. ការកំនត់ក្រុមដែលងាយរងគ្រោះនិងប្រជាជននៅថ្នាក់សហគមន៏***

ទិន្នន័យផ្សេងពីគ្នារបស់សមាជិកក្រុមដែលងាយរងគ្រោះ គួរតែត្រូវបានប្រមូលនិងរក្សាទុក មុនទឹកជំនន់កើតឡើង។ ជាទូទៅ ទិន្នន័យបែបនេះ មិនមានទេប៉ុន្តែអាចប្រមូលបានពីសហគមន៏ដោយមិនពិបាក

***ខ. ការពិគ្រោះយោបល់ជាមួយសមាជិកក្រុមដែលងាយរងគ្រោះក្នុងការធ្វើផែនការត្រៀមបង្ការទឹកជំនន់***

ដោយមានការជួយរបស់ក្រុមដែលងាយរងគ្រោះ តំរូវការជាក់លាក់របស់ពួកគេអាចកំនត់បាន និងបញ្ចូលទៅក្នុងផែនការត្រៀមបង្ការទឹកជំនន់។

***គ. ការប្រកាសអាសន្នមុនគួរឱ្យទុកចិត្ត និងប្រព័ន្ធព័ត៌មាននៅតាមសហគមន៏***

គោលការណ៏ណែនាំ គឺត្រូវតែជាវិធីសាស្ត្រងាយយល់សំរាប់ប្រជាជនគ្រប់ស្រទាប់វណ្ណៈ។

***ឃ. វិធានការបណ្តុះបណ្តាលជាក់ស្តែង លើកកំពស់ការយល់ដឹង និងសកម្មភាពគាំទ្រការសង្គ្រោះជីវិត***

ការបង្កើតនិងផ្តល់វិធានការកសាងសមត្ថភាពសមស្របសំរាប់សហគមន៏ដែលរស់នៅក្នុងតំបន់មានគ្រោះថ្នាក់ខ្ពស់ គឺត្រូវតែពិនិត្យឱ្យបានមុនដើម្បីធានាពីសុវត្ថិភាពរបស់ពួកគេ។ សកម្មភាពគួរតែផ្តោត

---

[2] សំរាប់ការពិភាក្សាលំអិតនិងការវិភាគស៊ីជំរៅ សូមមើល : Sullivan, Helen T. & Markku Häkkinen T. ការត្រៀមបង្ការគ្រោះមហន្តរាយសំរាប់ប្រជាជនដែលងាយរងគ្រោះ : ការកំណត់យុទ្ធសាស្ត្រមានប្រសិទ្ធិភាពសំរាប់ការទំនាក់ទំនងអំពីគ្រោះថ្នាក់ ការប្រកាសអាសន្ន និងការឆ្លើយតប។
URL: geography.rutgers.edu/events/magrann_conference/2006/_papers/sullivan.pdf

លើការលើកកំពស់ការយល់ដឹងរបស់សហគមន៍ ជាពិសេស លើធម្មជាតិនិងពីគ្រោះទឹកជំនន់ជាសក្តានុភាព ដែលពួកគេប្រឈមមុខ និងរបៀបឆ្លើយតបជាបុគ្គល និងជារួមនៅក្នុងសហគមន៍។

***ង. ការយល់ដឹងអំពីផ្លូវរត់គេចនិងតំបន់សុវត្ថិភាព***

សមាជិកទាំងអស់របស់សហគមន៍ត្រូវតែដឹងពីផ្លូវរត់គេចផ្សេងៗទាំងអស់ទៅតំបន់សុវត្ថិភាព។ វាត្រូវតែលើកកំពស់នៅមុនទឹកជំនន់កើតឡើង តាមរយៈការប្រើសំភារៈដែលអាចទទួលបាន គួបផ្សំជាមួយឧបករណ៍ដូចជា ព័ត៌មានជាសំលេង និងជារូបភាពអាចមើលឃើញ។ ឧទាហរណ៍ ការពិពណ៌នាផែនទីជាដើម។ វត្តមាននៃរូបភាព វិធីសាស្ត្រ និងការផ្តល់ជាសំលេង នៅក្នុងបរិយាកាសត្រូវតែមាននិយាយអំពីព័ត៌មាននៅក្នុងសំភារៈត្រៀមបង្ការ។

***ច. ការប្រកាសអាសន្ន និងការជូនដំណឹងដែលងាយទទួលបាន***

ប្រព័ន្ធប្រកាសអាសន្នសហគមន៍ដែលមានការសហការល្អ ច្បាស់លាស់ និងទាន់ពេលវេលា ត្រូវតែមាននៅនឹងកន្លែង។ បរិក្ខាដូចជា ស៊ីរ៉ែន និងមេគ្រូ ដែលដាក់នៅតាមទីសាធារណៈ អាចមានប្រសិទ្ធិភាពក្នុងការផ្សព្វផ្សាយបានធំទូលាយ។

***ឆ. ការបង្កើតទីជំរកសុវត្ថិភាពនៅមុនរដូវទឹកឡើងរាល់ឆ្នាំ***

***ជ. ផែនការគ្រប់គ្រងអ្នកស្ម័គ្រចិត្ត***

យុវជនស្ម័គ្រចិត្តអាចទៅដល់និងជួយសមាជិកក្រុមដែលងាយរងគ្រោះបានយ៉ាងងាយស្រួល។ ពួកគេអាចផ្តល់ការគាំទ្រក្នុងការជំលៀស ការចែកជំនួយសង្គ្រោះ និងថែទាំអ្នកមានជំងឺឬអ្នកដែលត្រូវការ។

**ការធ្វើឱ្យការគ្រប់គ្រងគ្រោះមហន្តរាយមានយេនឌ័រ :**

- យល់ច្បាស់ពីគោលគំនិតដែលបានលើកឡើង (អំពីអ្វី? ដោយនរណា?)
- បរិបទសង្គមជាក់លាក់និងការវិភាគយេនឌ័រ
- ការបង្វែរគោលគំនិតយេនឌ័រទៅក្នុងគោលការណ៍ណែនាំគោលនយោបាយ
- ការប្តេជ្ញាចិត្តជាបន្តដើម្បីអនុវត្តគោលនយោបាយ
- ប្រព័ន្ធនិងនីតិវិធីបង្វែរគោលនយោបាយទៅក្នុងការអនុវត្តន៍
- គោលដៅច្បាស់លាស់និងការព្រមព្រៀងស្តីពីបទដ្ឋានអប្បរមា

ពីវិសាលភាពយេនឌ័រនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ (ទំព័រ៩២)

## ៩.៦ មធ្យោបាយដោះស្រាយតំរូវការពិសេសរបស់ក្រុមដែលងាយរងគ្រោះ

គួរតែមានការយកចិត្តទុកដាក់ជាពិសេសក្នុងការដោះស្រាយតំរូវការរបស់ក្រុមដែលងាយរងគ្រោះ ដោយសារតែតំរូវការរបស់ពួកគេអាចស្មុគ្រស្មាញចំពោះសាវតាសង្គម វប្បធម៌និងសាសនាជាក់លាក់ ។ វិធានការដូចតទៅនេះត្រូវបានស្នើឡើង :

- បុគ្គលិកនៅថ្នាក់ខេត្ត ស្រុកនិងថ្នាក់កណ្តាល( ទាំងភ្នាក់ងាររដ្ឋាភិបាលនិងអង្គការ) គួរតែដឹងពីភាពចាំបាច់បញ្ចូលតំរូវការពិសេសរបស់ក្រុមដែលងាយរងគ្រោះនៅពេលបង្កើតផែនការត្រៀមបង្ការទឹកជំនន់និងគិតគូរនៅគ្រប់សកម្មភាព គ្រប់ដំណាក់កាលទាំងអស់( ការធ្វើផែនការ ការអនុវត្តន៍ និងការតាមដាន)
- ប៉ាន់ប្រមាណគ្រោះទឹកជំនន់ដើម្បីស្វែងយល់ពីការគំរាមកំហែង កំរិតគ្រោះថ្នាក់ កំរិតចាំបាច់នៃការត្រៀមបង្ការ តំរូវការគ្រប់គ្រងគ្រោះមហន្តរាយនិងវិធានការស្តារនីតិសម្បទាសំរាប់ក្រុមនីមួយៗ ។ ធានាថាការប្រមូលនិងការវិភាគព័ត៌មានមិនធ្វើដាច់ដោយឡែកពីគ្នាហើយយេនឌ័រនិងភាពស្វាហាប់នៃអំណាច ការបែងចែកការងារ និងតុល្យភាពអំណាចត្រូវបានបញ្ចូលគ្រប់គ្រាន់ ។ ការកំនត់ពីយន្តការដោះស្រាយរបស់បុរសនិងស្រ្តី និងសកម្មភាពរួម ។
- ប្រាកដថា ភាពងាយរងគ្រោះខុសៗគ្នាជាក់លាក់ដែលកើតឡើងពីកត្តាជាច្រើនដូចជា ភាពក្រីក្រ ការទទួលបានធនធាន វណ្ណៈ ជាតិពន្ធ ត្រូវបានយកមកពិចារណា ។
- ការប៉ាន់ប្រមាណពីភាពងាយរងគ្រោះនិងការទទួលបានធនធាននិងបរិក្ខាដូចជា សុខាភិបាលនិងការអប់រំពីទស្សនៈវិស័យយេនឌ័រនិងភាពក្រីក្រ ។
- ធានាការចូលរួមរបស់មន្រ្តីនិងអ្នកមានវិជ្ជាជីវៈពីវិស័យអភិវឌ្ឍ ផ្នែករដ្ឋបាល ហេដ្ឋារចនាសម្ព័ន្ធនិងអង្គការដែលមានសេវាកម្មទាក់ទងនៅក្នុងតំបន់ នៅពេលធ្វើការប៉ាន់ប្រមាណ ។
- ការបង្កើតយុទ្ធសាស្រ្តតាមរយៈការពិគ្រោះយោបល់បិទ និងទៀងទាត់ជាមួយស្ថាប័នរដ្ឋាភិបាលសំខាន់ៗដែលកំពុងធ្វើការនៅក្នុងតំបន់ ( ដូចជា ប៉ូលីស សេវាកម្មសុខាភិបាល កងកំលាំងប្រដាប់អាវុធ និងភ្នាកងាររដបាលរដ្ឋាភិបាល) ។
- សមាហរណកម្មលទ្ធផលនៃការប៉ាន់ប្រមាណនៅក្នុងផ្នែកទាំងអស់របស់ផែនការត្រៀមបង្ការទឹកជំនន់
- ការលើកកំពស់តំរូវការសំរាប់ការយល់ដឹងពីយេនឌ័រនៅក្នុងយុទ្ធសាស្រ្ត និងផែនការគ្រប់គ្រងគ្រោះមហន្តរាយទាំងមូលរបស់ទាំងរដ្ឋាភិបាលនិងភ្នាក់ងារក្រៅរដ្ឋាភិបាល ។

## ៩.៧ សេចក្តីយោង


- Imelda Abararque និង Zubair Mushed, ADPC (2004), **ការគ្រប់គ្រងគ្រោះមហន្តរាយតាមសហគមន៍** ភាគទី៣ ការពិចារណាសំខាន់ៗនៅក្នុងការអនុវត្តន៍ CBDRM, យុទ្ធសាស្រ្តយេនឌ័រមាន ស្មារតីពីរ នៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយតាមសហគមន៍ ADPC
- Ahmed, Y. (1994), A សិក្ខាសាលាត្រៀមបង្ការគ្រោះមហន្តរាយ នៅប្រទេសប៉ាគីស្ថាន។ **ការផ្តោតលើ យេនឌ័រ ២(១) ទំព័រ**. ៣៩-៤០. Oxford: Oxfam
- Begum, R. (1993), ស្ត្រីនៅក្នុងគ្រោះមហន្តរាយបរិដ្ឋាន : ខ្យល់ព្យុះស៊ីក្លូននៅក្នុងប្រទេសបង់ក្លាដែស ឆ្នាំ១៩៩១។ **ការផ្តោតលើយេនឌ័រ ១(១) :** ៣៤-៣៩. Oxford: Oxfam
- Bushra, J.E. (1999), ភាពខុសគ្នាផ្នែកសង្គមរវាងបុរសនិងស្ត្រី នៅក្នុងការធ្វើអន្តរាគមន៍មនុស្សធម៌។**ការឆ្លើយតបចំពោះគ្រោះមហន្តរាយ និងការបង្កើនការអភិវឌ្ឍន៍ : ទ្វេរគ្រោះនៃជំនួយមនុស្សធម៌** ទំព័រ : 97-101. s.l.: Zed book Ltd.
- Karl, M. (1995), **ស្ត្រីនិងការឱ្យអំណាច :ការចូលរួមនៅក្នុងការធ្វើការសំរេចចិត្ត។** London and New Jersey: Zed Books Ltd.
- Kottegoda, S. (1997), យេនឌ័រនិងគ្រោះមហន្តរាយ : បញ្ហាចំបង។ **ស្ត្រីអាស៊ីខាងត្បូងប្រឈមមុខនឹង គ្រោះមហន្តរាយ ការធ្វើឱ្យមានសុវត្ថិភាពជីវិត។** ទំព័រ 7-16. Colombo: Intermediate Technology Publications for Duryog Nivaran
- Madhavi Malalgoda Ariyabandu and Maithree Wickramasinghe, (2005), **វិសាលភាពយេនឌ័រនៅក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ-** ការណែនាំមួយសំរាប់អាស៊ីខាងត្បូង ITDG South Asia, India Edition
- Myers, M. (1994), ស្ត្រីនិងកុមារ បឋម : ការណែនាំយុទ្ធសាស្រ្តយេនឌ័រមួយនៅក្នុងការត្រៀមបង្ការ គ្រោះមហន្តរាយ។ ផ្តោតលើយេនឌ័រ **2(1)**, pp. 14-16. Oxford: Oxfam
- Vu Minh Hai, (2005), យេនឌ័រនិងការគ្រប់គ្រងគ្រោះមហន្តរាយ នៅប្រទេសវៀតណាម :ការវិភាគអំពី ការអនុវត្តន៍និងគោលនយោបាយ ដែលបានដាក់ជូនក្នុងការបំពេញជាផ្នែកនៃ MSc. កំរិតនៅក្នុងការអនុវត្តន៍ Oxford Brookes University, Oxford.

# ជំពូកទី ១០

## ការធ្វើសមាហរណកម្មផែនការត្រៀមបង្ការ
## គ្រោះទឹកជំនន់ ជាមួយ
## ផែនការអភិវឌ្ឍថ្នាក់ជាតិ ខេត្ត និង ស្រុក

# ការធ្វើសមាហរណកម្មផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយ ផែនការអភិវឌ្ឍថ្នាក់ជាតិ ខេត្ត និង ស្រុក

## ១០.១. ទិដ្ឋភាពរួម

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ភ្ជាប់ទំនាក់ទំនងជាមួយបញ្ហាការគ្រប់គ្រង និង អភិវឌ្ឍតាមមធ្យោបាយនៃកិច្ចសហប្រតិបត្តិការពហុវិស័យ និង ការគាំទ្រផ្នែកហិរញ្ញវត្ថុដែលខ្លួនស្វែងរកពីថវិកាអភិវឌ្ឍ។ នៅពេលមានទឹកជំនន់កើតឡើង វានាំមកនូវផលប៉ះពាល់លើការអភិវឌ្ឍន៍ ជាពិសេសផ្នែកកសិកម្ម ផ្ទះសម្បែង និង ហេដ្ឋារចនាសម្ព័ន្ធ សុខភាព ការអប់រំ និង ការអភិវឌ្ឍនសំរាប់ស្ត្រី។ ដូច្នេះ វាជាភាពចាំបាច់ដើម្បីអនុវត្ត និង សំរបសំរួលផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ឱ្យមានប្រសិទ្ធិភាពនៅថ្នាក់ខេត្ត-ក្រុង ហើយ នៅកំរិតពហុវិស័យ វាត្រូវតែភ្ជាប់ការទំនាក់ទំនងផ្ទៃក្នុង ជាមួយនឹងផែនការកាត់បន្ថយគ្រោះ មហន្ត-រាយទាំងមូល និង ភ្ជាប់ការទំនាក់ទំនងខាងក្រៅ ជាមួយផែនការអភិវឌ្ឍទាំងនៅថ្នាក់មូលដ្ឋាន និង នៅថ្នាក់ជាតិ។

ជំពូកនេះ នឹងជួយអ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ឱ្យយល់ពីការភ្ជាប់ទំនាក់ទំនងរវាងផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ផែនការកត់បន្ថយគ្រោះមហន្តរាយនិងផែនការអភិវឌ្ឍ និង ពីរបៀបដែលផែនការទាំងនេះ អាចដាក់បញ្ចូលជាមួយគ្នាបាន។ នៅទីបញ្ចប់ ការប្រឈមមុខជាចំបងនៃដំណើរការសមាហរណកម្មនេះ ត្រូវបានលើកឡើង ដើម្បីឱ្យអ្នកធ្វើផែនការ បានដឹងច្បាស់និងអាចយកឈ្នះលើវាបាន។

## ១០.២ គោលបំណង

- លើកឡើងពីសារៈសំខាន់នៃការធ្វើសមាហរណកម្មផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងផែន-ការកាត់បន្ថយគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន និង ថ្នាក់ជាតិ។
- ស្វែងយល់ពីទំនាក់ទំនង រវាងការត្រៀមបង្ការគ្រោះទឹកជំនន់និងការអភិវឌ្ឍន៍។
- ស្វែងយល់ពីការប្រឈមមុខជាចំបង នៃការធ្វើសមាហរណកម្មផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងផែនការផ្សេងៗដទៃទៀត។
- យល់ពីវិធីសហការល្អប្រសើរ នៅក្នុងភ្នាក់ងារខុសគ្នារបស់ខេត្ត-ស្រុក ដែលនាំទៅដល់ការភ្ជាប់ការទំនាក់ទំនងផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយផែនការផ្សេងៗទៀត។

## ១០.៣ គោលគំនិតសំខាន់ៗ

- ផែនការខុសៗគ្នាមាននៅគ្រប់កំរិតទាំងអស់របស់ប្រទេស ចាប់ពីថ្នាក់ជាតិ ខេត្ត ស្រុក និង ឃុំ។ អាស្រ័យលើទំហំ វិសាលភាពនិងពេលវេលានៃផែនការនីមួយៗ គោលបំណងនិងវដ្តផែនការ គឺមានភាពខុសគ្នា។ ការដែលសំខាន់ គឺអ្នកធ្វើផែនការមូលដ្ឋាន មានការយល់ដឹងល្អពីផែនការអភិវឌ្ឍ និងការកាត់បន្ថយគ្រោះមហន្តរាយនៅកំរិតខុសគ្នា គោលបំណងនិងវដ្តផែនការ និងកំណត់ពីការជាប់ទាក់ទង ដែលអាចបង្កើតបានរវាង ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ និង ផែនការអភិវឌ្ឍ ខេត្ត ឬ ស្រុក។
- សារៈសំខាន់នៃការធ្វើសមាហរណកម្មការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងវដ្តផែនការទៀងទាត់ (របស់ផ្នែកអភិវឌ្ឍ) មិនត្រឹមតែនៅថ្នាក់ខេត្តនិងថ្នាក់ស្រុកនោះទេ ប៉ុន្តែនៅថ្នាក់ជាតិ ក៏គួរឱ្យអ្នកពាក់ព័ន្ធ បានយល់ដឹងផងដែរ។ លទ្ធភាព នៃធនធានថវិកាបន្ថែមតាមរយៈការភ្ជាប់ទំនាក់ទំនង គួរតែបានលើកឡើង ដើម្បីធានាពីនិរន្តរភាព នៃការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់។
- សមាហរណកម្ម នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយផែនការកាត់បន្ថយគ្រោះមហន្តរាយ និង ការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន តំរូវឱ្យអ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ អាចចេះដឹងបាន អំពីនីតិវិធីធ្វើផែនការអភិវឌ្ឍ កំណត់ពេលវេលា និង យន្តកាថវិកានៅតាមតំបន់របស់គេ។
- សមាហរណកម្ម ក៏អំពាវនាវឱ្យមានប្រព័ន្ធសំរបសំរួលល្អប្រសើរជាច្រើន ដើម្បីឱ្យផែនការត្រៀមបង្ការគ្រោះទឹកជំនន់ មានការគាំទ្រទាំងពីអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយនិងការអភិវឌ្ឍន៍ និង មានថវិកាគ្រប់គ្រាន់។
- ដំណើរការធ្វើសមាហរណកម្ម នឹងបង្ហាញពីតំលៃមានប្រសិទ្ធិភាព ព្រោះស្ថាប័នគ្រប់គ្រងគ្រោះ មហន្តរាយនិងអភិវឌ្ឍ អាចអនុវត្តគំរោងរួមគ្នាបាន។ ដំណើរការនេះធ្វើឱ្យសកម្មភាពត្រួតស៊ីគ្នា មានជាអប្បរមា ជំរុញការបង្កើតកម្មវិធីបន្ថែម និង លើកកំពស់ការរួមកំលាំងគ្នារវាងវិស័យទាំងពីរ។
- ប្រសិនបើយើង ធ្វើមិនដឹងមិនឮចំពោះស្ថាប័នសំរាប់គ្រោះទឹកជំនន់ និង គ្រោះមហន្តរាយនៅថ្នាក់ខេត្ត-ស្រុកនោះ ផែនការអភិវឌ្ឍ នឹងនាំមកនូវភាពអសមត្ថភាព ដើម្បីព្យាករណ៍ទុកធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុ ដែលត្រូវការក្នុងកំឡុងពេលគ្រោះអាសន្ន។ វាទំនងជាថា កង្វះភាពយល់ដឹងបែបនេះ នឹងត្រូវចំណាយច្រើន និង ធ្វើឱ្យផែនការអភិវឌ្ឍនិងការប៉ាន់ប្រមាណហិរញ្ញវត្ថុ បរាជ័យ។ ដូច្នេះ ការធ្វើសមាហរណកម្ម ក្លាយជាដំណើរការមួយសំរាប់អ្នកធ្វើផែនការ នៅក្នុងវិស័យទាំងពីរ

លុបចោលវដ្តខុសៗគ្នា នៃគ្រោះមហន្តរាយ ដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ ហើយ ការអភិវឌ្ឍន៍ (ជាពិសេសការស្តារឡើងវិញក្រោយពេលគ្រោះមហន្តរាយ ការធ្វើផែនការអភិវឌ្ឍប្រថុចព្រុំចពេក) ធ្វើឱ្យឥទ្ធិពលគ្រោះមហន្តរាយ កាន់តែធ្ងន់ធ្ងរឡើង។

| ឧទាហរណ៍នៃផែនការខុសៗគ្នានៅថ្នាក់ខេត្ត និង ស្រុក | | |
|---|---|---|
| **ល.រ** | **ផែនការ** | **គោលបំណងនៃផែនការ** |
| ១ | ផែនការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ ខេត្ត-ស្រុក | ▪ ប្រមូលធនធាន និង កំណត់វិធានការជាក់លាក់ ដើម្បីត្រៀមបង្ការ ឆ្លើយតប និង ស្តារឡើងវិញពីគ្រោះមហន្តរាយ ដែលខេត្ត-ស្រុក អាចនឹងប្រឈមមុខ។ |
| | ផែនការអភិវឌ្ឍខេត្ត-ស្រុក | ▪ កំណត់វិស័យអភិវឌ្ឍ និង ធនធានសក្តានុភាព ដើម្បីអនុវត្តកិច្ចការនៅថ្នាក់ខេត្ត និង ស្រុក។ |
| | ផែនការមន្ទីរខេត្ត-ស្រុក | ▪ ចំណាត់ធនធានសំរាប់ប្រតិបត្តិការជាប្រចាំ និង សំរាប់ការខិតខំប្រឹងប្រែងថ្មីៗ |
| | ផែនការពិសេសផ្សេងទៀតនៅថ្នាក់ខេត្ត និង ស្រុក | ▪ ធានាថាសកម្មភាពថ្មី ដែលបានបង្កើតឡើង ត្រូវបានអនុវត្តដោយមានធនធានគ្រប់គ្រាន់ (មនុស្ស សំភារៈ ហិរញ្ញវត្ថុ) |

## ១០.៤ ឧបសគ្គធំៗនៃការធ្វើសមាហរណកម្ម

ការបញ្ចូលគ្នានៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយផែនការរួមកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង ការអភិវឌ្ឍ គឺមិនមែនជាដំណើរការសមាហរណកម្មល្អទេ នៅបណ្តារប្រទេសកំពុងអភិវឌ្ឍ។ វត្តមាននៃភាពមិនស៊ីគ្នារបស់ស្ថាប័ន នៅក្នុងចំណោមការធ្វើការងារ របស់មន្ទីរពាក់-ព័ន្ធខុសៗគ្នា បានក្លាយទៅជាឧបសគ្គចំបង ហើយ បរិយាកាសពហុវិស័យ ត្រូវតែបង្កើតឡើង នៅពេលដែលការរៀបចំមានការសហការអវត្តមាន។ ខាងក្រោមនេះ គឺជាការប្រឈមមុខចំបង ដែលអ្នកធ្វើផែនការ និង អ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយ អាចប្រឈមក្នុងពេលធ្វើសមាហរនកម្មផែនការខុសៗគ្នា និង មើលឃើញផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ត្រូវបានអនុវត្តមានប្រសិទ្ធិភាព។

i. **ចំណេះដឹងអំពីនីតិវិធីធ្វើផែនការអភិវឌ្ឍ និង ការតាមដានរបស់វា :** វាតំរូវឱ្យ អ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់និងអ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយ បានដឹងច្បាស់ពីនីតិវិធីធ្វើផែនការអភិវឌ្ឍនៅក្នុងតំបន់របស់ពួកគេ និង អាចវាស់ស្ទង់វាបាន។ ការនេះ នឹងតំរូវឱ្យមានការពិចារណាអំពី :

- តើប្រព័ន្ធផែនការអភិវឌ្ឍ មានដំណើរការយ៉ាងដូចម្តេចនៅតាមខេត្តឬស្រុក ។
- តើអ្វីខ្លះជាពេលវេលាជាក់លាក់ សំរាប់ធ្វើផែនការអភិវឌ្ឍ និង ស្នើឱ្យមានសំណើរសកម្មភាពអភិវឌ្ឍដែលទាក់ទង (ពីស្ថាប័នធ្វើផែនការថ្នាក់មូលដ្ឋាន) ដើម្បីបានបញ្ចូលទៅក្នុងផែនការ។
- តើនរណាជាអ្នកតាមមើល និង តើអ្វីជាកំរិតនៃអំណាចក្នុងការធ្វើផែនការអភិវឌ្ឍ។
- តើមន្ទីរពាក់ព័ន្ធ មានផែនការអភិវឌ្ឍដាច់ដោយឡែកពីគ្នា សំរាប់ច្របាច់បញ្ចូលទៅក្នុងផែនការរួម ឬ ខេត្ត-ស្រុក មានមន្ទីរផែនការរបស់ខ្លួន ដែលស្នើសុំមន្ទីរពាក់ព័ន្ធឱ្យដាក់ផែនការសំណើរដែរឬទេ។

ចំណេះដឹងអំពីនីតិវិធីទាំងនេះ នឹងអាចធ្វើឱ្យអ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ មានគំនិតល្អប្រសើរ ថានៅពេលណាត្រូវតាមរកកិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្ម និង លើកផែនការត្រៀមបង្ការ ដើម្បីឱ្យស៊ីគ្នាជាមួយនឹងវដ្តផែនការអភិវឌ្ឍ។

ii. **ការយល់ដឹងពីយន្តការថវិកាជាផ្លូវការ :** វាជាការសំខាន់ ដែលអ្នកធ្វើផែនការ និង អ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយ ដឹងពីយន្តការដែលបានយកមកចំណាត់ថវិកាសំរាប់ផែនការនៅតាមតំបន់។ ការនេះ នឹងវាស់កំរិតអ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដើម្បីដាក់ជូនផែនការត្រៀមបង្ការគ្រោះទឹកជំនន់ សំរាប់ការធ្វើសមាហរណកម្ម និង ចំណាត់ធនធានបានទាន់ពេលវេលា។

iii. **ការសហការណ៍ជាពហុវិស័យ**

- ផ្តល់និងចងក្រងទុកជាឯកសារនូវគំរោងការណ៍សហការតែមួយ។ វា នឹងធានាពីភាពស៊ីគ្នាការសហការ ការទំនាក់ទំនង និង ការកំណត់ច្បាស់លាស់នូវការទទួលខុសត្រូវនៅក្នុងវិស័យខុសៗគ្នា។
- ចាត់តាំងជនបង្គោលសំរាប់ការធ្វើសមាហរណកម្ម។
- ធ្វើគំរោងសំណើ គោលគំនិត របៀបវារៈការងារដើម្បីសំរបសំរួលការចូលរួម និងការអនុវត្តន៍នៅគ្រប់វិស័យ។ វា អាចនាំអោយមន្ទីរពាក់ព័ន្ធ និង អ្នកពាក់ព័ន្ធជាច្រើនធ្វើការសហការ និង

ជួយបង្កើតយន្តកា និង លើកកម្មវិធី ដែលអាចធ្វើការរួមគ្នាបាន។ ត្រូវផ្តល់ការថែទាំជាពិសេស ចំពោះការសហការគ្រប់វិស័-គ្រប់កំរិត។

- ធានាការចូលរួមរបស់សហគមន៏ នៅក្នុងការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់។ ជាមួយការ យល់ដឹងពិសេសចំពោះក្រុមដែលងាយរងគ្រោះ វានឹងស្តែងឱ្យឃើញនូវតំរូវការរបស់សហគមន៏ បង្កើតភាពជាម្ចាស់ការ និង ការទាមទារមកលើអាជ្ញាធរ ដើម្បីធ្វើការងារក្នុងសក្ខណៈបែបសហការគ្នា។
- គាំទ្រការទទួលខុសត្រូវតាមបែបវិមជ្ឈការ ក្នុងរចនាសម្ព័ន ដើម្បីធានាថាគោលនយោបាយត្រូវបានអនុវត្ត និងមានភាពបត់បែនក្នុងយុទ្ធវិធីស្របតាមការផ្លាស់ប្តូរនៅពេលអនាគត។

## ១០.៥ សចក្តីយោង

ADPC ការបញ្ជ្រាបការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងគោលនយោបាយ ការធ្វើផែនការ និង ការអនុវត្តន៏ នៅអាស៊ី

Osbahr, Henny. Viner, David & Wakhungu, Judi. ទំនាក់ទំនងលំនាំផ្លាស់ប្តូរអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ : ការសិក្សានៅប្រទេស Kenya

URL:
www.climatevarg.org/.../42ec25f6537f5eff85256dab0048d8e9/931fdb5a60b6399285256dab00581061/$FILE/**Kenya**.ppt

Manuta, Jesse. Khrutmuang, Supaporn. Huaisai, Darika & Lebel, Louis. អសមត្ថភាពរបស់ស្ថាប័ន និង ការគ្រប់គ្រងគ្រោះមហន្តរាយ នៅប្រទេសថៃ អង្គភាពស្រាវជ្រាវសង្គម និងបរិដ្ឋាន មហាវិទ្យាល័យឈៀងម៉ៃ ឈៀងម៉ៃ 50200, ប្រទេសថៃ